# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ ថេរគាថា ថេរីគាថា
# ឆដ្ឋភាគ
# ៥៧



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## KHUDDAKANIKĀYA

## THERAGĀTHĀ

## THERĪGĀTHĀ

## CHAṬṬHABHĀGA

## 57

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី

សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិរយោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# សេចក្ដីណែនាំក្នុងការអាន

១) *ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។*

***ឧទាហរណ៍***

*-ពាក្យខ្មែរ:* **សម្ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

*-ពាក្យបាលី:* **តស្ស** *គឺ* **តស្ស** *។*

២) *ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ* (**ជួន-ណាត**) *ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

៣) *ចំពោះ* **សង្កឹតច្រាប់ពាក្យខុស-ត្រូវ** *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ថេរគាថា ថេរីគាថា

## ឆដ្ឋភាគ

## ៥៧

# ថេរគាថាយ សត្តកនិបាតោ

[២២៥] អលង្កតា សុវសនា  មាលការី វិភូសិតា
អលត្តកកតា ចាទា  ចាទុការុយ្ហ វេសិកា
ចាទុកា ឱរុហិត្វាន  បុរតោ បញ្ជលីកតា
សា មំ សណ្ហេន មុទុនា  មិត្តបុព្វម[1]ភាសថ
យុវាសិ ត្វំ បព្វជិតោ  តិដ្ឋាហិ មម សាសនេ
ភុញ្ជ មានុសកេ កាមេ  អហំ វិត្តំ ទទាមិ តេ ។
សច្ចន្តេ បដិជានាមិ  អគ្គឹ វា តេ ហរាមហំ[2] ។
យទា ជិណ្ណា ភវិស្សាម  ឧភោ ទណ្ឌបរាយនា
ឧភោបិ បព្វជិស្សាម  ឧភយត្ថ កដគ្គហោ ។
តញ្ច ទិស្វាន អាយន្តឹ  វេសិកំ បញ្ជលីកតំ
អលង្កតំ សុវសនំ  មច្ចុចាសំវ ឱឌ្ឌិតំ
តតោ មេ មនសិការោ  យោនិសោ ឧទបជ្ជថ

។ បេ[3] ។

សុន្ទរសមុទ្ទោ ថេរោ ។

[២២៦] បរេ អម្ពាដការាមេ  វនសណ្ឌម្ហិ ភទ្ទិយោ
សមូលំ តណ្ហំ អព្ពុយ្ហ  តត្ថ ភទ្ទោ ឈិយាយតិ ។

---
១ ម. មិត្តបុព្វំ មសាសថ ។ ២ ម. ហរាមតំ ។ ៣ ចតុក្កនិបាតេ ទដ្ឋព្វា ។

# ថេរគាថា សត្តកនិបាត

[២២៥] ស្រីផ្កាមាស តាក់តែង ស្លៀកពាក់ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាង ហើយ មានជើងស្រឡាបដោយទឹកល័ខ ពាក់ស្បែកជើង លុះដោះស្បែកជើងចេញហើយ ក៏ធ្វើអញ្ជលីចំពោះមុខ ស្រីផ្កាមាសនោះនិយាយនូវពាក្យជាប្រធាននៃមិត្ត[១]នឹងខ្ញុំ ដោយសម្ដីដ៏ទន់ពីរោះថា លោកនៅកំលោះហើយបួស លោកចូរឋិតនៅក្នុងពាក្យប្រដៅរបស់ខ្ញុំ លោកចូរបរិភោគកាមជារបស់មនុស្សចុះ ខ្ញុំនឹងឲ្យសម្បត្តិដ៏ពេញចិត្តដល់លោក ។ ខ្ញុំប្ដេជ្ញាពាក្យពិតដល់លោក ឬនឹងនាំភ្លើងដល់លោក[២] ។ កាលណាយើងទាំងពីរនាក់ ជាមនុស្សចាស់ កាន់ឈើច្រត់ហើយ យើងនឹងបួសទាំងពីរនាក់ នឹងកាន់យកនូវជ័យជម្នះក្នុងលោកទាំងពីរ ។ ខ្ញុំបានឃើញស្រីផ្កាមាសនោះ មកធ្វើអញ្ជលី តាក់តែង ស្លៀកពាក់ល្អដូចជាជាប់អន្ទាក់មច្ចុ លំដាប់នោះ ខ្ញុំក៏បានធ្វើទុកក្នុងចិត្តដោយឧបាយនៃបញ្ញា ។

។ បេ[៣] ។

សុន្ទរសមុទ្ទត្ថេរ ។

[២២៦] ព្រះភទ្ទិយត្ថេរ នៅក្នុងអម្ពាដការាម ដ៏ប្រសើរ ក្បែរដងព្រៃ បានដកតណ្ហា ព្រមទាំងឫស ចោលអស់ហើយ ជាអ្នកប្រសើរ ចម្រើនឈាន ក្នុងអារាមនោះ ។

---

១ ពាក្យថៃចង់ ។ ២ ស្បថនឹងភ្លើង ។ ៣ គប្បីមើលក្នុងចតុក្កនិបាត ។

រមន្តេកេ មុទិង្គេហិ វីណាហិ បណវេហិ ច
អហញ្ច រុក្ខមូលស្មឹ រតោ ពុទ្ធស្ស សាសនេ ។
ពុទ្ធោ ច មេ វរំ ទជ្ជា សោ ច លព្ភេថ មេ វរោ
គណ្ហេហំ សព្វលោកស្ស និច្ចំ កាយគតាសតឹ ។
យេ មំ រូបេន បាមឹសុ យេ ច ឃោសេន អន្វគូ[(១)]
ឆន្ទរាគវសូបេតា ន មំ ជានន្តិ តេ ជនា ។
អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច ន បស្សតិ
សមន្តាវរណោ ពាលោ ស វេ ឃោសេន វុយ្ហតិ ។
អជ្ឈត្តញ្ច ន ជានាតិ ពហិទ្ធា ច វិបស្សតិ[(២)]
ពហិទ្ធាផលទស្សាវី សោបិ ឃោសេន វុយ្ហតិ ។
អជ្ឈត្តញ្ច បជានាតិ ពហិទ្ធា ច វិបស្សតិ
អនាវរណទស្សាវី ន សោ ឃោសេន វុយ្ហតីតិ ។

លកុណ្ឌកោ ថេរោ ។

[២២៧] ឯកបុត្តោ អហំ អាសឹ បិយោ មាតុ បិយោ បិតុ
ពហូហិ វតចរិយាហិ លទ្ធោ អាយាចនាហិ ច ។

---

១ ម. អន្ទគូ ។ ២ ម. ន បស្សតិ ។

ជនពួកខ្លះ ត្រេកអរដោយសម្ភោរ ដោយពិណ ដោយស្គរជ័យក៏មាន ចំណែកខ្ញុំនៅទៀបគល់ឈើ ត្រេកអរតែក្នុងពុទ្ធសាសនា ។ មួយទៀត ព្រះពុទ្ធទ្រង់ប្រទានពរដល់ខ្ញុំៗ បាននូវពរនោះ ខ្ញុំកាន់យកនូវកាយគតាសតិ ជានិច្ច ដើម្បីលោកទាំងអស់ ។ ពួកជនណាមើលងាយខ្ញុំដោយរូបក្តី ពួកជនណា តាមខ្ញុំទៅដោយសំឡេង(១)ក្តី ពួកជនទាំងនោះសុទ្ធតែលុះអំណាចនៃឆន្ទរាគៈ មិនស្គាល់ខ្ញុំទេ ។ បុគ្គលណាមិនដឹងធម៌ខាងក្នុង ទាំងមិនឃើញធម៌ខាងក្រៅ បុគ្គលនោះឯង ជាមនុស្សពាល មានធម៌ជាគ្រឿងរាំងរាជុំវិញ តែងត្រូវសំឡេងនាំបន្សាត់ទៅ ។ បុគ្គលណាមិនដឹងធម៌ខាងក្នុង ប៉ុន្តែឃើញច្បាស់នូវធម៌ខាងក្រៅ បុគ្គលនោះឈ្មោះថា ឃើញផលខាងក្រៅ ក៏ត្រូវសំឡេងបន្សាត់ទៅដែរ ។ បុគ្គលណាដឹងច្បាស់នូវធម៌ខាងក្នុង ទាំងឃើញច្បាស់នូវធម៌ខាងក្រៅ បុគ្គលនោះឈ្មោះថាជាអ្នកឃើញធម៌ដែលគ្មានអ្វីរាំងរា តែងមិនត្រូវសំឡេងបន្សាត់ទៅឡើយ ។

លកុណ្ឌកត្ថេរ ។

[២២៧] ខ្ញុំជាកូនប្រុសតែមួយ ជាទីស្រឡាញ់ របស់មាតា ជាទីស្រឡាញ់ របស់បិតា ដែលមាតាបិតា បានហើយ ដោយការប្រព្រឹត្តវ័ត ដ៏ច្រើនផង ដោយការបន់ស្រន់ផង ។

១ ឃោសនា ។

ថេរគាថាយ  សត្តកនិបាតោ

តេ ច មំ អនុកម្បាយ  អត្ថកាមា ហិតេសិនោ
ឧភោ បិតា ច មាតា ច  ពុទ្ធស្ស ឧបនាមយុំ ។
កិច្ឆា លទ្ធោ អយំ បុត្តោ  សុខុមាលោ សុខេធិតោ
ឥមំ ទទាម តេ នាថ  ជិនស្ស បរិចារកំ ។
សត្ថា ច មំ បដិគ្គយ្ហ  អានន្ទំ ឯតទព្រវិ
បព្វាជេហិ ឥមំ ខិប្បំ  ហេស្សត្យាជានិយោ អយំ ។
បព្វាជេត្វាន មំ សត្ថា  វិហារំ បាវិសី ជិនោ
អនោគ្គតស្មឹ សុរិយស្មឹ  តតោ ចិត្តំ វិមុច្ចិ មេ ។
តតោ សត្ថា និរង្កត្វា  បដិសល្លានវុដ្ឋិតោ
ឯហិ ភទ្ទាតិ មំ អាហ  សា មេ អាសូបសម្បទា ។
ជាតិយា សត្តវស្សេន  លទ្ធា មេ ឧបសម្បទា
តិស្សោ វិជ្ជា អនុប្បត្តា  អហោ ធម្មសុធម្មតាតិ ។

ភទ្ទោ ថេរោ ។

[២២៨] ទិស្វា បាសាទឆាយាយំ  ចង្កមន្តំ នរុត្តមំ
តត្ថ នំ ឧបសង្កម្ម  វន្ទិស្សំ បុរិសុត្តមំ ។

ឯមាតានិងបិតាទាំងពីរនោះ ជាអ្នកប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ទើបនាំខ្ញុំទៅថ្វាយព្រះពុទ្ធ ព្រោះសេចក្តីអនុគ្រោះ (ដោយពាក្យថា) ។ កូននេះធ្លាប់សុខ ចម្រើនដោយសេចក្តីសុខ ខ្ញុំព្រះអង្គបានដោយលំបាក បពិត្រព្រះលោកនាថ យើងខ្ញុំសូមថ្វាយកូននេះ ឲ្យជាអ្នកបម្រើព្រះអង្គ អ្នកទ្រង់ឈ្នះមារ ។ ទើបព្រះសាស្តាទទួលខ្ញុំ ហើយត្រាស់ពាក្យនេះនឹងព្រះអានន្ទថា អ្នកចូរបំបួសកុមារនេះឲ្យឆាប់ កុមារនេះនឹងបានជាបុរសអាជានេយ្យ ។ លុះព្រះសាស្តាអ្នកឈ្នះមារ ទ្រង់ឲ្យបំបួសខ្ញុំរួចហើយ ក៏ស្តេចចូលទៅកាន់វិហារ នាកាលព្រះអាទិត្យមិនទាន់លិច លំដាប់នោះ ចិត្តរបស់ខ្ញុំក៏ផុតចាកអាសវៈ ។ តពីនោះមក ព្រះសាស្តាទ្រង់ចេញចាកទីសម្ងំ លះបង់ ហើយត្រាស់នឹងខ្ញុំថា ម្នាលភទ្ទៈ អ្នកចូរមក ព្រះវាចានោះបានជាឧបសម្បទារបស់ខ្ញុំ ។ ខ្ញុំបានឧបសម្បទា ក្នុងអាយុ ៧ ឆ្នាំ អំពីកំណើត ខ្ញុំបានសម្រេចវិជ្ជា ៣ ហើយ ឱ! ព្រះធម៌ល្អណាស់តើ ។

ភទ្ទត្ថេរ ។

[២២៨] ខ្ញុំបានឃើញព្រះសាស្តា ព្រះអង្គឧត្តមជាងជន ដែលកំពុងចង្ក្រម ឰដ៏ម្លប់ប្រាសាទគឺគន្ធកុដិ ក៏បានចូលទៅគាល់ព្រះសាស្តានោះក្នុងទីនោះ ហើយថ្វាយបង្គំនូវព្រះអង្គ ជាបុរសដ៏ឧត្តម ។

៤



ឯកំសំ ចីវរំ កត្វា សង្ឃរិត្វាន(១) បាណិយោ
អនុចង្កមិស្សំ វិរជំ សព្វសត្តានមុត្តមំ ។
តតោ បញ្ហេ អាបុច្ឆិ មំ បញ្ហានំ កោវិទោ វិទូ
អច្ឆម្ភិ ច អភីតោ ច ព្យាកាសឹ សត្ថុនោ អហំ ។
វិស្សជ្ជិតេសុ បញ្ហេសុ អនុមោទិ តថាគតោ
ភិក្ខុសង្ឃំ វិលោកេត្វា ឥមមត្ថំ អភាសថ ។
លាភា អង្គមគធានំ យេសាយំ បរិភុញ្ជតិ
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ ។
បច្ចុដ្ឋានញ្ច សាមីចឹ តេសំ លាភាតិ ចាព្រវិ ។
អជ្ជតគ្គេ មំ សោបាក ទស្សនាយោបសង្កម
ឯសា ចេវ តេ សោបាក ភវតុ ឧបសម្បទា ។
ជាតិយា សត្តវស្សោហំ លទ្ធាន ឧបសម្បទំ ។
ធារេមិ អន្តិមំ ទេហំ អហោ ធម្មសុធម្មតាតិ ។

សោបាកោ ថេរោ ។

---

១ ឱ. សំហារិត្វាន ។

ខ្ញុំធ្វើនូវចីវរ ឆៀងស្មាម្ខាង ហើយផ្គុំដៃ បានដើរចង្ក្រមតាមព្រះពុទ្ធ ព្រះអង្គប្រាសចាកធូលីគឺរាគៈ ឧត្តមជាងសព្វសត្វ ។ លំដាប់នោះ ព្រះសាស្ដាព្រះអង្គទ្រង់ឈ្វាសវៃ ជ្រាបនូវប្រស្នា បានសួរប្រស្នាចំពោះខ្ញុំ ខ្ញុំក៏មិនតក់ស្លុត មិនភិតភ័យ បានឆ្លើយប្រស្នាថ្វាយព្រះសាស្ដា ។ កាលដែលខ្ញុំឆ្លើយប្រស្នាចប់ហើយ ព្រះតថាគតក៏ទ្រង់អនុមោទនា ហើយទ្រង់ទតមើលភិក្ខុសង្ឃ បានត្រាស់សេចក្ដីនេះថា ។ សោបាកៈនេះ ប្រើប្រាស់បច្ច័យ គឺចីវរ បិណ្ឌបាត ទីដេកនិងទីអង្គុយរបស់ពួកអ្នកដែនអង្គៈមគធៈណា ពួកជនអ្នកដែនអង្គៈមគធៈនោះ ហៅពេញជាមានលាភ ។ មួយទៀត ព្រះសាស្ដាត្រាស់នូវការក្រោកទទួល និងការប្រព្រឹត្តសមគួរ ថាជាលាភរបស់ពួកជនអ្នកដែនអង្គៈមគធៈនោះ ។ (ព្រះសាស្ដាត្រាស់ថា) ម្នាលសោបាកៈ តាំងពីថ្ងៃនេះជាដើមទៅ អ្នកចូរមកចួបនឹងតថាគតចុះ ម្នាលសោបាកៈ ការដោះស្រាយប្រស្នានេះឯង ចូរជាឧបសម្បទារបស់អ្នកចុះ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត ក៏បានឧបសម្បទាទ្រទ្រង់រាងកាយជាទីបំផុត ឱ! ព្រះធម៌ល្អណាស់តើ ។

សោបាកត្ថេរ ។

៨



[២២៩] សរេ ហត្ថេហិ ភញ្ជិត្វា កត្វាន កុដិមច្ឆិសំ

តេន មេ សរភង្គោតិ នាមំ សម្មតិយា[១] អហុ ។

ន មយ្ហំ កប្បតេ អជ្ជ សរេ ហត្ថេហិ ភញ្ជិតុំ

សិក្ខាបទា នោ បញ្ញត្តា គោតមេន យសស្សិនា ។

សកលំ សមត្តំ រោគំ សរភង្គោ នាទ្ទសំ បុព្វេ

សោយំ រោគោ ទិដ្ឋោ វច នករេនាតិទេវស្ស ។

យេនេវ មគ្គេន គតោ វិបស្សី

យេនេវ មគ្គេន សិខី ច វេស្សភូ

កកុសន្ធកោណាគមនោ ច កស្សបា

តេនញ្ជសេន អគមាសិ គោតមោ ។

វីតតណ្ហា អនាទានា សត្ត ពុទ្ធា ខយោគធា

យេហាយំ ទេសិតោ ធម្មោ ធម្មភូតេហិ តាទិហិ

ចត្តារិ អរិយសច្ចានិ អនុកម្បាយ បាណិនំ

ទុក្ខំ សមុទយោ មគ្គោ និរោធោ ទុក្ខសង្ខយោ ។

---

១ ឱ. ម. សម្មុតិយា ។

[២២៩] ខ្ញុំ (កាលនៅជាតាបស) បានច្រូតស្បូវដោយដៃឯងធ្វើកុដិសម្រាប់នៅ ព្រោះហេតុនោះ បានជាឈ្មោះរបស់ខ្ញុំថា សរភង្គ ដោយសម្មតិ ។ ការច្រូតស្បូវដោយដៃ មិនគួរដល់ខ្ញុំក្នុងថ្ងៃនេះទេ ព្រោះសិក្ខាបទទាំងឡាយ ព្រះគោតមដ៏មានយស បានបញ្ញត្តហើយដល់យើង ។ ខ្ញុំឈ្មោះសរភង្គ មិនបានឃើញរោគ ដែលពេញពោរទាំងអស់ ក្នុងកាលមុន រោគនោះ ដែលសរភង្គអ្នកធ្វើតាមឱវាទ នៃព្រះសម្មាសម្ពុទ្ធជាទេវតាដ៏ប្រសើរ បានឃើញហើយ ។

ព្រះវិបស្សីទ្រង់យាងទៅហើយ តាមផ្លូវណា ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈនិងព្រះកស្សបៈទ្រង់យាងទៅតាមផ្លូវណា ព្រះគោតមទ្រង់យាងទៅតាមផ្លូវនោះដែរ ។ ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ យាងចុះកាន់ព្រះនិញ្វន ព្រះអង្គមានធម្មកាយកើតហើយ ប្រកបដោយតាទិគុណ ទ្រង់សម្តែងនូវធម៌នេះគឺអរិយសច្ចៈ៤ បានដល់ទុក្ខ សមុទ័យ មគ្គ និរោធ ជាទីអស់ទៅនៃទុក្ខ ដើម្បីអនុគ្រោះដល់ពួកសត្វ ។

៦

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

យស្មិំ និវត្តតេ ទុក្ខំ សំសារស្មិំ អនន្តកំ
ភេទា ឥមស្ស កាយស្ស ជីវិតស្ស ច សង្ខយា
អញ្ញោ បុនព្ភវោ នត្ថិ សុវិមុត្តោម្ហិ សព្វជីតិ ។

សរភង្គោ ថេរោ ។

## ឧទ្ទានំ

សុន្ទរសមុទ្ទោ ថេរោ ថេរោ លកុណ្ឌកភទ្ទិយោ
ភទ្ទោ ថេរោ ច សោចាកោ សរភង្គោ មហាឥសិ
សត្តកេ បញ្ចកា ថេរា គាថាយោ បញ្ចតឹសតីតិ ។

សត្តកនិបាតោ និដ្ឋិតោ ។

---

៦



*ទុក្ខក្នុងសង្សារមិនមានទីបំផុត ប្រព្រឹត្តទៅក្នុងកាយណា អំពីការបែកធ្លាយនៃកាយនេះក្តី ការអស់ទៅនៃជីវិតក្តី ភពថ្មីដទៃទៀតមិនមាន ខ្ញុំផុតស្រឡះហើយចាកកិលេសទាំងអស់ ។*

សរភង្គត្ថេរ ។

# ឧទ្ទាន

*ព្រះថេរៈ ៥ អង្គ គឺសុន្ទរសមុទ្ទត្ថេរ ១ លកុណ្ឌកភទ្ទិយត្ថេរ ១ ភទ្ទត្ថេរ ១ សោបាកត្ថេរ ១ សរភង្គមហាឥសី ១ ពោលនូវគាថា ៣៥ ក្នុងសត្តកនិបាត ។*

ចប់ សត្តកនិបាត ។

---

៧

# ថេរគាថាយ អដ្ឋកនិបាតោ

[២៣០] កម្មំ ពហុកំ ន ការយេ
បរិវជ្ជេយ្យ ជនំ ន ឧយ្យមេ
សោ ឧស្សុក្កោ រសានុគិទ្ធោ
អត្ថំ រិញ្ចតិ យោ សុខាធិវាហោ ។
បង្កោតិ ហិ នំ អវេទយុំ
យាយំ វន្ទនបូជនា កុលេសុ
សុខុមំ សល្លំ ទុរុព្វហំ
សក្ការោ កាបុរិសេន ទុជ្ជហោ ។

ន បរស្សុបណិធាយ  កម្មំ មច្ចស្ស ចាបកំ[1]
អត្តនា តំ ន សេវេយ្យ  កម្មពន្ធូ ហិ មាតិយា ។
ន បរេ វចនា ចោរោ  ន បរេ វចនា មុនិ
អត្តានញ្ច[2] យថា វេទិ  ទេវាបិ នំ តថា វិទូ ។
បរេ ច ន វិជានន្តិ  មយមេត្ថ យមាម្ហ សេ
យេ ច តត្ថ វិជានន្តិ  តតោ សម្មន្តិ មេធគា ។
ជីវតេវាបិ សប្បញ្ញោ  អបិ វិត្តបរិក្ខយា
បញ្ញាយ ច អលាភេន  វិត្តវាបិ ន ជីវតិ ។

---

១ ម. អច្ចយបាបកំ ។ ២ អដ្ឋកថាយំ អត្តាចនន្តិ ទិស្សតិ ។

# ថេរគាថា អដ្ឋកនិបាត

[២៣០] បព្វជិតមិនគប្បីធ្វើនូវកម្មច្រើនទេ គប្បីលះបង់ជន (បាបមិត្ត) មិនគប្បីខ្វល់ខ្វាយ (ដើម្បីលាភទេ) ព្រោះបព្វជិតអ្នកខ្វល់ខ្វាយ ជាប់ចិត្តក្នុងរស រមែងលះបង់ប្រយោជន៍ ដែលនាំមកនូវសេចក្ដីសុខ ។ ការថ្វាយបង្គំនិងការបូជាណា ក្នុងត្រកូលទាំងឡាយ ពួកព្រះអរិយៈ ដឹងច្បាស់នូវការថ្វាយបង្គំ និងការបូជានោះ ថា ដូចជាភក់ ទាំងដឹងថាជាសរដ៏ឆ្មារ គេកម្រដកបាន ជាគ្រឿងសក្ការៈ ដែលបុរសអាក្រក់ លះបង់បានដោយកម្រ ។

បុគ្គលមិនគប្បីសេពនូវអំពើអាក្រក់ដោយខ្លួន ព្រោះបំពេញ(ទុក្ខ) ដល់សត្វដទៃ (ទាំងមិនញុំាងបុគ្គលដទៃឲ្យសេពនូវអំពើអាក្រក់នោះ) ព្រោះថាសត្វទាំងឡាយ មានកម្មជាផៅពង្ស ។ បុគ្គលជាចោរ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលជាអ្នកប្រាជ្ញ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលដឹងខ្លួនឯង យ៉ាងណា សូម្បីពួកទេវតាក៏ដឹងបុគ្គលនោះដូច្នោះដែរ ។ ពួកជនផ្ដេសផ្ដាស រមែងមិនដឹងច្បាស់ថា យើងទាំងឡាយនឹងលំបាកក្នុងលោកនេះ តែពួកជនណា ដឹងច្បាស់ក្នុងដំណើរនោះ ជម្លោះតែងស្ងប់រម្ងាប់ទៅ អំពីសំណាក់ពួកជននោះ ។ បុគ្គលប្រកបដោយបញ្ញា បើទុកជាអស់សម្បត្តិរលីងគេង ក៏ឈ្មោះថារស់នៅ ឯបុគ្គលមានសម្បត្តិ ឈ្មោះថា មិនរស់នៅ ព្រោះការមិនបាននូវបញ្ញា ។

សព្វំ សុណាតិ សោតេន សព្វំ បស្សតិ ចក្ខុមា
ន ច ទិដ្ឋំ សុតំ ធីរោ សព្វំ ឧជ្ឈិតុមរហតិ ។
ចក្ខុមស្ស យថា អន្ធោ សោតវា ពធិរោ យថា
បញ្ញវស្ស យថា មូគោ ពលវា ទុព្វលោរិវ
អថ អត្ថេ សមុប្បន្នេ សយេថ[១] មតសាយិកន្តិ ។

មហាកច្ចាយនោ ថេរោ ។

[២៣១] អក្កោធនោ អនុបនាហី អមាយោ រិត្តបេសុណោ
ស វេ តាទិសកោ ភិក្ខុ ឯវំ បេច្ច ន សោចតិ ។
អក្កោធនោ អនុបនាហី អមាយោ រិត្តបេសុណោ
គុត្តទ្វារោ សទា ភិក្ខុ ឯវំ បេច្ច ន សោចតិ ។
អក្កោធនោ អនុបនាហី អមាយោ រិត្តបេសុណោ
កល្យាណសីលោ យោ ភិក្ខុ ឯវំ បេច្ច ន សោចតិ ។

១ ម. បស្សេថ ។

បុគ្គលរមែងស្ដាប់នូវសំឡេងទាំងអស់បាន ដោយសារត្រចៀក បុគ្គលមានចក្ខុរមែងឃើញរូបគ្រប់យ៉ាង ចំណែកអ្នកប្រាជ្ញមិនគួរលះចោល (ឬប្រកាន់ ) នូវអារម្មណ៍ទាំងពួងដែលខ្លួនឃើញហើយ ឮហើយឡើយ ។ បុគ្គលអ្នកមានភ្នែក គប្បីធ្វើដូចជាខ្វាក់ បុគ្គលអ្នកមានត្រចៀក គប្បីធ្វើដូចជាថ្លង់ បុគ្គលអ្នកមានបញ្ញា គប្បីធ្វើដូចជាគ បុគ្គលអ្នកមានកម្លាំង គប្បីធ្វើដូចជាអ្នកខ្សោយកម្លាំង តែកាលបើហេតុ (មិនគួរធ្វើ) កើតឡើងហើយ ត្រូវដេកដូចជាដេកស្លាប់ ។

មហាកច្ចាយនត្ថេរ ។

[២៣១] ភិក្ខុណា គ្មានសេចក្ដីក្រោធ មិនចងសេចក្ដីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្ដីញុះញង់ ភិក្ខុមានសភាពដូច្នោះនោះឯងរមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្ដីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្ដីក្រោធ មិនចងសេចក្ដីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្ដីញុះញង់ មានទ្វាររក្សាហើយគ្រប់កាល ភិក្ខុនោះ រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្ដីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្ដីក្រោធ មិនចងសេចក្ដីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្ដីញុះញង់ មានសីលល្អ ភិក្ខុនោះ រមែងមិនសោយសោកក្នុងខាងមុខ ដោយសេចក្ដីប្រតិបត្តិយ៉ាងនេះ ។

៩

## ថេរគាថាយ អដ្ឋកនិបាតោ

អក្កោធនោ អនុបនាហី អមាយោ រិត្តបេសុណោ
កល្យាណមិត្តោ យោ ភិក្ខុ ឯវំ បេច្ច ន សោចតិ ។
អក្កោធនោ អនុបនាហី អមាយោ រិត្តបេសុណោ
កល្យាណបញ្ញោ យោ ភិក្ខុ ឯវំ បេច្ច ន សោចតិ ។
យស្ស សទ្ធា តថាគតេ អចលា សុបតិដ្ឋិតា
សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ
សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ
អទលិទ្ទោតិ តំ អាហុ អមោឃន្តស្ស ជីវិតំ ។
តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធាន សាសនន្តិ ។

សិរិមិត្តោ ថេរោ ។

[២៣២] យទា បឋមមទ្ទក្ខឹ សត្ថារមកុតោភយំ
តតោ មេ អហុ សំវេគោ បស្សិត្វា បុរិសុត្តមំ ។
សិរឹ ហត្ថេហិ បាទេហិ យោ បណាមេយ្យ អាគតំ

ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានមិត្តល្អ ភិក្ខុនោះ រមែងមិនសោកស្តាយ ក្នុងកាលខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ ភិក្ខុណា គ្មានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនមានមាយា ប្រាសចាកសេចក្តីញុះញង់ មានបញ្ញាល្អ ភិក្ខុនោះ រមែងមិនសោកស្តាយ ក្នុងកាលខាងមុខ ដោយសេចក្តីប្រតិបត្តិយ៉ាងនេះ ។ បុគ្គលណា មានសទ្ធាមិនញាប់ញ័រ បានតម្កល់ស៊ប់ក្នុងព្រះតថាគតផង បុគ្គលណា មានសីលល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈសរសើរហើយផង បុគ្គលណា មានសេចក្តីជ្រះថ្លា ក្នុងសង្ឃផង បុគ្គលណា មានការយល់ឃើញត្រង់ផង អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាអ្នកមិនខ្សត់ ជីវិតរបស់បុគ្គលនោះ មិនមែនជាមោឃៈទេ ។ ព្រោះហេតុនោះ មេធាវីបុគ្គល កាលរលឹកនូវពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គួរប្រកបរឿយ ៗ នូវសទ្ធាផង សីលផង សេចក្តីជ្រះថ្លាផង ការយល់ធម៌ផង ។

សិរិមិត្តត្ថេរ ។

[២៣២]កាលណា ខ្ញុំឃើញព្រះសាស្តា ព្រះអង្គគ្មានភ័យអំពីទីណាជាដំបូង ក្នុងកាលនោះ សេចក្តីសង្វេគក៏មានដល់ខ្ញុំ ព្រោះឃើញព្រះសាស្តាជាឧត្តមបុរស ។ អ្នកណា ប្រានសិរីដែលមក(រកខ្លួន)ដោយដៃឬជើង

ឯតាទិសំ សោ សត្ថារំ អារាធេត្វា វិរាធយេ ។
តថាហំ បុត្តទារញ្ច ធនធញ្ញញ្ច ឆឌ្ឌយឹ
កេសមស្សូនិ ឆេទេត្វា បព្វជឹ អនគារិយំ ។
សិក្ខាសាជីវសម្បន្នោ ឥន្ទ្រិយេសុ សុសំវុតោ
នមស្សមានោ សម្ពុទ្ធំ វិហាសឹ អបរាជិតោ ។
តតោ មេ បណិធី អាសិ ចេតសោ អភិបត្ថិតោ
ន និសីទេ មុហុត្តម្បិ តណ្ហាសល្លេ អនូហតេ ។
តស្ស មេវំ វិហរតោ បស្ស វីរិយបរក្កមំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
អរហា ទក្ខិណេយ្យោម្ហិ វិប្បមុត្តោ និរូបធិ ។
តតោ រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ
សព្វំ តណ្ហំ វិសោសេត្វា បល្លង្កេន ឧបាវិសិន្តិ ។

មហាបន្ថកោ ថេរោ ។

## ឧទ្ទានំ

មហាកច្ចាយនោ ថេរោ សិរិមិត្តោ មហាបន្ថកោ
តយោ[១] អដ្ឋនិបាតម្ហិ គាថាយោ ចតុវីសតីតិ ។

អដ្ឋកនិបាតោ និដ្ឋិតោ ។

១ ឱ. ប. ឯតេ ។

*អ្នកនោះឈ្មោះថា ញ៉ាំងព្រះសាស្តាបែបនេះឲ្យត្រេកអរ ហើយឲ្យប្រាសចាកសេចក្តីត្រេកអរវិញ ។ ក្នុងកាលនោះ ខ្ញុំលះចោលកូននិងប្រពន្ធផង ទ្រព្យនិងស្រូវផង កោរសក់និងពុកចង្កា ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំបរិបូណ៌ដោយសិក្ខានិងសាជីវៈ សង្រួមនូវឥន្ទ្រិយទាំងឡាយ ជាអ្នកមិនចាលចាញ់កិលេស តែងនមស្ការព្រះសម្ពុទ្ធ សម្រាន្តនៅ ។ ខណៈនោះ សេចក្តីតាំងចិត្ត ខ្ញុំបានតម្កល់ហើយថា កាលបើខ្ញុំមិនទាន់ដកសរគឺតណ្ហាបានទេ ខ្ញុំមិនអង្គុយសូម្បីមួយរំពេច ។ អ្នកចូរមើលសេចក្តីព្យាយាម និងការប្រឹងប្រែងរបស់ខ្ញុំនោះ យ៉ាងនេះ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធ-សាសនាខ្ញុំបានធ្វើហើយ ។ ខ្ញុំដឹងនូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំក៏បានជម្រះហើយ ខ្ញុំជាព្រះអរហន្ត គួរទទួលនូវទក្ខិណាទាន មានចិត្តរួចស្រឡះហើយ មិនមានឧបធិ ។ លំដាប់នោះ ក្នុងកាលរាត្រីអស់ទៅ ព្រះអាទិត្យក៏រះឡើង ខ្ញុំបានធ្វើតណ្ហាទាំងអស់ឲ្យរីងស្ងួត ហើយអង្គុយដោយភ្នែន ។*

មហាបន្ថកត្ថេរ ។

## ឧទ្ទាន

*ព្រះថេរៈ ៣ អង្គ គឺមហាកច្ចាយនត្ថេរ ១ សិរិមិត្តត្ថេរ ១ មហា-បន្ថកត្ថេរ ១ បានសម្តែងគាថាទាំងឡាយ ២៤ ក្នុងអដ្ឋកនិបាត ។*

ចប់ អដ្ឋកនិបាត ។

# ថេរគាថាយ នវកនិបាតោ

[២៣៣] យទា ទុក្ខំ ជរាមរណន្តិ បណ្ឌិតោ
អវិទ្ទសូ យត្ថ សិតា បុថុជ្ជនា
ទុក្ខំ បរិញ្ញាយ សតោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតិ ។
យទា ទុក្ខស្សាវហនឹ វិសត្តិកំ
បបញ្ចសង្ឃាតទុក្ខាធិវាហនឹ
តណ្ហំ បហត្វាន សតោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតិ ។
យទា សិវំ ទ្វេចតុរង្គគាមិនំ
មគ្គុត្តមំ សព្វកិលេសសោធនំ
បញ្ញាយ ផុសិត្វា(១) សតោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតិ ។
យទា អសោកំ វិរជំ អសង្ខតំ
សន្តំ បទំ សព្វកិលេសសោធនំ
ភាវេតិ សញ្ញោជនពន្ធនច្ឆិទំ
តតោ រតឹ បរមតរំ ន វិន្ទតិ ។

១ ឱ. ម. បស្សិត្វា ។

# ថេរគាថា នវកនិបាត

[២៣៣] ពួកបុថុជ្ជន មិនដឹងថា ជរាមរណៈជាទុក្ខ ហើយជាប់ចំពាក់ក្នុងឧបាទានក្ខន្ធណា អ្នកប្រាជ្ញមានស្មារតី បានកំណត់ដឹង (នូវឧបាទានក្ខន្ធនោះ) ថាជាទុក្ខហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរលើសលុបជាងឈាននោះឡើយ ។ បណ្ឌិតលុះលះបង់នូវតណ្ហា ដែលនាំមកនូវសេចក្តីទុក្ខ ជាធម្មជាតិផ្សាយទៅក្នុងអារម្មណ៍ផ្សេង ៗ នាំមកនូវកិលេសជាគ្រឿងនាំសត្វឲ្យយឺតយូរ និងសេចក្តីទុក្ខដូចជាឃ្នាប មានស្មារតីចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរដ៏លើសលុបជាង ឈាននោះឡើយ ។ បុគ្គលពាល់ត្រូវមគ្គដ៏ឧត្តមប្រកបដោយអង្គ ៨ ពីរជង ដ៏ក្សេម ជាគ្រឿងជម្រះនូវកិលេសទាំងអស់ ដោយបញ្ញា ជាអ្នកមានស្មារតី ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេក-អរដ៏ក្រៃលែងជាងឈាននោះឡើយ ។ បុគ្គលចម្រើននូវសន្តបទ ដែលឥតមានសោក ប្រាសចាកធូលីគឺកិលេស ឥតមានបច្ច័យតាក់តែង ជាគ្រឿងជម្រះនូវកិលេសទាំងអស់ ផ្តាច់នូវចំណងគឺសញ្ញោជនៈ ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្តីត្រេកអរដ៏ក្រៃលែង ជាងការចម្រើននូវសន្តបទនោះឡើយ ។

យទា នភេ គជ្ជតិ មេឃទុន្ទុភិ
ធារាកុលា វិហង្គបថេ សមន្តតោ
ភិក្ខុ ច បព្ភារគតោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតិ ។
យទា នទីនំ កុសុមាកុលានំ
វិចិត្តវានេយ្យវដំសកានំ
តីរេ និសិន្នោ សុមនោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតិ ។
យទា និសីវេ[(១)] រហិតម្ហិ កាននេ
ទេវេ គឡន្តម្ហិ នទន្តិ ទាឋិនោ
ភិក្ខុ ច បព្ភារគតោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតិ ។
យទា វិតក្កេ ឧបរុន្ធិយត្តនោ
នគន្តរេ នគវិវរំ សមស្សិតោ
វិតទ្ទរោ វិគតខិលោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតិ ។

---
១ ឱ. និសីថេ ។ ម. និសីទេ ។

ផ្គរលាន់ក្នុងអាកាស ទទឹកភ្លៀងពាសពេញ ដោយជុំវិញ ឰដ៏អាកាសក្នុងកាលណា កាលនោះ ភិក្ខុចូលទៅនៅក្នុងញកភ្នំ ចម្រើនឈាន រមែងមិនបាននូវសេចក្ដីត្រេកអរជាងឈាននោះឡើយ ។ ភិក្ខុអង្គុយក្បែរឆ្នេរស្ទឹងទាំងឡាយ ដ៏ដេរដាសដោយផ្កា មានផ្កាឈើក្នុងព្រៃដ៏វិចិត្រជាគ្រឿងប្រដាប់ មានចិត្តល្អ ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្ដីត្រេកអរដ៏លើសលុបជាងឈាននោះឡើយ ។ កាលបើភ្លៀងធ្លាក់ចុះក្នុងព្រៃស្ងាត់ ពេលយប់ ពួកសត្វមានចង្កូមបន្លឺឡើង ចំណែកភិក្ខុចូលទៅកាន់ញកភ្នំហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្ដីត្រេកអរដ៏លើសលុបជាងឈាននោះឡើយ ។ ភិក្ខុអាស្រ័យនូវចន្លោះភ្នំ ក្នុងកណ្ដាលនៃភ្នំ បិទនូវវិតក្កៈទាំងឡាយរបស់ខ្លួន ប្រាសចាកសេចក្ដីខ្វល់ ប្រាសចាកសេចក្ដីរឹងត្អឹងនៃចិត្ត ហើយចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្ដីត្រេកអរដ៏លើសលុបជាងឈាននោះឡើយ ។

១៣

ថេរគាថាយ នវកនិបាតោ

យទា សុខី មលខិលសោកនាសនោ
និរគ្គលោ និព្វនថោ វិសល្លោ
សព្វាសវេ ព្យន្តិកតោវ ឈាយតិ
តតោ រតឹ បរមតរំ ន វិន្ទតីតិ ។

ភូតោ ថេរោ ។

# ឧទ្ទានំ

ភូតោ តថទ្ទសោ ថេរោ ឯកោ ខគ្គវិសាណវា
នវកម្ហិ និបាតម្ហិ គាថាយោបិ ឥមា នវាតិ ។

នវកនិបាតោ និដ្ឋិតោ ។

(ភិក្ខុ)ជាអ្នកមានសេចក្ដីសុខ ជាអ្នកធ្វើសេចក្ដីរឹងត្អឹងជាមន្ទិល និងសេចក្ដីសោកឲ្យវិនាស ជាអ្នកគ្មានសន្ទះទ្វារគឺអវិជ្ជា គ្មានតណ្ហា ប្រាសចាកសរគឺរាគាទិក្កិលេស ធ្វើនូវអាសវៈទាំងអស់ឲ្យវិនាស ចម្រើនឈាន ក្នុងកាលណា កាលនោះ រមែងមិនបាននូវសេចក្ដីត្រេកអរដ៏លើសលុប ជាងឈាននោះឡើយ ។

ភូតត្ថេរ ។

# ឧទ្ទាន

ព្រះភូតត្ថេរ តែមួយអង្គឯង ដូចជាកុយរមាស ជាអ្នកឃើញពិត បានសម្ដែងគាថា ៩ ដែលមកក្នុងនវកនិបាត ។

ចប់ នវកនិបាត ។

---

# ថេរគាថាយ ទសកនិបាតោ

[២៣៤] អង្គារិនោទានិ ទុមា ភទន្តេ
ផលេសិនោ ឆទនំ វិប្បហាយ
តេ អច្ចិមន្តោវ បភាសយន្តិ
សមយោ មហាវីរ ភគី រសានំ ។
ទុមានិ ផុល្លានិ មនោរមានិ
សមន្តតោ សព្វទិសា បវន្តិ
បត្តំ បហាយ ផលមាសសានា[១]
កាលោ ឥតោ បក្កមនាយ វីរ ។
នេវាតិសីតំ ន បនាតិឧណ្ហំ
សុខា ឧតុ អទ្ធនិយា ភទន្តេ
បស្សន្តុ តំ សាកិយា កោឡិយា ច
បច្ឆាមុខំ រោហិណិយំ តរន្តំ[២] ។
អាសាយ កសតេ ខេត្តំ ពីជំ អាសាយ វប្បតិ
អាសាយ វាណិជា យន្តិ សមុទ្ទំ ធនហារកា ។
យាយ អាសាយ តិដ្ឋាមិ សា មេ អាសា វិបច្ចតុ[៣] ។

---
១ ម. ផលមាសមានា ។ ២ ម. តរន្តិ ។ ៣ ឱ. ម. សមិជ្ឈតុ ។

សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា

# ថេរគាថា ទសកនិបាត

[២៣៤] បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើកភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះរុងរឿង ដូចជាអណ្តាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាល នេះ ជាកាលគួរបានចំណែកធម្មរសហើយ ។ ឈើទាំងឡាយ ជាទីរីករាយនៃចិត្ត មានផ្លែ ផ្សាយក្លិនសព្វទិសដោយជុំវិញ ជម្រុះស្លឹ កចាស់ចោល ប្រុងនឹងចេញផ្លែថ្មីទៀត បពិត្រព្រះអង្គមានព្យាយាម កាលនេះជាកាលគួរដើម្បីចេញទៅអំពីទីនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិនក្តៅពេក វាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ពួកសក្យៈ និងពួកកោឡិយៈ សូមជួបព្រះអង្គ ដែលមានព្រះភក្ត្របែរត្រឡប់មកខាងក្រោយ កំពុងឆ្លងស្ទឹងរោហិណី ។ អ្នកស្រែភ្ជួរស្រែ ដោយសេចក្តីប្រាថ្នា ព្រោះពូជ ដោយសេចក្តីប្រាថ្នា ពួកឈ្មួញ អ្នករកទ្រព្យឆ្លងសមុទ្រ ដោយសេចក្តីប្រាថ្នា ។ ខ្ញុំព្រះអង្គ ឋិតនៅ ដោយសេចក្តីប្រាថ្នាណា សេចក្តីប្រាថ្នា របស់ខ្ញុំព្រះអង្គនោះ សូមឲ្យសម្រេច ។

បុនប្បុនញ្ចេវ វបន្តិ ពីជំ
បុនប្បុនំ វស្សតិ ទេវរាជា
បុនប្បុនំ ខេត្តំ កសន្តិ កស្សកា
បុនប្បុនំ ធញ្ញមុបេន្តិ រដ្ឋំ ។
បុនប្បុនំ យាចនកា ចរន្តិ
បុនប្បុនំ ទានបតី ទទន្តិ
បុនប្បុនំ ទានបតី ទទិត្វា
បុនប្បុនំ សគ្គមុបេន្តិ ឋានំ ។
ធីរោ[១] ហវេ សត្តយុគំ បុនេតិ[២]
យស្មឹ កុលេ ជាយតិ ភូរិបញ្ញោ
មញ្ញាមហំ សក្កតិ ទេវទេវោ
តយា ហិ ជាតោ មុនិ សច្ចនាមោ ។
សុទ្ធោទនោ នាម បិតា មហេសិនោ
ពុទ្ធស្ស មាតា បន មាយា មហេសី[៣]
យា[៤] ពោធិសត្តំ បរិហារិយ កុច្ឆិនា
កាយស្ស ភេទា តិទិវម្ហិ មោទតិ ។

---

១ ឱ. ម. វីរោ ។ ២ បុនេតិ សោធេតីតិ អដ្ឋកថាយំ ។
៣ ឱ. មាយនាមា ។ ម. មាយានាមស្ស ។ ៤ ម. យាតិ នត្ថិ ។

អ្នកស្រែទាំងឡាយ ព្រោះពូជរឿយៗ[១] ទេវរាជ បង្អុរភ្លៀងក៏រឿយៗ ពួកអ្នកស្រែ ភ្ជួរស្រែរឿយៗ ពួកអ្នកស្រែនោះនាំស្រូវចូលទៅកាន់ដែនក៏រឿយៗ ។ ពួកស្មូមត្រាច់សូមរឿយៗ អ្នកម្ចាស់ទាន តែងឲ្យក៏រឿយៗ ពួកម្ចាស់ទានលុះឲ្យរឿយៗ ហើយតែងទៅកាន់ឋានសួគ៌ក៏រឿយៗ ដែរ ។ អ្នកប្រាជ្ញមានបញ្ញាដូចផែនដី កើតក្នុងត្រកូលណា រមែងញុំាងគូនៃបុរស ៧ ជួរ ក្នុងត្រកូលនោះឲ្យស្អាត ខ្ញុំព្រះអង្គសម្គាល់ថា (ព្រះមានព្រះភាគ) ជាទេវតាប្រសើរជាងទេវតា អាច (ធ្វើសត្វដទៃឲ្យស្អាតបាន) ព្រោះអ្នកប្រាជ្ញមានព្រះនាមដ៏ពិត កើតហើយអំពីព្រះអង្គ ។ ព្រះបាទសុទ្ធោទនៈជាបិតារបស់ព្រះពុទ្ធព្រះអង្គស្វែងរកនូវគុណដ៏ធំ ឯព្រះមហេសីព្រះនាមមាយា ជាពុទ្ធមាតា ដែលរក្សាព្រះពោធិសត្វដោយផ្ទៃ លុះរំលាយខន្ធទៅ ត្រេកអរក្នុងតុសិតទេវលោក ។

---

១ បាលីថា “បុនប្បុនំ” ប្រែថា “រឿយៗ, ញយ ៗ, ដដែលៗ, ញឹកញាប់, ប៉ុកប៉ុន” ។

សា គោតមី កាលកតា ឥតោ ចុតា
ទិព្វេហិ កាមេហិ សមង្គិភូតា
សា មោទតិ កាមគុណេហិ បញ្ចហិ
បរិវារិតា ទេវគណេហិ តេហិ ។
ពុទ្ធស្ស បុត្តោម្ហិ អសយ្ហសាហិនោ
អង្គីរសស្សប្បដិមស្ស តាទិនោ
បិតុ បិតា មយ្ហំ តុវំសិ សក្ក
ធម្មេន មេ(១) គោតម អយ្យកោសីតិ ។

កាឡុទាយី ថេរោ ។

[២៣៤] បុរតោ បច្ឆតោ វាបិ អបរោ ចេ ន វិជ្ជតិ
អតីវ ផាសុ ភវតិ ឯកស្ស វសតោ វនេ ។
ហន្ទ ឯកោ គមិស្សាមិ(២) អរញ្ញំ ពុទ្ធវណ្ណិតំ
ផាសុំ ឯកវិហារិស្ស បហិតត្តស្ស ភិក្ខុនោ ។
យោគិបីតិករំ រម្មំ មត្តកុញ្ជរសេវិតំ
ឯកោ អត្តវសី ខិប្បំ បវិសិស្សាមិ កាននំ ។
សុបុប្ផិតេ សីតវនេ សីតលេ គិរិកន្ទរេ
គត្តានិ បរិសិញ្ចិត្វា ចង្កមិស្សាមិ ឯកកោ ។

១ ម. តេ. ។ ២ ម. ភវិស្សាមិ ។

ព្រះនាងទេវីនោះ ជាគោតមគោត្រលុះទិវង្គតច្យុតចាកលោកនេះទៅ បានស្កប់ស្កល់ដោយកាមជាទិព្វទាំងឡាយព្រះនាងទ្រង់រីករាយ ដោយកាមគុណទាំង ៥ មានពពួកទេវតាទាំងនោះចោមរោមហើយ ។ ខ្ញុំព្រះអង្គជាបុត្រនៃព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃគ្របសង្កត់បាន ព្រះនាមអង្គីរសៈមិនមានបុគ្គលដទៃប្រៀបបាន ប្រកបដោយតាទិគុណ បពិត្រព្រះអង្គជាសក្យៈ ព្រះអង្គជាបិតានៃបិតារបស់ខ្ញុំព្រះអង្គ បពិត្រព្រះគោតម ព្រះអង្គជាជីតា របស់ខ្ញុំព្រះអង្គ ដោយធម៌ ។

កាឡុទាយិត្ថេរ ។

[២៣៥] បើបុគ្គលដទៃ មិនមានអំពីមុខក្តី ក្រោយក្តី សេចក្តីសប្បាយក្រៃពេក រមែងមានដល់បុគ្គលម្នាក់ឯងនៅក្នុងព្រៃ ។ បើដូច្នោះអាត្មាអញតែម្នាក់ឯង នឹងទៅកាន់ព្រៃ ដែលព្រះពុទ្ធទ្រង់សរសើរហើយ ជាទីសប្បាយរបស់ភិក្ខុអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានជាអ្នកនៅតែម្នាក់ឯង ។ អាត្មាអញតែម្នាក់ឯង ជាអ្នកស្ទាត់ក្នុងប្រយោជន៍ នឹងចូលយ៉ាងឆាប់ទៅកាន់ព្រៃ ជាទីធ្វើឲ្យកើតបីតិដល់យោគាវចរ ជាទីរីករាយ ដែលដំរីចុះប្រេង សេពគប់ហើយ ។ អាត្មាអញ ម្នាក់ឯង នឹងស្រោចស្រប់ខ្លួន ហើយចង្ក្រម ក្នុងព្រៃត្រជាក់ មានផ្ការីកស្គុះស្គាយ ក្បែរជ្រោះភ្នំ ដ៏ត្រជាក់ ។

១៧

### ថេរគាថាយ ទសកនិបាតោ

ឯកាកិយោ អទុតិយោ រមណីយេ មហាវនេ
កទាហំ វិហរិស្សាមិ កតកិច្ចោ អនាសវោ ។
ឯវំ មេ កត្តុកាមស្ស អធិប្បាយោ សមិជ្ឈតុ
សាធយិស្សាមហំ យេវ នាញ្ញោ អញ្ញស្ស ការកោ ។
ឯស ពន្ធាមិ សន្នាហំ បវិសិស្សាមិ កាននំ
ន តតោ និក្ខមិស្សាមិ អប្បត្តោ អាសវក្ខយំ ។
មាលុតេ ឧបវាយន្តេ សីតេ សុរភិគន្ធកេ
អវិជ្ជំ ទាលយិស្សាមិ និសិន្នោ នគមុទ្ធនិ ។
វនេ កុសុមសញ្ឆន្នេ បព្ភារេ នូន សីតលេ
វិមុត្តិសុខេន សុខិតេ រមិស្សាមិ គិរិព្វជេ ។
សោហំ បរិបុណ្ណសង្កប្បោ ចន្ទោ បណ្ណរសោ យថា
សព្វាសវបរិក្ខីណោ នត្ថិ ទានិ បុនព្ភវោ ។

ឯកវិហារិយោ ថេរោ ។

[២៣៦] អនាគតំ យោ បដិកច្ច បស្សតិ
ហិតញ្ច អត្ថំ អហិតញ្ច តំ ទ្វយំ
វិទ្ទេសិនោ តស្ស ហិតេសិនោ វា
រន្ធំ ន បស្សន្តិ សមេក្ខមានា ។

អង្កាល់ណា អាត្មាអញនឹងទៅជាបុគ្គលម្នាក់ឯងមិនមានបុគ្គលជាគម្រប់ពីរ មានសោឡសកិច្ចធ្វើហើយ ជាអ្នកមិនមានអាសវៈ នៅក្នុងព្រៃធំ ដែលគួររីករាយ ។ សូមសេចក្តីប៉ុនប៉ងរបស់អាត្មាអញ ដែលប្រាថ្នាដើម្បីធ្វើសេចក្តីព្យាយាមយ៉ាងនេះ បានសម្រេច អាត្មាអញនឹងធ្វើឲ្យសម្រេច (ព្រោះថា)អ្នកដទៃ ធ្វើជួសអ្នកដទៃពុំបានទេ ។ ឥឡូវនេះ អាត្មាអញនោះនឹងចងក្រោះគឺព្យាយាម ហើយចូលទៅកាន់ព្រៃ បើអាត្មាអញមិនទាន់សម្រេចនូវធម៌ជាគ្រឿងអស់អាសវៈទេ នឹងមិនចេញពីព្រៃនោះឡើយ ។ កាលបើខ្យល់ត្រជាក់ មានក្លិនក្រអូបបក់ផ្សាយទៅ អាត្មាអញនឹងអង្គុយលើកំពូលភ្នំ ហើយទម្លាយអវិជ្ជាឲ្យបាន ។ អាត្មាអញទទួលសេចក្តីសុខ ដោយវិមុត្តិសុខក្នុងព្រៃ មានផ្កាដេរដាស ក្បែរញកភ្នំដ៏ត្រជាក់ រួចហើយនឹងត្រេកអរ ក្នុងក្រុងរាជគ្រឹះ មានភ្នំព័ទ្ធជុំវិញដូចក្រោលគោ ។ អាត្មាអញនោះ មានតម្រិះគ្រប់គ្រាន់ ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត អស់អាសវៈទាំងពួងហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។

ឯកវិហារិយត្ថេរ ។

[២៣៦] បុគ្គលណា ពិចារណាឃើញ នូវកិច្ចជាប្រយោជន៍និងមិនជាប្រយោជន៍ទាំងពីរនោះ ដែលមិនទាន់មកដល់ទុកជាមុនជនទាំងឡាយ ជាសត្រូវក្តី ជាអ្នកស្វែងរកប្រយោជន៍ក្តី កាលគយគន់មើល រមែងមិនឃើញ នូវទោសនៃបុគ្គលនោះឡើយ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

អាជាចានស្សតី យស្ស បរិបុណ្ណា សុភាវិតា
អនុបុព្វំ បរិចិតា យថា ពុទ្ធេន ទេសិតា
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។
ឱជាតំ វត មេ ចិត្តំ អប្បមាណំ សុភាវិតំ
និពទ្ធំ បគ្គហីតញ្ច សព្វា ឱភាសតេ ទិសា ។
ជីវតេវាបិ សប្បញ្ញោ អបិ វិត្តបរិក្ខយា
បញ្ញាយ ច អលាភេន វិត្តវាបិ ន ជីវតិ ។
បញ្ញា សុតវិនិច្ឆិនី បញ្ញា កិត្តិសិលោកវឌ្ឍនី
បញ្ញាសហិតោ នរោ ឥធ អបិ ទុក្ខេសុ សុខានិ វិន្ទតិ ។
នាយំ អជ្ជតនោ ធម្មោ នច្ឆេរោ នបិ អព្ភុតោ
យត្ថ ជាយេថ មីយេថ តត្ថ កិំ វិយ អព្ភុតំ ។
អនន្តរំ ហិ ជាតស្ស ជីវិតា មរណំ ធុវំ
ជាតា ជាតា មរន្តីធ ឯវំ ធម្មា ហិ ចាណិនោ ។

អានាបានស្សតិ ដែលព្រះយោគាវចរណា បានចម្រើនល្អគ្រប់គ្រាន់ ហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងមក ព្រះយោគាវចរនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺច្បាស់ ដូច ព្រះចន្ទផុតចាកពពក ។ ឱ ចិត្តរបស់អញ ស រកប្រមាណ មិនបាន អាត្មាអញ បានអប់រំល្អហើយផង បានផ្គងជានិច្ច ផង ញុំាងទិសទាំងពួងឲ្យភ្លឺផង ។ បុគ្គលប្រកបដោយប្រាជ្ញា បើទុកជាអស់ទ្រព្យរលីង ក៏ឈ្មោះថា រស់នៅ ឯបុគ្គលអ្នក មានទ្រព្យ មិនឈ្មោះថារស់នៅ ព្រោះកិរិយាមិនបាននូវប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿងវិនិច្ឆ័យនូវសុតៈ ប្រាជ្ញា ជាគ្រឿងញុំាងកិត្តិសព្ទ និងសេចក្តីសរសើរឲ្យចម្រើន នរជនប្រកបដោយប្រាជ្ញា រមែង បាននូវសេចក្តីសុខ សូម្បីក្នុងសភាវៈដែលជាទុក្ខ ។ ធម៌នេះមិន មែនជាធម៌ទើបនឹងមាន ក្នុងថ្ងៃនេះទេ ជាធម៌មិនអស្ចារ្យ មិន មែនជាធម៌ចំឡែកទេ សត្វកើតស្លាប់ ក្នុងលោកណា ហេតុតិចតួច ក៏មិនចំឡែក ក្នុងលោកនោះ ។ សេចក្តីពិតថា បន្ទាប់អំពី ការកើតមក មានសេចក្តីស្លាប់ចាកជីវិត ជាធម្មជាតទៀងទាត់ សត្វទាំងឡាយ ដែលកើតហើយ ៗ រមែងស្លាប់ ក្នុងលោកនេះ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះឯង ។

១៩



ន ហេតទត្ថាយ មតស្ស ហោតិ
យំ ជីវិតត្ថំ បរទោរិសានំ
មតម្ហិ រុណ្ណំ ន យសោ ន សោក្យំ[១]
ន វណ្ណិតំ សមណព្រាហ្មណេហិ ។
ចក្ខុំ សរីរំ ឧបហន្តិ រោណ្ណំ[២]
និហិយ្យតិ វណ្ណពលំ មតី ច[៣]
អានន្ទិនោ តស្ស ទិសា ភវន្តិ
ហិតេសិនោ ចស្ស[៤] ទុក្ខី ភវន្តិ ។
តស្មា ហិ ឥច្ឆេយ្យ កុលេ វសន្តេ
មេធាវិនោ ចេវ ពហុស្សុតេ ច
យេសំ ហិ បញ្ញាវិភវេន កិច្ចំ
តរន្តិ នាវាយ នទីវ បុណ្ណន្តិ ។

មហាកប្បិនោ ថេរោ ។

[២៣៧] ទន្ធា មយ្ហំ គតី អាសិ បរិភូតោ បុរេ អហំ
ភាតា ច មំ បណាមេសិ គច្ឆ ទានិ តុវំ ឃរំ ។
សោហំ បណាមិតោ[៥] សន្តោ សង្ឃារាមស្ស កោដ្ឋកេ
ទុម្មនោ តត្ថ អដ្ឋាសិ សាសនស្មឹ អបេក្ខវា ។

---

១ ឱ. ម. លោក្យំ ។ ២ ម. តេន ។ ៣ ម. មហី ច ។ ៤ ឱ. នាស្ស ។ ម. នស្ស ។ ៥ ម. បតិតោ ។

សេចក្ដីសោកស្ដាយណា របស់បុរសបុគ្គល ទាំងឡាយដទៃ ដើម្បីជីវិត សេចក្ដីសោកស្ដាយនុ៎ះ មិនមែនដើម្បីប្រយោជន៍ ដល់សត្វដែលស្លាប់ទៅហើយទេ ការយំចំពោះសត្វ ដែលស្លាប់ហើយ មិនមែនជាយស មិនមែនជាការល្អទេ សមណព្រាហ្មណ៍ទាំងឡាយ មិនសរសើរការយំឡើយ ។ ការយំ រមែងបៀតបៀននូវចក្ខុនិងសរីរៈ(របស់បុគ្គលអ្នកយំ) ពណ៌សម្បុរក្ដី កម្លាំងក្ដី ប្រាជ្ញាក្ដី នៃអ្នកយំរមែងសាបសូន្យ ពួកសត្រូវរបស់បុគ្គលអ្នកយំនោះ ក៏មានសេចក្ដីត្រេកអរ ពួកបុគ្គលអ្នកស្វែងរកប្រយោជន៍ ឲ្យបុគ្គលអ្នកយំនោះបាននូវសេចក្ដីទុក្ខ ។ ព្រោះហេតុនោះ ពួកជនច្នៃនូវកិច្ច (របស់ខ្លួន) ដោយកម្លាំងប្រាជ្ញា របស់អ្នកប្រាជ្ញទាំងឡាយណា ដូចពួកជនច្នៃនូវទន្លេមានទឹកពេញដោយទូក បុគ្គលគប្បីប្រាថ្នានូវអ្នកប្រាជ្ញ ជាពហុស្សូតនោះ ឲ្យនៅក្នុងត្រកូល (របស់ខ្លួន) ។

មហាកប្បិនត្ថេរ ។

[២៣៧] ញាណគតិ របស់អាត្មាអញទន់ខ្សោយ ក្នុងកាលមុន អាត្មាអញ ភ្លេចភ្លាំងស្មារតី ថែមទាំងបងប្រុស ក៏បណ្ដេញអាត្មាអញថា ឥឡូវនេះ អ្នកចូរទៅផ្ទះចុះ ។ អាត្មាអញនោះ ត្រូវបងបណ្ដេញហើយក៏តូចចិត្ត តែនៅមានអាឡោះអាល័យ ក្នុងសាសនា ក៏ឈរនៅជិតក្លោងទ្វារ នៃអារាម របស់សង្ឃនោះ ។

ភគវា តត្ថ អាគច្ឆិ សីសំ មយ្ហំ បរាមសិ
ពាហាយំ មំ គហេត្វាន សង្ឃារាមំ បវេសយិ ។
អនុកម្បាយ មេ សត្ថា ចាជាសិ ចាទបុញ្ឆនឹ
ឯតំ សុទ្ធំ អជិដ្ឋេហិ ឯកមន្តំ ស្វជិដ្ឋិតំ ។
តស្សាហំ វចនំ សុត្វា វិហាសឹ សាសនេ រតោ
សមាជឹ បដិចាទេសឹ ឧត្តមត្ថស្ស បត្តិយា ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោជិតំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
សហស្សក្ខត្តុំ អត្តានំ និម្មិនិត្វាន បន្ថកោ
និសីទិ អម្ពវនេ រម្មេ យាវ កាលប្បវេទនំ ។
តតោ មេ សត្ថា ចាហេសិ ទូតំ កាលប្បវេទកំ
បវេទិតម្ហិ កាលម្ហិ វេហាសានុបសង្កមឹ ។
វន្ទិត្វា សត្ថុនោ ចាទេ ឯកមន្តំ និសីទហំ
និសិន្នំ មំ វិទិត្វាន អថ សត្ថា បដិគ្គហិ ។
អាយាគោ សព្វលោកស្ស អាហុតីនំ បដិគ្គហោ
បុញ្ញក្ខេត្តំ មនុស្សានំ បដិគ្គណ្ហិត្ថ ទក្ខិណាន្តិ ។

ចូឡបន្ថកោ ថេរោ ។

ព្រះមានព្រះភាគ ទ្រង់យាងមកក្នុងទីនោះ បានស្ទាបអង្អែលក្បាលរបស់អាត្មាអញ ហើយក៏ចាប់អាត្មាអញត្រង់ដើមដៃ ឲ្យចូលទៅកាន់អារាមនៃសង្ឃ ។ ព្រះសាស្តាទ្រង់ប្រទាននូវសំពត់សម្រាបជូតជើង ដោយសេចក្តីអនុគ្រោះដល់អាត្មាអញថា អ្នកចូរអធិដ្ឋាននូវសំពត់ស្អាតនេះ ធ្វើឲ្យជាសំពត់ដែលខ្លួនអធិដ្ឋានល្អហើយ ក្នុងទីដ៏សមគួរចុះ ។ លុះអាត្មាអញបានស្តាប់ព្រះបន្ទូល របស់ព្រះមានព្រះភាគនោះហើយ ក៏ត្រេកអរក្នុងសាសនា បានញុំាំងសមាធិឲ្យសម្រេច ដើម្បីបាននូវប្រយោជន៍ដ៏ឧត្តម អាត្មាអញដឹងនូវបុព្វេនិវាស ទិព្វចក្ខុអាត្មាអញបានជម្រះហើយ ត្រៃវិជ្ជាអាត្មាអញបានដល់ដោយលំដាប់ហើយ ព្រះពុទ្ធសាសនា អាត្មាអញបានធ្វើហើយ ។ បន្ថកភិក្ខុនិម្មិតខ្លួនជាមួយពាន់ ហើយអង្គុយក្នុងអម្ពវ័នជាទីរីករាយ ដរាបដល់ការប្រាប់នូវភត្តកាល ។ លំដាប់នោះព្រះសាស្តាទ្រង់ប្រើទូតឲ្យទៅប្រាប់ភត្ត-កាលដល់អាត្មាអញ កាលទូតមកប្រាប់ភត្តកាល អាត្មាអញក៏មកតាមអាកាស ។ អាត្មាអញថ្វាយបង្គំព្រះបាទានៃព្រះសាស្តា រួចហើយអង្គុយក្នុងទីសមគួរ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបថា អាត្មាអញអង្គុយហើយ ទើបបានទ្រង់ទទួល (ទក្ខិណោទក) ។ ព្រះអង្គជាទីបូជារបស់សត្វលោក ជាបដិគ្គាហកៈរបស់បុគ្គលអ្នកបូជាទាំងឡាយ ជាបុញ្ញក្ខេត្តរបស់មនុស្សទាំងឡាយ ទ្រង់ទទួលនូវទក្ខិណាទាន ។

ចូឡបន្ថកត្ថេរ ។

[២៣៨] នានាកុលមលសម្បុណ្ណោ មហាឧក្ការសម្ភវោ
ចន្ទនិកំវ បរិបក្កំ មហាគណ្ឌោ មហាវណោ
បុព្វរុហិរសម្បុណ្ណោ គូថកូបេ និគាឡ្ហិកោ
អាចោបគ្ឃរណី កាយោ សទា សន្ទតិ បូតិកំ ។
សដ្ឋិកណ្ឌរសម្ពន្ធោ[១] មំសលេបនលេបិតោ
ចម្មកញ្ចុកសន្នទ្ធោ បូតិកាយោ និរត្ថកោ
អដ្ឋិសង្ឃាដឃដិតោ ន្ហារុសុត្តនិពន្ធនោ
នេកេសំ សង្គតិភាវា កប្បេតិ ឥរិយាបថំ ។
ធុវប្បយាតោ មរណាស្ស មច្ចុរាជស្ស សន្តិកេ
ឥធេវ ឆឌ្ឌយិត្វាន យេន កាមង្គមោ នរោ ។
អវិជ្ជាយ និវុតោ កាយោ ចតុគ្គន្ថេន គន្ថិតោ
ឱឃសំសីទនោ កាយោ អនុសយជាលមោត្ថតោ
បញ្ចនីវរណេ យុត្តោ វិតក្កេន សមប្បិតោ
តណ្ហាមូលេនានុគតោ មោហច្ឆាទនឆាទិតោ
ឯវាយំ វត្តតិ កាយោ កម្មយន្តេន យន្តិតោ ។
សម្បត្តិ ច វិបត្យន្តា នានាភាវោ វិបជ្ជតិ ។

១ ម. សដ្ឋិកណ្ឌរសម្បន្នោ ។

[២៣៨] *កាយដ៏ពេញដោយមន្ទិល មានចំណែកផ្សេង ៗ កើតក្នុងរណ្ដៅលាមកធំ គឺផ្ទៃមាតា ដូចជ្រាំចាស់ដែលអាប់អួយូរ ឬដូចបូសធំ ដំបៅធំជាកាយដ៏ពេញដោយខ្ទុះនិងឈាម ពេញព្រៀបក្នុងរណ្ដៅលាមក ជាទីហូរចេញនៃទឹក រមែងហូរចេញនូវវត្ថុ មិនស្អាត សព្វ ៗ កាល ។ កាយដែលចងភ្ជាប់ដោយសរសៃធំ ៦០ លាបដោយគ្រឿងលាប គឺសាច់ ប្រដាប់ដោយអាវគឺស្បែក ជាកាយស្អុយ រកប្រយោជន៍គ្មាន តភ្ជាប់គ្នាដោយពាងឆ្អឹង ចងស្រាក់ដោយចេសគឺសរសៃ សម្រេចឥរិយាបថបាន ព្រោះប្រជុំនៃអាការមិនតែមួយ ។ កាយមានដំណើរទៅរកសេចក្ដីស្លាប់ដ៏ទៀងទាត់ (បិតនៅ) ក្នុងសំណាក់នៃមច្ចុរាជ ឯនរជនតែងទម្លាក់ចោលនូវកាយ ក្នុងលោកនេះ ហើយទៅតាមយថាកម្ម ។ កាយត្រូវអវិជ្ជាដោតក្រងហើយ ត្រូវគ្រឿងចាក់ស្រែះ ៤ យ៉ាងចាក់ស្រែះហើយ កាយក៏លិចចុះក្នុងឱឃៈ ត្រូវបណ្ដាញនៃអនុសយៈ គ្របសង្កត់ហើយ ប្រកបក្នុងនីវរណៈ ៥ ពេញដោយមិច្ឆាវិតក្កៈ ជាប់ដោយមូលនៃភព គឺតណ្ហា ត្រូវដំបូលគឺមោហៈបិទបាំងហើយ កាយនេះ រមែងប្រព្រឹត្តទៅដូចពោលមកនេះ អន្ទោលទៅតាមយន្តគឺកម្ម ។ ធម្មតាសម្បត្តិ តែងមានវិបត្តិជាទីបំផុត ការកើតផ្សេងៗ រមែងវិនាសទៅវិញ ។*

យេមំ កាយំ មមាយន្តិ អន្ធពាលា បុថុជ្ជនា
វឌ្ឍេន្តិ កដសឹ ឃោរំ អាទិយន្តិ បុនព្ភវំ ។
យេមំ កាយំ វិវជ្ជេន្តិ គូថលិត្តំវ បន្នគំ
ភវមូលំ វមិត្វាន បរិនិព្វិស្សន្ត្យនាសវាតិ ។

កប្បោ ថេរោ ។

[២៣៩] វិវិត្តំ អប្បនិគ្ឃោសំ វាឡមិគនិសេវិតំ
សេវេ សេនាសនំ ភិក្ខុ បដិសល្លានការណា ។
សង្ការបុញ្ជា អាហត្វា សុសានា រថិយាហិ ច
តតោ សង្ឃាដិកំ កត្វា លូខំ ធារេយ្យ ចីវរំ ។
នីចំ មនំ ករិត្វាន សបទានំ កុលា កុលំ
បិណ្ឌិកាយ ចរេ ភិក្ខុ គុត្តទ្វារោ សុសំវុតោ ។
លូខេនបិ ច សន្តុស្សេ នាញ្ញំ បត្ថេ រសំ ពហុំ
រសេសុ អនុគិទ្ធស្ស ឈានេ ន រមតី មនោ ។
អប្បិច្ឆោ ចេវ សន្តុដ្ឋោ បវិវិត្តោ វសេ មុនិ
អសំសដ្ឋោ គហដ្ឋេហិ អនាគារេហិ ចូភយំ ។

ពួកជនណា ជាអន្ធពាលបុថុជ្ជន រាប់អានកាយនេះ ពួកជននោះ រមែងញុំាងសង្សារដ៏ពន្លឹកឲ្យចម្រើន តែងកាន់យកនូវភពថ្មីទៀត ។ ពួកជនណា វៀរបង់នូវកាយនេះ ដូចបុគ្គលវៀរបង់នូវអាសិរពិស ដែលប្រឡាក់ដោយលាមក ពួកជននោះ រមែងខ្ជាក់ចោលនូវអវិជ្ជា និងតណ្ហាដែលជាមូលនៃភព ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

កប្បត្ថេរ ។

[២៣៩] ភិក្ខុគប្បីសេពនូវសេនាសនៈស្ងាត់ ដែលមានសំឡេងគឹកកងតិច ដែលម្រឹគសាហាវអាស្រ័យនៅហើយ ព្រោះហេតុនៃការពួនសម្ងំ ។ ភិក្ខុគប្បីនាំមក (នូវកំណាត់សំពត់) អំពីគំនរនៃសម្រាម ឬព្រៃស្មសាន ឬចន្លោះនៃថ្នល់ ធ្វើជាសង្ឃាដី ដោយកំណាត់សំពត់ដែលខ្លួននាំមកនោះ ហើយទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ ភិក្ខុគប្បីធ្វើចិត្តឲ្យទាប គ្រប់គ្រងនូវទ្វារ សង្រួមដោយប្រពៃ ហើយត្រាច់ទៅកាន់ផ្ទះជាលំដាប់ គឺចេញអំពីត្រកូល ១ ទៅកាន់ត្រកូល ១ ដើម្បីបិណ្ឌបាត ។ ម្យ៉ាងទៀត ភិក្ខុត្រូវសន្តោស ដោយវត្ថុសៅហ្មង មិនគប្បីប្រាថ្នានូវរសឯទៀតឲ្យច្រើនទេ ចិត្តរបស់ភិក្ខុអ្នកជាប់ញៀមក្នុងរសទាំងឡាយ រមែងមិនត្រេកអរក្នុងឈាន ។ មុនីគប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងប់ស្ងាត់ នៅមិនច្រឡូកច្រឡំ ដោយបុគ្គលពីរពួក គឺគ្រហស្ថនិងបព្វជិត ។

ថេរគាថាយ ទសកនិបាតោ

យថា ជឡោ ច មូគោ ច　　អត្តានំ ទស្សយេ តថា
នាតិវេលំ បភាសេយ្យ　　សង្ឃមជ្ឈម្ហិ បណ្ឌិតោ ។
ន សោ ឧបវទេ កញ្ចិ　　ឧបឃាតំ វិវជ្ជយេ
សំវុតោ ចាតិមោក្ខស្មឹ　　មត្តញ្ញូ ចស្ស ភោជនេ ។
សុគ្គហីតនិមិត្តស្ស　　ចិត្តស្សុប្បាទកោវិទោ
សមថំ អនុយុញ្ជេយ្យ　　កាលេន ច វិបស្សនំ ។
វីរិយសាតច្ចសម្បន្នោ　　យុត្តយោគោ សទា សិយា
ន ច អប្បត្វា ទុក្ខន្តំ[១]　　វិស្សាសំ ឯយ្យ បណ្ឌិតោ
ឯវំ វិហរមានស្ស　　សុទ្ធិកាមស្ស ភិក្ខុនោ
ខិយ្យន្តិ អាសវា សព្វេ　　និព្វុតិញ្ចាធិគច្ឆតីតិ ។

ឧបសេនោ វង្គន្តបុត្តោ ថេរោ ។

[២៤០] វិជានេយ្យ សកំ អត្ថំ　　អវលោកេយ្យាថ បាវចនំ
យញ្ចេត្ថ អស្ស បតិរូបំ　　សាមញ្ញំ អជ្ឈុបគតស្ស ។
មិត្តំ ឥធេវ កល្យាណំ　　សិក្ខាវិបុលំ សមាទានំ

១ ឱ. ម. ទុក្ខស្សន្តំ ។

មនុស្សល្វេល្វើ និងមនុស្សគ យ៉ាងណា បណ្ឌិតគប្បីសម្តែងខ្លួន យ៉ាងនោះ មិនគប្បីពោលឲ្យហួសប្រមាណ ក្នុងកណ្តាលសង្ឃ ។ បណ្ឌិតនោះ មិនគប្បីតិះដៀលបុគ្គលណាមួយ គប្បីវៀរបង់នូវការបៀតបៀនផង សង្រួមក្នុងបាតិមោក្ខផង ដឹងប្រមាណក្នុងភោជនផង ។ បណ្ឌិតគប្បីជាអ្នកឈ្លាសវៃ ក្នុងការកើតឡើងនៃចិត្តដែលមាននិមិត្តកំណត់ល្អហើយ គប្បីប្រកបរឿយ ៗ នូវសមថៈនិងវិបស្សនាតាមកាលគួរ គប្បីជាអ្នកបរិបូណ៌ដោយព្យាយាម ប្រព្រឹត្តទៅរឿយ ៗ ប្រកបក្នុងធម៌ដ៏គួរ សព្វ ៗ កាល បើមិនទាន់ដល់នូវព្រះនិព្វានជាទីបំផុតនៃទុក្ខក្នុងវដ្តៈទេ កុំអាលដល់នូវសេចក្តីទុកចិត្តឡើយ ។ កាលភិក្ខុប្រាថ្នានូវសេចក្តីបរិសុទ្ធ សម្រាន្តនៅយ៉ាងនេះ អាសវៈទាំងពួងរមែងអស់ទៅ ភិក្ខុនោះរមែងដល់នូវការរលត់ទុក្ខ ។

ឧបសេនវង្គន្តបុត្តត្ថេរ ។

[២៤០] បុរសគប្បីដឹងច្បាស់នូវប្រយោជន៍របស់ខ្លួន គប្បីរមិលមើលនូវពាក្យជាប្រធានគឺសាសនា មួយទៀត អំពើណារបស់កុលបុត្រអ្នកចូលកាន់ផ្នួសជាសមណភាព ជាអំពើមានសភាពក៏សមគួរក្នុងសាសនានេះ (បុគ្គលគប្បីរមិលមើលនូវអំពើនោះផង) ។ ក្នុងសាសនានេះ (ការសេពគប់) នូវកល្យាណមិត្រ ១ ការសមាទាននូវសិក្ខាដ៏ធំទូលាយ ១

សុស្សូសា ច គរូនំ ឯតំ សមណស្ស បដិរូបំ ។
ពុទ្ធេសុ សគារវតា ធម្មេ អបចិតិ យថាភូតំ
សង្ឃេ ច ចិត្តការោ ឯតំ សមណស្ស បដិរូបំ ។
អាចារគោចរេ យុត្តោ អាជីវោ សោធិតោ អគារយ្ហោ
ចិត្តស្ស ច សណ្ឋបនំ ឯតំ សមណស្ស បដិរូបំ ។
ចារិត្តំ អថ វារិត្តំ ឥរិយាបថិយំ បសាទនិយំ
អធិចិត្តេ ច អាយោគោ ឯតំ សមណស្ស បដិរូបំ ។
អារញ្ញកានិ សេនាសនានិ បន្តានិ អប្បសទ្ទានិ
ភជិតព្វកានិ មុនិនា ឯតំ សមណស្ស បដិរូបំ ។
សីលញ្ច ពាហុសច្ចញ្ច ធម្មានំ បវិចយោ យថាភូតំ
សច្ចានំ អភិសមយោ ឯតំ សមណស្ស បដិរូបំ ។
ភាវេយ្យ ច អនិច្ចន្តិ អនត្តសញ្ញំ អសុភសញ្ញញ្ច
លោកម្ហិ ច អនភិរតឹ ឯតំ សមណស្ស បដិរូបំ ។
ភាវេយ្យ ច ពោជ្ឈង្គេ ឥទ្ធិបាទានិ ឥន្ទ្រិយពលានិ
អដ្ឋង្គមគ្គមរិយំ ឯតំ សមណស្ស បដិរូបំ ។

ការប្រុងស្តាប់ (នូវឱវាទ) នៃគ្រូទាំងឡាយ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ សេចក្តីគោរពក្នុងព្រះពុទ្ធទាំងឡាយ ១ ការកោតក្រែងក្នុងព្រះធម៌គួរតាមពិត ១ ការកោតក្រែងក្នុងព្រះសង្ឃ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុប្រកបក្នុងអាចារៈនិងគោចរៈ ១ មានអាជីវៈដ៏បរិសុទ្ធដែលអ្នកប្រាជ្ញមិនគប្បីតិះដៀលបាន ១ ការតម្កល់ចិត្តទុកដោយប្រពៃ ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ចារិត្តសីល ឬវារិត្តសីល ១ សម្បជញ្ញៈដែលអាស្រ័យនឹងឥរិយាបថជាទីនាំមកនូវសេចក្តីជ្រះថ្លា ១ ការប្រកបរឿយ ៗ ក្នុងអធិចិត្ត ១ ទាំង ៣ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ សេនាសនៈតាំងនៅក្នុងព្រៃស្ងាត់ មានសំឡេងតិចដែលអ្នកប្រាជ្ញគប្បីគប់រក នេះជាទីសមគួរដល់សមណៈ ។ សីល ១ ភាពជាពហុស្សូត ១ ការពិចារណានូវធម៌ទាំងឡាយ គួរតាមពិត ១ ការត្រាស់ដឹងនូវសច្ចៈទាំងឡាយ ១ ទាំង ៤ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុគប្បីចម្រើននូវអនិច្ចសញ្ញាផង អនត្តសញ្ញាផង អសុភសញ្ញាផង អនភិរតិសញ្ញាក្នុងលោកនេះផង ទាំង ៤ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។ ភិក្ខុគប្បីចម្រើននូវពោជ្ឈង្គទាំងឡាយផង ឥទ្ធិបាទទាំងឡាយផង ឥន្ទ្រិយនិងពលៈទាំងឡាយផង អរិយមគ្គមានអង្គ ៨ ផង ទាំង ៤ យ៉ាងនេះ ជាអំពើសមគួរដល់សមណៈ ។

តណ្ហំ បជហេយ្យ មុនិ សមូលកេ អាសវេ បទាលេយ្យ
វិហរេយ្យ វិប្បមុត្តោ ឯតំ សមណស្ស បដិរូបន្តិ ។

គោតមោ ថេរោ ។

## ឧទ្ទានំ

កាឡុទាយី ច សោ ថេរោ ឯកវិហារី ច កប្បិនោ
ចូឡបន្ថកោ កប្បោ ច ឧបសេនោ ច គោតមោ
សត្តិមេ ទសកេ ថេរា គាថាយោ ចេត្ថ សត្តតីតិ ។

ទសកនិបាតោ និដ្ឋិតោ ។

២៥

ថេរគាថា ទសកនិបាត

មុនិគប្បីលះបង់នូវតណ្ហា គប្បីទម្លុះទម្លាយនូវអាសវៈទាំងឡាយ ព្រមទាំងឫសគល់ គប្បីជាអ្នករួចស្រឡះ (ចាកកិលេសទាំងពួង) ហើយសម្រេចសម្រាន្តនៅ នេះជាអំពើដ៏សមគួរដល់សមណៈ ។

គោតមត្ថេរ ។

# ឧទ្ទាន

ព្រះថេរៈទាំងឡាយ ៧ អង្គនេះគឺ កាឡុទាយិត្ថេរ ១ ឯកវិហារិត្ថេរ ១ មហាកប្បិនត្ថេរ ១ ចូឡបន្ថកត្ថេរ ១ កប្បត្ថេរ ១ ឧបសេនវង្គន្តបុត្តត្ថេរ ១ គោតមត្ថេរ ១ (បានពោល) នូវគាថាទាំងឡាយ ៧០ ក្នុងទសកនិបាតនេះ ។

ចប់ ទសកនិបាត ។

# ថេរគាថាយ ឯកាទសកនិបាតោ

[២៤១] កិន្តវត្ថោ វនេ តាត ឧជ្ជុហានោវ ចាវុសេ
វេរម្ភា រមណីយា តេ បវិវេកោ ហិ ឈាយិនំ ។
យថា អព្ភានិ វេរម្ភោ វាតោ នុទតិ ចាវុសេ
សញ្ញា មេ អភិកិរន្តិ វិវេកបដិសញ្ញុតា ។
អបណ្ឌរោ អណ្ឌសម្ភវោ សីវថិកាយ និកេតចារិកោ
ឧប្បាទយតេវ មេ សតឹ សន្ទេហស្មឹ វិរាគនិស្សិតំ ។
យញ្ច អញ្ញេ ន រក្ខន្តិ យោ ច អញ្ញេ ន រក្ខតិ
ស វេ ភិក្ខុ សុខំ សេតិ កាមេសុ អនបេក្ខវា ។
អច្ឆោទិកា បុថុសិលា គោណង្គុលមិគាយុតា
អម្ពុសេវាលសញ្ឆន្នា តេ សេលា រមយន្តិ មំ ។
វសិតំ មេ អរញ្ញេសុ កន្ទរាសុ គុហាសុ ច
សេនាសនេសុ បន្តេសុ វាលមិគនិសេវិតេ ។

# ថេរគាថា ឯកាទសកនិបាត

[២៤១] ម្នាលសាមណេរ ប្រយោជន៍អ្វីដល់អ្នក (ដែលនៅ) ក្នុងព្រៃភ្នំ ឈ្មោះឧជ្ជុហានៈ (មិនជាទីសប្បាយ) ក្នុងរដូវភ្លៀង ខ្យល់ឈ្មោះ វេរម្ភៈ (ខ្យល់ព្យុះ) ជាទីរីករាយដល់អ្នកឬ ព្រោះថាសេចក្ដីស្ងប់ស្ងាត់ រមែងមានដល់បុគ្គលទាំងឡាយអ្នកមានឈាន ។ ខ្យល់ឈ្មោះ វេរម្ភៈ រមែងបក់ផាត់នូវពពកទាំងឡាយ ក្នុងរដូវភ្លៀង យ៉ាងណា សញ្ញារបស់ខ្ញុំ ដែលប្រកបដោយវិវេក ក៏រមែងរាយមាយ យ៉ាងនោះ ដែរ ។ សត្វដែលកើតអំពីពង មានសម្បុរខ្មៅ(ក្អែក)ត្រាច់ទៅកាន់ លំនៅក្នុងទីស្មសាន ក៏ញ៉ាំងសតិនៃខ្ញុំដែលអាស្រ័យនូវការប្រាស ចាកតម្រេកក្នុងរាងកាយឲ្យកើតឡើង ។ ជនទាំងឡាយដទៃ មិន រក្សានូវភិក្ខុណា ភិក្ខុណា មិនរក្សានូវជនទាំងឡាយដទៃ ភិក្ខុនោះ ជាអ្នកមិនមានសេចក្ដីអាឡោះអាល័យក្នុងកាមទាំងឡាយ រមែងដេក ជាសុខ ។ ភ្នំថ្មទាំងឡាយនោះ មានទឹកថ្លា មានថ្មក្រាស់ ប្រកប ដោយសត្វមានកន្ទុយដូចគោ មានទឹកដេរដាសដោយសារាយ រមែង ញ៉ាំងអាត្មាឲ្យរីករាយ ។ អាត្មាក៏ធ្លាប់នៅក្នុងព្រៃទាំងឡាយផង ក្នុង ប្រកភ្នំទាំងឡាយផង ក្នុងគុហាទាំងឡាយផង ក្នុងសេនាសនៈទាំង ឡាយដ៏ស្ងាត់ផង ក្នុងព្រៃដែលសត្វម្រឹគសាហាវអាស្រ័យនៅផង ។

២៧

ថេរគាថាយ ឯកាទសកនិបាតោ

ឥមេ ហញ្ញន្តុ វជ្ឈន្តុ ទុក្ខំ បប្បោន្តុ បាណិនោ
សង្កប្បំ នាភិជានាមិ អនរិយំ ទោសសំហិតំ ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
យស្សត្ថាយ បព្វជិតោ អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ និព្វិសំ ភតកោ យថា ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ សម្បជានោ បតិស្សតោតិ ។

សង្កិច្ចោ ថេរោ ។

## ឧទ្ទានំ

សង្កិច្ចត្ថេរោ ឯកោវ កតកិច្ចោ អនាសវោ
ឯកាទសនិបាតម្ហិ គាថា ឯកាទសេវ តាតិ ។

ឯកាទសកនិបាតោ និដ្ឋិតោ ។

*អាត្មាមិនធ្លាប់ដឹងនូវសេចក្តីត្រិះរិះ មិនប្រសើរ ប្រកបដោយទោស យ៉ាងនេះថា ពួកសត្វទាំងនេះ ចូរលំបាក ចូរស្លាប់ ចូរដល់នូវសេចក្តីទុក្ខ (ដូច្នេះឡើយ) ។ ព្រះសាស្តា អាត្មាបានបម្រើហើយ ព្រះពុទ្ធសាសនា អាត្មាបានធ្វើហើយ ភារៈដ៏ធ្ងន់ គឺខន្ធ អាត្មាបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព អាត្មាក៏បានដកចោលហើយ ។ បព្វជិតចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួងនោះ អាត្មាក៏បានដល់ហើយ ។ អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មាជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំ រង់ចាំតែកាលនឹងបរិនិព្វាន ។*

សង្កិច្ចត្ថេរ ។

# ឧទ្ទាន

*អំពីសង្កិច្ចត្ថេរ តែមួយអង្គឯង លោកមានកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ ពោលនូវគាថា ១១ នោះ ក្នុងឯកាទសកនិបាត ។*

ចប់ ឯកាទសកនិបាត ។

---

# ថេរគាថាយ ទ្វាទសកនិបាតោ

[២៤២] សីលមេវិធ សិក្ខេថ អស្មឹ លោកេ សុសិក្ខិតំ
សីលំ ហិ សព្វសម្បត្តឹ ឧបនាមេតិ សេវិតំ ។
សីលំ រក្ខេយ្យ មេធាវី បត្ថយានោ តយោ សុខេ
បសំសំ វិត្តិលាភញ្ច បេច្ច សគ្គេ បមោទនំ ។
សីលវា ហិ ពហូ មិត្តេ សញ្ញមេនាធិគច្ឆតិ
ទុស្សីលោ បន មិត្តេហិ ធំសតេ បាបមាចរំ ។
អវណ្ណញ្ច អកិត្តិញ្ច ទុស្សីលោ លភតេ នរោ
វណ្ណំ កិត្តឹ បសំសញ្ច សទា លភតិ សីលវា ។
អាទិ សីលំ បតិដ្ឋា ច កល្យាណានញ្ច មាតុកំ
បមុខំ សព្វធម្មានំ តស្មា សីលំ វិសោធយេ ។
វេលា ច សំវរំ សីលំ ចិត្តស្ស អភិហាសនំ[១]
តិត្ថញ្ច សព្វពុទ្ធានំ តស្មា សីលំ វិសោធយេ ។
សីលំ ពលំ អប្បដិមំ សីលំ អាវុធមុត្តមំ
សីលំ អាភរណំ សេដ្ឋំ សីលំ កវចមព្ភុតំ ។

---
១ ឱ. អភិភាសនំ ។

# ថេរគាថា ទ្វាទសកនិបាត

[២៤២] បុគ្គលគប្បីសិក្សានូវសីល ឲ្យជាសីលដែលខ្លួនសិក្សាល្អហើយក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។ ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាង គឺសេចក្តីសរសើរ ១ ការបាននូវសេចក្តីត្រេកអរ ១ ការលះលោកនេះទៅហើយ រីករាយក្នុងឋានសួគ៌ ១ គប្បីរក្សានូវសីល ។ ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាននូវមិត្តទាំងឡាយច្រើន ដោយការសង្រួម ចំណែកបុគ្គលទ្រុស្តសីល កាលប្រព្រឹត្តអាក្រក់ រមែងឃ្លាតចាកមិត្តទាំងឡាយ ។ ជនទ្រុស្តសីលរមែងបាននូវទោសផង នូវតំណិះដំណៀលផង ឯជនអ្នកមានសីលរមែងបាននូវគុណផង នូវកិត្តិសព្ទផង នូវសេចក្តីសរសើរផង សព្វ ៗ កាល ។ សីលជាខាងដើម ជាទីតាំង ជាមេនៃកល្យាណធម៌ និងជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគប្បីជម្រះសីល ។ សីលជាច្រាំង ជាទំនប់ ជាគ្រឿងញ៉ាំងចិត្តឲ្យរីករាយ ទាំងជាកំពង់របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គលគប្បីជម្រះនូវសីល ។ សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ។

២៩

## ថេរគាថាយ ទ្វាទសកនិបាតោ

សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ
សីលំ វិលេបនំ សេដ្ឋំ យេន វាតិ ទិសោ ទិសំ ។
សីលំ សម្ពលមេវគ្គំ សីលំ បាថេយ្យមុត្តមំ
សីលំ សេដ្ឋោ អតិវាហោ យេន វាតិ ទិសោ ទិសំ ។
ឥធេវ និន្ទំ លភតិ បេច្ចាបាយេ ច ទុម្មនោ
សព្វត្ថ ទុម្មនោ ពាលោ សីលេសុ អសមាហិតោ ។
ឥធេវ កិត្តឹ លភតិ បេច្ច សគ្គេ ច សុមនោ
សព្វត្ថ សុមនោ ធីរោ សីលេសុ សុសមាហិតោ ។
សីលមេវ ឥធ អគ្គំ បញ្ញវា បន ឧត្តមោ
មនុស្សេសុ ច ទេវេសុ សីលបញ្ញាណតោ ជយន្តិ ។

សីលវត្ថេរោ ។

[២៤៣] នីចេ កុលម្ហិ ជាតោហំ ទលិទ្ទោ អប្បភោជនោ
ហីនំ កម្មំ មមំ អាសិ អហោសឹ បុប្ផឆឌ្ឌកោ ។
ជិគុច្ឆិតោ មនុស្សានំ បរិភូតោ ច វម្ភិតោ
នីចំ មនំ ករិត្វាន វន្ទិស្សំ ពហុកំ ជនំ ។
អថទ្ទសាសឹ សម្ពុទ្ធំ ភិក្ខុសង្ឃបុរក្ខតំ
បវិសន្តំ មហាវីរំ មគធានំ បុរុត្តមំ ។

សីល ជាស្ពានមានសក្តិធំ សីលជាគ្រឿងក្រអូបដ៏ប្រសើរ សីលជាគ្រឿងលាបដ៏ប្រសើរ តែងបក់ទៅ សព្វ ៗ ទិស ។ សីលជាកញ្ចប់បាយដ៏ប្រសើរ សីលជាស្បៀងដ៏ឧត្តម សីលជាវាហនៈដ៏ប្រសើរ សម្រាប់ទៅកាន់ទិសទាំងពួង ។ បុគ្គលពាល មានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវសេចក្តីនិន្ទាក្នុងលោកនេះផង លុះលះលោកនេះទៅហើយ រមែងមានចិត្តជាទុក្ខក្នុងអបាយផង ។ អ្នកប្រាជ្ញ មានចិត្តល្អ ក្នុងទីទាំងពួងតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវកិត្តិសព្ទ ក្នុងលោកនេះផង លុះលះលោកនេះទៅ រមែងមានចិត្តរីករាយក្នុងឋានសួគ៌ផង ។ សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលមានប្រាជ្ញាក៏ឧត្តមដែរ ជ័យជម្នះក្នុងមនុស្សលោកនិងទេវលោក ព្រោះសីលនិងបញ្ញា ។

សីលវត្ថេរ ។

[២៤៣] ខ្ញុំកើតក្នុងត្រកូលទាប ជាអ្នកក្រីក្រ មានភោជនតិច ការងាររបស់ខ្ញុំ ក៏ថោកទាប ខ្ញុំជាអ្នកចាក់ចោល នូវផ្កាគឺលាមក ។ មនុស្សទាំងឡាយស្អប់ខ្ពើម មើលងាយ បន្ទុះបង្អាប់ខ្ញុំ ខ្ញុំបានធ្វើចិត្តឲ្យទាប សំពះនូវជនជាច្រើន ។ គ្រានោះ ខ្ញុំបានឃើញនូវព្រះសម្ពុទ្ធមានភិក្ខុសង្ឃហែហមហើយ ព្រះអង្គមានព្យាយាមធំ កំពុងយាងចូលទៅ កាន់បូរីដ៏ឧត្តម របស់ជនអ្នកមគធៈ ។

និក្ខិបិត្វាន ព្យាភង្គឹ វន្ទិតុំ ឧបសង្កមឹ
មមេវ អនុកម្បាយ អដ្ឋាសិ បុរិសុត្តមោ ។
វន្ទិត្វា សត្ថុនោ បាទេ ឯកមន្តំ ឋិតោ តទា
បព្វជ្ជំ អហមាយាចឹ សព្វសត្តានមុត្តមំ ។
តតោ ការុណិកោ សត្ថា សព្វលោកានុកម្បកោ
ឯហិ ភិក្ខូតិ មំ អាហ សា មេ អាសូបសម្បទា ។
សោហំ ឯកោ អរញ្ញស្មឹ វិហរន្តោ អតន្ទិតោ
អកាសឹ សត្ថុ វចនំ យថា មំ ឱវទី ជិនោ ។
រត្តិយា បឋមំ យាមំ បុព្វជាតិមនុស្សរឹ
រត្តិយា មជ្ឈិមំ យាមំ ទិព្វចក្ខុំ វិសោធយឹ[១]
រត្តិយា បច្ឆិមេ យាមេ តមោក្ខន្ធំ បទាលយឹ ។
តតោ រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ
ឥន្ទោ ព្រហ្មា ច អាគន្ត្វា មំ នមស្សឹសុ បញ្ជលី
នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
យស្ស តេ អាសវា ខីណា ទក្ខិណេយ្យោសិ មារិស ។

១ ឱ. ម. វិសោធិតំ ។

ខ្ញុំក៏ដាក់នូវអង្រែកចូលទៅដើម្បីថ្វាយបង្គំ ព្រះសម្ពុទ្ធជាបុរសដ៏ខ្ពង់-ខ្ពស់ ទ្រង់ឋិតនៅដើម្បីអនុគ្រោះខ្ញុំ ។ ខ្ញុំថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសាស្តា ហើយឋិតនៅក្នុងទីសមគួរ គ្រានោះ ខ្ញុំសូមបព្វជ្ជានឹងព្រះសម្ពុទ្ធ ព្រះអង្គឧត្តម ជាងសព្វសត្វទាំងឡាយ ។ លំដាប់នោះ ព្រះសាស្តាព្រះអង្គប្រកបដោយសេចក្តីករុណា ទ្រង់អនុគ្រោះដល់លោកទាំងមូល ត្រាស់ហៅខ្ញុំថា អ្នកចូរចូលមកជាភិក្ខុចុះ ដូច្នេះព្រះវាចានោះ ជាឧបសម្បទារបស់ខ្ញុំ ។ ព្រះជិនស្រី ទ្រង់ទូន្មានខ្ញុំយ៉ាងណា ខ្ញុំនោះជាបុគ្គលម្នាក់ឯង នៅក្នុងព្រៃ មិនខ្ជិលច្រអូសក៏បានធ្វើតាមព្រះពុទ្ធដីកា នៃព្រះសាស្តាយ៉ាងនោះ ។ ខ្ញុំរលឹកឃើញនូវបុព្វជាតិ ក្នុងបឋមយាមនៃរាត្រី ជម្រះនូវទិព្វចក្ខុ ក្នុងមជ្ឈិមយាមនៃរាត្រី បានទម្លាយនូវគំនរនៃងងឹត គឺអវិជ្ជា ក្នុងមច្ឆិមយាមនៃរាត្រី ។ លំដាប់នោះ កាលដែលរាត្រីអស់ទៅព្រះអាទិត្យជិតរះឡើង ព្រះឥន្ទ្រនិងព្រះព្រហ្ម មកផ្គងអញ្ជលីនមស្ការចំពោះខ្ញុំថា បពិត្រលោកជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកនិទ៌ុក អាសវៈទាំងឡាយរបស់លោកណាអស់ហើយ លោកនោះជាទក្ខិណេយ្យបុគ្គល ។

៣១



តតោ ទិស្វាន មំ សត្ថា ទេវសង្ឃបុរក្ខតំ
សិតំ បាតុករិត្វាន ឥមមត្ថំ អភាសថ
តបេន ព្រហ្មចរិយេន សញ្ញមេន ទមេន ច
ឯតេន ព្រាហ្មណោ ហោតិ ឯតំ ព្រាហ្មណមុត្តមន្តិ(១) ។

សុនីតោ ថេរោ ។

## ឧទ្ទានំ

សីលវា ច សុនីតោ ច ថេរា ទ្វេ មហិទ្ធិកា
ទ្វាទសម្ហិ និបាតម្ហិ គាថាយោ ចតុវីសតីតិ ។

ទ្វាទសកនិបាតោ និដ្ឋិតោ ។

---

១ អដ្ឋកថាយំ ព្រហ្មានមុត្តមន្តិ ទិស្សតិ ឥទំ យុត្តតរំ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ទតឃើញខ្ញុំ ដែលមានពួកទេវតាហែហម ទ្រង់ក៏ធ្វើនូវការញញឹមឲ្យប្រាកដ ហើយទ្រង់ត្រាស់សេចក្តីនេះថា បុគ្គលឈ្មោះថាព្រាហ្មណ៍ ព្រោះធម៌ ៤ ប្រការនេះ គឺតបៈ ១ ព្រហ្មចរិយៈ ១ សញ្ញមៈ ១ ទមៈ ១ នេះជាព្រាហ្មណវត្តដ៏ឧត្តម ។

សុនីតត្ថេរ ។

# ឧទ្ទាន

ព្រះថេរៈទាំងឡាយពីរអង្គនេះ គឺសីលវត្ថេរ ១ សុនីតត្ថេរ ១ សុទ្ធតែមានឫទ្ធិច្រើន បានពោលនូវគាថា ២៤ ក្នុងទ្វាទសកនិបាត ។

ចប់ ទ្វាទសកនិបាត ។

---

# ថេរគាថាយ តេរសកនិបាតោ

[២៤៤] យាហុ រដ្ឋេ សមុក្កដ្ឋោ រញ្ញោ អង្គស្ស បទ្ធគូ
ស្វាជ្ជ ធម្មេសុ[១] ឧក្កដ្ឋោ សោណោ ទុក្ខស្ស បារគូ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ចុត្តរិ ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។
ឧន្នឡស្ស បមត្តស្ស ពាហិរាសស្ស ភិក្ខុនោ
សីលំ សមាធិ បញ្ញា ច បារិបូរឹ ន គច្ឆតិ ។
យញ្ហិ កិច្ចំ តទបវិទ្ធំ អកិច្ចំ បន កយិរតិ
ឧន្នឡានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា ។
យេសញ្ច សុសមារទ្ធា និច្ចំ កាយគតាសតិ
អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ
សតានំ សម្បជានានំអត្ថំ គច្ឆន្តិ អាសវា ។
ឧជុមគ្គម្ហិ អក្ខាតេ គច្ឆថ មា និវត្តថ
អត្តនា ចោទយត្តានំ និព្វានមភិហារយេ ។

១ ម. សជ្ជ ធម្មេសុ ។

# ថេរគាថា តេរសកនិបាត

[២៤២] *ព្រះសោណៈណា ជាអ្នកប្រសើរ ល្បីក្នុងដែនអង្គៈ ព្រះសោណៈនោះ ជាអ្នកប្រសើរ ក្នុងធម៌ទាំងឡាយ បានដល់នូវត្រើយនៃទុក្ខក្នុងថ្ងៃនេះ ។ ភិក្ខុកាត់នូវសំយោជនៈ(ខាងក្រោម) ៥ ផង លះបង់នូវសំយោជនៈ(ខាងលើ)៥ ផង ចម្រើននូវឥន្ទ្រិយ ៥ តទៅទៀតផង ជាអ្នកកន្លងនូវធម៌ជាគ្រឿងជាប់ចំពាក់ ៥ យ៉ាងផង ទើបហៅថាអ្នកឆ្លងនូវអន្លង់បាន ។ សីល សមាធិ និងបញ្ញានៃភិក្ខុអ្នកមានមានះដូចបបុស ជាអ្នកប្រមាទ មានសេចក្តីប្រាថ្នាខាងក្រៅ រមែងមិនដល់នូវការពេញលេញឡើយ ។ ព្រោះថា អំពើណាដែលត្រូវធ្វើ អំពើនោះពួកភិក្ខុណាបោះបង់ចោល ត្រឡប់ធ្វើអំពើដែលមិនត្រូវធ្វើវិញ អាសវៈទាំងឡាយ នៃពួកភិក្ខុទាំងនោះ ដែលជាអ្នកមានមានះដូចបបុស ជាអ្នកប្រមាទ រមែងចម្រើនឡើង ។ លុះតែកាយគតាសតិ ភិក្ខុទាំងឡាយណា ប្រារព្ធល្អជានិច្ច ភិក្ខុទាំងឡាយនោះ ជាអ្នកមានកិរិយាធ្វើរឿយ ៗ ក្នុងអំពើដែលត្រូវធ្វើ មិនសេពនូវអំពើដែលមិនត្រូវធ្វើ អាសវៈទាំងឡាយ នៃភិក្ខុទាំងឡាយមានស្មារតី ជាអ្នកដឹងខ្លួន រមែងដល់នូវសេចក្តីវិនាសទៅ ។ ផ្លូវត្រង់ព្រះសាស្តាបានប្រាប់ហើយ អ្នកទាំងឡាយចូរដើរទៅចុះ កុំត្រឡប់វិញឡើយ កុលបុត្រគប្បីដាស់តឿនខ្លួនដោយខ្លួនឯង គប្បី(នាំខ្លួន)ទៅកាន់ព្រះនិព្វាន ។*

៣៣

ថេរគាថាយ តេរសកនិបាតោ

អច្ចារទ្ធម្ហិ វីរិយម្ហិ សត្ថា លោកេ អនុត្តរោ
វីណោបមំ ករិត្វាន ធម្មំ ទេសេសិ ចក្ខុមា ។
តស្សាហំ វចនំ សុត្វា វិហាសឹ សាសនេ រតោ
សមថំ បដិបាទេសឹ ឧត្តមត្ថស្ស បត្តិយា
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
នេក្ខម្មេ អធិមុត្តស្ស បវិវេកញ្ច ចេតសោ
អព្យាបជ្ឈាធិមុត្តស្ស ឧបាទានក្ខយស្ស ច
តណ្ហាក្ខយាធិមុត្តស្ស អសម្មោហញ្ច ចេតសោ
ទិស្វា អាយតនុប្បាទំ សម្មា ចិត្តំ វិមុច្ចតិ ។
តស្ស សម្មា វិមុត្តស្ស សន្តចិត្តស្ស ភិក្ខុនោ
កតស្ស បដិចយោ នត្ថិ ករណីយំ ន វិជ្ជតិ ។
សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ រូបា រសា សទ្ទា គន្ធា ផស្សា ច កេវលា
ឥដ្ឋា ធម្មា អនិដ្ឋា ច នប្បវេធេន្តិ តាទិនោ

*កាលខ្ញុំប្រារព្ធសេចក្តីព្យាយាម យ៉ាងតឹងរឹង ព្រះសាស្តា ជាបុគ្គលប្រសើរក្នុងលោក ព្រះអង្គមានចក្ខុ ទ្រង់បានសម្តែងធម៌ ធ្វើនូវសេចក្តីឧបមាដោយពិណ ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគនោះ ក៏ត្រេកអរក្នុងព្រះពុទ្ធសាសនា បានញ៉ាំងសមថៈឲ្យសម្រេចដើម្បីបាននូវប្រយោជន៍ដ៏ឧត្តម វិជ្ជាទាំង ៣ ខ្ញុំបានដល់ហើយដោយលំដាប់ ព្រះពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។ ព្រោះឃើញនូវសេចក្តីស្ងាត់របស់ចិត្ត ដែលបង្អោនទៅ ក្នុងការចេញចាកកាមផង នូវការមិនវង្វេងព្រមរបស់ចិត្ត ដែលបង្អោនទៅ ក្នុងការមិនព្យាបាទទាំងបង្អោនទៅ ក្នុងការអស់ទៅនៃតណ្ហា ព្រោះការអស់ទៅនៃឧបាទានផង នូវការកើតឡើងនៃអាយតនៈផង ចិត្តក៏រួចស្រឡះដោយប្រពៃ ។ កាលភិក្ខុនោះ មានចិត្តរួចដោយប្រពៃ មានចិត្តស្ងប់រម្ងាប់ហើយ ការសន្សំកុសល ឬអកុសល ដែលធ្វើរួចហើយ មិនមានទេ កិច្ចដែលត្រូវធ្វើ ក៏មិនមាន ។ ភ្នំថ្មតាន់មួយដុំ មិនរំកើបដោយខ្យល់ យ៉ាងណា រូប រស សំឡេង ក្លិន សម្ផស្ស ទាំងអស់នេះ ទាំងពួកធម្មារម្មណ៍ ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ក៏ញុំាំងចិត្តភិក្ខុ ជាតាទិបុគ្គល ឲ្យញាប់ញ័រមិនបាន យ៉ាងនោះដែរ*

បិតំ ចិត្តំ វិសញ្ញុត្តំ វយញ្ចស្សានុបស្សតីតិ ។

សោណោ កោឡិវិសោ ថេរោ ។

# ឧទ្ទានំ

សោណោ កោឡិវិសោ ថេរោ ឯកោយេវ មហិទ្ធិកោ

តេរសម្ហិ និបាតម្ហិ គាថាយោ ចេត្ថ តេរសាតិ ។

តេរសកនិបាតោ និដ្ឋិតោ ។

*ចិត្តដែលតាំងនៅនឹង ទាំងប្រាសចាកសំយោជនៈ រមែងឃើញច្បាស់ នូវការសូន្យទៅនៃអារម្មណ៍នោះ ។*

សោណកោឡិវិសត្ថេរ ។

# ឧទ្ទាន

*ព្រះសោណកោឡិវិសត្ថេរ តែម្នាក់ឯង ជាអ្នកមានឫទ្ធិច្រើន ពោលនូវគាថា ១៣ ដែលមកក្នុងតេរសកនិបាតនេះ ។*

ចប់ តេរសកនិបាត ។

---

# ថេរគាថាយ ចុទ្ទសកនិបាតោ

[២៤៨] យទា អហំ បព្វជិតោ អគារស្មា អនគារិយំ
នាភិជានាមិ សង្កប្បំ អនរិយំ ទោសសំហិតំ ។
ឥមេ ហញ្ញន្តុ វជ្ឈន្តុ ទុក្ខំ បប្បោន្តុ បាណិនោ
សង្កប្បំ នាភិជានាមិ ឥមស្មឹ ទីឃមន្តរេ ។
មេត្តញ្ច អភិជានាមិ អប្បមាណំ សុភាវិតំ
អនុបុព្វំ បរិចិតំ យថា ពុទ្ធេន ទេសិតំ ។
សព្វមិត្តោ សព្វសខោ សព្វភូតានុកម្បកោ
មេត្តំ ចិត្តញ្ច ភាវេមិ អព្យាបជ្ជរតោ សទា ។
អសំហិរំ អសំកុប្បំ ចិត្តំ អាមោទយាមហំ
ព្រហ្មវិហារំ ភាវេមិ អកាបុរិសសេវិតំ ។
អវិតក្កំ សមាបន្នោ សម្មាសម្ពុទ្ធសាវកោ
អរិយេន តុណ្ហីភាវេន ឧបេតោ ហោតិ តាវទេ ។
យថាបិ បព្វតោ សេលោ អចលោ សុប្បតិដ្ឋិតោ
ឯវំ មោហក្ខយា ភិក្ខុ បព្វតោវ ន វេធតិ ។
អនង្គណស្ស បោសស្ស និច្ចំ សុចិគវេសិនោ
វាលគ្គមត្តំ បាបស្ស អព្ភាមត្តំ វ ខាយតិ ។

# ថេរគាថា ចុទ្ទសកនិបាត

[២៤៥] ខ្ញុំចេញចាកផ្ទះចូលកាន់ផ្នួស ក្នុងកាលណា កាលណោះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះមិនប្រសើរ ដែលប្រកបដោយទោសទេ ។ ក្នុងចន្លោះកាលដ៏វែងនេះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះថា ពួកសត្វទាំងនេះចូរលំបាកចុះ ចូរស្លាប់ចុះ ចូរដល់នូវសេចក្តីទុក្ខចុះ ដូច្នេះទេ។ ប៉ុន្តែខ្ញុំធ្លាប់នឹកនូវមេត្តារកប្រមាណមិនបាន ដែលបានចម្រើនល្អហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងហើយ ។ ខ្ញុំមានសត្វទាំងពួងជាមិត្រ មានសត្វទាំងពួងជាសំឡាញ់ ជាអ្នកអនុគ្រោះដល់សត្វទាំងពួង បានចម្រើននូវមេត្តចិត្ត ត្រេកអរក្នុងការមិនបៀតបៀនសព្វកាល ។ ខ្ញុំត្រេកអរចំពោះចិត្តដែលមិនងឹកងាក មិនកម្រើក ខ្ញុំចម្រើនព្រហ្មវិហារធម៌ ដែលព្រះអរិយៈជាបុរសមិនថោកទាបគប់រកហើយ ។ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ដល់នូវឈានមិនមានវិតក្កៈ រមែងជាអ្នកប្រកបដោយតុណ្ហីភាពដ៏ប្រសើរ ក្នុងខណៈនោះ ។ ភ្នំថ្មមិនកម្រើក តាំងនៅស៊ប់ យ៉ាងណាមិញ ភិក្ខុរមែងមិនញាប់ញ័រដូចជាភ្នំព្រោះអស់ទៅនៃមោហៈ ក៏យ៉ាងនោះដែរ ។ សប្បុរសមិនមានទីទួលគឺកិលេស អ្នកស្វែងរកនូវសេចក្តីស្អាតជានិច្ច ទុកជាមានបាបបន្តិចបន្តួច ប៉ុនចុងរោមកន្ទុយសត្វ ក៏ប្រាកដដូចជាប៉ុនមេឃ ។

នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ និព្វិសំ ភតកោ យថា ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ សម្បជានោ បតិស្សតោ ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
យស្ស ចត្ថាយ បព្វជិតោ អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។
សម្បាទេថប្បមាទេន ឯសា មេ អនុសាសនី
ហន្ទាហំ បរិនិព្វិស្សំ វិប្បមុត្តោម្ហិ សព្វធីតិ ។

រេវតោ ថេរោ ។

[២៤៦] យថាបិ ភទ្ទោ អាជញ្ញោ ធុរេ យុត្តោ ធុរស្សហោ
មថិតោ អតិភារេន សំយុគំ នាតិវត្តតិ

នគរជាទីបំផុតនៃដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុងខាងក្រៅ យ៉ាងណាមិញ អ្នកទាំងឡាយ ចូរគ្រប់គ្រងខ្លួនយ៉ាងនោះ ខណៈកុំកន្លង នូវអ្នកទាំងឡាយឡើយ ។ ខ្ញុំមិនត្រេកអរនឹងសេចក្ដីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅទេ ខ្ញុំរង់ចាំតែកាល (បរិនិព្វាន) ប៉ុណ្ណោះ ដូចអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្ដីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំ រង់ចាំតែកាល (បរិនិព្វាន) ប៉ុណ្ណោះ ។ ព្រះសាស្ដាខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនាខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍គឺការអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានដល់ហើយ ។ អ្នកទាំងឡាយ ចូរឲ្យដល់ព្រម ដោយសេចក្ដីមិនប្រមាទចុះ នេះជាពាក្យប្រៀនប្រដៅរបស់ខ្ញុំ ណ្ហើយចុះ ខ្ញុំនឹងបរិនិព្វាន ខ្ញុំជាអ្នកមានចិត្តរួចស្រឡះហើយចាកកិលេសទាំពួង ។

រេវតត្ថេរ ។

[២៤៦] គោអាជានេយ្យដ៏ចម្រើន ដែលបុគ្គលទឹមហើយក្នុងនឹម ជាសត្វនាំទៅនូវធុរៈ ទុកជាម្ចាស់ញាំញីដោយភារៈ ដ៏លើសលុបក៏ដោយក៏មិនរលាស់ចោល នូវនឹមដែលម្ចាស់ទឹមឡើយ យ៉ាងណាមិញ

៣៧

ថេរគាថាយ ចុទ្ទសកនិបាតោ

ឯវំ បញ្ញាយ យេ តិត្តា សមុទ្ទោ វារិនា យថា
ន បរេ អតិមញ្ញន្តិ អរិយធម្មេវ បាណិនំ ។
កាលេ កាលវសម្បត្តា ភវាភវវសំ គតា
នរា ទុក្ខំ និគច្ឆន្តិ តេ ច[១] សោចន្តិ មាណវា ។
ឧន្នតា សុខធម្មេន ទុក្ខធម្មេន ចោនតា
ទ្វយេន ពាលា ហញ្ញន្តិ យថាភូតំ អទស្សិនោ ។
យេ ច ទុក្ខេ សុខម្ហិ ច មជ្ឈេ សិព្វិនិមច្ចគូ[២]
ឋិតា តេ ឥន្ទខីលោវ ន តេ ឧន្នតឱនតា ។
នហេវ លាភេ នាលាភេ នាយសេ ន ច កិត្តិយា
ន និន្ទាយ បសំសាយ ន តេ ទុក្ខេ សុខម្ហិ ច
សព្វត្ថ តេ ន លិម្បន្តិ ឧទពិន្ទុវ បោក្ខរេ

១ ឱ. តេ ធ ។ ២ ឱ. សិព្វនិ មជ្ឈគូ ។

បុគ្គលទាំងឡាយណា ឆ្អែតហើយដោយប្រាជ្ញា ដូចជាសមុទ្រដែលឆ្អែតហើយដោយទឹក បុគ្គលទាំងឡាយនោះ រមែងមិនមើលងាយនូវពួកជនដទៃ ដូចជាបុគ្គលមានធម៌ប្រសើរ មិនមើលងាយនូវសត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ មាណពទាំងឡាយ អ្នកលុះនូវអំណាចនៃកាល (លោកធម៌ មានលាភជាដើម) ក្នុងកាល (ដែលបរិបូណ៌ដោយលោកធម៌ មានលាភជាដើម) លុះអំណាចនៃសេចក្ដីចម្រើន និងសេចក្ដីវិនាស រមែងដល់នូវសេចក្ដីទុក្ខ មាណពទាំងឡាយនោះ រមែងសោកសៅ ។ បុគ្គលពាលទាំងឡាយជាអ្នកមិនឃើញតាមពិត ប៉ោងឡើង ដោយហេតុនៃសេចក្ដីសុខ ទ្រោមចុះដោយហេតុនៃសេចក្ដីទុក្ខ រមែងលំបាក ដោយហេតុទាំងពីរ ។ ចំណែកបុគ្គលទាំងឡាយណា បានកន្លងនូវតណ្ហាជាគ្រឿងចាក់ស្រែះ ព្រោះសុខទុក្ខ និងឧបេក្ខា បុគ្គលទាំងឡាយនោះឈ្មោះថាតាំងនៅនឹង ដូចជាសសរខឿន មិនប៉ោងឡើង ទាំងមិនទ្រោមចុះ ។ អ្នកប្រាជ្ញទាំងឡាយមិនបានជាប់ចំពាក់ក្នុងលាភ មិនជាប់ចំពាក់ក្នុងអលាភ មិនជាប់ចំពាក់ ក្នុងអយស មិនជាប់ចំពាក់ក្នុងកិត្តិយស មិនជាប់ចំពាក់ក្នុងនិន្ទា និងសេចក្ដីសរសើរ មិនជាប់ចំពាក់ក្នុងទុក្ខ និងសុខ អ្នកប្រាជ្ញទាំងឡាយនោះ មិនជាប់ចំពាក់ក្នុងទិសទាំងពួង ដូចជាតំណក់នៃទឹក ដែលមិនជាប់នឹងស្លឹកឈូក

សព្វត្ថ សុខិតា ធីរា[១]  សព្វត្ថ អបរាជិតា ។
ធម្មេន ច អលាភោ យោ  យោ ច លាភោ អធម្មិកោ
អលាភោ ធម្មិកោ សេយ្យោ  យញ្ចេ លាភោ អធម្មិកោ ។
យសោ ច អប្បពុទ្ធីនំ  វិញ្ញូនំ អយសោ ច យោ
អយសោ ច សេយ្យោ វិញ្ញូនំ  ន យសោ អប្បពុទ្ធីនំ ។
ទុម្មេធេហិ បសំសា ច  វិញ្ញូហិ គរហា ច យា
គរហាវ សេយ្យោ វិញ្ញូហិ  យញ្ចេ ពាលប្បសំសនា ។
សុខញ្ច កាមមយិកំ  ទុក្ខញ្ច បវិវេកិយំ
បវិវេកិយំ ទុក្ខំ សេយ្យោ  យញ្ចេ កាមមយំ សុខំ ។
ជីវិតញ្ច អធម្មេន  ធម្មេន មរណញ្ច យំ
មរណំ ធម្មិកំ សេយ្យោ  យញ្ចេ ជីវេ អធម្មិកំ ។

---
១ ឱ. វីរា ។

បានសេចក្តីសុខក្នុងទីទាំងពួង មិនចាលចាញ់ក្នុងទីទាំងពួង ។ ការមិនមានលាភ (ប្រកប) ដោយធម៌ណា ហើយនិងលាភមិនប្រកបដោយធម៌ណា ការមិនមានលាភដែលប្រកបដោយធម៌នោះប្រសើរ ឯលាភមិនប្រកបដោយធម៌ ពុំប្រសើរឡើយ ។ យសរបស់បុគ្គលមិនមានប្រាជ្ញាទាំងឡាយណា និងការមិនមានយស របស់អ្នកប្រាជ្ញទាំងឡាយណា ការមិនមានយស របស់អ្នកប្រាជ្ញទាំងឡាយនោះប្រសើរ ឯយសរបស់អ្នកមិនមានប្រាជ្ញាទាំងឡាយ ពុំប្រសើរឡើយ ។ ការសរសើរ អំពីបុគ្គលមិនមានបញ្ញាទាំងឡាយណា និងសេចក្តីតិះដៀល អំពីបុគ្គលមានបញ្ញាទាំងឡាយណា សេចក្តីតិះដៀល អំពីបុគ្គលមានបញ្ញាទាំងឡាយនោះ ប្រសើរ ឯការសរសើរ របស់បុគ្គលពាល ពុំប្រសើរឡើយ ។ សេចក្តីសុខកើតឡើង ព្រោះអាស្រ័យកាម និងសេចក្តីទុក្ខកើតឡើង អំពីសេចក្តីស្ងប់ស្ងាត់ សេចក្តីទុក្ខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ប្រសើរ ឯសេចក្តីសុខ ដែលកើតអំពីកាម ពុំប្រសើរឡើយ ។ ការរស់នៅមិន(ប្រកប) ដោយធម៌ណា និងសេចក្តីស្លាប់ប្រកបដោយធម៌ណា សេចក្តីស្លាប់ប្រកបដោយធម៌នោះ ប្រសើរ ឯបុគ្គលរស់នៅមិនប្រកបដោយធម៌ ពុំប្រសើរសោះឡើយ ។

៣៩

ថេរគាថាយ ចុទ្ទសកនិបាតោ

កាមកោធប្បហីនា យេ សន្តចិត្តា ភវាភវេ
ចរន្តិ លោកេ អសិតា នត្ថិ តេសំ បិយាបិយំ ។
ភាវយិត្វាន ពោជ្ឈង្គេ ឥន្ទ្រិយានិ ពលានិ ច
បប្បុយ្យ បរមំ សន្តឹ បរិនិព្វន្តិ អនាសវាតិ ។

គោទត្តោ ថេរោ ។

## ឧទ្ទានំ

រេវតោ ចេវ គោទត្តោ ថេរា ទ្វេតេ មហិទ្ធិកា
ចុទ្ទសម្ហិ និបាតម្ហិ គាថាយោ អដ្ឋវីសតីតិ ។

ចុទ្ទសកនិបាតោ និដ្ឋិតោ ។

*បុគ្គលទាំងឡាយណា មានកាមនិងសេចក្តីក្រោធលះបង់ហើយ មានចិត្តស្ងប់រម្ងាប់ហើយ រមែងត្រាច់ទៅ ក្នុងភពតូចនិងភពធំ មិនអាស្រ័យនឹងលោក (មានខន្ធលោកជាដើម) សេចក្តីស្រឡាញ់ ឬមិនស្រឡាញ់របស់ជនទាំងឡាយនោះ មិនមានសោះឡើយ ។ បុគ្គលទាំងឡាយ បានចម្រើនពោជ្ឈង្គទាំងឡាយផង ឥន្ទ្រិយទាំងឡាយផង ពលៈទាំងឡាយផង រមែងដល់នូវសេចក្តីស្ងប់ យ៉ាងក្រៃលែង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។*

គោទត្តត្ថេរ ។

# ឧទ្ទាន

*ព្រះថេរៈពីរអង្គនេះ គឺរេវតៈ ១ គោទត្តៈ ១ ជាអ្នកមានឫទ្ធិច្រើន បានពោលនូវគាថា ២៨ ដែលមកក្នុងចុទ្ទសកនិបាត ។*

ចប់ ចុទ្ទសកនិបាត ។

---

# ថេរគាថាយ សោឡសកនិបាតោ

[២៤៧] ឯស ភិយ្យោ បសីទាមិ សុត្វា ធម្មំ មហារសំ
វិរាគោ ទេសិតោ ធម្មោ អនុបាទាយ សព្វសោ ។
ពហូនិ លោកេ ចិត្រានិ អស្មឹ បឋវិមណ្ឌលេ[១]
មថេន្តិ មញ្ញេ សង្កប្បំ សុភំ រាគូបសំហិតំ ។
រជមុហតំ វាតេន យថា មេឃោ បសាមយេ
ឯវំ សម្មន្តិ សង្កប្បា យទា បញ្ញាយ បស្សតិ ។
សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
ពុទ្ធានុពុទ្ធោ យោ ថេរោ កោណ្ឌញ្ញោ តិព្វនិក្កមោ[២]
បហីនជាតិមរណោ ព្រហ្មចរិយស្ស កេវលី ។

---

១ ឱ. បុថុវិមណ្ឌលេ ។ ២ ឱ. តិព្វនិក្ខមោ ។

# ថេរគាថា សោឡសកនិបាត

[២៤៧] ខ្ញុំនេះបានស្តាប់ធម៌មានរសច្រើន ជ្រះថ្លាក្រៃលែង វិរាគធម៌ដែលលោកសម្តែងហើយ មិនកាន់យក (ធម៌ណាមួយ) ដោយប្រការទាំងពួង ។ អារម្មណ៍ទាំងឡាយច្រើន ដ៏វិចិត្រក្នុងលោក លើមណ្ឌលនៃផែនដីនេះ ទំនងជាញាំញីនូវសេចក្តីត្រិះរិះថា ល្អ ដែលប្រកបដោយរាគៈ ។ អរិយសាវ័ក ពិចារណាឃើញ ដោយប្រាជ្ញា ក្នុងកាលណា សេចក្តីត្រិះរិះទាំងឡាយ ក៏ស្ងប់រម្ងាប់ក្នុងកាលណោះ ដូចជាភ្លៀងរម្ងាប់នូវធូលី ដែលហុយឡើងដោយខ្យល់ ។ អរិយ-សាវ័ក ពិចារណាឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង មិនទៀង ក្នុងកាលណា រមែងនឿយណាយក្នុងសេចក្តីទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ អរិយសាវ័ក ពិចារណាឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងជាទុក្ខ ក្នុងកាលណា រមែងនឿយណាយក្នុងទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ អរិយសាវ័ក ពិចារណាឃើញ ដោយប្រាជ្ញាថា ធម៌ទាំងពួង មិនមែនជារបស់ខ្លួន ក្នុងកាលណា រមែងនឿយណាយក្នុងទុក្ខ ក្នុងកាលណោះ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ ព្រះថេរៈឈ្មោះកោណ្ឌញ្ញៈ ត្រាស់ដឹងតាមព្រះពុទ្ធ ដែលមានសេចក្តីព្យាយាមដ៏ក្លៀវក្លា មានជាតិនិងមរណៈលះបង់ហើយ បរិបូណ៌ដោយព្រហ្មចរិយធម៌ ។

ថេរគាថាយ សោឡសកនិបាតោ

ឱឃបាសោ ទឡ្ហោ ខីលោ បព្វតោ ទុប្បទាលិយោ
ឆេត្វា ខីលញ្ច បាសញ្ច សេលំ ភេត្វាន ទុព្ភិទំ
តិណ្ណោ បារង្គតោ ឈាយី មុត្តោ សោ មារពន្ធនា ។
ឧទ្ធតោ ចបលោ ភិក្ខុ មិត្តេ អាគម្ម បាបកេ
សំសីទតិ មហោឃស្មឹ ឩម្មិយា បដិកុជ្ជិតោ ។
អនុទ្ធតោ អចបលោ និបកោ សំវុតិន្ទ្រិយោ
កល្យាណមិត្តោ មេធាវី ទុក្ខស្សន្តករោ សិយា ។
កាលាបព្វង្គសង្កាសោ កិសោ ធមនិសន្ថតោ
មត្តញ្ញូ អន្នបានស្មឹ អទីនមនសោ[១] នរោ
ផុដ្ឋោ ឌំសេហិ មកសេហិ អរញ្ញស្មឹ ព្រហាវនេ
នាគោ សង្គាមសីសេវ សតោ តត្រាធិវាសយេ ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ និព្វិសំ ភតកោ យថា ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ សម្បជានោ បតិស្សតោ ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ

១ អល្លីនមនសោតិបិ បាឋោ ។

អន្ទាក់គឺឱឃៈក្តី ចិត្តរឹងរូសដ៏មាំក្តី មោហៈដូចភ្នំដែលទម្លាយបាន ដោយកម្រក្តី ព្រះអញ្ញាកោណ្ឌញ្ញៈនោះ បានកាត់នូវចិត្តដ៏រឹងរូសផង នូវអន្ទាក់គឺឱឃៈផង នូវភ្នំគឺមោហៈដែលបុគ្គលបំបែកបានដោយកម្រ ផង បានឆ្លងទៅដល់ត្រើយ ជាអ្នកមានឈាន រួចចាកចំណងនៃ មារ ។ ភិក្ខុអ្នកមានចិត្តរាយមាយ ឃ្លេងឃ្លោង អាស្រ័យនឹងពួកបាប-មិត្រ រមែងត្រូវរលកគឺឧបាយនៃសេចក្តីក្រោធជ្រមុច ហើយលិច ចុះក្នុងអន្លង់ធំ ។ ឯភិក្ខុមានប្រាជ្ញា មានចិត្តមិនរាយមាយ មិនឃ្លេង ឃ្លោង មានប្រាជ្ញាល្អិត សង្រួមឥន្ទ្រិយល្អ មានកល្យាណមិត្រ តែងធ្វើនូវទីបំផុតនៃទុក្ខបាន ។ ជនអ្នកមានអវយវៈប្រាកដស្មើ ដោយថ្នាំងវល្លិ៍ ស្គម រីមរវាមដោយសរសៃ ជាអ្នកដឹងប្រមាណ ក្នុងបាយនិងទឹក មានចិត្តមិនរួញរា ត្រូវរបោមនិងមូសទាំងឡាយ ខាំហើយ ក្នុងព្រៃតូចនិងព្រៃធំ ជាអ្នកមានស្មារតី គង់អត់ទ្រាំនៅ ក្នុងព្រៃនោះបាន ដូចដំរីដ៏ប្រសើរ (អត់ទ្រាំ) ក្នុងប្រធាននៃ សង្គ្រាម ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹង ការរស់នៅ ខ្ញុំរង់ចាំតែកាល (បរិនិព្វាន) ដូចអ្នកធ្វើការឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹង ការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតី រង់ចាំតែបរិនិព្វានកាល ។ ព្រះសាស្តាខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ

ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
យស្ស ចត្ថាយ បព្វជិតោ អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ កឹ មេ សទ្ធិវិហារិនាតិ[១] ។

អញ្ញាកោណ្ឌញ្ញោ ថេរោ ។

[២៤៨] មនុស្សភូតំ សម្ពុទ្ធំ អត្តទន្តំ សមាហិតំ
ឥរិយមានំ ព្រហ្មបថេ ចិត្តស្សូបសមេ រតំ
យំ មនុស្សា នមស្សន្តិ សព្វធម្មាន បារគុំ
ទេវាបិ នំ នមស្សន្តិ ឥតិ មេ អរហតោ សុតំ
សព្វសំយោជនាតីតំ វនា និព្វនមាគតំ
កាមេហិ នេក្ខម្មរតំ មុត្តំ សេលាវ កញ្ចនំ
ស វេ អច្ចរុចិ[២] នាគោ ហិមវាវញ្ញេ សិលុច្ចយេ
សព្វេសំ នាគនាមានំ សច្ចនាមោ អនុត្តរោ
នាគំ វោ កិត្តយិស្សាមិ ន ហិ អាគុំ ករោតិ សោ ។

១ ឱ. សន្ធិវិហារេនាតិ ។ ២ ឱ. អច្ចន្តរុចី ។ ម. អច្ចន្តរុចិ ។

ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំដកចោលហើយ ។ កុលបុត្រអ្នកចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ខ្ញុំបានដល់ហើយ ខ្ញុំមានប្រយោជន៍អ្វី ដោយសទ្ធិវិហារិក ។

អញ្ញាកោណ្ឌញ្ញត្ថេរ ។

[២៤៨] មនុស្សទាំងឡាយ តែងនមស្ការ នូវព្រះសម្ពុទ្ធ ដែលទ្រង់មានព្រះជាតិជាមនុស្ស ទ្រង់បានបង្វឹកព្រះអង្គត្រឹមត្រូវឥតមានធ្គង់ មានព្រះទ័យខ្ជាប់ខ្ជួន ទ្រង់ប្រព្រឹត្តក្នុងគន្លងដ៏ប្រសើរ ទ្រង់ពេញព្រះទ័យចំពោះឈានជាគ្រឿងស្ងប់ចិត្ត ព្រះអង្គបានដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ឆ្លងរំលងនូវសំយោជនៈទាំងពួងហើយ ទ្រង់(ចេញផុត)ចាកព្រៃគឺកិលេស ស្តេចមកដល់ព្រះនិព្វានហើយ ទ្រង់ពេញព្រះទ័យការចេញចាកកាមទាំងឡាយ ដូចមាសចេញផុតចាកជាតុថ្មហើយ ទោះបីពួកទេវតាក៏នមស្ការព្រះអង្គដែរ ពាក្យដូច្នេះនេះ ខ្ញុំព្រះអង្គបានស្តាប់ (ក្នុងសំណាក់) នៃព្រះអរហន្ត ឯព្រះសម្ពុទ្ធទ្រង់ព្រះនាមថានាគនោះឯង ព្រះអង្គរុងរឿងក្រៃពេក ដូចភ្នំហិមពាន្តដែលរុងរឿងកន្លងនូវពួកភ្នំឯទៀត ព្រះអង្គមានព្រះនាមពិតប្រាកដ ប្រសើរបំផុតជាងជនទាំងពួង ដែលមាននាមថានាគដែរ ខ្ញុំនឹងថ្លែងនូវពុទ្ធនាគដល់អ្នកទាំងឡាយ ព្រះពុទ្ធនាគនោះ មិនធ្វើនូវអំពើអាក្រក់ឡើយ ។

៤៣

ថេរគាថាយ សោឡសកនិបាតោ

សោរច្ចំ អវិហឹសា ច បាទា នាគស្ស តេ ទុវេ ។
សតិ ច សម្បជញ្ញញ្ច ចរណា នាគស្ស តេ បរេ ។
សទ្ធា ហត្ថោ មហានាគោ ឧបេក្ខាសេតទន្តវា ។
សតិ គីវា សិរោ បញ្ញា វិមំសា ធម្មចិន្តនា
ធម្មកុច្ឆិ សមាវាសោ វិវេកោ តស្ស វាលធិ ។
សោ ឈាយី អស្សាសរតោ អជ្ឈត្តំ សុសមាហិតោ
គច្ឆំ សមាហិតោ នាគោ ឋិតោ នាគោ សមាហិតោ
សយំ សមាហិតោ នាគោ និសិន្នោបិ សមាហិតោ
សព្វត្ថ សំវុតោ នាគោ ឯសា នាគស្ស សម្បទា ។
ភុញ្ជតិ អនវជ្ជានិ សាវជ្ជានិ ន ភុញ្ជតិ
ឃាសំ អច្ឆាទនំ លទ្ធា សន្និធឹ បរិវជ្ជយំ
សំយោជនំ អណុំ ថូលំ សព្វំ ឆេត្វាន ពន្ធនំ
យេន យេនេវ គច្ឆតិ អនបេក្ខោវ គច្ឆតិ ។
យថាបិ ឧទកេ ជាតំ បុណ្ឌរីកំ បវឌ្ឍតិ
នោបលិប្បតិ តោយេន សុចិគន្ធំ មនោរមំ

សោរច្ចៈនិងអវិហឹសា ទាំងពីរនោះ ជាបាទា(ខាងមុខ) របស់ព្រះពុទ្ធ-នាគ ។ សតិ និងសម្បជញ្ញៈទាំងពីរនោះ ជាបាទាខាងក្រោយរបស់ព្រះពុទ្ធនាគ ។ ព្រះសម្ពុទ្ធជាមហានាគ ទ្រង់មានសទ្ធាជាប្រមោយ មានឧបេក្ខាជាភ្លុកស ។ ព្រះពុទ្ធនាគនោះ មានសតិជាក បញ្ញាជាសិរប្រទេស គំនិតសម្រាប់គិតគូរធម៌ ជាចុងប្រមោយ ធម៌ជាផ្ទៃសម្រាប់ដាក់នូវគ្រឿងចម្អែត វិវេកជាកន្ទុយ ។ ព្រះពុទ្ធនាគនោះ មានឈាន ទ្រង់រីករាយចំពោះខ្យល់ដកដង្ហើម គឺព្រះនិព្វាន មានព្រះទ័យតាំងមាំខាងក្នុង ព្រះពុទ្ធនាគ កាលបើទ្រង់ស្តេចយាត្រា ក៏មានព្រះទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគទ្រង់បិត ក៏មានព្រះទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគទ្រង់ផ្ទំ ក៏មានព្រះទ័យខ្ជាប់ខ្ជួន ទ្រង់គង់ ក៏មានព្រះទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគ ទ្រង់សង្រួមរក្សាទ្វារទាំងអស់ នេះជាសម្បទារបស់ព្រះពុទ្ធនាគ ។ ព្រះពុទ្ធនាគ ទ្រង់សោយតែភោជនដែលឥតទោស មិនសោយនូវភោជន ដែលប្រកបដោយទោស (កាលបើ) ទ្រង់បាននូវចង្ហាន់ និងគ្រឿងស្លៀកដណ្តប់ ទ្រង់វៀរនូវការសន្សំទុក ទ្រង់កាត់នូវសំយោជនៈ ដែលជាចំណងតូចធំទាំងអស់ ហើយទ្រង់យាងទៅណា ៗ ក៏ស្តេចទៅដោយឥតមានព្រះទ័យអាឡោះអាល័យ ។ ឈូកស ដុះចម្រើនឡើងក្នុងទឹក មិនជាប់ប្រឡាក់ដោយទឹក មានក្លិនក្រអូប ជាទីរីករាយចិត្ត យ៉ាងណាមិញ

៤៤



តថេវ ច លោកេ ជាតោ ពុទ្ធោ លោកេ វិហរតិ
នោបលិប្បតិ លោកេន តោយេន បទុមំ យថា ។
មហាគ្គិនិ បជ្ជលិតោ អនាហារោបសម្មតិ
អង្គារេសុ ច សន្តេសុ និព្វុតោតិ បវុច្ចតិ ។
អត្ថស្សាយំ វិញ្ញាបនី ឧបមា វិញ្ញូហិ ទេសិតា
វិញ្ញិស្សន្តិ មហានាគា នាគំ នាគេន ទេសិតំ
វីតរាគោ វីតទោសោ វីតមោហោ អនាសវោ
សរីរំ វិជហំ នាគោ បរិនិព្វិស្សត្យនាសវោតិ ។

ឧទាយី ថេរោ ។

## តត្រុទ្ទានំ ភវតិ

កោណ្ឌញ្ញោ ច ឧទាយី ច ថេរា ទ្វេ តេ មហិទ្ធិកា
សោឡសម្ហិ និបាតម្ហិ គាថាយោ ទ្វេ ច តឹស ចាតិ ។

សោឡសកនិបាតោ និដ្ឋិតោ ។

*ព្រះពុទ្ធ ទ្រង់កើតក្នុងលោក គង់នៅក្នុងលោក មិនប្រឡាក់ដោយលោក ដូចជាឈូក មិនជាប់ប្រឡាក់ដោយទឹកដូច្នោះឯង ។ គំនរភ្លើងធំ ដែលឆេះសន្ធោ មិនមានចំណី រមែងរលត់ បើទុកជារងើកទាំងឡាយ មាននៅ ក៏គេនិយាយថា ភ្លើងរលត់ហើយ ។ ពាក្យឧបមានេះ ជាគ្រឿងបញ្ជាក់នូវសេចក្តី ដែលពួកវិញ្ញូជនបានសម្តែងហើយ មហានាគ គឺព្រះខីណាស្រពទាំងឡាយ គង់ដឹងច្បាស់ នូវព្រះពុទ្ធនាគ ដែលខ្ញុំជានាគសម្តែងរួចមកហើយនេះថា ព្រះពុទ្ធនាគ ទ្រង់ប្រាសចាករាគៈ ទោសៈ មោហៈហើយ អស់អាសវៈហើយ លះបង់សរីរៈ មិនមានអាសវៈ នឹងបរិនិព្វាន ។*

ឧទាយិត្ថេរ ។

# ឧទ្ទាន មានក្នុងសោឡសកនិបាតនោះ

*ព្រះថេរៈពីរអង្គ អ្នកមានឫទ្ធិច្រើននោះ គឺ ព្រះកោណ្ឌញ្ញៈ ១ ព្រះឧទាយី ១ ពោលនូវគាថា ៣២ ក្នុងសោឡសកនិបាត ។*

ចប់ សោឡសកនិបាត ។

---

# ថេរគាថាយ វីសតិនិបាតោ

[២៤៩] យញ្ញត្ថំ វា ធនត្ថំ វា  យេ ហនាម មយំ បុរេ
អវសេសំ ភយំ ហោតិ  វេធន្តិ វិលបន្តិ ច ។
តស្ស តេ នត្ថិ ភីតត្តំ  ភិយ្យោ វណ្ណោ បសីទតិ
កស្មា ន បរិទេវេសិ  ឯវរូបេ មហព្ភយេ ។
នត្ថិ ចេតសិកំ ទុក្ខំ  អនបេក្ខស្ស គាមណិ
អតិក្កន្តា ភយា សព្វេ  ខីណសំយោជនស្ស វេ ។
ខីណាយ ភវនេត្តិយា  ទិដ្ឋេ ធម្មេ យថាតថា[១]
ន ភយំ មរណេ ហោតិ  ភារនិក្ខេបនេ យថា ។
សុចិណ្ណំ ព្រហ្មចរិយំ មេ  មគ្គោ ចាបិ សុភាវិតោ
មរណេ មេ ភយំ នត្ថិ  រោគានមិវ សង្ខយេ ។
សុចិណ្ណំ ព្រហ្មចរិយំ មេ  មគ្គោ ចាបិ សុភាវិតោ
និរស្សាទា ភវា ទិដ្ឋា  វិសំ បិត្វាន ឆឌ្ឌិតំ ។

---

១. ឱ. ម. យថាតថេ ។

# ថេរគាថា វីសតិនិបាត

[២៤៩] (ចោរពោលថា) ក្នុងកាលមុន យើងខ្ញុំទាំងឡាយ សម្លាប់សត្វពួកណា ដើម្បីយញ្ញ ឬដើម្បីទ្រព្យ ភ័យក៏កើតមាន (ដល់សត្វពួកនោះ) ឥតមានសេសសល់ សត្វទាំងនោះ រមែងញាប់ញ័រផង សោកសៅផង ។ សេចក្ដីភិតភ័យនៃលោកមិនមាន ទាំងសម្បុរ (មុខលោក) ក៏ស្រស់បស់ក្រៃពេក ហេតុអ្វីក៏លោកមិនខ្សឹកខ្សួល ព្រោះភ័យធំ មានសភាពយ៉ាងនេះ ។

(ព្រះអធិមុត្តត្ថេរពោលថា) ម្នាលចោរជាធំ សេចក្ដីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត នៃបុគ្គលអ្នកមិនមានសេចក្ដីអាឡោះអាល័យ មិនមានទេ បុគ្គលអ្នកមានសំយោជនៈអស់ហើយ បានកន្លងផុតនូវភ័យទាំងពួង ។ កាលបើតណ្ហា ជាគ្រឿងនាំសត្វទៅកាន់ភពក្នុងបច្ចុប្បន្នអស់ហើយ ដោយហេតុណាមួយ ភ័យចំពោះសេចក្ដីស្លាប់ ក៏មិនមានឡើយ ដូចការមិនមានភ័យ ក្នុងកិរិយាដាក់ចុះនូវភារៈចេញ(អំពីក្បាល) ។ ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គ អាត្មាក៏បានចម្រើនល្អហើយ ភ័យចំពោះសេចក្ដីស្លាប់ នៃអាត្មា មិនមានទេ ដូចការមិនមានភ័យ ក្នុងកិរិយាអស់ទៅនៃរោគទាំងឡាយ ។ ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គ អាត្មាក៏បានចម្រើនល្អហើយ ភពទាំងឡាយដែលមិនមានសេចក្ដីត្រេកអរ អាត្មាក៏បានឃើញហើយ ដូចបុគ្គលផឹកនូវថ្នាំពិស ហើយខ្ជាក់ចោលវិញ ។

## ៤៦



ចារកូ អនុចាគាដោ កតកិច្ចោ អនាសវោ
តុដ្ឋោ អាយុក្ខយា ហោតិ មុត្តោ អាឃាតនា យថា ។
ឧត្តមំ ធម្មតំ បត្តោ សព្វលោកេ អនត្ថិកោ
អាទិត្តាវ ឃរា មុត្តោ មរណស្មឹ ន សោចតិ ។
យទត្ថិ សង្គតំ កិញ្ចិ ភវោ ច យត្ថ លព្ភតិ
សព្វំ អនិស្សរំ ឯតំ ឥតិ វុត្តំ[១] មហេសិនា ។
យោ តំ តថា បជានាតិ យថា ពុទ្ធេន ទេសិតំ
ន គណ្ហាតិ ភវំ កិញ្ចិ សុតត្តំ វ អយោគុឡំ ។
ន មេ ហោតិ អហោសិន្តិ ភវិស្សន្តិ ន ហោតិ មេ
សង្ខារា វិភវិស្សន្តិ តត្ថ កា បរិទេវនា ។
សុទ្ធំ ធម្មសមុប្បាទំ សុទ្ធំ សង្ខារសន្តតឹ
បស្សន្តស្ស យថាភូតំ ន ភយំ ហោតិ គាមណិ ។
តិណកដ្ឋសមំ លោកំ យទា បញ្ញាយ បស្សតិ

---

១ ឱ. ម. ឥតិ វុត្តំ ។

បុគ្គលអ្នកដល់នូវត្រើយ គឺព្រះនិព្វាន មិនមានសេចក្តីប្រកាន់ មានសោឡសកិច្ចធ្វើហើយ មិនមានអាសវៈ រមែងជាអ្នកត្រេកអរ ក្នុងកិរិយាអស់ទៅនៃអាយុ ដូចបុគ្គលរួចហើយចាកការសម្លាប់ ។ បុគ្គលបានដល់នូវធម៌ដ៏ឧត្តម ជាអ្នកមិនត្រូវការ ក្នុងលោកទាំងអស់ រមែងមិនសោកសៅ ព្រោះសេចក្តីស្លាប់ ដូចបុគ្គលស្ទុះផុតចាកផ្ទះដែលភ្លើងឆេះ ។ ការជួបជុំដោយសត្វនិងសង្ខារឯណានីមួយក្តី ការកើតមានក្នុងពួកសត្វឯណាក្តី ទាំងអស់នុ៎ះ មិនមែនជាធំឡើយ ពាក្យនេះព្រះសម្មាសម្ពុទ្ធ អ្នកស្វែងរកនូវគុណធំបានសម្តែងហើយ ។ បុគ្គលណា បានដឹងច្បាស់នូវព្រះពុទ្ធដីកាតាមដែលព្រះពុទ្ធទ្រង់សម្តែងហើយនោះ បុគ្គលនោះមិនប្រកាន់នូវភពនីមួយឡើយ ដូចបុរសមិនកាន់ដុំដែកដែលក្តៅសព្វ ។ អាត្មាមិនមានសេចក្តីត្រិះរិះថាខ្លួនអញបានមានហើយទេ អាត្មាមិនមានគិតថា ខ្លួនអញនឹងមានតទៅទេ (ព្រោះថា) សង្ខារទាំងឡាយ ទៀងតែវិនាសទៅវិញ ហេតុនោះសេចក្តីខ្សឹកខ្សួលក្នុងសង្ខារទាំងនោះដូចម្តេចកើត ។ ម្នាលចោរជាធំ បុគ្គលដែលឃើញច្បាស់តាមសេចក្តីពិត នូវការប្រជុំកើតនៃធម៌ដ៏បរិសុទ្ធ និងតំណនៃសង្ខារ ដ៏បរិសុទ្ធ ភ័យមិនមានឡើយ ។ បុគ្គលដែលឃើញច្បាស់ ដោយបញ្ញា នូវលោក ប្រាកដស្មើដោយស្មៅ និងកំណាត់ឈើ ក្នុងកាលណា

៤៧

## ថេរគាថាយ វីសតិនិបាតោ

មមត្តំ សោ អសំវិន្ទំ    នត្ថិ មេតិ ន សោចតិ ។

ឧក្កណ្ឋាមិ សរីរេន    ភវេនម្ហិ អនត្ថិកោ

សោយំ ភិជ្ជិស្សតិ កាយោ    អញ្ញោ ច ន ភវិស្សតិ ។

យំ វោ កិច្ចំ សរីរេន    តំ ករោថ យទិច្ឆថ

ន មេ តប្បច្ចយា តត្ថ    ទោសោ បេមំ ច ហេហីតិ ។

តស្ស តំ វចនំ សុត្វា    អព្ភុតំ លោមហំសនំ

សត្ថានិ និក្ខិបិត្វាន    មាណវា ឯតទព្រវុំ

កឹ ភន្តេ ករិត្វាន    កោ វា អាចរិយោ តវ

កស្ស សាសនមាគម្ម    លព្ភតេ តំ អសោកតា ។

សព្វញ្ញូ សព្វទស្សាវី    ជិនោ អាចរិយោ មម

មហាការុណិកោ សត្ថា    សព្វលោកតិកិច្ឆកោ ។

តេនាយំ ទេសិតោ ធម្មោ    ខយគាមី អនុត្តរោ

តស្ស សាសនមាគម្ម    លព្ភតេ តំ អសោកតា ។

ក្នុងកាលនោះ បុគ្គលនោះ ក៏មិនបានទូវសេចក្ដីប្រកាន់ ថារបស់អញ រមែងមិនសោកសៅថា អ្វីមិនមានដល់អាត្មាឡើយ ។ អាត្មាធុញទ្រាន់នឹងសរីរៈ ជាអ្នកមិនត្រូវការដោយភព ព្រោះថា កាយនេះនឹងបែកធ្លាយទៅ ទាំងកាយដទៃទៀត ក៏នឹងមិនមានដែរ ។ កិច្ចណាដោយសរីរៈមានដល់ពួកអ្នក ពួកអ្នកប្រាថ្នានូវកិច្ចណា ចូរធ្វើនូវកិច្ចនោះចុះ សេចក្ដីទោមនស្សក្ដី សេចក្ដីស្រឡាញ់ក្ដី នៃអាត្មានឹងមិនមានក្នុងអំពើទាំងនោះ ព្រោះបច្ច័យនៃកិច្ចនោះ ។ ពួកចោរ បានស្ដាប់ពាក្យនៃព្រះអធិមុត្តត្ថេរនោះ ជាពាក្យចម្លែកអស្ចារ្យ គួរឲ្យព្រឺរោម ហើយក៏ទម្លាក់ចោល នូវគ្រឿងសស្ត្រាទាំងឡាយ បានពោលពាក្យនេះថា បពិត្រលោកដ៏ចម្រើន លោកបានធ្វើតបោកម្មដូចម្ដេច ឬ អ្នកណាជាអាចារ្យរបស់លោក សេចក្ដីមិនសោកសៅ លោកបានព្រោះអាស្រ័យពាក្យប្រដៅ របស់អ្នកណា ។

ព្រះថេរៈឆ្លើយថា ព្រះជិនស្រីព្រះអង្គជាសព្វញ្ញូ ទ្រង់ឃើញនូវធម៌ទាំងពួង ជាសាស្ដាប្រកបដោយករុណាដ៏ធំ ទ្រង់រក្សានូវសត្វលោកទាំងអស់ ជាអាចារ្យរបស់អាត្មា ។ ព្រះធម៌នេះ ជាធម៌ដល់នូវកិរិយាអស់ទៅនៃកិលេស ជាធម៌ដ៏ប្រសើរ ព្រះជិនស្រីនោះបានសម្ដែងហើយ សេចក្ដីមិនសោកសៅ ដែលអាត្មាបានព្រោះអាស្រ័យនូវធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីនោះ ។

សុត្វាន ចោរា ឥសិនោ សុភាសិតំ
និក្ខិប្ប សត្ថានិ ច អាវុធានិ ច
តម្ហា ច កម្មា វិរមឹសុ ឯកេ
ឯកេ ច បព្វជ្ជមរោចយឹសុ ។
តេ បព្វជិត្វា សុគតស្ស សាសនេ
ភាវេត្វា ពោជ្ឈង្គពលានិ បណ្ឌិតា
ឧទគ្គចិត្តា សុមនា កតិន្ទ្រិយា
ផុសឹសុ និព្វានបទំ អសង្ខតន្តិ ។

អធិមុត្តោ ថេរោ ។

[២៨០] សមណស្ស អហុ ចិន្តា ធារាសរិយស្ស[១] ភិក្ខុនោ
ឯកកស្ស និសិន្នស្ស បវិវិត្តស្ស ឈាយិនោ
កិមានុបុព្វំ បុរិសោ កឹ វតំ្ត កឹ សមាចារំ
អត្តនោ កិច្ចការិស្ស ន ច កិញ្ចិ វិហេឋយេ ។
ឥន្ទ្រិយានិ មនុស្សានំ ហិតាយ អហិតាយ ច
អរក្ខិតានិ អហិតាយ រក្ខិតានិ ហិតាយ ច ។
ឥន្ទ្រិយានេវ សារក្ខំ ឥន្ទ្រិយានិ ច គោបយំ
អត្តនោ កិច្ចការិស្ស ន ច កិញ្ចិ វិហេឋយេ ។

១ ឱ. ម. បារាបរិយស្ស ។

ចោរទាំងឡាយ បានស្តាប់នូវសុភាសិតនៃឥសី(អធិមុត្ត-ត្ថេរ)ក៏ទម្លាក់ចោល នូវគ្រឿងសស្ត្រាទាំងឡាយផង នូវអាវុធទាំងឡាយផង ពួកខ្លះក៏វៀរចាកចោរកម្មនោះ ពួកខ្លះក៏ពេញចិត្តនឹងបព្វជ្ជា ។ ចោរទាំងនោះ ក៏ចូលទៅបួសក្នុងសាសនានៃព្រះសុគត ចម្រើននូវពោជ្ឈង្គ និងពលៈទាំងឡាយ ជាបណ្ឌិតមានចិត្តខ្ពស់ឡើង មានចិត្តល្អ មានឥន្ទ្រិយចម្រើនហើយ ក៏បានពាល់ត្រូវនូវនិព្វានបទ ជាអសង្ខតធម៌ ។

អធិមុត្តត្ថេរ ។

[២៥០] ភិក្ខុឈ្មោះបារាសរិយៈ ជាសមណៈ អង្គុយតែម្នាក់ឯង ជាអ្នកស្ងប់ស្ងាត់ ចម្រើនឈាន មានគំនិតថា បុរសគប្បីប្រតិបត្តិដោយលំដាប់ ដូចម្តេច គប្បីប្រព្រឹត្តនូវវត្ត ដូចម្តេច នូវសមាចារៈដូចម្តេច ទើបឈ្មោះថាជាអ្នកធ្វើនូវកិច្ចរបស់ខ្លួន ទាំងមិនបៀតបៀននូវអ្វីណាមួយ ។ ឥន្ទ្រិយទាំងឡាយ របស់ពួកមនុស្សមានដើម្បីជាប្រយោជន៍ផង មិនជាប្រយោជន៍ផង ឥន្ទ្រិយទាំងឡាយដែលគេមិនរក្សា ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដែលគេរក្សាហើយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ។ បុគ្គលកាលរក្សានូវឥន្ទ្រិយទាំងឡាយផង គ្រប់គ្រងនូវឥន្ទ្រិយទាំងឡាយផង ឈ្មោះថាជាអ្នកធ្វើនូវកិច្ចរបស់ខ្លួន ទាំងមិនបៀតបៀន នូវអ្វីណាមួយ ។

៤៩

## ថេរគាថាយ វីសតិនិបាតោ

ចក្ខុន្ទ្រិយញ្ចេ រូបេសុ គច្ឆន្តំ អនិវារយំ
អនាទីនវទស្សាវី សោ ទុក្ខា ន ហិ មុច្ចតិ ។
សោតិន្ទ្រិយញ្ចេ សទ្ទេសុ គច្ឆន្តំ អនិវារយំ
អនាទីនវទស្សាវី សោ ទុក្ខា ន ហិ មុច្ចតិ ។
អនិស្សរណទស្សាវី គន្ធេ ចេ បដិសេវតិ
ន សោ មុច្ចតិ ទុក្ខម្ហា គន្ធេសុ អធិមុច្ឆិតោ ។
អម្ពិលមធុរគ្គញ្ច តិត្តកគ្គមនុស្សរំ
រសតណ្ហាយ គធិតោ ហទយំ ជាវពុជ្ឈតិ ។
សុភានយប្បដិកុលានិ[១] ផោដ្ឋព្វានិ អនុស្សរំ
រត្តោ រាគាធិករណំ វិវិធំ វិន្ទតេ ទុក្ខំ ។
មនញ្ចេតេហិ ធម្មេហិ យោ ន សក្កោតិ រក្ខិតុំ
តតោ នំ ទុក្ខមន្វេតិ សព្វសោតេហិ បញ្ចហិ ។
បុព្វលោហិតសម្បុណ្ណំ ពហុស្ស កុណបស្ស ច
នវវីរកាតំ វត្តុំ សមុគ្គមិវ ចិត្តិតំ ។

---

១ សុភាន្យប្បដិកូលានីតិ យុត្តតរំ ។

បើបុគ្គលណា មិនឃាត់នូវចក្ខុន្ទ្រិយ ដែលប្រព្រឹត្តទៅ ក្នុងរូបទាំងឡាយ ជាអ្នកមិនឃើញនូវទោសទេ បុគ្គលនោះ មិនរួចចាកទុក្ខឡើយ ។ មួយទៀត បុគ្គលណា មិនឃាត់នូវសោតិន្ទ្រិយ ដែលប្រព្រឹត្តទៅ ក្នុងសំឡេងទាំងឡាយ ជាអ្នកមិនឃើញនូវទោសទេ បុគ្គលនោះ មិនរួចចាកទុក្ខឡើយ ។ បើបុគ្គលណា មិនឃើញនូវការរលាស់ចេញ ជាអ្នកជ្រប់នៅក្នុងក្លិនទាំងឡាយ ហើយសេពចំពោះនូវក្លិនទាំងឡាយ បុគ្គលនោះ មិនរួចចាកទុក្ខទេ ។ បុគ្គលណា រលឹករឿយ ៗ នូវរសជូរនិងចំណែកនៃរសផ្អែមផង នូវចំណែកនៃរសល្វីងផង ជាអ្នកជាប់នៅក្នុងរសតណ្ហា បុគ្គលនោះរមែងមិនដឹងច្បាស់នូវបេះដូងនៃសាសនា ។ បុគ្គល កាលរលឹករឿយ ៗ នូវផោដ្ឋព្វៈទាំងឡាយ ដែលស្អាត មិនគួរខ្ពើម ជាអ្នកត្រេកអរ (ក្នុងផស្សព្វនោះ) រមែងបាននូវសេចក្ដីទុក្ខផ្សេង ៗ ដែលមានរាគៈជាហេតុ ។ បុគ្គលណា មិនអាចរក្សានូវចិត្ត ដោយធម៌ទាំងឡាយនេះ ព្រោះហេតុតែមិនបានរក្សានោះឯង ទុក្ខរមែងជាប់តាមបុគ្គលនោះដោយខ្សែទាំងពួង មានប្រមាណ ៥ គឺអារម្មណ៍ទាំង ៥ ។ សរីរៈនេះ ពេញដោយខ្ទុះនិងឈាមផង ពេញដោយសាកសព ដ៏ច្រើនផង ដូចស្មុគ្រដែលបុគ្គលមានព្យាយាមធ្វើឲ្យរលីង វិចិត្រហើយ ។

កដុកំ មធុរស្សាទំ បិយនិពន្ធនំ ទុក្ខំ
ខុរំវ មធុនាលិត្តំ ឧល្លិត្តំ នាវពុជ្ឈតិ ។
ឥត្ថីរូបេ ឥត្ថីរសេ ផោដ្ឋព្វេបិច ឥត្ថិយា
ឥត្ថីគន្ធេសុ សារត្តោ វិវិធំ វិន្ទតេ ទុក្ខំ ។
ឥត្ថីសោតានិ សព្វានិ សន្ទន្តិ បញ្ច បញ្ចសុ
តេសមាវរណំ កាតុំ យោ សក្កោតិ វីរិយវា
សោ អត្ថវា សោ ធម្មដ្ឋោ សោ ទក្ខោ សោ វិចក្ខណោ
ករេយ្យ រមមានោ ហិ កិច្ចំ ធម្មត្ថសំហិតំ ។
អថោ សីទតិ សញ្ញុត្តំ[១] វជ្ជេ កិច្ចំ និរត្ថកំ
ន តំ កិច្ចន្តិ មញ្ញិត្វា អប្បមត្តោ វិចក្ខណោ ។
យញ្ច អត្ថេន សញ្ញុត្តំ យា ច ធម្មគតា រតិ
តំ សមាទាយ វត្តេថ ស ហិ វេ ឧត្តមា រតិ ។
ឧច្ចាវចេហុបាយេហិ បរេសមភិជិគីសាតិ
ហន្ត្វា វធិត្វា អថ សោចយិត្វា
អាលោបតិ សាហសា យោ បរេសំ ។

១ អថោបិ រតិសំយុត្តន្តិ អដ្ឋកថាយំ ទិស្សតិ ។

បុគ្គលរមែងមិនដឹងនូវសេចក្តីទុក្ខ ក្តៅក្រហាយ តែមានរសផ្អែមឆ្ងាញ់ពី-សា ដែលមានសេចក្តីស្រឡាញ់ជាចំណង ដូចកាំបិតកោរដែលគេលាបប្រឡាក់ដោយទឹកឃ្មុំ ។ បុគ្គលអ្នកត្រេកអរក្រៃពេក ក្នុងរូបស្ត្រីផង ក្នុងរសនៃស្ត្រីផង ក្នុងការប៉ះពាល់នូវកាយនៃស្ត្រីផង ក្នុងក្លិននៃស្ត្រីផង រមែងបាននូវសេចក្តីទុក្ខផ្សេង ៗ ។ ខ្សែនៃតណ្ហាទាំង ៥ របស់ស្ត្រីទាំងអស់រមែងហូរទៅក្នុងទ្វារនៃបុរសទាំង ៥ ដែរ បុគ្គលណាមានការព្យាយាម អាចធ្វើនូវការបិទរាំងនូវខ្សែតណ្ហាទាំងនោះ(មិនឲ្យកើតឡើងបាន) បុគ្គលនោះឈ្មោះថាជាអ្នកមានប្រយោជន៍ ជាអ្នកឋិតនៅក្នុងធម៌ ជាអ្នកឈ្លាសវៃ ជាអ្នកមានបញ្ញាជាគ្រឿងពិចារណា បុគ្គលនោះគប្បីត្រេកអរធ្វើនូវកិច្ចប្រកបដោយធម៌និងអត្ថ ។ ម្យ៉ាងទៀត កិច្ចដែលប្រកបដោយសេចក្តីត្រេកអរ រមែងលិចចុះ បុគ្គលគប្បីវៀរនូវកិច្ចដែលមិនមានប្រយោជន៍ អ្នកប្រាជ្ញ មិនមានសេចក្តីប្រមាទ តែងសម្គាល់នូវកិច្ចនោះថាជាអំពើមិនគួរធ្វើ ។ មួយទៀត កិច្ចណាប្រកបដោយប្រយោជន៍ក្តី សេចក្តីត្រេកអរណាប្រព្រឹត្តទៅក្នុងធម៌ក្តី បុគ្គលគប្បីប្រព្រឹត្តកាន់យកនូវប្រយោជន៍និងសេចក្តីត្រេកអរនោះ ព្រោះថា សេចក្តីត្រេកអរនោះជាគុណជាតិដ៏ឧត្តម ។ បុគ្គលណាសម្លាប់ វាយឬធ្វើឲ្យអ្នកដទៃសោកសៅ ហើយប្លន់ដណ្តើម (យកទ្រព្យ) នៃពួកជនដទៃដោយ ការកំហែង បុគ្គលនោះរមែងនាំទៅនូវទ្រព្យជារបស់ពួកជនដទៃ ដោយឧបាយទាំងតូចទាំងធំបាន ។

ថេរគាថាយ វីសតិនិបាតោ

តច្ឆន្តោ អាណិយា អាណឹ និហន្តិ ពលវា យថា
ឥន្ទ្រិយានិន្ទ្រិយេហេវ និហន្តិ កុសលា តថា ។
សទ្ធំ វីរិយំ សមាធិញ្ច សតិបញ្ញញ្ច ភាវយំ
បញ្ច បញ្ចហិ ហន្ត្វាន អនីឃោ យាតិ ព្រាហ្មណោ ។
សោ អត្ថវា សោ ធម្មដ្ឋោ កត្វា វាក្យានុសាសនី
សព្វេន សព្វំ ពុទ្ធស្ស សោ នរោ សុខមេធតីតិ ។

បារាសរិយោ ថេរោ ។

[២៥១] ចិររត្តំ វតាតាបី ធម្មំ អនុវិចិន្តយំ
សមំ ចិត្តស្ស នាលត្ថំ បុច្ឆំ សមណព្រាហ្មណោ
កោ សោ បារគតោ លោកេ កោ បត្តោ អមតោគធំ
កស្ស ធម្មំ បដិច្ឆាមិ បរមត្ថវិជាននំ ។
អន្តោវង្កគតោ អាសី មច្ឆោវ ឃសមាមិសំ
ពទ្ធោ មហិន្ទបាសេន វេបចិត្យាសុរោ យថា ។

ជនអ្នកមានកម្លាំង កាលចាំងឈើ រមែងនាំចេញនូវដែកគោល ដោយដែកគោល យ៉ាងណាមិញ ពួកជនអ្នកឈ្លាស រមែងរម្ងាប់នូវឥន្ទ្រិយទាំងឡាយ ដោយឥន្ទ្រិយទាំងឡាយ ក៏យ៉ាងនោះដែរ ។ បុគ្គលណាចម្រើននូវសទ្ធា វិរិយៈ សមាធិ សតិ និងបញ្ញា សម្ងាប់នូវឥន្ទ្រិយ ៥ (មានចក្ខុន្ទ្រិយជាដើម) ដោយឥន្ទ្រិយ ៥ បុគ្គលនោះឈ្មោះថាព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ប្រព្រឹត្តទៅ ។ បុគ្គលណាធ្វើតាមពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ដោយសព្វគ្រប់ បុគ្គលនោះឈ្មោះថាជាអ្នកមានប្រយោជន៍ ជាអ្នកតាំងនៅក្នុងធម៌ នរជននោះ តែងដល់នូវសេចក្តីសុខ ។

បារាសរិយត្ថេរ ។

[២៥១] ខ្ញុំមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស កាលគិតរកនូវធម៌អស់កាលមានរាត្រីដ៏យូរណាស់ តែមិនបាននូវការស្ងប់រម្ងាប់នៃចិត្ត ទើបសួរនូវសមណព្រាហ្មណ៍ទាំងឡាយថា បុគ្គលណាសោតដែលបានដល់នូវត្រើយក្នុងលោក អ្នកណាដែលបានដល់នូវព្រះនិព្វានឈ្មោះអមតៈខ្ញុំនឹងប្រតិបត្តិនូវធម៌ ជាគ្រឿងដឹងច្បាស់នូវប្រយោជន៍ដ៏ឧត្តមរបស់សមណព្រាហ្មណ៍ណា ។ ខ្ញុំលុះក្នុងកិលេសជាគ្រឿងវៀចខាងក្នុងដូចត្រីស៊ីនុយ ឬដូចអសុរឈ្មោះវេបចិត្តិ ជាប់ចំណងព្រះឥន្ទ្រ ។

អញ្ចាមិ នំ ន មុញ្ចាមិ អស្មា សោកបរិទ្ទវា
កោ មេ ពន្ធំ មុញ្ចំ លោកេ សម្ពោធឹ វេទយិស្សតិ ។
សមណំ ព្រាហ្មណំ វា កំ អាទិសន្តំ បភង្គុណំ
កស្ស ធម្មំ បដិច្ឆាមិ ជរាមច្ចុបវាហនំ ។
វិចិកិច្ឆាកង្ខាគន្ថិតំ សារម្ភពលសញ្ញុតំ
កោធប្បត្តមនត្ថទ្ធំ អភិជប្បបធារណំ
តណ្ហាធនុសមុដ្ឋានំ ទ្វេ ច បន្នរសាយុតំ
បស្ស ឱរសិកំ ពាលំ ភេត្វាន យទិ(១) តិដ្ឋតិ ។
អនុទិដ្ឋីនំ អប្បហានំ សង្កប្បសរតេជិតំ
តេន វិទ្ធោ បវេធាមិ បត្តំវ មាលុតេរិតំ ។
អជ្ឈត្តំ មេ សមុដ្ឋាយ ខិប្បំ បច្ចតិ មាមកំ(២)
ឆផស្សាយតនី កាយោ តត្ថ សរតិ សព្វទា ។

---

១ ឱ. យទិដ្ឋតិ ។២ ឱ. ម. បច្ចតិ មាមកំ ។

ខ្ញុំទាញដកអន្ទាក់គឺកិលេសនោះ តែមិនរួចចាកសេចក្តីសោកនិងការខ្សឹកខ្សួលនេះទេ អ្នកណាអាចស្រាយនូវចំណងនៃខ្ញុំក្នុងលោក រួចប្រាប់នូវធម៌ជាគ្រឿងត្រាស់ដឹងដល់ខ្ញុំបាន ។ ខ្ញុំ(គប្បីបាន) នូវសមណៈឬព្រាហ្មណ៍ណា ដែលអាចប្រាប់ធម៌ជាគ្រឿងកម្ចាត់បង់កិលេសបាន ខ្ញុំនឹងទទួលនូវធម៌ជាគ្រឿងបន្សាត់បង់ នូវជរានិងមច្ចុ អំពីសំណាក់នៃបុគ្គលណា ។ (សរគឺទិដ្ឋិណា) ដែលមាននិស្ស័យជាប់ក្នុងទ្រូង អាចទម្លាយយ៉ាងខ្លាំង ហើយឋិតនៅក្នុងហឫទ័យ អ្នកចូរមើលនូវសរគឺទិដ្ឋិនោះ ដែលធ្លាក់ចុះក្នុងសេចក្តីសង្ស័យនិងសេចក្តីងឿងឆ្ងល់ ប្រកបដោយកម្លាំងនៃសេចក្តីប្រណាំងប្រជែង មានសេចក្តីរឹងត្អឹងនៃចិត្ត ដែលផ្សំដោយសេចក្តីក្រោធ មានតណ្ហាជាគ្រឿងទម្លាយ កើតព្រមអំពីធ្នូគឺតណ្ហា មានប្រភេទ ១៥ ពីរដង[១] ។ ការដែលមិនបានលះបង់នូវទិដ្ឋិបន្ទាប់បន្សំទាំងឡាយ ត្រូវសរគឺសេចក្តីត្រិះរិះខុសឲ្យក្លាហាន ហើយ អាត្មាអញឈ្មោះថាត្រូវសរគឺទិដ្ឋិនោះមុតហើយ រមែងញាប់ញ័រដូចស្លឹកឈើ ដែលត្រូវខ្យល់បក់ដូច្នោះ ។ កាយប្រកបដោយផស្សាយតនៈ ៦ តាំងឡើងក្នុងសន្តាន របស់អាត្មាអញ ហើយក៏ដុតយ៉ាងឆាប់ នូវអត្តភាព ដែលគេរាប់ថាជារបស់នៃខ្លួន (កាយនោះ) កើតឡើងក្នុងភពណា ក៏ប្រព្រឹត្តទៅក្នុងភពនោះ សព្វកាល ។

១ ប្រភេទ ១៥ ពីរដង គឺសក្កាយទិដ្ឋិ ២០ មិច្ឆាទិដ្ឋិ ១០ (អដ្ឋកថា) ។

៥៣

## ថេរគាថាយ វីសតិនិបាតោ

តំ ន បស្សាមិ តេកិច្ឆំ យោ មេ តំ សល្លមុទ្ធរេ
នានារជ្ជេន សត្ថេន នាញ្ញេន វិចិកិច្ឆិតំ ។
កោ មេ អសត្ថោ អវណោ សល្លមព្ភន្តរបស្សយំ
អហឹសំ សព្វគត្តានិ សល្លំ មេ ឧទ្ធរិស្សតិ ។
ធម្មប្បតិ ហិ សោ សេដ្ឋោ វិសទាសបវាហកោ
គម្ភីរេ បតិតស្ស មេ ថលំ ចាណឹវ ទស្សយេ ។
រហទេហមស្មិ ឱគាឡ្ហោ អហារិយរជមត្តិកេ
មាយាឧស្សុយ្យសារម្ភ- ថីនមិទ្ធមបត្ថដេ ។
ឧទ្ធច្ចមេឃថនិតំ សំយោជនវលាហកំ
វាហា វហន្តិ កុទ្ទិដ្ឋី សង្កប្បា រាគនិស្សិតា ។
សវន្តិ សព្វធី សោតា លតា ឧព្ភិជ្ជ តិដ្ឋតិ
តេ សោតេ កោ និវារេយ្យ តំ លតំ កោ ហិ ឆេច្ឆតិ ។

អាត្មាអញ រកមិនឃើញនូវពេទ្យ ដែលគប្បីដកឡើងនូវសរ គឺសេចក្តីសង្ស័យនោះរបស់អាត្មាអញដោយដង្កាប់សម្រាប់ដកផ្សេង ៗ ឬដោយកាំបិត មិនមែនដោយមន្តដទៃឡើយ ។ បុគ្គលណាហ្ន៎មិនមានកាំបិត (កាត់) នូវសរ មិនឲ្យមានដំបៅដល់អាត្មាអញ មិនបានបៀតបៀននូវខ្លួនទាំងមូល ហើយដកនូវសរគឺកិលេស ដែលអាស្រ័យនូវហឫទ័យរបស់អាត្មាអញបាន ។ ព្រោះថា កាលបើអាត្មាអញធ្លាក់ចុះក្នុងសង្សារដ៏ជ្រៅហើយ (បុគ្គលណា) គប្បីបង្ហាញនូវដៃ ដែលញុំាងអាត្មាអញឲ្យដល់ទីគោក គឺព្រះនិព្វានបាន បុគ្គលនោះឈ្មោះថាជាធំហេតុធម៌ ជាអ្នកប្រសើរ ជាអ្នកបន្សាត់បង់នូវពិស គឺទោសៈ ។ អាត្មាអញជាអ្នកលិចចុះក្នុងអន្លង់គឺសង្សារវដ្ត មានធូលី គឺកិលេសនៅខាងក្នុង ដែលគេមិនអាចនឹងនាំចេញបាន ជាទីផ្សាយទៅដោយមាយា ដោយសេចក្តីច្រណែន ដោយការប្រណាំងប្រជែងនិងថីនមិទ្ធៈ ។ សេចក្តីត្រិះរិះទាំងឡាយ ដែលអាស្រ័យនូវរាគៈ ប្រាកដស្មើដោយទឹកដែលហូរទៅ តែងបន្សាត់ទៅនូវបុគ្គលអ្នកមានទិដ្ឋិអាក្រក់ ដែលមានឧទ្ធច្ចៈជាមេឃគ្រហឹម មានសំយោជនៈជាភ្លៀង ។ ខ្សែតណ្ហា រមែងហូរទៅក្នុងអារម្មណ៍ទាំងពួង តណ្ហាដូចជាវល្លិ៍ រមែងដុះបែកខ្នែង តើបុគ្គលណា ឃាត់នូវខ្សែតណ្ហានោះបាន ចុះបុគ្គលណាកាត់ផ្តាច់ នូវតណ្ហា ដូចជាវល្លិ៍នោះបាន ។

៥៤

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

វេលំ ករោថ ភទ្ទន្តេ សោតានំ សន្និវារណំ
មា តេ មនោមយោ សោតោ រុក្ខំវ សហសា លុវេ ។
ឯវំ មេ ភយជាតស្ស អបារា បារមេសតោ
តាណោ បញ្ញាវុធោ សត្ថា ឥសិសង្ឃនិសេវិតោ
សោបាណំ សុកតំ សុទ្ធំ ធម្មសារមយំ ទឡ្ហំ
បាទាសិ វុយ្ហមានស្ស មា ភាយីតិ ច មព្រវី ។
សតិបដ្ឋានបាសាទំ អារុយ្ហ បច្ចវេក្ខិសំ
យន្តំ បុព្វេ អមញ្ញិស្សំ សក្កាយាភិរតំ បជំ ។
យទា ច មគ្គមទ្ទក្ខឹ នាវាយ អភិរូហនំ
អនធិដ្ឋាយ អត្តានំ តិត្ថមទ្ទក្ខិមុត្តមំ ។
សល្លំ អត្តសមុដ្ឋានំ ភវនេត្តិបភាវិតំ
ឯតេសំ អប្បវត្តាយ ទេសេសិ មគ្គមុត្តមំ ។

បពិត្រអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយចូរធ្វើនូវទំនប់ជាគ្រឿងទប់នូវខ្សែតណ្ហាទាំងឡាយ ខ្សែតណ្ហាដែលសម្រេចអំពីចិត្តកុំគប្បីញុំាងអ្នកឲ្យវិនាសដោយរហ័ស ដូចជាខ្សែទឹក (ច្រោះ) នូវដើមឈើ (ឲ្យរលំ) ដូច្នោះឡើយ ។ កាលអាត្មាអញមានភ័យកើតហើយ កំពុងស្វែងរកត្រើយខាងនាយគឺព្រះនិព្វាន ចាកត្រើយខាងអាយគឺសង្សារវដ្តយ៉ាងនេះ ព្រះសាស្តាមានបញ្ញាជាអាវុធ ជាទីពឹងនៃសត្វលោក ព្រះអង្គត្រូវពួកនៃបុគ្គលអ្នកស្វែងរកនូវគុណ សេពគប់ហើយ ទ្រង់ប្រទាន (ដល់ខ្ញុំ) នូវជណ្តើរគឺវិបស្សនា ដែលទេសនាញាណធ្វើល្អហើយ ជាជណ្តើរដ៏ស្អាត សម្រេចអំពីធម៌មានខ្លឹមដ៏មាំ កាលខ្ញុំកំពុងត្រូវជំនន់ជំគួចទៅ ព្រះអង្គក៏បានត្រាស់ថា អ្នកកុំភ័យឡើយ ។ ខ្ញុំបានឡើងកាន់ប្រាសាទ គឺសតិប្បដ្ឋាន ហើយក្រឡេកមើល ក៏សម្គាល់នូវសត្វ ដែលត្រេកអរក្នុងសក្កាយក្នុងកាលមុន ។ អាត្មាអញបានឃើញនូវផ្លូវគឺវិបស្សនា ជាទីឡើងកាន់ទូក គឺអរិយមគ្គ ក្នុងកាលណា កាលនោះអាត្មាអញមិនបានតាំងចិត្ត ក៏បានឃើញនូវអរិយមគ្គដ៏ឧត្តម ជាកំពង់(នៃនិព្វាន) ។ សរគឺទិដ្ឋិមានះជាដើម ដែលមានខ្លួនជាសមុដ្ឋាន មានតណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពជាដែនកើត ព្រះសាស្តាទ្រង់សម្តែងមគ្គដ៏ឧត្តមដើម្បីមិនឲ្យប្រព្រឹត្តទៅនៃបាបធម៌ទាំងឡាយនុ៎ះ ។

ថេរគាថាយ វីសតិនិបាតោ

ជីយរត្តានុសយិតំ ចិររត្តបតិដ្ឋិតំ

ពុទ្ធោ មេ ចានុជី គណ្ឌំ វិសទោសបវាហនោតិ ។

តេលុកានិ(១) ថេរោ ។

[២៤២] បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ

អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។

បស្ស ចិត្តកតំ រូបំ មណិនា កុណ្ឌលេន ច

អដ្ឋិតចេន ឱនទ្ធំ សហ វត្ថេហិ សោភតិ ។

អល្តត្តកកតា បាទា មុខំ ចុណ្ណកមក្ខិតំ

អលំ ពាលស្ស មោហាយ នោ ច បារគវេសិនោ ។

អដ្ឋាបទកតា កេសា នេត្តា អញ្ជនមក្ខិតា

អលំ ពាលស្ស មោហាយ នោ ច បារគវេសិនោ ។

១ ឱ. ម. តេលកានិ ។

ព្រះពុទ្ធបន្សាត់បង់នូវទោសៈជាពិស ទ្រង់បន្ទោបង់នូវកិលេស ជាគ្រឿងចាក់ស្រេះរបស់អញ ដែលត្រាំនៅក្នុងចិត្ត អស់រាត្រីដ៏វែង ដែលតាំងស៊ប់ហើយក្នុងសន្ដាន អស់កាលដ៏យូរ ។

តេលុកានិត្ថេរ ។

[២៥២] អ្នកចូរមើលនូវអត្តភាព ដែលធ្វើឲ្យវិចិត្រ ជាទីប្រជុំនៃដំបៅដែលតាំងឡើងព្រមហើយ (ដោយឆ្អឹង ៣០០ កំណាត់) ជាអត្តភាពក្តៅក្រហាយ ដែលជនពាលត្រិះរិះដោយច្រើន ជាអត្តភាពមិនទៀងទាត់ឋិតថេរ ។ អ្នកចូរមើលនូវរូបដែលធ្វើឲ្យវិចិត្រដោយកែវមណី និងកណ្ឌល ដែលឆ្អឹងនិងស្បែករួបរឹតហើយ (រូបនោះ) រមែងល្អដោយសារសំពត់ទាំងឡាយ ។ ជើងទាំងឡាយលាបដោយល័ខស្រស់ មុខលាបដោយគ្រឿងលម្អិត អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គលអ្នកស្វែងរកនូវត្រើយគឺព្រះនិព្វានឲ្យវង្វេងបានទេ ។ សក់ទាំងឡាយដែលគេរចនាដូចជាក្រឡាចតុរង្គ ភ្នែកទាំងឡាយលាបដោយថ្នាំសម្រាប់បន្តក់ភ្នែក អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានឡើយ ។ កាយស្អុយដែលគេតាក់តែងហើយ ដូចជានាឡិសម្រាប់ដាក់ថ្នាំបន្តក់ ដែលគេវិចិត្រហើយថ្មី ៗ អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានឡើយ ។

អញ្ជនីវ នវា ចិត្តា បូតិកាយោ អលង្កតោ
អលំ ពាលស្ស មោហាយ នោ ច បារគវេសិនោ ។
ឱទហិ មិគវោ បាសំ នាសទា វាគុរំ មិគោ
ភុត្វា និវាបំ គច្ឆាម កន្ទន្តេ មិគពន្ធកេ ។
ឆិន្នោ បាសោ មិគវស្ស នាសទា វាគុរំ មិគោ
ភុត្វា និវាបំ គច្ឆាម សោចន្តេ មិគលុទ្ទកេ ។

បស្សាមិ លោកេ សធនេ មនុស្សេ
លទ្ធាន វិត្តំ ន ទទន្តិ មោហា ។
លុទ្ធា ធនំ សន្និចយំ ករោន្តិ
ភិយ្យោ ច កាមេ អភិបត្ថយន្តិ ។
រាជា បសយ្ហប្បថវឹ វិជេត្វា
សសាគរន្តំ មហិមាវសន្តោ
ឱរំ សមុទ្ទស្ស អតិត្តរូបោ
បារំ សមុទ្ទស្សបិ បត្ថយេថ ។
រាជា ច អញ្ញេ ច ពហូ មនុស្សា
អវីតតណ្ហា មរណំ ឧបេន្តិ
ឩនាវ ហុត្វាន ជហន្តិ ទេហំ
កាមេហិ លោកម្ហិ ន ហត្ថិ តិត្តិ ។

ព្រានម្រឹគដាក់នូវអន្ទាក់ ម្រឹគក៏មិនបានប៉ះពាល់នូវអន្ទាក់ ហើយស៊ីនូវចំណី កាលដែលព្រានម្រឹគកំពុងកន្ទក់កន្ទេញ (ក៏បោលចេញទៅយ៉ាងណាមិញ) ពួកយើងក៏ដើរចេញទៅ (យ៉ាងនោះដែរ) ។ អន្ទាក់របស់ព្រានម្រឹគដាច់ហើយ ម្រឹគក៏មិនប៉ះពាល់នូវអន្ទាក់ហើយ ស៊ីនូវចំណី កាលព្រានម្រឹគកំពុងសោកស្តាយ (ក៏បោលចេញទៅយ៉ាងណាមិញ) ពួកយើងក៏ដើរចេញទៅ (យ៉ាងនោះដែរ) ។

អាត្មា បានឃើញនូវមនុស្សទាំងឡាយ បរិបូណ៌ដោយទ្រព្យសម្បត្តិក្នុងលោក (ពួកមនុស្សទាំងនោះ) លុះបានទ្រព្យគាប់ចិត្តហើយ មិនឲ្យ (ដល់បុគ្គលណាមួយឡើយ) ព្រោះតែសេចក្តីវង្វេង ។ ពួកមនុស្សបានទ្រព្យហើយ ក៏ធ្វើនូវការសន្សំទុក ទាំងប្រាថ្នាក្នុងកាមដ៏លើសលុប ។ ព្រះរាជាឈ្នះនូវផែនដីដែលព្រះអង្គរឹបជាន់បានហើយ នៅគ្រប់គ្រងផែនដី មានសាគរជាទីបំផុត មានសភាពមិនឆ្អែតនឹងត្រើយសមុទ្រខាងអាយ ក៏ប្រាថ្នានូវត្រើយសមុទ្រខាងនាយ ។ ព្រះរាជាក្តី ពួកមនុស្សដទៃច្រើននាក់ក្តីមិនទាន់ប្រាសចាកតណ្ហា រមែងដល់នូវសេចក្តីស្លាប់ គឺជាជាអ្នកមានសេចក្តីខ្វះខាត លះបង់រាងកាយ ព្រោះថាសេចក្តីឆ្អែតដោយកាមទាំងឡាយក្នុងលោកមិនមាន ។

៤៧



កន្ទន្តិ នំ ញាតិ បកិរិយ កេសេ
អហោ វតា នោ អមរាតិ ចាហុ
វត្ថេន នំ ចារុតំ នីហរិត្វា
ចិត្តំ សមោធាយ តតោ ឌហន្តិ ។
សោ ឌយ្ហតិ សូលេហិ តុជ្ជមានោ
ឯកេន វត្ថេន[១] បហាយ ភោគេ
ន មិយ្យមានស្ស ភវន្តិ តាណា
ញាតី ច មិត្តា អថ វា សហាយា ។
ទាយាទកា តស្ស ធនំ ហរន្តិ
សត្តោ បន គច្ឆតិ យេន កម្មំ
ន មិយ្យមានំ ធនមន្វេតិ កិញ្ចិ
បុត្តា ច ទារា ច ធនញ្ច រដ្ឋំ ។
ន ទីឃមាយុំ លភតេ ធនេន
ន ចាបិ វិត្តេន ជរំ វិហន្តិ
អប្បញ្ហិ នំ ជីវិតមាហុ ធីរា
អសស្សតំ វិបរិណាមធម្មំ ។
អឌ្ឍា ទលិទ្ទា ច ផុសន្តិ ផស្សំ

១ ម. ឯតេន គត្តេន ។

ពួកញាតិ រំសាយសក់កន្ទក់កន្ទេញ ចំពោះបុគ្គលដែលស្លាប់ហើយនោះ ទាំងបាននិយាយថា ធ្វើម្ដេចហ្ន៎ ញាតិរបស់យើងទាំងឡាយ កុំស្លាប់វិញ ក៏នាំខ្មោចនោះ ដែលរុំដោយសំពត់ទៅកាន់ជើងថ្ករ ប្រជុំគ្នាដុតក្នុងទីនោះ ។ បុគ្គលដែលស្លាប់នោះ ត្រូវពួកអ្នកដុតចាក់ដោយឈើសូលដុត បុគ្គលនោះលះបង់នូវភោគៈទាំងឡាយ មានតែសំពត់មួយស្លាប់ទៅ ញាតិទាំងឡាយក្ដី មិត្រទាំងឡាយក្ដី ឬសំឡាញ់ទាំងឡាយក្ដី ជាទីពឹងមិនមានទេ ។ ពួកទាយាទ (អ្នកត្រូវទទួលមត៌ក) រមែងនាំទៅនូវទ្រព្យរបស់សត្វដែលស្លាប់នោះ ចំណែកសត្វដែលស្លាប់នោះ ក៏ទៅតាមយថាកម្ម ទ្រព្យតិចតួច កូនប្រពន្ធមាសប្រាក់ និងដែន ក៏មិនមែនជាប់តាមសត្វដែលស្លាប់នោះទេ ។ បុគ្គលមិនមែនបាននូវអាយុវែង ដោយសារទ្រព្យទេ ទាំងមិនមែនកម្ចាត់នូវជរា ដោយសារទ្រព្យបានទេ ព្រោះថាអ្នកប្រាជ្ញទាំងឡាយបានពោលនូវជីវិតនោះថា តិច មិនទៀងមានការប្រែប្រួលទៅជាធម្មតា ។ ជនទាំងឡាយ អ្នកស្ដុកស្ដម្ភ និងអ្នកទាល់ក្រ រមែងប៉ះពាល់នូវផស្សៈ (មិនជាទីប្រាថ្នា)

ពាលោ ច ធីរោ ច តថេវ ផុដ្ឋោ
ពាលោ ហិ ពាល្យា វធិតោវ សេតិ
ធីរោ ច ន វេធតិ ផស្សផុដ្ឋោ ។
តស្មា ហិ បញ្ញាវ ធនេន សេយ្យោ
យាយ វោសានមិធាធិគច្ឆតិ
អព្យោសិតត្តា ហិ ភវាភវេសុ
បាបានិ កម្មានិ ករោន្តិ មោហា ។
ឧបេតិ គព្ភញ្ច បរញ្ច លោកំ
សំសារមាបជ្ជ បរម្បរាយ
តស្សប្បបញ្ញោ អភិសទ្ទហន្តោ
ឧបេតិ គព្ភញ្ច បរញ្ច លោកំ ។
ចោរោ យថា សន្ធិមុខេ គហីតោ
សកម្មុនា ហញ្ញតិ បាបធម្មោ
ឯវំ បជា បេច្ច បរម្ហិ លោកេ
សកម្មុនា ហញ្ញតិ បាបធម្មោ ។
កាមា ហិ ចិត្រា មធុរា មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ

បុគ្គលពាលនិងអ្នកប្រាជ្ញ រមែងប៉ះពាល់ដូចគ្នា ប៉ុន្តែបុគ្គលពាល បើមានសេចក្តីទុក្ខបៀតបៀនហើយ រមែងដេក (សោកស្តាយ) ព្រោះភាវៈនៃខ្លួនពាល ឯអ្នកប្រាជ្ញ បើទុកជាប៉ះពាល់នូវផស្សៈ ក៏មិនបានញាប់ញ័រ ។ ព្រោះហេតុនោះ បុគ្គលបាននូវព្រះនិព្វាន ជាទីបំផុតនៃភព ក្នុងលោកនេះ ដោយបញ្ញាណា បញ្ញានោះ ជាធម្មជាតិប្រសើរជាងទ្រព្យ ដ្បិតបុគ្គលទាំងឡាយមិនទាន់បាន សម្រេចប្រយោជន៍ រមែងធ្វើនូវបាបកម្មទាំងឡាយ ក្នុងភពតូច និងភពធំ ព្រោះតែមោហៈ ។ បុគ្គលណា (បានធ្វើបាបកម្ម) ក៏ដល់នូវការអន្ទោលទៅមក រមែងចូលទៅកាន់គភ៌និងបរលោក បុគ្គលអ្នកអ័ប្បប្រាជ្ញា (ឯទៀត) កាលបើជឿបុគ្គលអ្នកធ្វើបាបកម្ម នោះ ក៏ទៅកាន់គភ៌និងបរលោក ។ ចោរអ្នកមានធម៌ដ៏លាមក ដែលគេចាប់បានត្រង់មុខតំណ[១] (នៃផ្ទះ) រមែងក្តៅក្រហាយ ដោយកម្មរបស់ខ្លួន យ៉ាងណាមិញ សត្វអ្នកមានធម៌ដ៏លាមក លុះស្លាប់ទៅ រមែងក្តៅក្រហាយ ក្នុងលោកខាងមុខ ដោយកម្ម របស់ខ្លួន ក៏យ៉ាងនោះដែរ ។ កាមទាំងឡាយដ៏វិចិត្រ មានរស ឆ្ងាញ់ ជាទីរីករាយនៃចិត្ត តែងញាំញីចិត្តដោយសភាពផ្សេងៗ

១ គេចាប់បានត្រង់កន្លែងជញ្ជាំងដែលខ្លួនចោះឬកាត់នោះ ។

៤៩

ថេរគាថាយ វីសតិនិបាតោ

អាទីនវំ កាមគុណេសុ ទិស្វា
តស្មា អហំ បព្វជិតោម្ហិ រាជ ។
ទុមប្ផលានីវ បតន្តិ មាណវា
ទហរា ច វុឌ្ឍា ច សរីរភេទា
ឯតម្បិ ទិស្វា បព្វជិតោម្ហិ រាជ
អបណ្ណកំ សាមញ្ញមេវ សេយ្យោ ។

សទ្ធាយាហំ បព្វជិតោ ឧបេតោ ជិនសាសនេ
អវជ្ជា មយ្ហំ បព្វជ្ជា អនណោ ភុញ្ជាមិ ភោជនំ ។
កាមេ អាទិត្តតោ ទិស្វា ជាតរូបានិ សត្ថតោ
គព្ភេ វោក្កន្តិតោ ទុក្ខំ និរយេសុ មហព្ភយំ ។
ឯតមាទីនវំ ទិស្វា សំវេគំ អលភឹ តទា
សោហំ វិទ្ធោ តទា សន្តោ សម្បត្តោ អាសវក្ខយំ ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។

*បពិត្រមហារាជ ហេតុនោះ អាត្មាភាពឃើញទោសក្នុងកាម-*
*គុណទាំងឡាយ ទើបចេញទៅបួស ។ សត្វទាំងឡាយ*
*ទោះក្មេងក្តី ចាស់ក្តី តែងបែកធ្លាយនូវសរីរៈ ដូចជាផ្លែឈើ*
*ជ្រុះ (ចាកដើម) បពិត្រមហារាជ អាត្មាភាពបានឃើញនូវ*
*របស់មិនទៀងនេះឯង បានជាចេញបួស ភាពជាសមណៈ*
*មិនសូវខុសក្នាត់ ជារបស់ប្រសើរលើសលុប ។*

*អាត្មាភាពបួសដោយសទ្ធា បានប្រកបសេចក្តីប្រតិបត្តិ ក្នុងសាសនានៃព្រះជិនស្រី បព្វជ្ជា របស់អាត្មាភាព មិនមានទោស អាត្មាភាពបរិភោគភោជន មិនមានបំណុលទេ ។ អាត្មាភាពឃើញនូវកាមទាំងឡាយ ហាក់ដូចជាភ្លើងឆេះសព្វហើយ ឃើញនូវជាតរូបហាក់ដូចជាគ្រឿងសស្ត្រាវុធ ឃើញហេតុនាំមកនូវទុក្ខ តាំងតែអំពីការចុះចាប់បដិសន្ធិក្នុងគភ៌ ឃើញនូវភ័យធំ ក្នុងនរកទាំងឡាយ ។ អាត្មាភាពឃើញនូវទោសនេះឯង ក៏បាននូវសេចក្តីសំវេគ ក្នុងកាលនោះ អាត្មាភាពហ្នឹងឯង ជាអ្នកត្រូវសរមុតហើយ ក្នុងកាលនោះ (ឥឡូវនេះ) បានដល់ហើយនូវការអស់ទៅនៃអាសវៈ ។ ព្រះសាស្តាអាត្មាភាពបានបម្រើហើយ ព្រះពុទ្ធសាសនា អាត្មាភាពក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ អាត្មាភាពបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព អាត្មាភាព បានដកចោលហើយ ។*

៦០

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

យស្ស ចត្ថាយ បព្វជិតោ អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោតិ ។

រដ្ឋបាលោ ថេរោ ។

[២៤៣] រូបំ ទិស្វា សតិ មុដ្ឋា បិយនិមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ តញ្ច អជ្ឈោស តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា អនេកា រូបសម្ភវា
អភិជ្ឈា ច វិហេសា ច ចិត្តមស្សុបហញ្ញតិ
ឯវមាចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ ។
សទ្ទំ សុត្វា សតិ មុដ្ឋា បិយនិមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ តញ្ច អជ្ឈោស តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា អនេកា សទ្ទសម្ភវា
អភិជ្ឈា ច វិហេសា ច ចិត្តមស្សុបហញ្ញតិ
ឯវមាចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ ។

កុលបុត្របានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំងពួង អាត្មាភាពបានដល់ហើយ ។

រដ្ឋបាលត្ថេរ ។

[២៥៣] បុគ្គលកាលឃើញរូបហើយ ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ ស្មារតី រមែងភ្លាំងភ្លាត់ បុគ្គលនោះរមែងមានចិត្តត្រេកអរ ទទួលយក លេបយកនូវអារម្មណ៍នោះ ។ វេទនាទាំងឡាយជាច្រើន មានរូបជាដែនកើត រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងចង្អៀតចង្អល់ ព្រោះអភិជ្ឈា (ការសម្លឹងរំពៃ)ផង ព្រោះវិហេសា (ការបៀតបៀន)ផង កាលបុគ្គល សន្សំយ៉ាងនេះ ទុក្ខ (រមែងប្រព្រឹត្តទៅ) បុគ្គលនោះ លោកពោលថា ឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាលឮសំឡេងហើយ ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ ស្មារតី រមែងភ្លាំងភ្លាត់ បុគ្គលនោះ រមែងមានចិត្តត្រេកអរ ទទួលយក លេបយកនូវអារម្មណ៍នោះ ។ វេទនាទាំងឡាយជាច្រើន មានសំឡេងជាដែនកើត រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងចង្អៀតចង្អល់ ព្រោះអភិជ្ឈាផង ព្រោះវិហេសាផង បុគ្គលកាលសន្សំយ៉ាងនេះ ទុក្ខ (រមែងប្រព្រឹត្តទៅ) បុគ្គលនោះ លោកពោលថា ឆ្ងាយអំពីព្រះនិព្វាន ។

៦១

ថេរគាថាយ វីសតិនិបាតោ

គន្ធំ ឃត្វា សតិ មុដ្ឋា បិយនិមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ តញ្ច អជ្ឈោស តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា អនេកា គន្ធសម្ភវា
អភិជ្ឈា ច វិហេសា ច ចិត្តមស្សូបហញ្ញតិ
ឯវមាចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ ។
រសំ ភោត្វា សតិ មុដ្ឋា បិយនិមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ តញ្ច អជ្ឈោស តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា អនេកា រសសម្ភវា
អភិជ្ឈា ច វិហេសា ច ចិត្តមស្សូបហញ្ញតិ
ឯវមាចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ ។
ផស្សំ ផុស្ស សតិ មុដ្ឋា បិយនិមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ តញ្ច អជ្ឈោស តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា អនេកា ផស្សសម្ភវា
អភិជ្ឈា ច វិហេសា ច ចិត្តមស្សូបហញ្ញតិ
ឯវមាចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ ។

បុគ្គលកាលធុំក្លិនហើយ ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ ស្មារតី រមែងភ្លាំងភ្លាត់ បុគ្គលនោះ រមែងមានចិត្តត្រេកអរ ទទួលយក លេបយកនូវអារម្មណ៍នោះ ។ វេទនាទាំងឡាយជាច្រើន មានក្លិន ជាដែនកើត រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងចង្អៀតចង្អល់ ព្រោះអភិជ្ឈាផង ព្រោះវិហេសាផង បុគ្គល កាលសន្សំយ៉ាងនេះ ទុក្ខ (រមែងប្រព្រឹត្តទៅ) បុគ្គលនោះ លោក ពោលថា ឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាលបរិភោគរសហើយ ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ ស្មារតី រមែងភ្លាំងភ្លាត់ បុគ្គល នោះ រមែងមានចិត្តត្រេកអរ ទទួលយក និងលេបយកនូវអារម្មណ៍ នោះ ។ វេទនាទាំងឡាយជាច្រើន មានរសជាដែនកើត រមែង ចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងចង្អៀតចង្អល់ ព្រោះអភិជ្ឈាផង ព្រោះវិហេសាផង បុគ្គលកាលសន្សំយ៉ាងនេះ ទុក្ខ (រមែងប្រព្រឹត្តទៅ) បុគ្គលនោះលោកពោលថា ឆ្ងាយអំពីព្រះនិ-ព្វាន ។ បុគ្គលកាលប៉ះនូវផស្សៈហើយ ធ្វើទុកក្នុងចិត្តនូវនិមិត្តជា ទីស្រឡាញ់ ស្មារតីរមែងភ្លាំងភ្លាត់ បុគ្គលនោះ រមែងមានចិត្តត្រេក-អរទទួលយក លេបយកនូវអារម្មណ៍នោះ ។ វេទនាទាំងឡាយជា ច្រើន មានផស្សៈជាដែនកើត រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់ បុគ្គលនោះរមែងចង្អៀតចង្អល់ ព្រោះអភិជ្ឈាផង ព្រោះវិហេសាផង

ធម្មំ ញត្វា សតិ មុដ្ឋា បិយនិមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ តញ្ច អជ្ឈោស តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា អនេកា ធម្មសម្ភវា
អភិជ្ឈា ច វិហេសា ច ចិត្តមស្សូបហញ្ញតិ
ឯវមាចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ រូបេសុ រូបំ ទិស្វា បតិស្សតោ
វិរត្តចិត្តោ វេទេតិ តញ្ច នាជ្ឈោស[១] តិដ្ឋតិ ។
យថាស្ស បស្សតោ រូបំ សេវតោ ចាបិ វេទនំ
ខិយ្យតិ នោបចិយ្យតិ ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ សទ្ទេសុ សទ្ទំ សុត្វា បតិស្សតោ
វិរត្តចិត្តោ វេទេតិ តញ្ច នាជ្ឈោស តិដ្ឋតិ ។

---
១ ឱ. ម. នជ្ឈោស ។

បុគ្គលកាលសន្សំយ៉ាងនេះ ទុក្ខ(រមែងប្រព្រឹត្តទៅ) បុគ្គលនោះលោកពោលថាឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាលដឹងនូវធម្មារម្មណ៍ហើយ[១] ធ្វើទុកក្នុងចិត្តនូវនិមិត្តជាទីស្រឡាញ់ ស្មារតីរមែងភ្លាំងភ្លាត់ បុគ្គលនោះ រមែងមានចិត្តត្រេកអរទទួលយក លេបយកអារម្មណ៍នោះ ។ វេទនាទាំងឡាយជាច្រើន មានធម្មារម្មណ៍ជាដែនកើត រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងចង្អៀតចង្អល់ ព្រោះអភិជ្ឈាផង ព្រោះវិហេសាផង បុគ្គលកាលសន្សំយ៉ាងនេះ ទុក្ខ(រមែងប្រព្រឹត្តទៅ) បុគ្គលនោះលោកពោលថា ឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលនោះឃើញរូបហើយ មានស្មារតីខ្ជាប់ខ្ជួន មិនត្រេកអរក្នុងរូបទាំងឡាយ រមែងមានចិត្តប្រាសចាកតម្រេក គ្រាន់តែទទួលដឹងតែមិនលេបយកនូវអារម្មណ៍នោះ ។ បុគ្គលនោះកាលឃើញរូបទទួលវេទនា (កិលេសវដ្ដ:) រមែងអស់ទៅ មិនចម្រើនឡើងដោយប្រការណា បុគ្គលនោះ ជាអ្នកមានស្មារតី ប្រព្រឹត្តទៅដោយប្រការនោះ បុគ្គលកាលមិនសន្សំយ៉ាងនេះ ទុក្ខ(រមែងមិនប្រព្រឹត្តទៅ)បុគ្គលនោះលោកពោលថា ជិតព្រះនិព្វាន ។ បុគ្គលនោះ ឮសំឡេង មានស្មារតីខ្ជាប់ខ្ជួន រមែងមិនត្រេកអរ ក្នុងសំឡេងទាំងឡាយ រមែងមានចិត្តប្រាសចាកតម្រេក គ្រាន់តែទទួលដឹង មិនលេបយកនូវអារម្មណ៍នោះ ។

១ ពាក្យថាធម៌ក្នុងទីនេះ សំដៅយកចិត្តដែលប្រកបដោយតម្រេក ។ អដ្ឋកថា ។

៦៣

## ថេរគាថាយ វីសតិនិបាតោ

យថាស្ស សុណតោ សទ្ទំ  សេវតោ វាបិ វេទនំ
ខិយ្យតិ នោបចិយ្យតិ  ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ  សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ គន្ធេសុ  គន្ធំ ឃត្វា បតិស្សតោ
វិរត្តចិត្តោ វេទេតិ  តញ្ច នាជ្ឈោស តិដ្ឋតិ ។
យថាស្ស ឃាយតោ គន្ធំ  សេវតោ វាបិ វេទនំ
ខិយ្យតិ នោបចិយ្យតិ  ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ  សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ រសេសុ  រសំ ភោត្វា បតិស្សតោ
វិរត្តចិត្តោ វេទេតិ  តញ្ច នាជ្ឈោស តិដ្ឋតិ ។
យថាស្ស សាយតោ រសំ  សេវតោ វាបិ វេទនំ
ខិយ្យតិ នោបចិយ្យតិ  ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ  សន្តិកេ និព្វាន វុច្ចតិ ។

បុគ្គលនោះ កាលឮនូវសំឡេង ទទួលវេទនា (កិលេសវដ្ដៈ) រមែងអស់ទៅ មិនចម្រើនឡើង ដោយប្រការណា បុគ្គលនោះ ជាអ្នកមានស្មារតីប្រព្រឹត្តដោយប្រការៈនោះ បុគ្គលកាលមិនសន្សំយ៉ាងនេះ ទុក្ខ (រមែងមិនប្រព្រឹត្តទៅ) បុគ្គលនោះលោកពោលថា ជិតព្រះនិព្វាន ។ បុគ្គលធុំក្លិនហើយ មានស្មារតីខ្ជាប់ខ្ជួន មិនត្រេកអរ ក្នុងក្លិនទាំងឡាយ រមែងមានចិត្តប្រាសចាកតម្រេក គ្រាន់តែទទួលដឹង តែមិនលេបយកនូវអារម្មណ៍នោះ ។ បុគ្គលនោះ កាលធុំក្លិន ទទួលវេទនា (កិលេសវដ្ដៈ) រមែងអស់ទៅ មិនចម្រើនឡើង ដោយប្រការៈណា បុគ្គលនោះ ជាអ្នកមានស្មារតី ប្រព្រឹត្តដោយប្រការៈនោះ បុគ្គលកាលមិនសន្សំយ៉ាងនេះ ទុក្ខ (រមែងមិនប្រព្រឹត្តទៅ) បុគ្គលនោះ លោកពោលថា ជិតព្រះនិព្វាន ។ បុគ្គលនោះ បរិភោគ នូវរសហើយ មានស្មារតីខ្ជាប់ខ្ជួន មិនត្រេកអរក្នុងរសទាំងឡាយ រមែងមានចិត្តប្រាសចាកតម្រេក គ្រាន់តែទទួលដឹង តែមិនលេបយក នូវអារម្មណ៍នោះ ។ បុគ្គលនោះ កាលភ្លក្សនូវរស ទទួលវេទនា (កិលេសវដ្ដៈ) រមែងអស់ទៅ មិនចម្រើនឡើង ដោយប្រការៈណា បុគ្គលនោះ ជាអ្នកមានស្មារតី ប្រព្រឹត្តទៅដោយប្រការៈនោះ បុគ្គលកាលមិនសន្សំយ៉ាងនេះ ទុក្ខ (រមែងមិនប្រព្រឹត្តទៅ) បុគ្គលនោះ លោកពោលថា ជិតព្រះនិព្វាន ។

ន សោ រជ្ជតិ ផស្សេសុ ផស្សំ ផុស្ស បតិស្សតោ
វិរត្តចិត្តោ វេទេតិ តញ្ច នាជ្ឈោស តិដ្ឋតិ ។
យថាស្ស ផុសតោ ផស្សំ សេវតោ វាបិ វេទនំ
ខិយ្យតិ នោបចិយ្យតិ ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ ធម្មេសុ ធម្មំ ញត្វា បតិស្សតោ
វិរត្តចិត្តោ វេទេតិ តញ្ច នាជ្ឈោស តិដ្ឋតិ ។
យថាស្ស វិជានតោ ធម្មំ សេវតោ វាបិ វេទនំ
ខិយ្យតិ នោបចិយ្យតិ ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ សន្តិកេ និព្វាន វុច្ចតិ ។

មាលុង្ក្យបុត្តោ ថេរោ ។

[២៩៤] បរិបុណ្ណកាយោ សុរុចិ សុជាតោ ចារុទស្សនោ
សុវណ្ណវណ្ណោសិ ភគវា សុសុក្កទាឋោសិ វីរិយវា ។

១ ម. បរិបុណ្ណការោ ។

បុគ្គលនោះ ប៉ះពាល់នូវផស្សៈហើយ មានស្មារតីខ្ជាប់ខ្ជួនមិនត្រេកអរ ក្នុងផស្សៈទាំងឡាយ រមែងមានចិត្តប្រាសចាកតម្រេក គ្រាន់តែទទួលដឹង តែមិនលេបយកនូវអារម្មណ៍នោះ ។ បុគ្គលនោះកាលប៉ះពាល់នូវផស្សៈ ទទួលវេទនា (កិលេសវដ្ដៈ) រមែងអស់ទៅ មិនចម្រើនឡើង ដោយប្រការៈណា បុគ្គលនោះ ជាអ្នកមានស្មារតី ប្រព្រឹត្តដោយប្រការៈនោះ បុគ្គលកាលមិនសន្សំយ៉ាងនេះ ទុក្ខ (រមែងមិនប្រព្រឹត្តទៅ) បុគ្គលនោះលោកពោលថា ជិតព្រះនិព្វាន ។ បុគ្គលនោះ ដឹងនូវធម្មារម្មណ៍ មានស្មារតីខ្ជាប់ខ្ជួន មិនត្រេកអរក្នុងធម្មារម្មណ៍ទាំងឡាយ រមែងមានចិត្តប្រាសចាកតម្រេក គ្រាន់តែទទួលដឹង តែមិនលេបយកនូវអារម្មណ៍នោះ ។ បុគ្គលនោះកាលដឹងច្បាស់នូវធម្មារម្មណ៍ ទទួលវេទនា (កិលេសវដ្ដៈ) រមែងអស់ទៅ មិនចម្រើនឡើង ដោយប្រការៈណា បុគ្គលនោះជាអ្នកមានស្មារតី ប្រព្រឹត្តទៅដោយប្រការៈនោះ បុគ្គលកាលមិនសន្សំយ៉ាងនេះ ទុក្ខ (រមែងមិនប្រព្រឹត្តទៅ) បុគ្គលនោះលោកពោលថាជិតព្រះនិព្វាន ។

មាលុង្ក្យបុត្តត្ថេរ ។

[២៥៤] បពិត្រព្រះមានព្រះភាគ ព្រះអង្គមានព្រះកាយដ៏បរិបូណ៌ ជាទីគាប់ចិត្តក្រៃលែង មានព្រះជាតិដ៏ល្អ មានព្រះនេត្រដ៏ល្អ មានសម្បុរដូចជាសម្បុរនៃមាស មានព្រះទាឋាដ៏សក្បុស ទ្រង់មានព្យាយាម ។

ថេរគាថាយ វីសតិនិបាតោ

នរស្ស ហិ សុជាតស្ស    យេ ភវន្តិ វិយញ្ជនា

សព្វេ តេ តវ កាយស្មឹ    មហាបុរិសលក្ខណា ។

បសន្ននេត្តោ សុមុខោ    ព្រហា[១] ឧជុ បតាបវា[២]

មជ្ឈេ សមណសង្ឃស្ស    អាទិច្ចោវ វិរោចសិ ។

កល្យាណទស្សនោ ភិក្ខុ    កញ្ចនសន្និភត្តចោ

កឹ តេ សមណភាវេន    ឯវំ ឧត្តមវណ្ណិនោ ។

រាជា អរហសិ ភវិតុំ    ចក្កវត្តិ រថេសភោ

ចាតុរន្តោ វិជិតាវី    ជម្ពុសណ្ឌស្ស ឥស្សរោ ។

ខត្តិយា ភោជរាជានោ    អនុយន្តា ភវន្តិ តេ

រាជាភិរាជា មនុជិន្ទោ    រជ្ជំ ការេហិ គោតម ។

រាជាហមស្មិ សេលាតិ    (ភគវា) ធម្មរាជា អនុត្តរោ

ធម្មេន ចក្កំ វត្តេមិ    ចក្កំ អប្បដិវត្តិយំ ។

សម្ពុទ្ធោ បដិជានាសិ    (ឥតិ សេលោ ព្រាហ្មណោ)

ធម្មរាជា អនុត្តរោ

ធម្មេន ចក្កំ វត្តេមិ    ឥតិ ភាសសិ គោតម ។

---

១ ម. ព្រហ្មា ។ ២ បភាបវា ។

ព្យញ្ជនៈណា របស់ជនមានជាតិល្អ ព្យញ្ជនៈ (និងអនុព្យញ្ជនៈ)ទាំងអស់នោះ ជាមហាបុរិសលក្ខណៈ មានក្នុងព្រះកាយ របស់ព្រះអង្គ ។ ព្រះអង្គមានព្រះនេត្រថ្លា មានព្រះភក្ត្រល្អ មានទំហំនិងកម្ពស់សមសួន មានព្រះកាយត្រង់ មានរស្មីរុងរឿង ក្នុងកណ្តាលនៃពួកសមណៈ ដូចព្រះអាទិត្យ ។ បពិត្រភិក្ខុ ព្រះអង្គមានរូបល្អគួរជាទីរមិលមើល មានស្បែកដ៏ភ្លឺថ្លាដូចមាស ព្រះអង្គមានសម្បុរដ៏ឧត្តមយ៉ាងនេះ តើមានប្រយោជន៍អ្វីដោយសមណភាព ។ ព្រះអង្គគួរបានជាស្តេចចក្រពត្តិ ដូចគោឧសភក្នុងរថ ជាធំ (លើផែនដី) មានសមុទ្រទាំងបួនជាទីបំផុត មានជ័យជម្នះ ជាឥស្សរៈរបស់អ្នកជម្ពូទ្វីប ។ បពិត្រព្រះគោតម ពួកក្សត្រិយ៍ជាស្តេចចំណុះតែងចុះចូលនឹងព្រះអង្គ សូមព្រះអង្គសោយរាជ្យ ជារាជាធិរាជដ៏ធំជាងពួកមនុស្សចុះ ។

(ព្រះមានព្រះភាគត្រាស់ថា) ម្នាលសេលៈ តថាគត ជាធម្មរាជជាស្តេចប្រសើរ អាចញ៉ាំងចក្រឲ្យប្រព្រឹត្តទៅតាមធម៌ ជាចក្រដែលអ្នកណាមួយមិនអាចឲ្យប្រព្រឹត្តទៅបាន ។

(សេលព្រាហ្មណ៍ក្រាបទូលថា) បពិត្រព្រះគោតម ព្រះអង្គទ្រង់ប្តេជ្ញាថា ព្រះអង្គជាអ្នកត្រាស់ដឹង ទ្រង់ត្រាស់ថា តថាគតជាធម្មរាជជាស្តេច ប្រសើរ អាចញ៉ាំងចក្រឲ្យប្រព្រឹត្តទៅតាមធម៌បាន ។

៦៦



កោ នុ សេនាបតិ ភោតោ    សាវកោ សត្ថុរន្វយោ
កោ ឥមំ អនុវត្តេតិ    ធម្មចក្កំ បវត្តិតំ ។
មយា បវត្តិតំ ចក្កំ(សេលាតិ ភគវា) ធម្មចក្កមនុត្តរំ
សារីបុត្តោនុវត្តេតិ    អនុជាតោ តថាគតំ ។
អភិញ្ញេយ្យំ អភិញ្ញាតំ    ភាវេតព្វញ្ច ភាវិតំ
បហាតព្វំ បហីនំ មេ    តស្មា ពុទ្ធោស្មិ ព្រាហ្មណ ។
វិនយស្សុ មយិ កង្ខំ    អធិមុច្ចស្សុ ព្រាហ្មណ
ទុល្លភំ ទស្សនំ ហោតិ    សម្ពុទ្ធានំ អភិណ្ហសោ ។
យេសំ វេ ទុល្លភោ លោកេ បាតុភាវោ អភិណ្ហសោ
សោហំ ព្រាហ្មណ ពុទ្ធោស្មិ    សល្លកត្តោ អនុត្តរោ
ព្រហ្មភូតោ អតិតុលោ    មារសេនប្បមទ្ទនោ
សព្វាមិត្តេ វសីកត្វា    មោទាមិ អកុតោ ភយោ ។

ចុះភិក្ខុណា ជាសេនាបតីរបស់ព្រះអង្គ ជាសាវ័កប្រព្រឹត្តតាមព្រះសាស្តា ភិក្ខុណា ញ៉ាំងធម្មចក្កនេះ ដែលព្រះអង្គឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅបាន ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសេលៈ) ភិក្ខុសារីបុត្ត ជាអនុជាត របស់តថាគត ញ៉ាំងធម្មចក្កដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅបាន ។ ម្នាលព្រាហ្មណ៍ ទុក្ខសច្ចដែលគួរដឹងច្បាស់ តថាគតបានដឹងច្បាស់ហើយ មគ្គសច្ចដែលគួរចម្រើន តថាគតបានចម្រើនហើយ សមុទយសច្ច ដែលគួរលះ តថាគតក៏បានលះហើយ ព្រោះហេតុនោះ ទើបតថាគតជាព្រះពុទ្ធ ។ ម្នាលព្រាហ្មណ៍ អ្នកចូរកម្ចាត់បង់នូវសេចក្តីសង្ស័យក្នុងតថាគតចេញ អ្នកចូរជឿស៊ប់ចុះ (ព្រោះថា) ការចួបប្រទះនឹងព្រះសម្មាសម្ពុទ្ធទាំងឡាយរឿយៗ ជាការរកបានក្រ ។ ម្នាល-ព្រាហ្មណ៍ ការកើតប្រាកដឡើងរឿយៗ នៃព្រះសម្មាសម្ពុទ្ធណា ដែលរកបានដោយក្រក្នុងលោក តថាគតនោះ ជាព្រះពុទ្ធ ដូចពេទ្យវិះជាបុគ្គលប្រសើរបំផុត មានសភាពដូចព្រហ្ម មានតម្លៃដ៏លើសលុប ជាអ្នកញាំញីនូវមារនិងសេនានៃមារ ធ្វើនូវបច្ចាមិត្តទាំងអស់ឲ្យនៅក្នុងអំណាច ហើយរីករាយ ឥតមានភ័យអំពីទីណាឡើយ ។

## ៦៧

### ថេរគាថាយ វីសតិនិបាតោ

ឥទំ ភោន្តោ និសាមេថ    យថា ភាសតិ ចក្ខុមា
សល្លកត្តោ មហាវីរោ    សីហោវ នទតី វនេ ។

ព្រហ្មភូតំ អតិតុលំ    មារសេនប្បមទ្ទនំ
កោ ទិស្វា នប្បសីទេយ្យ    អបិ កណ្ហាភិជាតិកោ ។

យោ មំ ឥច្ឆតិ អន្វេតុ    យោ វា និច្ឆតិ គច្ឆតុ
ឥធាហំ បព្វជិស្សាមិ    វរបញ្ញស្ស សន្តិកេ ។

ឯតញ្ចេ រុចតី ភោតោ    សម្មាសម្ពុទ្ធសាសនំ
មយម្បិ បព្វជិស្សាម    វរបញ្ញស្ស សន្តិកេ ។

ព្រាហ្មណា តិសតា ឥមេ    យាចន្តិ បញ្ជលីកតា
ព្រហ្មចរិយំ ចរិស្សាម    ភគវា តវ សន្តិកេ ។

ស្វាក្ខាតំ ព្រហ្មចរិយំ    (សេលាតិ ភគវា)
សន្ទិដ្ឋិកមកាលិកំ
យត្ថ អមោឃា បព្វជ្ជា    អប្បមត្តស្ស សិក្ខតោ ។

(សេលព្រាហ្មណ៍ពោលថា) ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយ ចូរផ្ទៀងស្តាប់នូវពាក្យតាមដែលព្រះមានព្រះភាគព្រះអង្គមានចក្ខុ សម្តែងនេះចុះ ដ្បិតព្រះមានព្រះភាគដូចជាពេទ្យវះ ជាមហាវីរបុរស បន្លឺសីហនាទដូចជាសត្វសីហៈក្នុងព្រៃ ។ តោះបីនរណាជាកណ្ហាភិជាតិ (អ្នកមានជាតិខ្មៅ) បានឃើញព្រះមានព្រះភាគព្រះអង្គមានសភាពដូចជាព្រហ្ម មានតម្លៃដ៏លើសលុប ទ្រង់ញាំញីនូវមារនិងសេនានៃមារហើយ តើនឹងមិនជ្រះថ្លាដូចម្តេចបាន ។ បុគ្គលណាចង់មក ចូរតាមយើងមក បុគ្គលណាមិនចង់ទេ ចូរទៅវិញចុះ ខ្ញុំនឹងបួសក្នុងសំណាក់ព្រះពុទ្ធព្រះអង្គមានប្រាជ្ញាដ៏ប្រសើរក្នុងទីនេះ ។

(ពួកមាណពនោះពោលថា) បើលោកពេញចិត្តនឹងសាសនាព្រះសម្មាសម្ពុទ្ធនុ៎ះ ពួកយើងក៏នឹងបួសក្នុងសំណាក់ព្រះពុទ្ធ មានប្រាជ្ញាដ៏ប្រសើរដែរ ។ ពួកព្រាហ្មណ៍ទាំង ៣០០ នេះ ក៏ផ្គងអញ្ជលីសុំផ្នួសថា បពិត្រព្រះមានព្រះភាគ ពួកយើង សូមប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះអង្គ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសេលៈ ព្រហ្មចរិយធម៌តថាគតសម្តែងទុកប្រពៃហើយ ជាធម៌ដែលគួរឃើញជាក់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល បព្វជ្ជារបស់បុគ្គលអ្នកមិនប្រមាទជាអ្នកសិក្សា ក្នុងព្រហ្មចរិយធម៌នោះ មិនឥតអំពើឡើយ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

យន្តំ សរណមាគម្ម ឥតោ អដ្ឋមិ ចក្ខុម
សត្តរត្តេន ភគវា ទន្តម្ហា តវ សាសនេ ។
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆេត្វា តិណ្ណោ តារេសិ មំ បជំ ។
ឧបធី តេ សមតិក្កន្តា សាសវា តេ បទាលិតា
សីហោវ អនុបាទានោ បហីនភយភេរវោ ។
ភិក្ខវោ តិសតា ឥមេ តិដ្ឋន្តិ បញ្ជលីកតា
បាទេ វីរ បសារេហិ នាគា វន្ទន្តុ សត្ថុនោតិ ។

សោណោ ថេរោ ។

[២៤៤] យាតំ មេ ហត្ថិគីវាយ សុខុមា វត្ថា បធារិតា
សាលីនំ ឱទនោ ភុត្តោ សុចិមំសូបសេចនោ ។
សោជ្ជ ភទ្ទោ សាតតិកោ ឧញ្ឆាបត្តាគតេ រតោ
ឈាយតិ អនុបាទានោ បុត្តោ គោធាយ ភទ្ទិយោ ។

(សេលព្រាហ្មណ៍ក្រាបទូលថា) បពិត្រព្រះមានព្រះភាគ មានចក្ខុ ពួកខ្ញុំព្រះអង្គ បានដល់នូវទីពឹងណា ក្នុងថ្ងៃទី ៨ អំពីថ្ងៃនេះទៅ (ពួកខ្ញុំព្រះអង្គ) ជាបុគ្គលបានទូន្មានខ្លួន ក្នុងសាសនារបស់ព្រះអង្គ ដោយទីពឹងនោះ អស់ ៧ រាត្រី ។ ព្រះអង្គជាព្រះពុទ្ធ ព្រះអង្គជាសាស្តា ព្រះអង្គជាមុនី គ្របសង្កត់នូវមារ ព្រះអង្គបានកាត់បង់នូវអនុស័យ ឆ្លងរួចហើយទើបចម្លងពពួកសត្វនេះ ។ ព្រះអង្គបានកន្លងនូវឧបធិទាំងឡាយហើយ ព្រះអង្គបានទម្លាយនូវកិលេសព្រមទាំងអាសវៈហើយ ព្រះអង្គជាបុគ្គលមិនមានសេចក្តីប្រកាន់ បានលះបង់នូវភ័យដ៏ពន្លឹក ដូចជាសត្វសីហៈ ។ ពួកភិក្ខុទាំង ៣០០ នេះ ឈរផ្គងអញ្ជលីថា បពិត្រព្រះវីរបុរស សូមព្រះអង្គលាតនូវព្រះបាទទាំងឡាយ ពួកភិក្ខុជានាគ សូមថ្វាយបង្គំនូវព្រះបាទនៃព្រះសាស្តា ។

សេលត្ថេរ ។

[២៥៥] ខ្ញុំព្រះអង្គយាត្រាដោយ-កដំរី ធ្លាប់ស្លៀកដណ្តប់សំពត់សាច់ម៉ដ្ឋ បរិភោគបាយអង្ករនៃស្រូវសាលី លាយដោយសាច់ដ៏ស្អាត ។ ថ្ងៃនេះព្រះភទ្ទិយៈជាបុត្រនៃសាក្យានីឈ្មោះគោធានោះ ជាអ្នកចម្រើនដោយគុណ ព្យាយាមជាប់មិនដាច់ ត្រេកអរចំពោះអាហារដែលមកដល់បាត្រដោយការស្វែងរក មិនមានសេចក្តីប្រកាន់ ចម្រើនឈាន ។

៦៩

ថេរគាថាយ វីសតិនិបាតោ

បំសុកូលី សាតតិកោ ឧញ្ឆាបត្តាគតេ រតោ
ឈាយតិ អនុថាជាជោ បុត្តោ គោជាយ ភទ្ទិយោ ។
បិណ្ឌចាតី សាតតិកោ ............................
តេចីវរី សាតតិកោ ............................
សបទានចារី សាតតិកោ ............................
ឯកាសនី សាតតិកោ ............................
បត្តបិណ្ឌី សាតតិកោ ............................
ខលុបច្ឆាភត្តី សាតតិកោ ............................
អារញ្ញិកោ សាតតិកោ ............................
រុក្ខមូលិកោ សាតតិកោ ............................
អព្ភោកាសី សាតតិកោ ............................
សោសានិកោ សាតតិកោ ............................
យថាសន្ថតិកោ សាតតិកោ ........................
នេសជ្ជិកោ សាតតិកោ ............................
អប្បិច្ឆោ សាតតិកោ ............................
សន្តុដ្ឋោ សាតតិកោ ............................
បវិវិត្តោ សាតតិកោ ............................
អសំសដ្ឋោ សាតតិកោ ............................

ថេរគាថា វីសតិនិបាត

ព្រះកទ្ទិយៈ ជាបុត្រនៃសាក្យានីឈ្មោះគោធា ជាអ្នកសមាទានបំសុកូ-លិកង្គធុតង្គ ព្យាយាមជាប់មិនដាច់ ត្រេកអរចំពោះអាហារដែលមកដល់បាត្រដោយការស្វែងរក មិនមានសេចក្តីប្រកាន់ ចម្រើនឈាន ។
ជាអ្នកសមាទាន បិណ្ឌបាតិកង្គធុតង្គ ព្យាយាមជាប់មិនដាច់.............
ជាអ្នកសមាទាន តេចីវរិកង្គធុតង្គ ព្យាយាមជាប់មិនដាច់...................
ជាអ្នកសមាទាន សបទានចារិកង្គធុតង្គ ព្យាយាមជាប់មិនដាច់..........
ជាអ្នកសមាទាន ឯកាសនិកង្គធុតង្គ ព្យាយាមជាប់មិនដាច់...............
ជាអ្នកសមាទាន បត្តបិណ្ឌិកង្គធុតង្គ ព្យាយាមជាប់មិនដាច់...............
ជាអ្នកសមាទាន ខលុបច្ឆាភត្តិកង្គធុតង្គ ព្យាយាមជាប់មិនដាច់ ..........
ជាអ្នកសមាទាន អារញ្ញិកង្គធុតង្គ ព្យាយាមជាប់មិនដាច់...................
ជាអ្នកសមាទាន រុក្ខមូលិកង្គធុតង្គ ព្យាយាមជាប់មិនដាច់..................
ជាអ្នកសមាទាន អព្ភោកាសិកង្គធុតង្គ ព្យាយាមជាប់មិនដាច់............
ជាអ្នកសមាទាន សោសានិកង្គធុតង្គ ព្យាយាមជាប់មិនដាច់..............
ជាអ្នកសមាទាន យថាសន្ថតិកង្គធុតង្គ ព្យាយាមជាប់មិនដាច់...........
ជាអ្នកសមាទាន នេសជ្ជិកង្គធុតង្គ ព្យាយាមជាប់មិនដាច់..................
ជាអ្នកប្រាថ្នាតិច ព្យាយាមជាប់មិនដាច់...........................................
ជាអ្នកសន្តោស ព្យាយាមជាប់មិនដាច់ ...........................................
ជាអ្នកស្ងាត់ ព្យាយាមជាប់មិនដាច់.................................................
ជាអ្នកមិនច្រឡំ (ដោយពួក) ព្យាយាមជាប់មិនដាច់......................

៧០

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

អារទ្ធវីរិយោ សាតតិកោ ឧញ្ឆាបត្តាគតេ រតោ
ឈាយតិ អនុបាទានោ បុត្តោ គោធាយ ភទ្ទិយោ ។
ហិត្វា សតបលំ កំសំ សោវណ្ណំ សតរាជិកំ
អគ្គហឹ មត្តិកាបត្តំ ឥទំ ទុតិយាភិសេចនំ ។
ឧច្ចេ មណ្ឌលិបាការេ ទឡ្ហមដ្ដាលកោដ្ឋកេ
រក្ខិតោ ខគ្គហត្ថេហិ ឧត្តសំ វិហរឹ បុរេ ។
សោជ្ជ ភទ្ទោ អនុត្រាសី បហីនភយភេរវោ
ឈាយតិ វនមោគយ្ហ បុត្តោ គោធាយ ភទ្ទិយោ ។
សីលក្ខន្ធេ បតិដ្ឋាយ សតឹ បញ្ញញ្ច ភាវយំ
បាបុណឹ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។

ភទ្ទិយោ កាឡិគោធាយ បុត្តោ ថេរោ ។

[២៨៦] គច្ឆំ វទេសិ សមណ ឋិតោម្ហិ
មមញ្ច ព្រូសិ ឋិតមដ្ឋិតោតិ
បុច្ឆាមិ តំ សមណ ឯតមត្ថំ
កស្មា ឋិតោ ត្វំ អហមដ្ឋិតោម្ហិ ។

ព្រះភទ្ទិយៈជាបុត្រនៃសាក្យានីឈ្មោះគោធា ព្យាយាមជាប់មិនដាច់ ជាអ្នកមានព្យាយាមមុតមាំ ព្យាយាមជាប់មិនដាច់ ត្រេកអរចំពោះបិណ្ឌបាតដែលមកដល់បាត្រ ដោយការស្វែងរក មិនមានសេចក្តីប្រកាន់ ចម្រើនឈាន ។ ខ្ញុំព្រះអង្គលះបង់នូវភាជន៍ មានទម្ងន់ជាច្រើនបលៈ ជាវិការៈនៃមាស មានក្បាច់ដ៏ច្រើនស្រទាប់ ហើយកាន់យកនូវបាត្រដីនេះ ចាត់ជាការអភិសេកទី ២ ។ ក្នុងកាលមុន ខ្ញុំព្រះអង្គ មានពួកជនដែកាន់ព្រះខាន់រក្សាហើយ ក្នុងទីខ្ពស់ មានកំពែងដ៏មូល មានប៉មនិងក្លោងទ្វារយ៉ាងមាំ គង់នៅរន្ធត់ ។ ថ្ងៃនេះព្រះភទ្ទិយៈ ដ៏ចម្រើន ជាបុត្រនៃសាក្យានីឈ្មោះគោធានោះ មិនមានសេចក្តីតក់-ស្លុត បានលះបង់នូវភ័យដ៏ពន្លឹក ចូលកាន់ព្រៃ ចម្រើនឈាន ។ ខ្ញុំព្រះអង្គបានតម្កល់ខ្លួនក្នុងសីលក្ខន្ធ ចម្រើននូវសតិ និងបញ្ញា ក៏បានដល់នូវការអស់ទៅនៃសំយោជនៈទាំងពួង តាមលំដាប់ ។

ព្រះភទ្ទិយត្ថេរ ជាបុត្រនៃសាក្យានីឈ្មោះកាលិគោធា ។

[២៨៦] បពិត្រព្រះសមណៈ ព្រះអង្គកំពុងស្តេចយាង តែពោលថា តថាគតឈប់ ទាំងពោលចំពោះខ្ញុំដែលឈប់ ថាជាបុគ្គលមិនទាន់ឈប់ដូច្នេះវិញ បពិត្រព្រះសមណៈ ខ្ញុំសូមសួរសេចក្តីនុ៎ះនឹងព្រះអង្គ ព្រោះហេតុអ្វី បានជាព្រះអង្គ ឈ្មោះថាឈប់ ខ្ញុំព្រះអង្គឈ្មោះថាមិនឈប់ ។

៧១

ថេរគាថាយ វីសតិនិបាតោ

ឋិតោ អហំ អង្គុលិមាល សព្វទា
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
តុវញ្ច បាណេសុ អសញ្ញតោសិ
តស្មា ឋិតោហំ តុវមដ្ឋិតោសិ ។
ចិរស្សំ វត មេ មហិតោ មហេសិ
មហាវនំ សមណោ បច្ចុបាទិ
សោហំ ចជិស្សាមិ សហស្សបាបំ
សុត្វាន គាថំ តវ ធម្មយុត្តំ ។
ឥច្ចេវ ចោរោ អសិមាវុធញ្ច
សោព្ភេ បបាតេ នរកេ អន្វកាសិ
អវន្ទិ ចោរោ សុគតស្ស បាទេ
តត្ថេវ បព្វជ្ជមយាចិ ពុទ្ធំ ។
ពុទ្ធោ ច ខោ ការុណិកោ មហេសិ
យោ សត្ថា លោកស្ស សទេវកស្ស
តមេហិ ភិក្ខូតិ តទា អវោច
ឯសេវ តស្ស អហុ ភិក្ខុភាវោ ។

(ព្រះមានព្រះភាគត្រាស់ថា) ម្នាលអង្គុលិមាល តថាគត ឈ្មោះថា ឈប់ ព្រោះដាក់បង់នូវអាជ្ញា ចំពោះពួកសត្វទាំង ពួងគ្រប់កាលហើយ ចំណែកខាងអ្នក ជាបុគ្គលមិនសង្រួម ក្នុងពួកសត្វ ព្រោះហេតុនោះ តថាគតទើបឈ្មោះថា ឈប់ ឯអ្នកឈ្មោះថា មិនឈប់ទេ ។

(អង្គុលិមាលចោរពោលថា)យូរណាស់មកហើយ ព្រះសម-ណៈអ្នកស្វែងរកនូវគុណដ៏ធំដែលគេបូជា ទើបតែនឹងយាងមក កាន់ព្រៃធំ (ដើម្បីអនុគ្រោះ) ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនោះនឹង លះបង់នូវបាបដ៏ច្រើន ព្រោះបានស្តាប់ព្រះគាថាដែលប្រកប ដោយធម៌របស់ព្រះអង្គ ។ អង្គុលិមាលចោរពោលដូច្នេះហើយ ក៏ទម្លាក់ចោលនូវដាវនិងអាវុធ ទៅក្នុងត្រពាំង ក្នុងជ្រោះ ក្នុង រណ្តៅ អង្គុលិមាលចោរ បានថ្វាយបង្គំនូវព្រះបាទទាំងឡាយ នៃព្រះសុគត ហើយសុំផ្នួសនឹងព្រះពុទ្ធ ក្នុងទីនោះឯង ។

ព្រះមានព្រះភាគអង្គណា ជាព្រះពុទ្ធប្រកបដោយករុណា ទ្រង់ស្វែងរកនូវគុណដ៏ធំ ជាសាស្តានៃមនុស្សលោក ព្រម ទាំងទេវលោក ព្រះមានព្រះភាគអង្គនោះ ទ្រង់បានត្រាស់នឹង អង្គុលិមាលចោរ ក្នុងកាលនោះថា អ្នកចូរមកជាភិក្ខុចុះ ភិក្ខុ-ភាពនុ៎ះឯង ក៏សម្រេចដល់អង្គុលិមាលចោរនោះ ។

៧២



យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។
យស្ស បាបំ កតំ កម្មំ កុសលេន បិធីយតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។
យោ ហវេ ទហរោ ភិក្ខុ យុញ្ជតី ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

ទិសា ហិ មេ ធម្មកថំ សុណន្តុ
ទិសា ហិ មេ យុញ្ជន្តុ ពុទ្ធសាសនេ ច
ទិសា ហិ មេ តេ មនុស្សេ ភជន្តុ
យេ ធម្មមេវាទបយន្តិ សន្តោ ។

ទិសា ហិ មេ ខន្តិវាទានំ អវិរោធប្បសំសិនំ
សុណន្តុ ធម្មំ កាលេន តញ្ច អនុវិធីយន្តុ ។
ន ហិ ជាតុ សោ មមំ ហឹសេ អញ្ញំ វា បន កញ្ចិ នំ
បប្បុយ្យ បរមំ សន្តឹ រក្ខេយ្យ តសថាវរេ ។

ឧទកំ ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា ។

(ព្រះអង្គុលិមាលត្ថេរពោលថា) បុគ្គលណា ប្រមាទក្នុងកាលមុន ហើយមិនប្រមាទក្នុងកាលខាងក្រោយ បុគ្គលនោះរមែងញុំាងលោកនេះឲ្យរុងរឿង ដូចព្រះចន្ទ្រផុតស្រឡះចាកពពក ។ បុគ្គលណាបានធ្វើអំពើបាប ហើយបិទ (អំពើបាបនោះ) ដោយកុសល បុគ្គលនោះ រមែងញុំាងលោកនេះឲ្យរុងរឿង ដូចព្រះចន្ទ្រផុតស្រឡះចាកពពក ។ ភិក្ខុណា នៅក្មេង តែខ្មីឃ្មាតក្នុងពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកនេះឲ្យរុងរឿង ដូចព្រះចន្ទ្រផុតស្រឡះចាកពពក ។

សូមពួកជនជាសត្រូវនឹងយើង ស្តាប់នូវធម្មកថា សូមពួក
ជនជាសត្រូវនឹងយើង ខ្មីឃ្មាតក្នុងពុទ្ធសាសនាចុះ ពួកមនុស្ស
ណា ដែលជាសប្បុរស តែងដឹកនាំក្នុងធម៌តែម្យ៉ាង សូមពួក
ជនជាសត្រូវនឹងយើង គប់រកនូវមនុស្សទាំងនោះចុះ ។

សូមពួកជនជាសត្រូវនឹងយើង ស្តាប់ធម៌របស់ពួកសប្បុរស ដែលជាអ្នកពោលនូវខន្តី ជាអ្នកសរសើរនូវសេចក្តីមិនក្រោធ តាមកាលគួរផង ចូរធ្វើតាមនូវធម៌នោះផង ។ បើជននោះ មិនបៀតបៀនយើង ឬសត្វដទៃណាមួយទេ ជននោះ គប្បីដល់នូវសេចក្តីស្ងប់យ៉ាងឧត្តម គប្បីរក្សានូវជនដែលមានចិត្តតក់ស្លុត និងមានចិត្តមាំមួន ។

ពួកអ្នកបង្ហូរទឹក តែងបង្ហូរទឹក ពួកជាងព្រួញ តែងពត់ព្រួញ
ពួកជាងចាំង តែងចាំងពត់ឈើ ពួកអ្នកប្រាជ្ញ តែងទូន្មានខ្លួន ។

៧៣

ថេរគាថាយ វីសតិនិបាតោ

ទណ្ឌេនេកេ ទមយន្តិ　　អង្កុសេហិ កសាហិ ច
អទណ្ឌេន អសត្ថេន　　អហំ ទន្តោម្ហិ តាទិនា ។
អហឹសកោតិ មេ នាមំ　　ហឹសកស្ស បុរេ សតោ
អជ្ជាហំ សច្ចនាមោម្ហិ　　ន នំ ហឹសាមិ កញ្ចិ នំ ។
ចោរោ អហំ បុរេ អាសឹ　　អង្គុលិមាលោតិ វិស្សុតោ
វុយ្ហមានោ មហោឃេន　　ពុទ្ធំ សរណមាគមំ ។
លោហិតចាណី បុរេ អាសឹ　　អង្គុលិមាលោតិ វិស្សុតោ
សរណាគមនំ បស្ស　　ភវនេត្តិ សមូហតា ។
តាទិសំ កម្មំ កត្វាន　　ពហុំ ទុគ្គតិគាមិនំ
ផុដ្ឋោ កម្មវិចាកេន　　អនណោ ភុញ្ជាមិ ភោជនំ ។
បមាទមនុយុញ្ជន្តិ　　ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី　　ធនំ សេដ្ឋំវ រក្ខតិ ។
មា បមាទមនុយុញ្ជេថ　　មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ　　បប្បោតិ បរមំ សុខំ ។

ជនពួកខ្លះ តែងទូន្មាន (នូវសត្វពាហនៈមានដំរីជាដើម) ដោយដំបង កង្វេរ និងរំពាត់ផ្តៅ ព្រះមានព្រះភាគ ជាតាទិបុគ្គល ទ្រង់ទូន្មានខ្ញុំ ដោយមិនបាច់ប្រើដំបង និងគ្រឿងសស្ត្រាទេ ។ ក្នុងកាលមុន ខ្ញុំជាអ្នកបៀតបៀនគេ តែមាននាមថា អហឹសកៈ[១] ក្នុងថ្ងៃនេះ ខ្ញុំមាននាមត្រូវតាមដំណើរពិតហើយ ព្រោះខ្ញុំមិនបៀតបៀនជនណាមួយឡើយ ។ ក្នុងកាលមុន ខ្ញុំជាចោរល្បីឈ្មោះថា អង្គុលិមាល ដែលជំនន់ធំក្ជួចនាំទៅហើយ (ឥឡូវ) ខ្ញុំបានដល់នូវព្រះពុទ្ធជាទីពឹងហើយ ។ ក្នុងកាលមុន ខ្ញុំជាអ្នកមានដៃប្រឡាក់ឈាម ល្បីឈ្មោះថា អង្គុលិមាល អ្នកចូរមើលនូវដំណើរមកកាន់សរណៈ (របស់ខ្ញុំ)ចុះ ខ្ញុំបានដកនូវតណ្ហា ដែលនាំទៅកាន់ភពហើយ ។ ខ្ញុំបានធ្វើកម្ម ដែលជាដំណើរទៅកាន់ទុគ្គតិបែបនោះជាច្រើន ត្រូវផលនៃកម្មប៉ះពាល់ (ឥឡូវ) ជាអ្នកមិនមានបំណុលបរិភោគនូវភោជន ។ ពួកជនពាលឥតប្រាជ្ញា តែងប្រកបរឿយ ៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ តែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចគេរក្សាទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយកុំប្រកបរឿយ ៗ នូវសេចក្តីប្រមាទ កុំធ្វើនូវសេចក្តីស្និទ្ធស្នាលដោយតម្រេក ក្នុងកាមឡើយ ដ្បិតថា បុគ្គលអ្នកមិនប្រមាទប្រឹងចម្រើនឈាន រមែងបាននូវសេចក្តីសុខ យ៉ាងក្រៃលែង ។

១ អ្នកមិនបៀតបៀនគេ ។

៧៤



ស្វាគតំ នាបគតំ　　នេតំ ទុម្មន្តិតំ មម
សំវិភត្តេសុ ធម្មេសុ　　យំ សេដ្ឋំ តទុបាគមំ ។
ស្វាគតំ នាបគតំ　　នេតំ ទុម្មន្តិតំ មម
តិស្សោ វិជ្ជា អនុប្បត្តា　　កតំ ពុទ្ធស្ស សាសនំ ។
អរញ្ញេ រុក្ខមូលេ វា　　បព្វតេសុ គុហាសុ វា
តត្ថ តត្ថេវ អដ្ឋាសឹ　　ឧព្វិគ្គមនសោ តទា ។
សុខំ សយាមិ ឋាយាមិ　　សុខំ កប្បេមិ ជីវិតំ
អហត្ថបាសោ មារស្ស　　អហោ សត្ថានុកម្បិតោ ។
ព្រហ្មជច្ចោ បុរេ អាសឹ　　ឧទិច្ចោ ឧភតោ អហុំ
សោជ្ជ បុត្តោ សុគតស្ស　　ធម្មរាជស្ស សត្ថុនោ ។
វីតតណ្ហោ អនាទានោ　　គុត្តទ្វារោ សុសំវុតោ
អឃមូលំ វធិត្វាន[១]　　បត្តោ មេ អាសវក្ខយោ ។
បរិចិណ្ណោ មយា សត្ថា　　កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ　　ភវនេត្តិ សមូហតាតិ ។

អង្គុលិមាលោ ថេរោ ។

---

១ ឱ. វមិត្វាន ។

ដំណើរមករបស់ខ្ញុំ ជាដំណើរល្អ មិនមែនជាដំណើរប្រាសចាក (ប្រយោជន៍) គំនិតរបស់ខ្ញុំនុ៎ះ មិនមែនជាគំនិតខុសទេ ព្រោះខ្ញុំបានសម្រេចធម៌ដ៏ប្រសើរបំផុត ក្នុងពួកធម៌ ដែលព្រះមានព្រះភាគចែកទុកដោយប្រពៃ ។ ដំណើរមករបស់ខ្ញុំ ជាដំណើរល្អ មិនមែនជាដំណើរប្រាសចាក (ប្រយោជន៍) គំនិតរបស់ខ្ញុំនុ៎ះមិនមែនជាគំនិតខុសទេ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំក៏បានធ្វើហើយ ។ (ក្នុងកាលមុន)ខ្ញុំបិតក្នុងទីទាំងឡាយនោះ ៗ គឺព្រៃក្តី ម្លប់ឈើក្តី ភ្នំក្តី គុហាក្តី ខ្ញុំក៏មានចិត្តតក់ស្លុត ក្នុងកាលនោះ ។ ឥឡូវនេះ ខ្ញុំដេកជាសុខ ឈរជាសុខ ចិញ្ចឹមជីវិតជាសុខ ជាបុគ្គលមិននៅក្នុងអន្ទាក់ដៃរបស់មារ ឱ! ព្រះសាស្តា ទ្រង់អនុគ្រោះខ្ញុំ ។ ក្នុងកាលមុន ខ្ញុំបានកើតជាព្រាហ្មណ៍ មានត្រកូលខ្ពស់ទាំងពីរខាង គឺខាងមាតានិងខាងបិតា ថ្ងៃនេះ ខ្ញុំបានជាបុត្តនៃព្រះសុគត ជាសាស្តា ធម្មរាជ ។ ខ្ញុំជាបុគ្គលប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ បានគ្រប់គ្រងទ្វារសង្រួមដោយប្រពៃហើយ ការអស់ទៅនៃអាសវៈ ខ្ញុំបានដល់ហើយ ព្រោះបានសម្លាប់ឫសគល់នៃទុក្ខ ព្រះសាស្តា ខ្ញុំបានប្រណិប័តន៍ហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចោលហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏ដកចោលហើយ ។

អង្គុលិមាលត្ថេរ ។

ថេរគាថាយ វីសតិនិបាតោ

[២៨៧] បហាយ មាតាបិតរោ ភគិនីញាតិភាតរោ
បញ្ច កាមគុណេ ហិត្វា អនុរុទ្ធោវ ឈាយតិ ។
សមេតោ នច្ចគីតេហិ សម្មតាឡប្បពោធនោ
ន តេន សុទ្ធិមជ្ឈគមា មារស្ស វិសយេ រតោ ។
ឯតញ្ច សមតិក្កម្ម រតោ ពុទ្ធស្ស សាសនេ
សព្វោឃំ សមតិក្កម្ម អនុរុទ្ធោវ ឈាយតិ ។
រូបា សទ្ទា រសា គន្ធា ផោដ្ឋព្វា ច មនោរមា
ឯតេ ច សមតិក្កម្ម អនុរុទ្ធោវ ឈាយតិ ។
បិណ្ឌបាតបតិក្កន្តោ ឯកោ អទុតិយោ មុនិ
ឯសតិ បំសុកូលានិ អនុរុទ្ធោ អនាសវោ ។
វិចិនិ អគ្គហី ធោវិ រជយី ធារយី មុនិ
បំសុកូលានិ មតិមា អនុរុទ្ធោ អនាសវោ ។
មហិច្ឆោ ច អសន្តុដ្ឋោ សំសដ្ឋោ យោ ច ឧទ្ធតោ
តស្ស ធម្មា ឥមេ ហោន្តិ បាបកា សង្កិលេសិកា ។
សតោ ច ហោតិ អប្បិច្ឆោ សន្តុដ្ឋោ អវិឃាតវា
បវិវេករតោ វិត្តោ និច្ចមារទ្ធវីរិយោ

[២៩៧] អនុរុទ្ធ បានលះបង់នូវមាតា បិតា បងប្អូនស្រី ញាតិ និងបងប្អូនប្រុសទាំងឡាយ លះបង់នូវកាមគុណ ៥ ហើយចម្រើននូវឈាន ។ (ក្នុងកាលមុន) អនុរុទ្ធ ជាអ្នកបរិបូណ៌ដោយរបាំ និងចម្រៀង ភ្ញាក់រលឹកដោយគ្រឿងប្រគំ ជាអ្នកត្រេកអរតែក្នុងវិស័យរបស់មារ ក៏មិនបានដល់នូវសេចក្តីបរិសុទ្ធ ដោយហេតុនោះ ។ (ឥឡូវនេះ) អនុរុទ្ធ បានកន្លងនូវវិស័យរបស់មារនុ៎ះហើយ ត្រេកអរក្នុងសាសនារបស់ព្រះពុទ្ធ បានឆ្លងផុតនូវឱឃៈទាំងពួង ចម្រើនឈាន ។ អនុរុទ្ធ បានកន្លងនូវរូប សំឡេង ក្លិន រស ផ្សព្វ ជាទីគាប់ចិត្តទាំងនុ៎ះ ចម្រើនឈាន ។ អនុរុទ្ធ ជាបុគ្គលម្នាក់ឯង មិនមានតណ្ហាជាគម្រប់ពីរ ជាអ្នកប្រាជ្ញ មិនមានអាសវៈ ត្រឡប់អំពីបិណ្ឌបាត ស្វែងរកនូវចីវរបង្សុកូលទាំងឡាយ ។ អនុរុទ្ធ ជាអ្នកប្រាជ្ញ មានយោបល់ មិនមានអាសវៈ រើសកាន់យក គក់លាង ជ្រលក់ ប្រើប្រាស់ នូវចីវរបង្សុកូលទាំងឡាយ ។ បុគ្គលណា មានសេចក្តីប្រាថ្នាច្រើនមិនមានសន្តោស ជាអ្នកច្រឡំដោយពួក មានចិត្តរាយមាយ ធម៌ដ៏លាមក ជាគ្រឿងសៅហ្មងទាំងនេះ តែងកើតមានដល់បុគ្គលនោះ ។ បុគ្គលណា ជាអ្នកមានស្មារតី មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មិនមានចិត្តចង្អៀតចង្អល់ ត្រេកអរក្នុងទីស្ងាត់ ជាអ្នកស្ងាត់ មានការព្យាយាមតឹងតែងជានិច្ច

តស្ស ធម្មា ឥមេ ហោន្តិ     កុសលា ពោធិបក្ខិកា
អនាសវោ ច សោ ហោតិ     ឥតិ វុត្តំ មហេសិនា ។
មម សង្កប្បមញ្ញាយ     សត្ថា លោកេ អនុត្តរោ
មនោមយេន កាយេន     ឥទ្ធិយា ឧបសង្កមិ ។
យទា មេ អហុ សង្កប្បោ     តតោ ឧត្តរី ទេសយិ
និប្បបញ្ចរតោ ពុទ្ធោ     និប្បបញ្ចមទេសយិ ។
តស្សាហំ ធម្មមញ្ញាយ     វិហាសឹ សាសនេ រតោ
តិស្សោ វិជ្ជា អនុប្បត្តា     កតំ ពុទ្ធស្ស សាសនំ ។
បញ្ចបញ្ញាស វស្សានិ     យតោ នេសជ្ជិកោ អហំ
បញ្ចវីសតិ វស្សានិ     យតោ មិទ្ធំ សមូហតំ ។
ណាហុ អស្សាសបស្សាសា     ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ     ចក្ខុមា បរិនិព្វុតោ ។
អសល្លីនេន ចិត្តេន     វេទនំ អជ្ឈវាសយិ
បជ្ជោតស្សេវ និព្វានំ     វិមោក្ខោ ចេតសោ អហុ ។
ឯតេ បច្ឆិមកា ទានិ     មុនិនោ ផស្សបញ្ចមា

ធម៌ជាកុសល ជាចំណែកនៃការត្រាស់ដឹងទាំងនោះ តែងកើតមាន ដល់បុគ្គលនោះ ព្រះពុទ្ធជាមហេសី ទ្រង់ត្រាស់ថាបុគ្គលនោះ ជាអ្នកមិនមានអាសវៈ ។ ព្រះសាស្តាជាបុគ្គលប្រសើរក្នុងលោក ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ក៏យាងមកដោយឫទ្ធិ ដោយព្រះកាយដែលសម្រេចអំពីចិត្ត ។ ខ្ញុំមានសេចក្តីត្រិះរិះ ក្នុងកាលណា ព្រះសាស្តាទ្រង់បានសម្តែងនូវធម៌ (មហាបុរិសវិតក្កៈ) ដ៏លើសលុប ក្នុងកាលនោះ ព្រះពុទ្ធ ទ្រង់ត្រេកអរក្នុងធម៌ដែលមិនមានដំណើរយឺតយូរ សម្តែងនូវធម៌ ដែលមិនមានដំណើរយឺតយូរ ។ ខ្ញុំដឹងនូវធម្មទេសនា របស់ព្រះសាស្តានោះហើយ ត្រេកអរក្នុងសាសនា វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ ខ្ញុំបានសមាទាន នេសជ្ជិកង្គធុតង្គអស់ ៥៥ ឆ្នាំ ខ្ញុំបានដករំលើងនូវកិរិយាងោកងុយអស់ ២៥ ឆ្នាំហើយ ។ ព្រះពុទ្ធ ព្រះអង្គជាបុគ្គលនឹងធឹង មានព្រះទ័យខ្ជាប់ខ្ជួន មិនមានខ្យល់អស្សាសបស្សាសៈហើយ ព្រះពុទ្ធ មានចក្ខុ មិនមានកិលេសជាគ្រឿងញាប់ញ័រ ទ្រង់ប្រារព្ធនូវសេចក្តីស្ងប់ បរិនិព្វានហើយ ។ ព្រះពុទ្ធ ទ្រង់អត់សង្កត់នូវវេទនាដោយព្រះទ័យមិនរួញរា ការផុតស្រឡះនៃចិត្ត (របស់ព្រះអង្គ) ដូចជាកិរិយារលត់នៃប្រទីប ។ សភាវៈមានផស្សៈជាគម្រប់ ៥ របស់ព្រះពុទ្ធ ជាអ្នកប្រាជ្ញទុំះ មានក្នុងទីបំផុត ក្នុងកាលឥឡូវនេះហើយ

៧៧

ថេរគាថាយ វីសតិនិបាតោ

ណាញ្ញេ ធម្មា ភវិស្សន្តិ សម្ពុទ្ធេ បរិនិព្វុតេ ។
នត្ថិ ទានិ បុនាវាសោ ទេវកាយស្មឹ ជាលិនិ
វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោ ។

យស្ស មុហុត្តេ សហស្សធា លោកោ
សំវិទិតោ សព្រហ្មកប្បោ
វសី ឥទ្ធិគុណេ ចុតូបបាតេ
កាលេ បស្សតិ ទេវតា ស ភិក្ខុ ។

អន្នភារោ បុរេ អាសឹ ទលិទ្ទោ ឃាសហារកោ
សមណំ បដិបាទេសឹ ឧបរិដ្ឋំ យសស្សិនំ ។
សោម្ហិ សក្យកុលេ ជាតោ អនុរុទ្ធោតិ មំ វិទូ
ឧបេតោ នច្ចគីតេហិ សម្មតាឡប្បពោធនោ ។
អថទ្ទសាសឹ សម្ពុទ្ធំ សត្ថារំ អកុតោភយំ
តស្មឹ ចិត្តំ បសាទេត្វា បព្វជឹ អនគារិយំ ។
បុព្វេនិវាសំ ជានាមិ យត្ថ មេ វុសិតំ បុរេ
តាវតឹសេសុ ទេវេសុ អដ្ឋាសឹ សក្កជាតិយា ។
សត្តក្ខត្តុំ មនុស្សិន្ទោ អហំ រជ្ជមការយឹ
ចាតុរន្តោ វិជិតាវី ជម្ពុសណ្ឌស្ស ឥស្សរោ

នាកាលព្រះសម្ពុទ្ធទ្រង់បរិនិព្វានហើយ ធម៌ដទៃ គឺចិត្ត និងចេតសិក មិនមានទៀតទេ ។ ម្នាលទេវតា ឈ្មោះជាលិនី ឥឡូវនេះ (អាត្មា) មិនមានការអាស្រ័យនៅក្នុងពួកទេវតាទៀតឡើយ ជាតិសង្សារ របស់អាត្មាក៏អស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។

ភិក្ខុណា អាចដឹងច្បាស់នូវលោក មានចំណែកមួយពាន់ ព្រមទាំងព្រហ្មលោក ក្នុងមួយរំពេចបាន ភិក្ខុនោះ អ្នកស្ទាត់ក្នុងឥទ្ធិគុណ ក្នុងចុតូបបាតញ្ញាណ រមែងឃើញពួកទេវតាក្នុងកាលគួរ ។

ក្នុងកាលមុន ខ្ញុំបានកើតជាបុរសកម្សត់ ឈ្មោះអន្នភារៈ ជាអ្នកធ្វើការឈ្នួល ដើម្បីអាហារ បានផ្គត់ផ្គង់សមណៈ (ព្រះបច្ចេកពុទ្ធ) ឈ្មោះឧបរិដ្ឋៈ ជាអ្នកមានយស ។ ពួកជនអ្នកចេះដឹង តែងស្គាល់ខ្ញុំថា ខ្ញុំនោះឈ្មោះអនុរុទ្ធ កើតក្នុងសក្យត្រកូល ជាអ្នកបរិបូណ៌ដោយរបាំនិងចម្រៀង ភ្ញាក់រលឹកដោយគ្រឿងប្រគំ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ជាសាស្តា មិនមានភ័យអំពីទីណា ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះសម្ពុទ្ធនោះ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំដឹងនូវបុព្វេនិវាស ដែលជាលំនៅរបស់អាត្មា ធ្លាប់នៅក្នុងកាលមុន ក្នុងទេវលោក ឈ្មោះតាវត្តិង្ស បានឋិតនៅក្នុងជាតិជាសក្កៈ(ព្រះឥន្ទ្រ) ។ អាត្មាបានជាធំក្នុងមនុស្ស សោយរាជ្យអស់ ៧ ជាតិ ជាធំលើផែនដី មានសមុទ្រទាំងបួនជាទីបំផុត មានជ័យជម្នះ ជាឥស្សរៈក្នុងជម្ពូទ្វីប

អនព្ភោន អសត្ថេន ជម្មេន អនុសាសយី ។
ឥតោ សត្ត ឥតោ សត្ត សំសារានិ ចតុទ្ទស
និវាសមភិជានិស្សំ ទេវលោកេ ឋិតោ តទា ។
បញ្ចង្គិកេ សមាធិម្ហិ សន្តេ ឯកោទិការិតេ
បដិប្បស្សទ្ធិលទ្ធម្ហិ ទិព្វចក្ខុំ វិសុជ្ឈិ មេ ។
ចុតូបបាតំ ជានាមិ សត្តានំ អាគតឹ គតឹ
ឥត្ថភាវញ្ញថាភាវំ ឈានេ បញ្ចង្គិកេ ឋិតោ ។
បរិចិណ្ណោ មយា សត្ថា ។ បេ ។ ភវនេត្តិ សមូហតា ។
វជ្ជីនំ វេឡុវគាមេ អហំ ជីវិតសង្ខយា
ហេដ្ឋតោ វេឡុគុម្ពស្មឹ និព្វាយិស្សំ អនាសវោតិ ។

អនុរុទ្ធោ ថេរោ ។

[២៤៨] សមណស្ស អហុ ចិន្តា បុប្ផិតម្ហិ មហាវនេ
ឯកគ្គស្ស និសិន្នស្ស បវិវិត្តស្ស ឈាយិនោ ។

ប្រៀនប្រដៅ (ប្រជាជន) ដោយធម៌ មិនប្រើដំបងនិងគ្រឿងសស្ត្រា ។ កាលនោះ ខ្ញុំបានឋិតនៅក្នុងទេវលោក ដឹងច្បាស់នូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន អស់ ១៤ សង្សារវដ្ត(១៤ ជាតិ) គឺខាងទេវលោកនេះ ៧ ជាតិ ខាងមនុស្សលោកនេះ ៧ ជាតិ ។ កាលសមាធិប្រកបដោយអង្គ[១] ៥ ខ្ញុំបានចម្រើនឲ្យមានអារម្មណ៍មូលតែមួយហើយ ខ្ញុំក៏បានសេចក្តីស្ងប់រម្ងាប់ ទិព្វចក្ខុរបស់ខ្ញុំ ក៏បរិសុទ្ធ ។ ខ្ញុំលុះបានឋិតនៅក្នុងឈានប្រកបដោយអង្គ ៥ ហើយ ក៏ដឹងនូវការច្យុតិនិងការកើតគឺដំណើរមក និងដំណើរទៅ (ព្រមទាំង) ការកើតឡើងយ៉ាងនេះនិងការប្រែប្រួលទៅ ជាយ៉ាងដទៃ របស់សត្វទាំងឡាយ ។ ព្រះសាស្តាខ្ញុំបានបម្រើហើយ ។ បេ ។ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំបានដកចោលហើយ ។ ខ្ញុំជាបុគ្គលមិនមានអាសវៈ លុះអស់ជីវិត ខ្ញុំនឹងនិព្វានក្រោមគុម្ពឫស្សី ក្នុងវេឡុវគ្រាម របស់ពួកជនអ្នកនៅ ក្នុងដែនវជ្ជី ។

អនុរុទ្ធត្ថេរ ។

[២៥៨] ចិន្តារបស់សមណៈអ្នកមានអារម្មណ៍មូលតែមួយ អង្គុយក្នុងព្រៃធំមានផ្ការីកជាអ្នកមានសេចក្តីស្ងប់ស្ងាត់ មានឈានបានកើតមានហើយ។

---

១ សមាធិប្រកបដោយអង្គ ៥ គឺបីតិផរណតា ការផ្សាយទៅនៃបីតិ ១ ចេតោផរណតា ការផ្សាយទៅនៃចិត្ត ១ អាលោកផរណតា ការផ្សាយទៅនៃពន្លឺ ១ បច្ចវេក្ខណា ការពិចារណាស្ទាត់ ១ និមិត្តំ ការប្រកបដោយនិមិត្ត មានបរិកម្មជានិមិត្ត ១ ។ អដ្ឋកថា ។

៧៩

## ថេរគាថាយ វីសតិនិបាតោ

អញ្ញថា លោកនាថម្ហិ តិដ្ឋន្តេ បុរិសុត្តមេ
ឥរិយំ អាសិ ភិក្ខូនំ អញ្ញថាទានិ ទិស្សតេ ។
សីតវាតបរិត្តាណំ ហិរិកោបីនឆាទនំ
មត្តដ្ឋិយំ អភុញ្ជឹសុ សន្តុដ្ឋា ឥតរីតរេ ។
បណីតំ យទិ វា លូខំ អប្បំ វា យទិ វា ពហុំ
យាបនត្ថំ អភុញ្ជឹសុ អគិទ្ធា នាធិមុច្ឆិតា ។
ជីវិតានំ បរិក្ខារេ ភេសជ្ជេ អថ បច្ចយេ
ន ពាឡ្ហំ ឧស្សុកា អាសុំ យថា តេ អាសវក្ខយេ ។
អរញ្ញេ រុក្ខមូលេសុ កន្ទរាសុ គុហាសុ ច
វិវេកមនុព្រូហន្តា វិហឹសុ តប្បរាយណា ។
នីចនិវិដ្ឋា សុភរា មុទូ អត្ថទ្ធមានសា
អព្យាសេកា អមុខរា អត្ថចិន្តាវសានុគា ។
តតោ បាសាទិកំ អាសិ គតំ ភុត្តំ និសេវិតំ
សិនិទ្ធា តេលធារាវ អហោសិ ឥរិយាបថោ ។
សព្វាសវបរិក្ខីណា មហាឈាយី មហាហិតា
និព្វុតា ទានិ តេ ថេរា បរិត្តា ទានិ តាទិសា ។

កាលដែលព្រះលោកនាថ ជាឧត្តមបុរស មានព្រះជន្មនៅឡើយ ការប្រព្រឹត្តរបស់ពួកភិក្ខុ មានដោយឡែក ឥឡូវនេះ (ការប្រព្រឹត្ត) ក៏ប្រាកដដោយឡែក ។ ពួកភិក្ខុជាអ្នកសន្តោសក្នុងបច្ច័យតាមមានតាមបាន បានប្រើប្រាស់នូវចីវរ គ្រាន់តែជាគ្រឿងការពារនូវត្រជាក់និងខ្យល់ គ្រាន់តែជាគ្រឿងបិទបាំងនូវកេរ្តិ៍ខ្មាស ។ ពួកភិក្ខុជាអ្នកមិនជាប់ មិនជ្រប់ បានបរិភោគរបស់ថ្លៃថ្លាក្តី សៅហ្មងក្តី តិចក្តី ច្រើនក្តី ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ។ ពួកភិក្ខុ មិនបានខ្វល់ខ្វាយក្នុងភេសជ្ជបច្ច័យ ជាបរិក្ខារនៃជីវិតខ្លាំងពេក ដូចជាខ្វល់ខ្វាយក្នុងធម៌ជាទីអស់នៃអាសវៈទេ ។ ពួកភិក្ខុចម្រើនរឿយ ៗ នូវវិវេកធម៌ ប្រព្រឹត្តឈមទៅរកវិវេក នៅក្នុងព្រៃ ទៀបគល់នៃឈើក្នុងជ្រោះ និងក្នុងគុហាទាំងឡាយ ។ ពួកភិក្ខុជាអ្នកប្រព្រឹត្តបន្ទាបខ្លួន តាំងមាំ (ក្នុងសាសនា) ជាអ្នកចិញ្ចឹមងាយ ជាអ្នកមានចិត្តទន់ មានចិត្តមិនរឹងត្អឹង មិនច្របូកច្របល់ដោយកិលេស មិនមានមាត់រឹង ជាអ្នកលុះក្នុងអំណាចនៃការគិតរកប្រយោជន៍(ខ្លួននិងអ្នកដទៃ) ។ ព្រោះហេតុនោះ ដំណើរទៅនិងការបរិភោគ ការសេព (របស់ពួកភិក្ខុ) គួរជាទីជ្រះថ្លាទាំងមានឥរិយាបថ ដូចជារនៃប្រេងដ៏ស្និទ្ធល្អ ។ ព្រះថេរៈទាំងនោះ មានអាសវៈទាំងពួងអស់ហើយ មានឈានច្រើន មានប្រយោជន៍ច្រើន ឥឡូវនេះបរិនិព្វានហើយ ឥឡូវនេះពួកភិក្ខុបែបនោះមានតិច ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

កុសលានញ្ច ធម្មានំ   បញ្ញាយ ច បរិក្ខយា
សព្វាការវរូបេតំ   លុជ្ជតេ ជិនសាសនំ ។
ចាបកានញ្ច ធម្មានំ   កិលេសានញ្ច យោ ឧតុ
ឧបដ្ឋិតា វិវេកាយ   យេ ច សទ្ធម្មសេសកា ។
តេ កិលេសា បវឌ្ឍន្តា   អាវិសន្តិ ពហុំ ជនំ
កីឡន្តិ មញ្ញេ ពាលេហិ   ឧម្មត្តេហិវ រក្ខសា ។
កិលេសេហាភិភូតា តេ   តេន តេន វិធាវិតា
នរា កិលេសវត្ថូសុ   សយំគាហេវ[១] ឃោសិតេ ។
បរិច្ចជិត្វា សទ្ធម្មំ   អញ្ញមញ្ញេហិ ភណ្ឌរេ
ទិដ្ឋិគតានិ អន្វេន្តា   ឥទំ សេយ្យោតិ មញ្ញរេ ។
ធនញ្ច បុត្តភរិយញ្ច   ឆឌ្ឌយិត្វាន និគ្គតា
កដច្ឆុភិក្ខាហេតូបិ   អកិច្ចានិ និសេវរេ

១ ម. សសង្គាមេវ ។

សាសនានៃព្រះជិនស្រី ប្រកបដោយអាការដ៏ប្រសើរគ្រប់យ៉ាង រមែងសាបសូន្យទៅ ព្រោះការអស់ទៅនៃកុសលធម៌ផង នៃបញ្ញាផង ។ កាលជារដូវនៃបាបធម៌ និងកិលេស (កំពុងប្រព្រឹត្តទៅ) ពួកភិក្ខុណាខ្លះខ្នែង ដើម្បីវិវេក ពួកភិក្ខុនោះ ឈ្មោះថា មានព្រះសទ្ធម្មសល់នៅ[១] ។ កិលេសទាំងនោះកាលចម្រើនឡើង រមែងជ្រៀតជ្រែកនូវជនជាច្រើន ទំនងហាក់ប្រឡែងលេងនឹងពួកជនពាលដូចពួកអារក្សទឹក ប្រឡែងលេងនឹងមនុស្សឆ្កួត ។ ពួកនរជនទាំងនោះ លុះត្រូវកិលេសគ្របសង្កត់ហើយ តែងស្ទុះទៅតាមចំណែកនៃកិច្ចនោះ ៗ ព្រោះកិលេសវត្ថុទាំងឡាយ ក្នុងកាលជាទីចាប់យក ដោយខ្លួនឯងដែលពួកកិលេសឃោសនាហើយ ។ ពួកជននោះលះបង់នូវព្រះសទ្ធម្ម ហើយឈ្លោះប្រកែកគ្នានិងគ្នា លុះក្នុងអំណាចទិដ្ឋិ សម្គាល់ថា វត្ថុនេះប្រសើរបំផុត ដូច្នេះ ។ ពួកជន ដែលលះបង់ នូវទ្រព្យ និងកូនប្រពន្ធ ហើយចេញទៅ (អំពីផ្ទះ) រមែងសេពនូវអំពើដែលមិនគួរធ្វើ ព្រោះហេតុ សូម្បីត្រឹមតែចង្ក្រាន់មួយវែក ។

---

១ កាលរដូវដែលពួកបុថុជ្ជន កំពុងសម្បូរដោយបាបធម៌និងកិលេសទោះបីភិក្ខុពួកខ្លះប្រកបព្យាយាម ក្នុងវិធីនៃកម្មដ្ឋាន ដោយសេចក្តីប្រតិបត្តិយ៉ាងឧក្រិដ្ឋ ក៏មិនអាចនឹងញ៉ាំងសេចក្តីប្រតិបត្តិឲ្យសម្រេចបានដោយងាយ ព្រោះព្រះសទ្ធម្មដែលសល់នៅក្រៅអំពីសេចក្តីប្រតិបត្តិនោះជាច្រើន ដោយបាបធម៌និងកិលេសចូលជ្រៀតជ្រែក។ អដ្ឋកថា ។

៨១

ថេរគាថាយ វីសតិនិបាតោ

ឧទភរហេកំ ភុត្វា　　សយន្តុត្តានសេយ្យកា
កាចំ វត្តេន្តិ[១] បដិពុទ្ធា　　យា កថា សត្ថុគរហិតា ។
សព្វការុកសិប្បានិ[២]　　ចិត្តំ កត្វាន សិក្ខរេ
អវូបសន្តា អជ្ឈត្តំ　　សាមញ្ញត្ថោតិ អច្ឆតិ ។
មត្តិកំ តេលចុណ្ណញ្ច　　ឧទកាសនភោជនំ
គិហីនំ ឧបនាមេន្តិ　　អាកង្ខន្តា ពហុត្តរំ ។
ទន្តបោណំ កបិដ្ឋញ្ច　　បុប្ផខាទនិយានិ ច
បិណ្ឌបាតេ ច សម្បន្នេ　　អម្ពេ អាមលកានិ ច
ភេសជ្ជេសុ យថា វេជ្ជា　　កិច្ចាកិច្ចេ យថា គិហី
គណិកាវ វិភូសាយំ　　ឥស្សរេ ខត្តិយា យថា
នេកតិកា វញ្ចនិកា　　កូដសក្ខី អបាដុកា[៣]
ពហូហិ បរិកប្បេហិ　　អាមិសំ បរិភុញ្ជរេ ។
លេសកប្បេ បរិយាយេ　　បរិកប្បេនុធាវិតា
ជីវិកត្ថា ឧបាយេន　　សង្កឌ្ឍន្តិ ពហុំ ធនំ ។

---
១ ឱ. កថា វទេន្តិ ។ ម. កថា វទ្ធេន្តិ ។ ២ សព្វការុណិកសិប្បានីតិបិ បាឋោ ។
៣ ម. អបាដុកា ។

(ពួកភិក្ខុនោះ) បរិភោគអាហារពេញពោះ ហើយដេកផ្ងារ ភ្ញាក់ឡើងហើយក៏នាំគ្នានិយាយពាក្យ ដែលព្រះសាស្តាទ្រង់តិះដៀល ។ ពួកភិក្ខុហាត់ធ្វើយ៉ាងផ្ចិតផ្ចង់ នូវសិល្បៈដូចជាងទាំងពួង មិនរម្ងាប់នូវសន្តានចិត្តខាងក្នុង គុណវិសេស គឺប្រយោជន៍ នៃសមណធម៌ (របស់ពួកភិក្ខុនោះ) ក៏អាក់ខាន ។ ពួកភិក្ខុកាលប្រាថ្នានូវចតុប្បច្ច័យច្រើនលើសលុប រមែងបង្អោននូវដីស្អិត ប្រេង គ្រឿងលម្អិត ទឹក អាសនៈ និងភោជន ដល់ពួកគ្រហស្ថ ។ ឲ្យនូវឈើស្ទន់ផ្លែខ្វិដ្ឋ ផ្កាឈើ វត្ថុសម្រាប់ទំពាស៊ី បិណ្ឌបាតដ៏ល្អ ៗ ផ្លែស្វាយ និងផ្លែកន្ទួតព្រៃទាំងឡាយ ខ្វល់ខ្វាយក្នុងភេសជ្ជៈ ដូចពួកពេទ្យ ខ្វល់ខ្វាយក្នុងកិច្ចតូច-ធំ (នៃជំងឺ) ដូចពួកគ្រហស្ថប្រកបក្នុងការស្អិតស្អាង ដូចស្រីពេស្យា ឬដូចពួកក្សត្រិយ៍ ខ្វល់ខ្វាយក្នុងឥស្សរភាព ជាអ្នកបោកប្រាសបញ្ឆោត ធ្វើជាសាក្សីវៀច ជាអ្នកកោងកាច បរិភោគអាមិសៈ ដោយអាការជាមិច្ឆាជីវៈច្រើនយ៉ាង ។ ពួកភិក្ខុជាអ្នកវេះវាម (ដោយបាបធម៌) ក្នុងលេសដ៏គួរ ក្នុងរបិចវាសវាង ត្រូវការចិញ្ចឹមជីវិត ប្រមូលមកនូវទ្រព្យដ៏ច្រើន ដោយឧបាយ ។

៨២

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

ឧបដ្ឋបេន្តិ បរិសំ កម្មតោ នោ ច ធម្មតោ
ធម្មំ បរេសំ ទេសេន្តិ លាភតោ នោ ច អត្ថតោ ។
សង្ឃលាភស្ស ភណ្ឌន្តិ សង្ឃតោ បរិពាហិរា
បរលាភោបជីវន្តា អហិរិកា ន លជ្ជរេ ។
នានុយុត្តា តថា ឯកេ មុណ្ឌា សង្ឃាដិបារុតា
សម្ភាវនំ យេវិច្ឆន្តិ លាភសក្ការមុច្ឆិតា ។
ឯវំ នានប្បយាតម្ហិ នទានិ សុករំ តថា
អផុសិតំ វា ផុសិតុំ ផុសិតំ វានុរក្ខិតុំ ។
យថា កណ្ដកដ្ឋានម្ហិ ចរេយ្យ អនុបាហនោ
សតឹ ឧបដ្ឋបេត្វាន ឯវំ គាមេ មុនី ចរេ ។
សរិត្វា បុព្វកេ យោគី តេសំ វត្តមនុស្សរំ
កិញ្ចាបិ បច្ឆិមោ កាលោ ផុសេយ្យ អមតំ បទំ ។

ពួកភិក្ខុញ៉ាំងបរិស័ទ ឲ្យផ្គត់ផ្គង់ ព្រោះការងារ មិនមែនព្រោះធម៌ សម្តែងធម៌ដែលជនដទៃ ព្រោះតែលាភ មិនសម្តែងព្រោះ(ប្រាថ្នា) ប្រយោជន៍(សាធារណៈ) ។ ពួកភិក្ខុឈ្មោះប្រកែកព្រោះតែសង្ឃលាភ ជាខាងក្រៅអំពីសង្ឃ ចិញ្ចឹមជីវិតដោយលាភរបស់ជនដទៃ ជាបុគ្គល មិនខ្មាសអៀន ។ មួយទៀត ភិក្ខុពួកខ្លះ ជាអ្នកមិនប្រកប(សមណធម៌) ជាបុគ្គលមានក្បាលត្រងោល ដណ្តប់សង្ឃាដី ជាអ្នកល្មោភដោយលាភសក្ការៈ ប្រាថ្នាតែសេចក្តីសរសើរ ។ កាលបើ កិលេសធម៌ ប្រព្រឹត្តទៅដោយប្រការផ្សេង ៗ យ៉ាងនេះ ឥឡូវនេះ ភិក្ខុមិនអាច នឹងប៉ះពាល់នូវគុណវិសេសដែលមិនទាន់បានប៉ះពាល់ ឬមិនអាចនឹង រក្សានូវគុណវិសេសដែលបានប៉ះពាល់ដូច្នោះបានឡើយ ។ ជនមិន មានស្បែកជើង ត្រាច់ទៅក្នុងទីមានបន្លាយ៉ាងណា អ្នកប្រាជ្ញគួរប្រុង ស្មារតី ត្រាច់ទៅក្នុងស្រុកយ៉ាងនោះ ។ យោគី កាលរលឹកឃើញពួក លោកអ្នកមានព្យាយាម ក្នុងកាលពីដើម រលឹកឃើញនូវវត្តប្រតិបត្តិ របស់ពួកលោកទាំងនោះ ទោះបីកាលជាខាងក្រោយ (អំពីកាលដែល ព្រះសាស្តាគង់នៅ) ក៏ដោយ គង់បានប៉ះពាល់នូវផ្លូវអមតៈ ។

## ៨៣

ថេរគាថាយ វីសតិនិបាតោ

ឥធំ វត្វា សាលវនេ        សមណោ ភាវិតិន្ទ្រិយោ
ព្រាហ្មណោ បរិនិព្វាយិ      ឥសិ ខីណាបុនព្ភវោតិ ។

បារាសរិយោ [១] ថេរោ ។

# ឧទ្ទានំ

អធិមុត្តោ បារាសរិយោ      តេលុកានិ រដ្ឋបាលោ
មាលុង្ក្យសេលោ ច ភទ្ទិយោ   អង្គុលិ ទិព្វចក្ខុកោ ។
បារាសរិយោ ច ឯសេតេ      វីសម្ហិ សុបរិកិត្តិតា
គាថាយោ ទ្វេ សតា ហោន្តិ បញ្ចតាឡីសឧត្តរិន្តិ ។

វីសតិនិបាតោ និដ្ឋិតោ ។

---

១ ឱ. បារាបរិយោ ។ ម. បារំបរិយោ ។

សមណៈ បានចម្រើននូវឥន្ទ្រិយ ជាអ្នកបណ្តោតបោលនូវបាប ជាអ្នកស្វែងរកនូវគុណ មានភពថ្មីអស់ហើយ លុះពោលយ៉ាងនេះហើយ ក៏បរិនិព្វាន ក្នុងសាលវ័ន ។

បារាសរិយត្ថេរ ។

# ឧទ្ទាន

ព្រះថេរៈ ១០ នេះ គឺអធិមុត្តត្ថេរ ១ បារាសរិយត្ថេរ ១ តេលុកានិត្ថេរ ១ រដ្ឋបាលត្ថេរ ១ មាលុង្ក្យបុត្តត្ថេរ ១ សេលត្ថេរ ១ ភទ្ទិយត្ថេរ ១ អង្គុលិមាលត្ថេរ ១ អនុរុទ្ធត្ថេរ មានទិព្វចក្ខុ ១ បារាសរិយត្ថេរ ១ បានសម្តែងគាថា ២០០ លើស ៤៥ ដែលមកក្នុងវីសតិនិបាត ។

ចប់ វីសតិនិបាត ។

# ថេរគាថាយ តឹសនិបាតោ

[២៨៩] ចាសាទិកេ ពហូ ទិស្វា ភាវិតត្តេ សុសំវុតេ
ឥសិ បណ្ឌរសគោត្តោ អបុច្ឆិ បុស្សសវ្ហយំ ។
កឹ ឆន្ទា កិមធិប្បាយា កិមាកប្បា ភវិស្សរេ
អនាគតម្ហិ កាលម្ហិ តំ មេ អក្ខាហិ បុច្ឆិតោ ។
សុណោហិ វចនំ មយ្ហំ ឥសិ បណ្ឌរសវ្ហយ
សក្កច្ចំ ឧបធារេហិ អាចិក្ខិស្សាម្យនាគតំ ។
កោធនា ឧបនាហី ច មក្ខី ថម្ភី សឋា ពហូ
ឥស្សុកី នានាវាទា ច ភវិស្សន្តិ អនាគតេ ។
អញ្ញាតមានិនោ ធម្មេ គម្ភីរេ តីរគោចរា
លហុកា អគរូ ធម្មេ អញ្ញមញ្ញមគារវា ។
ពហូ អាទីនវា លោកេ ឧប្បជ្ជិស្សន្ត្យនាគតេ
សុទេសិតំ ឥមំ ធម្មំ កិលិសិស្សន្តិ ទុម្មតី ។
គុណហីនាបិ សង្ឃម្ហិ វោហរន្តា(១) វិសារទា
ពលវន្តោ ភវិស្សន្តិ មុខរា អស្សុតាវិនោ ។

---
១ ឱ. ម. វោហរន្តិ ។

# ថេរគាថា តឹសនិបាត

[២៥៩] ឥសីឈ្មោះបណ្ឌរសគោត្រ ឃើញពួកភិក្ខុជាច្រើន ដែលគួរនាំមកនូវសេចក្ដីជ្រះថ្លា មានចិត្តអប់រំហើយ សង្រួមល្អហើយ ក៏បានសួរនូវព្រះថេរៈឈ្មោះបុស្សៈថា ។ ពួកភិក្ខុនឹងមានប្រាថ្នាដូចម្ដេច មានបំណងដូចម្ដេច មានអាកប្បកិរិយា ដូចម្ដេច ក្នុងកាលអនាគត លោកដែលខ្ញុំសួរហើយ សូមប្រាប់នូវដំណើរនោះឲ្យទាន ។

(ព្រះបុស្សត្ថេរពោលថា)ម្នាលឥសីឈ្មោះបណ្ឌរសៈ អ្នកចូរស្ដាប់ពាក្យអាត្មា ចូរចាំទុកដោយគោរព អាត្មានឹងប្រាប់នូវកាលជាអនាគត ។ ពួកភិក្ខុច្រើនរូប ជាបុគ្គលមានសេចក្ដីក្រោធ ចងសេចក្ដីក្រោធទុក ជាអ្នកលុបគុណគេ ជាបុគ្គលរបឹង ជាអ្នកបោកប្រាស ជាអ្នកច្រណែន ជាអ្នកមានវាទៈផ្សេង ៗ គ្នា នឹងមានក្នុងអនាគត ។ ភិក្ខុមានសេចក្ដីប្រកាន់ថាខ្លួន ដឹងធម៌ដ៏ជ្រាលជ្រៅ មានអារម្មណ៍ក្នុងត្រើយ (ខាងអាយអំពីធម៌នោះ) មានចិត្តស្រាល មិនធ្ងន់ក្នុងព្រះសទ្ធម្ម រមែងជាអ្នកមិនមានសេចក្ដីគោរពគ្នានិងគ្នា ។ ទោសទាំងឡាយជាច្រើននឹងកើតឡើងក្នុងលោក ក្នុងកាលជាអនាគត គឺពួកភិក្ខុអប្បប្រាជ្ញា នឹងញុំាងធម៌ ដែលព្រះមានព្រះភាគសម្ដែងហើយ ដោយប្រពៃនេះ ឲ្យសៅហ្មង ។ ពួកភិក្ខុសាបសូន្យចាកគុណ កាលចរចាក្នុងសង្ឃ នឹងជាអ្នកក្លៀវក្លា មានកម្លាំង មានមាត់រឹង តែជាអ្នកមិនមានការចេះដឹង ។

កុណារន្តោបិ សង្ឃម្ហិ ពេហារន្តា យថត្ថតោ
ទុព្វលា តេ ភវិស្សន្តិ ហិរិមណា អនត្ថិកា ។
រជតំ ជាតរូបញ្ច ខេត្តំ វត្ថុំ អជេឡកំ
ទាសីទាសញ្ច ទុម្មេធា សាទិយិស្សន្ត្យនាគតេ ។
ឧជ្ឈានសញ្ញិនោ ពាលា សីលេសុ អសមាហិតា
ឧន្នឡា វិចរិស្សន្តិ កលហាភិរតា មិគា
ឧទ្ធតា ច ភវិស្សន្តិ នីលចីវរបារុតា
កុហា ថទ្ធា លបា សិង្គី ចរិស្សន្ត្យរិយា វិយ ។
តេលសណ្ឋេហិ កេសេហិ ចបលា អញ្ជនក្ខិកា
រថិយាយ គមិស្សន្តិ ទន្តវណ្ណកបារុតា ។
អជេគុច្ឆំ វិមុត្តេហិ សុរត្តំ អរហទ្ធជំ
ជិគុច្ឆិស្សន្តិ កាសាវំ ឱទាតេសុ សមុច្ឆិតា ។
លាភកាមា ភវិស្សន្តិ កុសីតា ហីនវីរិយា
កិច្ឆន្តា វនបត្ថានិ គាមន្តេសុ វសិស្សរេ ។
យេ យេ លាភំ លភិស្សន្តិ មិច្ឆាជីវរតា សទា
តេ តេ ច អនុសិក្ខន្តា គមិស្សន្តិ[១] អសញ្ញតា ។

១ ឱ. ម. ភជិស្សន្តិ អសំយតា ។

ឯពួកភិក្ខុមានគុណ មានហិរិ មិនមានសេចក្តីត្រូវការ (របស់អ្វី) កាលពោលពាក្យក្នុងសង្ឃតាមសេចក្តីពិត នឹងជាអ្នកមានកម្លាំងថយ ។ ក្នុងអនាគតកាល ពួកភិក្ខុដែលឥតប្រាជ្ញា នឹងត្រេកត្រអាលចំពោះប្រាក់មាស ស្រែ ចម្ការ ពពែ ចៀម ខ្ញុំស្រី និងខ្ញុំប្រុស ។ ពួកភិក្ខុពាលជាអ្នកសម្គាល់ ក្នុងការលើកទោស មិនតាំងមាំក្នុងសីលទាំងឡាយជាអ្នកក្រអឺតក្រអោង ត្រេកត្រអាលក្នុងជម្លោះ នឹងត្រាច់ទៅផ្សេង ៗ ដូចម្រឹគ មួយទៀត នឹងមានពួកភិក្ខុជាអ្នករាយមាយស្លៀកដណ្តប់ចីវរមានពណ៌ខៀវ ជាមនុស្សកុហក ជាបុគ្គលរឹងត្អឹង ជាអ្នកចរចារួសរាយ មានកិលេសដូចស្នែង នឹងប្រព្រឹត្តដូចព្រះអរិយៈ ។ ពួកភិក្ខុដែលមានសក់រលើបដោយប្រេង ជាអ្នកឃ្វេងឃ្វាង មានភ្នែកលាបថ្នាំដណ្តប់សំពត់មានសម្បុរដូចភ្លុក នឹងដើរតាមច្រក ។ ភិក្ខុពាលទាំងនោះនឹងខ្ពើមនូវសំពត់កាសាវៈ ដែលពួកព្រះអរិយៈ មានចិត្តផុតស្រឡះមិនខ្ពើម ជាសំពត់ជ្រលក់ត្រឹមត្រូវ ជាទង់ជ័យនៃព្រះអរិយៈ ហើយជាអ្នកជ្រប់នៅតែក្នុងសំពត់មានពណ៌ស ។ នឹងមានពួកភិក្ខុជាអ្នកប្រាថ្នាលាភ ជាបុគ្គលខ្ជិល មានព្យាយាមទន់ ទាំងជាបុគ្គលធុញទ្រាន់នឹងព្រៃធំ ៗ ទាំងឡាយ ហើយនៅតែក្នុងសេនាសនៈជិត ៗ ស្រុក ។ ពួកភិក្ខុណា ៗ ត្រេកអរក្នុងមិច្ឆាជីវៈ នឹងបានលាភគ្រប់កាលទាំងពួងពួកភិក្ខុដែលសិក្សាតាមភិក្ខុទាំងនោះ ៗ ក៏នឹងទៅជាអ្នកមិនសង្រួម ។

៨៦



យេ យេ អលាភិនោ លាភំ ន តេ បុជ្ជា ភវិស្សរេ
សុបេសលេបិ តេ ធីរេ សេវិស្សន្តិ ន តេ តទា ។
មិលក្ខុរជនំ រត្តំ គរហន្តា សកំ ធជំ
តិត្ថិយានំ ធជំ កេចិ ធារេស្សន្ត្យវទាតកំ ។
អគារវោ ច កាសាវេ តទា តេសំ ភវិស្សតិ
បដិសង្ខា ច កាសាវេ ភិក្ខូនំ ន ភវិស្សតិ ។
អភិភូតស្ស ទុក្ខេន សល្លវិទ្ធស្ស រុប្បតោ
បដិសង្ខា មហាឃោរា នាគស្សាសិ អចិន្តិយា ។
ឆទ្ទន្តោ ហិ តទា ទិស្វា សុរត្តំ អរហទ្ធជំ
តាវទេវ ភណី គាថា គជោ អត្ថោបសញ្ហិតា ។
អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។
យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

ពួកភិក្ខុណា ៗ ជាអ្នកមិនបានលាភ ពួកភិក្ខុទាំងនោះ នឹងមិនមានគេបូជា ពួកភិក្ខុទាំងនោះ នឹងមិនគប់រកនូវអ្នកប្រាជ្ញដែលមានសីលជាទីស្រឡាញ់ក្នុងកាលនោះ ។ ពួកភិក្ខុខ្លះ នឹងតិះដៀលនូវសំពត់កាសាវៈជាទង់ជ័យរបស់ខ្លួន ហើយទៅស្លៀកដណ្ដប់សំពត់ ជាទង់ជ័យពួកតិរ្ថិយ ដែលជ្រលក់ដោយមក្លឿក៏មាន ជាសំពត់ស ក៏មាន ។ សេចក្ដីមិនគោរពក្នុងសំពត់កាសាវៈ នៃពួកភិក្ខុទាំងនោះ នឹងមានក្នុងកាលនោះ ទាំងការពិចារណាក្នុងសំពត់កាសាវៈនៃពួកភិក្ខុ ក៏នឹងមិនមានដែរ ។ ដំរីដ៏ប្រសើរ កាលត្រូវសេចក្ដីទុក្ខគ្របសង្កត់ ត្រូវសរមុត ញាំរកាយចំប្រប់ ក៏មានការគិតពិចារណា ដ៏ខ្លាំងក្រៃលែង ជាគំនិតដែលមិនធ្លាប់គិតមក ។ ព្រោះថា គ្រានោះ ដំរីឆទ្ទន្ត បានឃើញសំពត់កាសាវៈ ជាទង់ជ័យព្រះអរហន្ត ដែលជ្រលក់យ៉ាងល្អ ហើយបានពោលនូវគាថាទាំងឡាយ ដែលប្រកបដោយប្រយោជន៍ ក្នុងខណៈនោះឯង ។ បុគ្គលណា មិនទាន់ប្រាសចាកទឹកចត់គឺរាគាទិក្កិលេស ជាអ្នកប្រាសចាកទមៈនិងសច្ចៈ ស្លៀកដណ្ដប់នូវសំពត់កាសាវៈ បុគ្គលនោះ មិនគួរ(ស្លៀកដណ្ដប់) នូវសំពត់កាសាវៈឡើយ ។ លុះតែបុគ្គលណា បានខ្ជាក់ចោលនូវទឹកចត់ គឺរាគាទិក្កិលេស តាំងមាំល្អក្នុងសីលទាំងឡាយ ប្រកបដោយទមៈ និងសច្ចៈ បុគ្គលនោះឯង ទើបគួរ(ស្លៀកដណ្ដប់) នូវសំពត់កាសាវៈ ។

## ៨៧

### ថេរគាថាយ តឹសនិបាតោ

វិបន្នសីលោ ទុម្មេធោ ចាកដោ កាមការិយោ
វិក្ខិត្តចិត្តោ និស្សុក្កោ ន សោ កាសាវមរហតិ ។
យោ ច សីលេន សម្បន្នោ វីតរាគោ សមាហិតោ
ឱទាតមនសង្កប្បោ ស វេ កាសាវមរហតិ ។
ឧទ្ធតោ ឧន្នឡោ ពាលោ សីលំ យស្ស ន វិជ្ជតិ
ឱទាតកំ អរហតិ កាសាវំ កឹ ករិស្សតិ ។
ភិក្ខូ ច ភិក្ខុនិយោ ច ទុដ្ឋចិត្តា អនាទរា
តាទីនំ មេត្តចិត្តានំ និគ្គណ្ហិស្សន្តនាគតេ ។
សិក្ខាបេន្តាបិ ថេរេហិ ពាលា ចីវរធារណំ
ន សុណិស្សន្តិ ទុម្មេធា ចាកដា កាមការិយា ។
តេ តថា សិក្ខិតា ពាលា អញ្ញមញ្ញំ អគារវា
នាទិយិស្សន្តុបជ្ឈាយេ ខលុង្កោ វិយ សារថឹ ។
ឯវំ អនាគតទ្ធានំ បដិបត្តិ ភវិស្សតិ
ភិក្ខូនំ ភិក្ខុនីនញ្ច បត្តេ កាលម្ហិ បច្ឆិមេ ។

បុគ្គលណា ជាអ្នកវិបត្តិសីល មានគំនិតអាក្រក់ ប្រាកដជាអ្នកទ្រុស្ត សីល ធ្វើតាមតែប្រាថ្នា មានចិត្តរាយមាយ មិនមានធម៌ស បុគ្គលនោះ មិនគួរ(ស្លៀកដណ្តប់) នូវសំពត់កាសាវៈឡើយ ។ លុះតែបុគ្គលណា បរិបូណ៌ដោយសីល ប្រាសចាកឆន្ទរាគ មានចិត្តតាំងមាំ មានសេចក្តីត្រិះរិះក្នុងចិត្តដ៏ស បុគ្គលនោះឯង ទើបគួរ (ស្លៀកដណ្តប់) នូវសំពត់កាសាវៈ សីលរបស់បុគ្គលណាមិនមាន បុគ្គលនោះ ជាអ្នករវើរវាយ ក្រអឺតក្រអោង ជាបុគ្គលពាល គួរតែ (ស្លៀកដណ្តប់) នូវសំពត់មានពណ៌ស នឹងស្លៀកដណ្តប់នូវសំពត់កាសាវៈដូចម្តេចកើត ។ ក្នុងកាលជាអនាគត ពួកភិក្ខុ ភិក្ខុនី ជាអ្នកមានចិត្តប្រទូស្ត ជាអ្នកឃ្នើសឃ្នង នឹងសង្កត់សង្កិន នូវពួកលោកដែលប្រកបដោយតាទិគុណ មានចិត្តប្រកបដោយមេត្តា ។ ពួកភិក្ខុពាល ដែលមានគំនិតអាក្រក់ ប្រាកដជាអ្នកទ្រុស្តសីល ធ្វើតាមតែប្រាថ្នា កាលបើពួកព្រះថេរៈបង្ហាត់នូវការស្លៀកដណ្តប់ចីវរ នឹងមិនព្រមស្តាប់ ។ ពួកភិក្ខុពាលទាំងនោះ ដែលឧបជ្ឈាយាចារ្យឲ្យសិក្សាយ៉ាងនោះហើយ ក៏ជាបុគ្គលមិនមានការគោរពគ្នានិងគ្នា នឹងមិនអើពើចំពោះឧបជ្ឈាយាចារ្យ ដូចសេះមានពុតត្បុត មិនអើពើនឹងនាយសារថី ។ ក្នុងកាលជាអនាគត ពួកភិក្ខុ ភិក្ខុនី នឹងមានសេចក្តីប្រតិបត្តិ យ៉ាងនេះ ក្នុងបច្ឆិមកាល ដែលមកដល់ ។

បុរា អាគច្ឆតេ ឯតំ អជាតតំ មហព្ភយំ
សុពចា ហោថ សខិលា អញ្ញមញ្ញំ សគារវា ។
មេត្តចិត្តា ការុណិកា ហោថ សីលេសុ សំវុតា
អារទ្ធវីរិយា បហិតត្តា និច្ចំ ទឡ្ហបរក្កមា ។
បមាទំ ភយតោ ទិស្វា អប្បមាទញ្ច ខេមតោ
ភាវេថដ្ឋង្គិកំ មគ្គំ ផុសន្តា អមតំ បទន្តិ ។

បុស្សត្ថេរោ[១] ។

[២៦០] យថាចារី យថាសតោ សតិមា
យថាសង្កប្បចរិយាយ[២] អប្បមត្តោ
អជ្ឈត្តរតោ សុសមាហិតត្តោ
ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។
អល្លំ សុក្ខំ វ ភុញ្ជន្តោ ន ពាឡ្ហំ សុហិតោ សិយា
ឩនូទរោ មិតាហារោ សតោ ភិក្ខុ បរិព្វជេ ។
ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ
អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ ។

១ ឱ. ម. ផុស្សត្ថេរោ ។ ២ សំយតសង្កប្បិបរិឈាយីតិ អដ្ឋកថាយំ ទិស្សតិ ។

ភ័យដ៏ធំនេះ ដែលមិនទាន់មកដល់ ក៏រមែងមកដល់មុនមិនខាន អ្នកទាំងឡាយ ចូរជាបុគ្គលប្រដៅងាយ មានចិត្តដ៏ទន់ ប្រកបដោយសេចក្តីគោរពដល់គ្នានិងគ្នាចុះ ។ អ្នកទាំងឡាយ ចូរជាបុគ្គលមានចិត្តមេត្តា ករុណា សង្រួមក្នុងសីលទាំងឡាយ មានការព្យាយាមតឹងតែងមានចិត្តស្ទុងទៅកាន់និព្វាន មានសេចក្តីសង្វាតមាំ អស់កាលជានិច្ចចុះ ។ អ្នកទាំងឡាយ បើឃើញសេចក្តីប្រមាទថាជាភ័យ ទាំងឃើញនូវសេចក្តីមិនប្រមាទថាជាទីក្សេមហើយ ចូរចម្រើននូវមគ្គមានអង្គ ៨ (កាលបើយ៉ាងនេះ) ពួកភិក្ខុ ក៏រមែងបាននូវអមតបទគឺព្រះនិព្វាន ។

បុស្សត្ថេរ ។

[២៦០] បុគ្គលណា ជាអ្នកប្រព្រឹត្តសមគួរ ជាអ្នកស្ងប់សមគួរ មានស្មារតី ជាអ្នកមិនធ្វេសប្រហែស ក្នុងការត្រិះរិះ និងការប្រព្រឹត្តសមគួរ ត្រេកអរដោយភាវនាក្នុងសន្តាន មានចិត្តតាំងមាំ ជាបុគ្គលម្នាក់ឯង មានសេចក្តីសន្តោស អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាភិក្ខុ ។

ភិក្ខុកាលបរិភោគ នូវអាហារស្រស់ ឬក្រៀម មិនគប្បីឲ្យឆ្អែតជ្រុលទេ គប្បីជាអ្នកមានពោះធូរ មានអាហារដ៏ល្មមមានស្មារតីវៀរចេញ ។ ភិក្ខុឈប់បរិភោគ៤ ឬ៥ពំនូត(ក្នុងកាលជិតឆ្អែត)ហើយគប្បីផឹកទឹកនេះជាការល្មមដល់កិរិយានៅជាសុខ នៃភិក្ខុអ្នកមានចិត្តស្ទុងទៅរក (ព្រះនិព្វាន) ។

## ថេរគាថាយ តឹសនិបាតោ

កប្បិយតញ្ចូ អាទេតិ[១] ចីវរំ ឥធមត្តិកំ
អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ ។
បល្លង្កេន និសិន្នស្ស ជណ្ណុកេ នាភិវស្សតិ
អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ ។
យោ សុខំ ទុក្ខតោ អទ្ទ ទុក្ខំ អទ្ទក្ខិ សល្លតោ
ឧភយន្តរេន នាហោសិ កេន លោកស្មិ កឹ សិយា ។
មា មេ កទាចិ បាបិច្ឆោ កុសីតោ ហីនវីរិយោ
អប្បស្សុតោ អនាទរោ កេន លោកស្មិ កឹ សិយា ។
ពហុស្សុតោ ច មេធាវី សីលេសុ សុសមាហិតោ
ចេតោសមថមនុយុត្តោ អបិ មុទ្ធនិ តិដ្ឋតុ ។
យោ បបញ្ចមនុយុត្តោ បបញ្ចាភិរតោ មគោ
វិរាធយី សោ និព្វានំ យោគក្ខេមំ អនុត្តរំ ។

១ ម. កប្បិយំ តញ្ចេ ឆាទេតិ ។

ភិក្ខុស្លៀកដណ្តប់ នូវចីវរជាកប្បិយៈ ប្រយោជន៍ (ត្រឹមតែការពារត្រជាក់ជាដើម) នេះ ជាការគួរដល់កិរិយានៅជាសុខ នៃភិក្ខុអ្នកមានចិត្តស្ទុងទៅរក(ព្រះនិព្វាន) ។ កាលភិក្ខុអង្គុយដោយភ្នែន ភ្លៀងមិនស្រក់ត្រូវត្រង់ជង្គង់ទាំងពីរ នេះជាការគួរដល់កិរិយានៅជាសុខ នៃភិក្ខុអ្នកមានចិត្តស្ទុងទៅរក (ព្រះនិព្វាន) ។ បុគ្គលណាបានឃើញសុខ ថាជាទុក្ខ បានឃើញទុក្ខ ថាជាគ្រឿងចាក់ដោត ដូចកូនសរការជាប់ចំពាក់មិនមានក្នុងចន្លោះនៃសុខនិងទុក្ខទាំងពីរ បុគ្គលនោះគប្បីជាប់ក្នុងលោកដូចម្តេច គប្បីមានដោយកិលេសដូចម្តេចបាន ។ បុគ្គលមានសេចក្តីប្រាថ្នាអាក្រក់ ជាអ្នកខ្ជិលច្រអូស មានការព្យាយាមថោកទាប ជាអ្នករៀនសូត្រតិច មិនអើពើ (ចំពោះធម៌និងវិន័យ) សូមកុំមានក្នុងសំណាក់ខ្ញុំ ក្នុងកាលណាៗឡើយ ប្រយោជន៍អ្វីដោយឱវាទក្នុងលោក គប្បីមាន (ដល់បុគ្គលនោះ) ដោយបការៈដូចម្តេច ។ មួយទៀត បុគ្គលអ្នកចេះដឹងច្រើន មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស តាំងមាំក្នុងសីល ប្រកបរឿយៗនូវចេតោសមថៈសូមឋិតនៅសូម្បីលើក្បាល ។ បុគ្គលណាមានចិត្តប្រកបរឿយ ៗ នូវធម៌ជាគ្រឿងយឺតយូរ ត្រេកអរចំពោះធម៌ជាគ្រឿងយឺតយូរ បុគ្គលនោះឈ្មោះថា ឃ្លាតចាកព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។

យោ ច បបញ្ចំ ហិត្វាន និប្បបញ្ចបថេ រតោ
អារាធយី សោ និព្វានំ យោគក្ខេមំ អនុត្តរំ ។
គាមេ វា យទិ វារញ្ញេ និន្នេ វា យទិ វា ថលេ
យត្ថ អរហន្តោ វិហរន្តិ តំ ភូមិរាមណេយ្យកំ ។
រមណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ
វីតរាគា រមិស្សន្តិ ន តេ កាមគវេសិនោ ។
និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន ចាបិយោ ។
ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។
អញ្ញស្ស ភគវា ពុទ្ធោ ធម្មំ ទេសេសិ ចក្ខុមា
ធម្មេ ទេសិយមានម្ហិ សោតមោធេសិមត្ថិកោ ។
តំ មេ អមោឃំ សវនំ វិមុត្តោម្ហិ អនាសវោ
នេវ បុព្វេនិវាសាយ នបិ ទិព្វស្ស ចក្ខុនោ ។

បុគ្គលណាលះបង់នូវធម៌ជាគ្រឿងឃឺតយូរ ត្រេកអរក្នុងធម៌ជាផ្លូវមិនឃឺតយូរ បុគ្គលនោះ ឈ្មោះថាត្រេកអរនឹងព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។ ព្រះអរហន្តទាំងឡាយនៅក្នុងទីណា ទោះបីស្រុកឬព្រៃ ទោះបីទំនាប ឬ ទួល ទីនោះឯង ជាទីគួរត្រេកអរ ។ ជនអ្នក (ស្វែងរកកាម) រមែងមិនត្រេកអរក្នុងព្រៃជាទីគួរត្រេកអរទេ ពួកបុគ្គលអ្នកប្រាសចាករាគៈ ទើបត្រេកអរ ព្រោះពួកលោកទាំងនោះ មិនមែនជាអ្នកស្វែងរកកាម ។ បុគ្គលឃើញអ្នកប្រាជ្ញណា ជាអ្នកពោលសង្កត់សង្កិន ជាអ្នកបង្ហាញទោស ដូចគេបង្ហាញនូវកំណប់ទ្រព្យ គួរគប់រកអ្នកប្រាជ្ញមានសភាពដូច្នោះ ។ កាលបើបុគ្គលគប់រកអ្នកប្រាជ្ញប្រាកដដូច្នោះ សេចក្តីប្រសើររមែងមាន សេចក្តីអាក្រក់ពុំមានទេ ។ បុគ្គលណាទូន្មានប្រៀនប្រដៅ ហាមឃាត់ (គេ) ចាកអសប្បុរិសធម៌ បុគ្គលនោះ រមែងជាទីស្រឡាញ់របស់ពួកសប្បុរស តែមិនជាទីស្រឡាញ់របស់ពួកអសប្បុរសទេ ។ ព្រះពុទ្ធ មានព្រះភាគ មានចក្ខុ បានសម្តែងធម៌ដល់បុគ្គលដទៃ នាកាលធម៌ដែលព្រះអង្គសម្តែង ខ្ញុំមានសេចក្តីត្រូវការផ្ចង់សោតប្បសាទ ។ ការស្តាប់របស់ខ្ញុំនោះ មិនឥតអំពើទេ (ព្រោះ) ខ្ញុំជាអ្នកមិនមានអាសវៈ រួចស្រឡះហើយ ខ្ញុំមិនមានការតាំងចិត្តចំពោះបុព្វេនិវាសានុស្សតិវិជ្ជាឬទិព្វចក្ខុវិជ្ជាឡើយ ។

៩១



ចេតោបរិយាយ ឥទ្ធិយា ចុតិយា ឧបបត្តិយា
សោតធាតុវិសុទ្ធិយា បណិធី មេ ន វិជ្ជតិ ។
រុក្ខមូលំ វ និស្សាយ មុណ្ឌោ សង្ឃាដិបារុតោ
បញ្ញាយ ឧត្តមោ ថេរោ ឧបតិស្សោវ ឈាយតិ ។
អវិតក្កំ សមាបន្នោ សម្មាសម្ពុទ្ធសាវកោ
អរិយេន តុណ្ហីភាវេន ឧបេតោ ហោតិ តាវទេ ។
យថាបិ បព្វតោ សេលោ អចលោ សុបតិដ្ឋិតោ
ឯវំ មោហក្ខយា ភិក្ខុ បព្វតោវ ន វេធតិ ។
អនង្គណស្ស បោសស្ស និច្ចំ សុចិគវេសិនោ
វាលគ្គមត្តំ បាបស្ស អព្ភា មត្តំវ ខាយតិ ។
នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ
និក្ខិបិស្សំ ឥមំ កាយំ សម្បជានោ បតិស្សតោ ។
នាភិនន្ទាមិ មរណំ ។ បេ ។ និព្វិសំ ភតកោ យថា ។
ឧភយេនមិទំ មរណមេវ
នាមរណំ បច្ឆា វា បុរេ វា
បដិបជ្ជថ មា វិនស្សថ ខណោ វេ មា ឧបច្ចគា ។
នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ ខណោ វេ មា ឧបច្ចគា

ខ្ញុំមិនមានការតាំងចិត្តចំពោះចេតោបរិយវិជ្ជា ឥទ្ធិវិធវិជ្ជា ចុតូបបាតវិជ្ជា និងសេចក្តីបរិសុទ្ធនៃសោតធាតុឡើយ ។ ព្រះថេរៈឈ្មោះឧបតិស្សៈខ្ពង់ខ្ពស់ដោយប្រាជ្ញា ទើបកោរថ្មីៗ ដណ្តាប់សង្ឃាដីអាស្រ័យនៅក្រោមម្លប់ឈើ ចម្រើនឈាន ។ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ចូលកាន់ឈាន មិនមានវិតក្កៈ ប្រកបដោយតុណ្ហីភាពដ៏ប្រសើរក្នុងខណៈនោះឯង ។ ភ្នំថ្ម មិនកម្រើក បិតនឹងថ្កល់យ៉ាងណា ភិក្ខុ ព្រោះអស់ទៅនៃមោហៈ ក៏មិនញាប់ញ័រដូចភ្នំយ៉ាងនោះដែរ ។ បុគ្គលអ្នកមិនមានទីទួលគឺកិលេស ស្វែងរកនូវធម៌ដ៏ស្អាតអស់កាលជានិច្ច សូម្បីបាបប្រមាណប៉ុនចុងរោមកន្ទុយសត្វ រមែងប្រាកដដូច (ព្រះចន្ទ្រ) ដែលផុតចាកពពក ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំជាបុគ្គលដឹងខ្លួន មានស្មារតីខ្ជាប់ខ្ជួន ទម្លាយចោលនូវរាងកាយនេះ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ទេ ។ បេ ។ ដូចអ្នកស៊ីឈ្នួលទន្ទឹងតែការអស់ទៅនៃថ្ងៃ ។

មរណៈនេះឯង រមែងមានក្នុងកាលទាំងពីរ មរណៈមិនមែន
មានតែក្នុងកាលខាងក្រោយ ឬខាងមុខទេ អ្នកទាំងឡាយ ចូរ
ប្រតិបត្តិ អ្នកទាំងឡាយចូរកុំវិនាស កុំឲ្យខណៈប្រព្រឹត្តកន្លង ។

អ្នកទាំងឡាយ ចូរគ្រប់គ្រងខ្លួន ឲ្យដូចជានគរត្រង់ទីប្រទល់ដែនដែលគេគ្រប់គ្រងទាំងខាងក្នុងទាំងខាងក្រៅ កុំឲ្យខណៈប្រព្រឹត្តកន្លង ។

ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។
ឧបសន្តោ ឧបរតោ មន្តភាណី អនុទ្ធតោ
ធុនាតិ បាបកេ ធម្មេ ទុមបត្តំវ មាលុតោ ។
ឧបសន្តោ ឧបរតោ មន្តភាណី អនុទ្ធតោ
អព្វហិ បាបកេ ធម្មេ ទុមបត្តំវ មាលុតោ ។
ឧបសន្តោ អនាយាសោ វិប្បសន្នមនាវិលោ
កល្យាណសីលោ មេធាវី ទុក្ខស្សន្តករោ សិយា ។

ន វិស្សសេ ឯកតិយេសុ ឯវំ
អគារិសុ បព្វជិតេសុ ចាបិ
សាធូបិ ហុត្វាន អសាធុ ហោន្តិ
អសាធុ ហុត្វា បុន សាធុ ហោន្តិ ។

កាមច្ឆន្ទោ ច ព្យាបាទោ ថីនមិទ្ធញ្ច ភិក្ខុនោ
ឧទ្ធច្ចំ វិចិកិច្ឆា ច បញ្ចេ តេ ចិត្តកេលិសា ។
យស្ស សក្ការិយមានស្ស អសក្ការេន ចូភយំ
សមាធិ ន វិកម្បតិ អប្បមាទវិហារិនោ ។

ព្រោះថា ពួកបុគ្គលដែលមានខណៈកន្លងហួសហើយ រមែងសោកស្តាយដេរដាស ក្នុងនរក ។ បុគ្គលអ្នកស្ងប់ វៀរចាកបាប ពោលពាក្យដោយយោបល់ ជាបុគ្គលមិនរាយមាយ រមែងកម្ចាត់បង់នូវធម៌ដ៏លាមកបាន ដូចខ្យល់កម្ចាត់បង់នូវស្លឹកឈើ ។ បុគ្គលអ្នកស្ងប់ វៀរចាកបាប ពោលពាក្យដោយយោបល់ ជាបុគ្គលមិនរាយមាយ រមែងដកភើច នូវពួកធម៌ដ៏លាមកចេញបាន ដូចខ្យល់បក់ផ្តាច់នូវស្លឹកឈើ ។ បុគ្គលអ្នកស្ងប់ មិនមានសេចក្តីក្រវល់ក្រវាយ មានចិត្តថ្លាមិនល្អក់ មានកល្យាណសីល មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស គប្បីធ្វើនូវទីបំផុតនៃទុក្ខបាន ។

បុគ្គលមិនគប្បីស្និទ្ធស្នាល ចំពោះបុថុជ្ជនពួកខ្លះ ទាំងគ្រហស្ថទាំងបព្វជិត ព្រោះថា ពួកជន សូម្បីជាបុគ្គលល្អហើយ បែរទៅជាមិនល្អវិញក៏មាន ជាបុគ្គលមិនល្អហើយ បែរទៅជាល្អវិញ ក៏មាន ។

កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចៈ ១ វិចិកិច្ឆា ១ ទាំង ៥ នោះ ជាគ្រឿងសៅហ្មងចិត្ត របស់ភិក្ខុ ។ ភិក្ខុណា កាលគេធ្វើសក្ការៈ ឬមិនធ្វើសក្ការៈទាំងពីរ (មិនត្រេកអរ មិនទោមនស្ស) សមាធិរបស់ភិក្ខុអ្នកនៅដោយសេចក្តីមិនប្រមាទនោះ រមែងមិនញាប់ញ័រ ។

៩៣

ថេរគាថាយ តឹសនិបាតោ

តំ ឈាយិនំ សាតតិកំ សុខុមជិដ្ឋិវិបស្សកំ
ឧចាជានក្ខយារាមំ អាហុ សប្បុរិសោ ឥតិ ។
មហាសមុទ្ទោ បឋវី បព្វតោ អនិលោបិ ច
ឧបមាយ ន យុញ្ជន្តិ សត្ថុ វរវិមុត្តិយា ។
ចក្កានុវត្តកោ ថេរោ មហាញាណី សមាហិតោ
បឋវាបគ្គិសមានោ ន រជ្ជតិ ន ទុស្សតិ ។
បញ្ញាចារមិតំ បត្តោ មហាពុទ្ធិ មហាមុនិ
អជឡោ ជឡសមានោ សទា ចរតិ និព្វុតោ ។
បរិចិណ្ណោ មយា សត្ថា ។ បេ ។ ភវនេត្តិ សមូហតា ។
សម្បាទេថប្បមាទេន ឯសា មេ អនុសាសនី
ហន្ទាហំ បរិនិព្វិស្សំ វិប្បមុត្តោម្ហិ សព្វធីតិ ។

សារីបុត្តោ ថេរោ ។

[២៦១] បិសុណេន ច កោធនេន
មច្ឆរិនា ច វិភូតិនន្ទិនា
សខិតំ ន ករេយ្យ បណ្ឌិតោ
ចាចោ កាបុរិសេន សង្គមោ ។

អ្នកប្រាជ្ញទាំងឡាយ សរសើរ នូវភិក្ខុអ្នកមានឈាន មានព្យាយាមទៀងទាត់ មានការឃើញច្បាស់ដោយសុខុមទិដ្ឋិ ត្រេកអរក្នុងធម៌ជាទីអស់ទៅនៃឧបាទាននោះថា ជាសប្បុរស ។ មហាសមុទ្រ ប្រឹថពី ភ្នំ និងខ្យល់ មិនគួរឧបមា និងវិមុត្តិដ៏ប្រសើរ របស់ព្រះសាស្តាទេ ។ ព្រះថេរៈអ្នកញ៉ាំងចក្កគឺធម៌ឲ្យប្រព្រឹត្តទៅតាម (ព្រះសារីបុត្ត) លោកមានប្រាជ្ញាច្រើន មានចិត្តខ្ជាប់ខ្ជួន ស្មើដោយដី ទឹក ភ្លើង មិនត្រេកអរ មិនប្រទូស្ត ។ ព្រះថេរៈ សម្រេចនូវបញ្ញាបារមី មានប្រាជ្ញាច្រើន ជាមហាមុនិ ជាបុគ្គលមិនគ តែមានសភាពដូចជាគ មានចិត្តដ៏ត្រជាក់គ្រប់កាល ។ ព្រះសាស្តា ខ្ញុំបានបម្រើហើយ ។ បេ ។ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏បានដកចេញហើយ ។ អ្នកទាំងឡាយ ចូរញ៉ាំងសេចក្តីមិនប្រមាទឲ្យបរិបូណ៌ នេះជាពាក្យប្រៀនប្រដៅរបស់ខ្ញុំ ឥឡូវនេះ ខ្ញុំនឹងបរិនិព្វាន ខ្ញុំជាបុគ្គលផុតស្រឡះចាកកិលេសកាមទាំងអស់ ។

សារីបុត្តត្ថេរ ។

[២៦១] បណ្ឌិតមិនគួរធ្វើសខិភាព គឺភាពជាសំឡាញ់នឹង
បុគ្គលអ្នកញុះញង់ អ្នកក្រេវក្រោធ អ្នកកំណាញ់
ទាំងជាអ្នកត្រេកអរនឹងសេចក្តីវិនាសទេ (ព្រោះថា)
ការសមគប់នឹងបុរសអាក្រក់ ជាអំពើដ៏លាមក ។

សទ្ធេន ច បេសលេន ច

បញ្ញវតា ពហុស្សុតេន ច

សខិតំ ហិ ករេយ្យ បណ្ឌិតោ

ភព្វោ សប្បុរិសេហិ សង្គមោ ។

បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ

អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។

ពហុស្សុតោ ចិត្តកថី ពុទ្ធស្ស បរិចារកោ

បន្នភារោ វិសញ្ញុត្តោ សេយ្យំ កប្បេតិ គោតមោ ។

ខីណាសវោ វិសញ្ញុត្តោ សង្គាតីតោ សុនិព្វុតោ

ធារេតិ អន្តិមំ ទេហំ ជាតិមរណបារគូ ។

យស្មឹ បតិដ្ឋិតា ធម្មា ពុទ្ធស្សាទិច្ចពន្ធុនោ

និព្វានគមនេ មគ្គេ សោយំ តិដ្ឋតិ គោតមោ ។

ទ្វាសីតិ ពុទ្ធតោ គណ្ហឹ ទ្វេ សហស្សានិ ភិក្ខុតោ

ចតុរាសីតិ សហស្សានិ យេ មេ ធម្មា បវត្តិនោ ។

*បណ្ឌិតគួរធ្វើសេពគ្គពនឹងបុគ្គលអ្នកមានសទ្ធា មានសីល ជាទីស្រឡាញ់ អ្នកមានប្រាជ្ញា មានការចេះដឹងច្រើន (ព្រោះថា) ការសមគប់នឹងពួកសប្បុរស ជាការចម្រើន ។*

*អ្នកចូរមើលនូវពុម្ពគឺអត្តភាពដែលធ្វើឲ្យវិចិត្រ ជាទីប្រជុំនៃដំបៅ ផ្គុំឡើង (ដោយឆ្អឹង ៣០០ កំណាត់) ជាគ្រឿងពោលពាល ជាទីប្រាថ្នានៃជនច្រើន ជាកាយឥតទៀងទាត់ឋិតថេរ ព្រះអានន្ទត្ថេរជាគោតមគោត្រ ជាអ្នកចេះដឹងច្រើន មានវាចាដ៏វិចិត្រ ជាអ្នកបម្រើនូវព្រះពុទ្ធ បានដាក់ចុះនូវភារៈ ជាអ្នកប្រាសចាកកិលេសជាគ្រឿងប្រកប សម្រេចនូវការសិង ។ ព្រះអានន្ទត្ថេរ ជាខីណាស្រព ប្រាសចាកកិលេសជាគ្រឿងប្រកប កន្លងនូវកិលេសជាគ្រឿងជាប់ចំពាក់ មានចិត្តត្រជាក់ល្អ ដល់នូវត្រើយនៃជាតិ និងមរណៈ ទ្រទ្រង់ទុកនូវអត្តភាពជាបំផុត ។ សាសនធម៌ទាំងឡាយ របស់ព្រះពុទ្ធ ជាអាទិច្ចពន្ធុ ប្រតិស្ឋានក្នុងព្រះអានន្ទត្ថេរណា ព្រះអានន្ទត្ថេរនោះ ជាគោតមគោត្រ ឋិតនៅក្នុងផ្លូវជាទីទៅកាន់ព្រះនិព្វាន ។ សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ (ក្នុងហឫទយ័) របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ហ្មឺន ៤ ពាន់ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ហ្មឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ។*

៩៨

## ថេរគាថាយ តឹសនិបាតោ

អប្បស្សុតាយំ បុរិសោ	ពលិវទ្ទោវ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ	បញ្ញា តស្ស ន វឌ្ឍតិ ។
ពហុស្សុតោ អប្បស្សុតំ	យោ សុតេនាតិមញ្ញតិ
អន្ធោ បទីបធារោវ	តថេវ បដិភាតិ មំ ។
ពហុស្សុតំ ឧបាសេយ្យ	សុតញ្ច ន វិនាសយេ
តំ មូលំ ព្រហ្មចរិយស្ស	តស្មា ធម្មធរោ សិយា ។
បុព្វាបរញ្ញូ អត្ថញ្ញូ	និរុត្តិបទកោវិទោ
សុគ្គហីតញ្ច គណ្ហាតិ	អត្ថញ្ចោបបរិក្ខតិ ។
ខន្ត្យា ឆន្ទិកតោ ហោតិ	ឧស្សហិត្វា តុលេតិ តំ
សមយេ សោ បទហតិ	អជ្ឈត្តំ សុសមាហិតោ ។
ពហុស្សុតំ ធម្មធរំ	សប្បញ្ញំ ពុទ្ធសាវកំ
ធម្មវិញ្ញាណមាកង្ខំ	តំ ភជេថ តថាវិធំ ។
ពហុស្សុតោ ធម្មធរោ	កោសារក្ខោ មហេសិនោ
ចក្ខុ សព្វស្ស លោកស្ស	បូជនេយ្យោ ពហុស្សុតោ ។

បុរសនេះមិនបានរៀនសូត្រ រមែងចាស់(ឥតអំពើ) ដូចគោបម្រើ ចម្រើនតែសាច់ ត្រង់ប្រាជ្ញារបស់វា មិនចម្រើនឡើយ ។ បុគ្គលណាជាអ្នករៀនសូត្រច្រើន ហើយមើលងាយបុគ្គលអ្នកមិនបានរៀនសូត្រ ដោយការរៀនសូត្រ (របស់ខ្លួន) បុគ្គលនោះ ដូចមនុស្សខ្វាក់កាន់ប្រទីប រមែងភ្លឺច្បាស់ដល់ខ្ញុំយ៉ាងនេះឯង ។ បុគ្គលគួរចូលទៅអង្គុយជិតនឹងអ្នករៀនសូត្រច្រើនផង មិនគប្បីញុំាងការរៀនសូត្រឲ្យវិនាសផង (ព្រោះថា) ការរៀនសូត្រនោះជាឫសគល់នៃព្រហ្មចរិយធម៌ ហេតុនោះ បុគ្គលគួរជាអ្នកទ្រទ្រង់ធម៌ ។ បុគ្គលអ្នកចេះដឹង នូវខាងដើម និងខាងចុង (នៃភាសិត) ជាអ្នកដឹងអត្ថ ឈ្លាសវៃក្នុងនិរុត្តិ (ភាសា) និងបទ (ដ៏សេស) រមែងកាន់យកនូវធម៌ឲ្យជាធម៌ដែលកាន់យកល្អហើយផង ពិចារណានូវសេចក្តីផង ។ បុគ្គលអ្នកមានសេចក្តីប្រាថ្នា (ក្នុងធម៌) ដោយសេចក្តីអត់ធន់ រមែងខ្មីឃ្មាត ពិចារណានូវនាមរូបនោះ បុគ្គលនោះមានចិត្តតាំងមាំល្អខាងក្នុងសន្តាន រមែងផ្តងចិត្តទុកក្នុងសម័យដ៏គួរ ។ បុគ្គល កាលប្រាថ្នានូវការដឹងធម៌ គប្បីគប់រកអ្នករៀនសូត្រច្រើន អ្នកចងចាំនូវធម៌ អ្នកមានប្រាជ្ញា ជាសាវ័ករបស់ព្រះពុទ្ធ បែបដូច្នោះនោះ ។ បុគ្គលអ្នករៀនសូត្រច្រើន រមែងជាអ្នកចងចាំនូវធម៌ អ្នករក្សាទុកនូវឃ្លាំងធម៌របស់ព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណាដ៏ធំ ឯបុគ្គលអ្នករៀនសូត្រច្រើននោះឈ្មោះថា ជាចក្ខុរបស់សត្វលោកទាំងពួង ជាបុគ្គលគួរគេបូជា ។

ធម្មារាមោ ធម្មរតោ    ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ    សទ្ធម្មា ន បរិហាយតិ ។
កាយមច្ឆេរគរុនោ    ហិយ្យមានេ អនុដ្ឋហេ
សរីរសុខគិទ្ធស្ស    កុតោ សមណផាសុតា ។
ន បក្ខន្តិ ទិសា សព្វា    ធម្មា ន បដិភន្តិ មំ
គតេ កល្យាណមិត្តម្ហិ    អន្ធការំវ ខាយតិ ។
អព្ភតីតសហាយស្ស    អតីតគតសត្ថុនោ
នត្ថិ ឯតាទិសំ មិត្តំ    យថា កាយគតា សតិ ។
យេ បុរាណា អតីតា តេ    ន វេហិ ន សមេតិ មេ
ស្វជ្ជ ឯកោវ ឈាយាមិ    វស្សុបេតោវ បក្ខិមា ។
ទស្សនាយ អភិក្កន្តេ    នានាវេរជ្ជកេ ពហូ
មា វារយិត្ថ សោតារោ    បស្សន្តុ សមយោ មមំ ។
ទស្សនាយ អភិក្កន្តេ    នានាវេរជ្ជកេ បុថូ
ករោន្តិ សត្ថា ឱកាសំ    ន និវារេតិ ចក្ខុមា ។
បណ្ណវីសតិ វស្សានិ    សេក្ខភូតស្ស មេ សតោ
ន កាមសញ្ញា ឧប្បជ្ជិ    បស្ស ធម្មសុធម្មតំ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ កាលគិតរឿយ ៗ នូវធម៌ រលឹករឿយ ៗ នូវធម៌ រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ។ បុគ្គលអ្នកជូន់ដោយសេចក្តីកំណាញ់(ថ្នម) កាយ (កាលបើកាយនិងជីវិត) សាបសូន្យទៅ ក៏មិនខ្មីឃ្មាត (ចំពោះកិច្ចគួរធ្វើ) បុគ្គលអ្នកជាប់ចំពាក់ដោយសេចក្តីសុខក្នុងសរីរៈ តើសេចក្តីសប្បាយ ដោយសមណភាព (នឹងមានមក) អំពីទីណា ។ ទិសទាំងអស់ រមែងមិនប្រាកដ ធម៌មិនភ្លឺច្បាស់ដល់ខ្ញុំ កាលបើព្រះសារីបុត្ត ជាកល្យាណមិត្ត ទៅ (កាន់និព្វាន) ហើយ សត្វលោកប្រាកដដូចជាទីងងឹត ។ បុគ្គលដែលមានសំឡាញ់ព្រាត់ប្រាសហើយ មានសាស្តាកន្លងទៅហើយ រមែងមិនមានមិត្តបែបនុ៎ះ ដូចជាកាយគតាសតិឡើយ ។ ពួកព្រះថេរៈណាចាស់ ៗ ពួកព្រះថេរៈនោះកន្លងទៅហើយ ចិត្តរបស់ខ្ញុំមិនល្មមនឹងភិក្ខុថ្មី ៗ ថ្ងៃនេះខ្ញុំចម្រើនឈានតែម្នាក់ឯង ដូចសត្វបក្សីចូលទៅសម្ងំក្នុងសម្បុក ក្នុងរដូវភ្លៀង ។ អ្នកកុំឃាត់ពួកជនច្រើននៅក្នុងប្រទេសផ្សេង ៗ ដែលពុំទាន់បានចួប ឯពួកអ្នកស្តាប់ ចូរមកចួបចុះ ព្រោះថាជាសម័យ (គួរចួប) នឹងខ្ញុំហើយ ។ ព្រះសាស្តាមានចក្ខុទ្រង់ប្រទានឱកាសមិនហាមឃាត់ពួកជនច្រើន នៅក្នុងប្រទេសផ្សេង ៗ ដែលពុំទាន់បានចួប ។ កាលខ្ញុំនៅជាសេក្ខបុគ្គលអស់ ២៥ ឆ្នាំ កាមសញ្ញាមិនកើតឡើងទេ អ្នកចូរមើលនូវសភាពល្អរបស់ធម៌ចុះ ។

៩៧

ថេរគាថាយ តឹសនិបាតោ

បណ្ណវីសតិ វស្សានិ សេខភូតស្ស មេ សតោ
ន ទោសសញ្ញា ឧប្បជ្ជិ បស្ស ធម្មសុធម្មតំ ។
បណ្ណវីសតិ វស្សានិ ភគវន្តំ ឧបដ្ឋហឹ
មេត្តេន កាយកម្មេន ឆាយាវ អនបាយិនី ។
បណ្ណវីសតិ វស្សានិ ភគវន្តំ ឧបដ្ឋហឹ
មេត្តេន វចីកម្មេន ឆាយាវ អនបាយិនី ។
បណ្ណវីសតិ វស្សានិ ភគវន្តំ ឧបដ្ឋហឹ
មេត្តេន មនោកម្មេន ឆាយាវ អនបាយិនី ។
ពុទ្ធស្ស ចង្កមន្តស្ស បិដ្ឋិតោ អនុចង្កមឹ
ធម្មេ ទេសិយមានម្ហិ ញាណំ មេ ឧទបជ្ជថ ។
អហំ សករណីយោម្ហិ សេក្ខោ អប្បត្តមានសោ
សត្ថុ ច បរិនិព្វានំ យោ អម្ហំ អនុកម្បកោ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេ ។
ពហុស្សុតោ ធម្មធរោ កោសារក្ខោ មហេសិនោ
ចក្ខុ សព្វស្ស លោកស្ស អានន្ទោ បរិនិព្វុតោ ។
ពហុស្សុតោ ធម្មធរោ កោសារក្ខោ មហេសិនោ
ចក្ខុ សព្វស្ស លោកស្ស អន្ធការេ តមោនុទោ ។

កាលខ្ញុំនៅជាសេក្ខបុគ្គលអស់ ២៥ ឆ្នាំ ទោសសញ្ញាមិនកើតឡើងទេ អ្នកចូរមើលនូវភាពល្អរបស់ធម៌ចុះ ។ ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយកាយកម្មប្រកបដោយមេត្តា អស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។ ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយវចីកម្មប្រកបដោយមេត្តា អស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។ ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយមនោកម្ម ប្រកបដោយមេត្តា អស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។ កាលព្រះពុទ្ធម្ចាស់ទ្រង់ចង្រ្កម ខ្ញុំបានចង្រ្កមតាមក្រោយព្រះអង្គ នាកាលធម៌ដែលព្រះអង្គសម្តែង ញាណរបស់ខ្ញុំក៏កើតឡើង ។ ខ្ញុំជាសេក្ខបុគ្គល ប្រកបដោយកិច្ច មានសេចក្តីប្រាថ្នាក្នុងចិត្តមិនទាន់សម្រេច (អរហត្តផល) ព្រះសាស្តា ព្រះអង្គអនុគ្រោះខ្ញុំ ទ្រង់បរិនិព្វាន ។ កាលព្រះសម្ពុទ្ធប្រកបដោយអាការដ៏ប្រសើរគ្រប់យ៉ាង ទ្រង់បរិនិព្វានហើយ សេចក្តីស្ញប់ស្ញែងនៃខ្ញុំក៏កើតមាន សេចក្តីព្រឺរោមនៃខ្ញុំក៏កើតមាន ។ ព្រះអានន្ទជាពហុស្សូត អ្នកចងចាំនូវធម៌ រក្សាទុកនូវឃ្លាំងធម៌នៃព្រះពុទ្ធទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ លោកជាចក្ខុនៃសត្វលោកទាំងអស់បរិនិព្វានហើយ ។ ព្រះអានន្ទជាពហុស្សូត អ្នកចងចាំនូវធម៌ ជាឃ្លាំងរក្សាទុកនូវធម៌នៃព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ លោកជាចក្ខុនៃសត្វលោកទាំងអស់ ជាអ្នកបន្ទោបង់នូវងងឹត ក្នុងទីដ៏ងងឹត ។

កតិមន្តោ សតីមន្តោ ធិតិមន្តោ ច យោ ឥសិ
សទ្ធម្មធារកោ[១] ថេរោ អានន្ទោ រតនាករោ ។
បរិចិណ្ណោ មយា សត្ថា ។ បេ ។ភវនេត្តិ សមូហតាតិ ។

អានន្ទោ ថេរោ ។

# ឧទ្ទានំ

បុស្សោ ឧបតិស្សោ អានន្ទោ តយោតិមេ បកិត្តិតា
គាថាយោ តត្ថ សង្ខាតា សតំ បញ្ច ច ឧត្តរីតិ ។

តឹសនិបាតោ និដ្ឋិតោ ។

---

១ ម. សទ្ធម្មាគរកោ ។

*ព្រះអានន្ទត្ថេរ មានញាណគតិ មានស្មារតី មានប្រាជ្ញាជាគ្រឿងទ្រទ្រង់ ជាអ្នកស្វែងរកនូវគុណ ទ្រទ្រង់ទុកនូវព្រះសទ្ធម្ម ជាអណ្តូងនៃធម្មរតនៈ ។ ព្រះសាស្តា ខ្ញុំបានបម្រើហើយ ។ បេ ។ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏បានដកចេញហើយ ។*

អានន្ទត្ថេរ ។

# ឧទ្ទាន

*ព្រះថេរៈ ៣ អង្គនេះគឺ ព្រះបុស្សៈ ១ ព្រះឧបតិស្សៈ ១ ព្រះអានន្ទ ១ លោកបានសម្តែងគាថា ដែលបានពោលទុកក្នុងទីនោះ ១០៥ គាថា ។*

ចប់ តឹសនិបាត ។

# ថេរគាថាយ ចត្តាឡីសនិបាតោ

[២៦២] ន គណេន បុរក្ខតោ ចរេ
វិមនោ ហោតិ សមាធិ ទុល្លភោ
នានាជនសង្គហោ ទុក្ខោ
ឥតិ ទិស្វាន គណំ ន រោចយេ ។
ន កុលានិ ឧបព្វជេ មុនិ
វិមនោ ហោតិ សមាធិ ទុល្លភោ
សោ ឧស្សុក្កោ រសានុគិទ្ធោ
អត្ថំ រិញ្ចតិ យោ សុខាធិវាហោ(១) ។
បង្កោតិ ហិ នំ អវេទយុំ
យាយំ វន្ទនបូជនា កុលេសុ
សុខុមំ សល្លំ ទុរច្ចយំ(២)
សក្ការោ កាបុរិសេន ទុជ្ជហោ ។
សេនាសនម្ហា ឱរុយ្ហ នគរំ បិណ្ឌាយ បាវិសឹ ។
ភុញ្ជន្តំ បុរិសំ កុដ្ឋឹ សក្កច្ចន្តំ ឧបដ្ឋហឹ ។
សោ មេ(៣) បក្កេន ហត្ថេន អាលោបំ ឧបនាមយិ
អាលោបំ បក្ខិបន្តស្ស អង្គុលី ចេត្ថ ឆិជ្ជតិ(៤) ។

១ ឱ. ម. សុខាវហោ ។ ២ ឱ. ទុរុព្វហំ ។ ម. ទុជ្ជហំ ។ ៣ ឱ. ម. តំ ។
៤ ឱ. ម. ឆិជ្ជថ ។

# ថេរគាថា ចត្តាឡីសនិបាត

[២៦២] ភិក្ខុមិនគប្បីប្រព្រឹត្តមានគណៈចោមរោម (ព្រោះ) រមែងមានចិត្តក្តៅក្រហាយ បានសមាធិ ដោយលំបាក ការសង្គ្រោះជននានា នាំមកនូវសេចក្តីទុក្ខ ភិក្ខុឃើញដូច្នេះហើយ មិនគប្បីត្រេកអរនឹងគណៈឡើយ ។ អ្នកប្រាជ្ញ មិនគប្បីចូលទៅអែបអបនឹងត្រកូលទាំងឡាយទេ (ព្រោះ) រមែងមានចិត្តក្តៅក្រហាយ បានសមាធិដោយលំបាក ភិក្ខុណាជាអ្នកល្មោភក្នុងរសមានចម្ងាញ់ ភិក្ខុនោះជាអ្នករនេះរនាត ជាប់ចិត្តក្នុងរសរមែងខូចបង់ប្រយោជន៍ ។ មែនពិត អ្នកប្រាជ្ញទាំងឡាយ បានដឹង នូវការថ្វាយបង្គំនឹងការបូជាក្នុងត្រកូលទាំងឡាយ ថាដូចជាភក់ (ព្រោះថា) សរគឺកិលេសល្អិត ៗ ភិក្ខុកន្ទងបង់បានដោយលំបាក គ្រឿងសក្ការៈ បុរសលាមក លះបង់បានដោយក្រ ។

ខ្ញុំចុះចាកសេនាសនៈ (លើភ្នំ)ចូលទៅកាន់នគរ ដើម្បីបិណ្ឌបាត ។ ខ្ញុំបានយកចិត្តទុកដាក់ចូលទៅឈរជិតបុរសឃ្លង់ ដែលកំពុងតែបរិភោគ ។ បុរសនោះ បានបង្អោនពំនូតបាយដល់ខ្ញុំ ដោយដៃ ដែលមានរោគឃ្លង់ ទុំផេរៗ ហើយ កាលបុរសនោះកំពុងដាក់ពំនូតបាយ ម្រាមដៃក៏ដាច់ធ្លាក់ ទៅក្នុងបាត្រនុ៎ះ ។

កុឌ្ឌមូលញ្ច និស្សាយ អាលោបន្តំ អភុញ្ជិសំ
ភុញ្ជមានេ ច ភុត្តេ វា ជេគុច្ឆំ មេ ន វិជ្ជតិ ។
ឧត្តិដ្ឋបិណ្ឌោ អាហារោ បូតិមុត្តញ្ច ឱសធំ
សេនាសនំ រុក្ខមូលំ បំសុកូលញ្ច ចីវរំ
យស្សេតេ អភិសម្ភុត្វា ស វេ ចាតុទ្ទិសោ នរោ ។
យត្ថ ឯកេ វិហញ្ញន្តិ អារុហន្តា សិលុច្ចយំ
តត្ថ[១] ពុទ្ធស្ស ទាយាទោ សម្បជានោ បតិស្សតោ
ឥទ្ធិពលេនុបត្ថទ្ធោ កស្សបោ អភិរូហតិ ។
បិណ្ឌបាតប្បដិក្កន្តោ សេលមារុយ្ហ កស្សបោ
ឈាយតិ អនុបាទានោ បហីនភយភេរវោ ។
បិណ្ឌបាតប្បដិក្កន្តោ សេលមារុយ្ហ កស្សបោ
ឈាយតិ អនុបាទានោ ឌយ្ហមានេសុ និព្វុតោ ។
បិណ្ឌបាតប្បដិក្កន្តោ សេលមារុយ្ហ កស្សបោ
ឈាយតិ អនុបាទានោ កតកិច្ចោ អនាសវោ ។
ករេរិមាលាវិតតា ភូមិភាគា មនោរមា
កុញ្ជរាភិរុទា រម្មា តេ សេលា រមយន្តិ មំ ។

១ ឱ. ម. តស្ស ។

ខ្ញុំផ្អែកនឹងជញ្ជាំងផ្ទះ ហើយក៏បានឆាន់នូវពំនូតបាយនោះ កាលពំនូតបាយដែលខ្ញុំកំពុងបរិភោគក្តី បរិភោគរួចហើយក្តី ខ្ញុំមិនមានសេចក្តីខ្ពើមរអើមឡើយ ។ ដុំបាយដែលភិក្ខុទៅឈរទៀបទ្វារផ្ទះនៃជនដទៃ ហើយបានមកជាអាហារ ១ សម៉ដែលត្រាំដោយទឹកមូត្រគោស្អុយជាឱសថ ១ ម្លប់ឈើជាសេនាសនៈ ១ សំពត់បង្សុកូលចីវរ ១ ភិក្ខុណាបានបរិភោគនូវរបស់ទាំងនេះហើយ ភិក្ខុនោះអាចនៅក្នុងទិសទាំង ៤ បាន ។ ពួកមនុស្សខ្លះ កាលឡើងភ្នំតែងតែលំបាកចិត្តក្នុងបច្ឆិមវ័យណា កស្សប ជាទាយាទរបស់ព្រះពុទ្ធ ជាអ្នកដឹងខ្លួន មានស្មារតីមាំ រឹងប៉ឹងដោយកម្លាំងឫទ្ធិ ឡើង (ភ្នំ) ក្នុងបច្ឆិមវ័យនោះបាន ។ កស្សប តែឆាន់រួចហើយ ឡើងទៅលើភ្នំ ហើយចម្រើនឈាន ជាអ្នកមិនមានសេចក្តីប្រកាន់ មានភ័យដ៏ពន្លឹកលះចោលហើយ ។ កស្សប តែឆាន់រួចហើយ ឡើងទៅលើភ្នំ ហើយចម្រើនឈាន ជាអ្នកមិនមានសេចក្តីប្រកាន់ កាលពួកសត្វក្តៅក្រហាយ លោកក៏ជាបុគ្គលត្រជាក់ ។ កស្សប តែឆាន់រួចហើយ ឡើងទៅលើភ្នំ ហើយចម្រើនឈាន ជាអ្នកមិនមានសេចក្តីប្រកាន់ មានកិច្ចធ្វើហើយ មិនមានអាសវៈ ។ ចំណែកផែនដីដែលផ្សាយទៅដោយក្លិននៃផ្កាក្តម្ពុ ជាទីត្រេកអរនៃចិត្ត សម្រែកនៃដំរីជាទីត្រេកអរ ភ្នំទាំងឡាយនោះ រមែងញ៉ាំងខ្ញុំ ឲ្យត្រេកអរ ។

១០១

## ថេរគាថាយ ចត្តាឡីសនិបាតោ

នីលព្ភវណ្ណា រុចិរា　　វារិសីតា សុចិន្ធរា
ឥន្ទគោបកសញ្ឆន្នា　　តេ សេលា រមយន្តិ មំ ។
នីលព្ភកូដសទិសា　　កូដាគារវរូបមា
វារណាភិរុទា រម្មា　　តេ សេលា រមយន្តិ មំ ។
អភិវុដ្ឋា រម្មតលា　　នគា ឥសីភិ សេវិតា
អព្ភុន្នទិតា[១] សិខីភិ　　តេ សេលា រមយន្តិ មំ ។
អលំ ឈាយិតុកាមស្ស　　បហិតត្តស្ស មេ សតោ
អលំ មេ អត្ថកាមស្ស　　បហិតត្តស្ស ភិក្ខុនោ
អលំ មេ ផាសុកាមស្ស　　បហិតត្តស្ស សិក្ខតោ[២]
អលំ មេ យោគកាមស្ស　　បហិតត្តស្ស តាទិនោ ។
ឧម្មាបុប្ផសមានា　　គគនាវព្ភឆាទិតា
នានាទិជគណាកិណ្ណា　　តេ សេលា រមយន្តិ មំ ។
អនាកិណ្ណា គហដ្ឋេហិ　　មិគសង្ឃនិសេវិតា
នានាទិជគណាកិណ្ណា　　តេ សេលា រមយន្តិ មំ ។
អច្ឆោទិកា បុថុសិលា　　គោណង្គុលមិគាយុតា
អម្ពុសេវាលសញ្ឆន្នា　　តេ សេលា រមយន្តិ មំ ។

---
១ ម. អព្ភុន្នទិសា ។ ២ ឱ. ម. ភិក្ខុនោ ។

ភ្នំទាំងនោះ មានពណ៌ដូចពពកខៀវ ដ៏រុងរឿង មានទឹកត្រជាក់ ទ្រទ្រង់នូវវត្ថុដ៏ស្អាត ដេរដាសដោយក្អៀង តែងញ៉ាំងខ្ញុំឲ្យត្រេកអរ ។ ភ្នំទាំងនោះ ប្រាកដស្មើដោយកំពូលពពកដ៏ខៀវ ឧបមាដូចផ្ទះមានកំពូលដ៏ប្រសើរ មានសម្រែកនៃដំរី ជាទីត្រេកអរ តែងញ៉ាំងខ្ញុំឲ្យត្រេកអរ ។ ភ្នំថ្មទាំងនោះ ដែលភ្លៀងបន្ទរហើយ មានផ្ទៃជាទីត្រេកអរ ដែលឥសីទាំងឡាយធ្លាប់អាស្រ័យនៅហើយ ដែលពួកសត្វក្ងោក ស្រែកយំហើយ តែងញ៉ាំងខ្ញុំឲ្យត្រេកអរ ។ (ភ្នំទាំងឡាយ) គួរដល់ខ្ញុំ ដែលប្រាថ្នាដើម្បីចម្រើនឈាន មានចិត្តស្ទុងទៅរកព្រះនិព្វាន គួរដល់ខ្ញុំដែលប្រាថ្នាប្រយោជន៍ ជាភិក្ខុមានចិត្តស្ទុងទៅរកព្រះនិព្វាន គួរដល់ខ្ញុំ ដែលប្រាថ្នារកសេចក្តីស្រួល មានចិត្តស្ទុងទៅរកព្រះនិព្វាន ជាអ្នកសិក្សា គួរដល់ខ្ញុំដែលប្រាថ្នាព្យាយាម មានចិត្តស្ទុងទៅរកព្រះនិព្វាន ជាតាទិបុគ្គល ។ ភ្នំទាំងនោះ ដ៏ដេរដាសដោយផ្កាកណ្ណិកា រីកព្រោងព្រាត ដូចផ្ទៃមេឃ ដេរដាសដោយពួកបក្សីផ្សេង ៗ តែងញ៉ាំងខ្ញុំឲ្យត្រេកអរ ។ ភ្នំទាំងឡាយនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ មានតែពួកម្រឹគនៅអាស្រ័យ ដេរដាសដោយពួកបក្សីផ្សេង ៗ តែងញ៉ាំងខ្ញុំឲ្យត្រេកអរ ។ ភ្នំទាំងនោះមានទឹកថ្លា មានថ្មក្រាស់ ប្រកបដោយពួកម្រឹគមានកន្ទុយដូចគោ ដេរដាសដោយទឹកនិងសារាយ តែងញ៉ាំងខ្ញុំឲ្យត្រេកអរ ។

បញ្ចង្គិកេន តុរិយេន ន រតិ ហោតិ តាទិសី
យថា ឯកគ្គចិត្តស្ស សម្មា ធម្មំ វិបស្សតោ ។

កម្មំ ពហុកំ នការយេ
បរិវជ្ជេយ្យ ជនំ ន ឧយ្យមេ
សោ ឧស្សុក្កោ រសានុគិទ្ធោ
អត្ថំ រិញ្ចតិ យោ សុខាធិវាហោ ។

កម្មំ ពហុកំ ន ការយេ
បរិវជ្ជេយ្យ អនត្តមេតំ[១]
កិច្ឆតិ កាយោ កិលមតិ
ទុក្ខិតោ សោ សមថំ ន វិន្ទតិ ។

ឱដ្ឋបហតមត្តេន អត្តានំបិ ន បស្សតិ
បត្ថទ្ធគីវោ[២] ចរតិ អហំ សេយ្យោតិ មញ្ញតិ ។

អសេយ្យោ សេយ្យសមានំ ពាលោ មញ្ញតិ អត្តានំ
ន តំ វិញ្ញូ បសំសន្តិ បត្ថទ្ធមានសំ នរំ ។

យោ ច សេយ្យោហមស្មីតិ នាហំ សេយ្យោតិ វា បុន
ហីនោហំ សទិសោ វាតិ វិធាសុ ន វិកម្បតិ ។

១ ឱ. ម. អនត្តនេយ្យ មេតំ ។ ២ ឱ. បត្ថទ្ធគីវោ ។ ម. បតទ្ធិគីវោ ។

សេចក្ដីត្រេកអរ (នៃខ្ញុំ) ដោយសារតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ប្រាកដ ដូច្នោះមិនមានឡើយ ដូច (ការមិនមានសេចក្ដីត្រេកអរ) នៃព្រះយោគី ដែលមានចិត្តមានអារម្មណ៍មូលតែមួយ ឃើញច្បាស់នូវធម៌ដោយប្រពៃ

បុគ្គលមិនត្រូវធ្វើការងារឲ្យច្រើន ត្រូវវៀរជន (មិនមែនជាកល្យាណមិត្រ) មិនត្រូវខ្នះខ្នែង (ដើម្បីបច្ច័យ) បុគ្គលណាជាអ្នកល្មោភក្នុងរសមានចម្ងាញ់ បុគ្គលនោះ ជាអ្នកខ្នះខ្នែងជាប់ចិត្តក្នុងរស រមែងខូចបង់ប្រយោជន៍ បុគ្គលមិនត្រូវធ្វើការងារឲ្យច្រើន ត្រូវវៀរចាកជន (មិនមែនជាកល្យាណមិត្តព្រោះ) ការងារនុ៎ះមិនមែនជាប្រយោជន៍ កាយរមែងលំបាកនឿយព្រួយ បុគ្គលអ្នកដល់ នូវសេចក្ដីនឿយព្រួយនោះ រមែងមិនបាននូវសេចក្ដីស្ងប់រម្ងាប់ឡើយ ។

បុគ្គលមិនពិចារណាឃើញខ្លួនឯង ដោយត្រឹមតែរលាស់បបូរមាត់ (ស្វាធ្យាយពុទ្ធវចនៈ) បុគ្គលប្រព្រឹត្តរឹងរូស តែងសម្គាល់ថា អាត្មាអញប្រសើរ ។ បុគ្គលពាល មិនប្រសើរ តែងសម្គាល់ខ្លួនថាស្មើនឹងបុគ្គលប្រសើរ អ្នកប្រាជ្ញទាំងឡាយ មិនសរសើរជនអ្នកមានចិត្តរឹងរូសនោះឡើយ ។ បុគ្គលណា មិនញាប់ញ័រក្នុងមានះ(ទាំង ៩ ណាមួយ) ដោយចិត្តកើតឡើងថា អញជាមនុស្សប្រសើរ ឬថា អញជាមនុស្សមិនប្រសើរ អញជាមនុស្សថោក ឬថាអញជាមនុស្សប្រហែលនឹងគេ ។

១០៣

## ថេរគាថាយ ចត្តាឡីសនិបាតោ

បញ្ញវន្តំ តថាវាទឹ សីលេសុ សុសមាហិតំ
ចេតោសមថមនុយុត្តំ[១] តំ វេ វិញ្ញូ បសំសរេ ។
យស្ស សព្រហ្មចារីសុ គារវោ នូបលព្ភតិ
អារកា ហោតិ សទ្ធម្មា នភសោ បុថវី យថា ។
យេសញ្ច ហិរិឱត្តប្បំ សទា សម្មា ឧបដ្ឋិតំ
វិរូឡ្ហព្រហ្មចរិយា តេសំ ខីណា បុនព្ភវា ។
ឧទ្ធតោ ចបលោ ភិក្ខុ បំសុកូលេន បារុតោ
កបិវ សីហចម្មេន ន សោ តេនុបសោភតិ ។
អនុទ្ធតោ អចបលោ និបកោ សំវុតិន្ទ្រិយោ
សោភតិ បំសុកូលេន សីហោវ គិរិគព្ភរេ ។
ឯតេ សម្ពហុលា ទេវា ឥទ្ធិមន្តោ យសស្សិនោ
ទស ទេវសហស្សានិ សព្វេ តេ ព្រហ្មកាយិកា
ធម្មសេនាបតឹ វីរំ មហាឈាយឹ សមាហិតំ
សារីបុត្តំ នមស្សន្តា តិដ្ឋន្តិ បញ្ជលីកតា
នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
យស្ស តេ នាភិជានាម យំបិ និស្សាយ ឈាយតិ ។

១ ឱ. ម. ចេតោសមថសំយុត្តំ ។

អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលនោះ ថាជាអ្នកមានប្រាជ្ញា អ្នកនិយាយទៀងទាត់ អ្នកមានចិត្តតម្កល់មាំក្នុងសីលទាំងឡាយ អ្នកប្រកបរឿយ ៗ នូវការស្ងប់ស្ងាត់ចិត្ត ។ បុគ្គលណា មិនបានគោរពសព្រហ្មចារីបុគ្គលទាំងឡាយទេ បុគ្គលនោះ រមែងឆ្ងាយចាកព្រះសទ្ធម្ម ដូចផែនដី (ឆ្ងាយ) ពីមេឃ ។ បុគ្គលទាំងឡាយណា មានហិរិនិងឱត្តប្បៈតម្កល់នៅ ដោយប្រពៃ គ្រប់ពេល បុគ្គលទាំងនោះ មានព្រហ្មចារ្យដុះចម្រើនហើយ មានភពថ្មីអស់ហើយ ។ ភិក្ខុណា មានចិត្តរវើរវាយ ឃ្វេងឃ្វាង ស្លៀកដណ្តប់សំពត់បង្សុកូល ភិក្ខុនោះ មិនសមនឹងសំពត់បង្សុកូលនោះឡើយ ដូចស្វាដណ្តប់ស្បែកសីហៈ ។ ភិក្ខុណា មានចិត្តមិនរវើរវាយ មិនឃ្វេងឃ្វាង ជាអ្នកមានប្រាជ្ញាចាស់ សង្រួមឥន្ទ្រិយ ទើបសមនឹងសំពត់បង្សុកូល ដូចសីហៈក្នុងប្រកភ្នំ ។ ពួកទេវតាដ៏ច្រើន មានឫទ្ធិ មានយសសក្តិ ទេវតាមួយហ្មឺន ទាំងអស់នុ៎ះ ជាពួកព្រហ្ម ឈរនមស្ការ ប្រណម្យអញ្ជលី ចំពោះព្រះសារីបុត្ត ជាធម្មសេនាបតី ជាអ្នកប្រាជ្ញ មានឈានច្រើន មានចិត្តតម្កល់មាំ ថា បពិត្របុរសអាជានេយ្យ ខ្ញុំសូមក្រាបថ្វាយបង្គំលោកម្ចាស់ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមក្រាបថ្វាយបង្គំលោកម្ចាស់ លោកម្ចាស់ចម្រើនឈាន អាស្រ័យអារម្មណ៍ណា ពួកយើងខ្ញុំមិនបាន នូវអារម្មណ៍នោះ របស់លោកម្ចាស់ទេ ។

១០៤

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរគាថា

អច្ឆេរំ វត ពុទ្ធានំ គម្ភីរេ គោចរេ សកោ
តេ មយំ ធាតិជាធាម ពាលវេធី សមាគតា ។
តំ តថា ទេវកាយេហិ បូជិតំ បូជនារហំ
សារីបុត្តំ តទា ទិស្វា កប្បិនស្ស សិតំ អហុ ។
យាវតា ពុទ្ធខេត្តម្ហិ ឋបយិត្វា មហាមុនឹ
ធុតគុណោ វិសិដ្ឋោហំ សទិសោ មេ ន វិជ្ជតិ ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
ន ចីវរេ ន សយនេ ភោជនេ នូបលិប្បតិ
គោតមោ អនប្បមេយ្យោ មុឡាលិបុប្ផំ វិមលំវ
អម្ពុនា និក្ខម្មនិន្នោ តិភវាភិនិស្សដោ ។
សតិប្បដ្ឋានគីវោ សោ សទ្ធាហត្ថោ មហាមុនិ
បញ្ញាសីសោ មហាញាណី សទា ចរតិ និព្ពុតោតិ ។

មហាកស្សបោ ថេរោ ។

អស្ចារ្យហ្ន៎ អារម្មណ៍របស់ពួកលោកអ្នកត្រាស់ដឹងនូវសច្ចៈទាំង ៤ ជាអារម្មណ៍ដ៏ជ្រាលជ្រៅ (ពិបាកដឹងណាស់) ពួកយើង ដូចពួកខ្មាន់ធ្នូបាញ់នូវរោមកន្ទុយសត្វ មកប្រជុំគ្នា (ពិចារណា) នៅតែមិនដឹង ។ ព្រះកប្បិនត្ថេរបានញញឹម ព្រោះឃើញព្រះសារីបុត្តត្ថេរនោះ គួរជាទីបូជា ដែលពពួកទេវតាបូជាហើយ ដោយប្រការដូច្នោះ ។ ក្នុងពុទ្ធខេត្តទាំងមូល ខ្ញុំជាមនុស្សវិសេសខាងធុតង្គគុណ គ្មានលោកណាស្មើនឹងខ្ញុំទេ លើកលែងតែព្រះមហាមុនីចេញ ។ ព្រះសាស្តាខ្ញុំបានបម្រើហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំដាក់ចោលហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពទៀត ខ្ញុំក៏ដកចោលហើយ ។ ព្រះគោតម មានគុណប្រមាណមិនបាន មានព្រះហឫទ័យឱនទៅរកនេក្ខម្មៈ រលាស់ចោលនូវភពទាំង ៣ មិនជាប់ចំពាក់ក្នុងចីវរ មិនជាប់ចំពាក់ក្នុងសេនាសនៈ មិនជាប់ចំពាក់ក្នុងភោជនាហារ ដូចផ្កាឈូក មិនមានមន្ទិលសៅហ្មង មិនជាប់ដោយទឹក ។ ព្រះមហាមុនីនោះ មានសតិប្បដ្ឋានជាព្រះសូរង្គ មានសទ្ធាជាព្រះហស្ត មានប្រាជ្ញាជាព្រះសិរ្សៈ មានព្រះញាណធំ ព្រះអង្គប្រព្រឹត្តរំលត់ទុក្ខ គ្រប់ពេល ។

ព្រះមហាកស្សបត្ថេរ ។

១០៥

ថេរគាថាយ ចត្តាឡីសនិបាតោ

# ឧទ្ទានំ

ចត្តាឡីសនិបាតម្ហិ មហាកស្សបវ្ហយោ
ឯកោវ ថេរោ គាថាយោ ចត្តាឡីស ទុវេបិ ចាតិ ។

ចត្តាឡីសនិបាតោ សមត្តោ ។

---

ថេរគាថាយ ចត្តាឡីសនិបាតោ

# ឧទ្ទាន

*ក្នុងចត្តាឡីសនិបាត (នេះ) ព្រះថេរៈព្រះនាមមហាកស្សប តែមួយព្រះអង្គឯង បានសម្ដែងនូវគាថាទាំងឡាយ ៤២ ។*

ចប់ ចត្តាឡីសនិបាត ។

---

# ថេរគាថាយ បញ្ញាសនិបាតោ

[២៦៣] កទា នុហំ បព្វតកន្ទរាសុ
ឯកាកិយោ អទ្ទុតិយោ វិហស្សំ
អនិច្ចតោ សព្វភវំ វិបស្សំ
តំ មេ ឥទន្តំ នុ កទា ភវិស្សតិ ។
កទា នុហំ ភិន្នបដន្ធរោ មុនិ
កាសាវវត្ថោ អមមោ និរាសយោ[១]
រាគញ្ច ទោសញ្ច តថេវ មោហំ
ហិត្វា[២] សុខី បវនគតោ វិហស្សំ ។
កទា អនិច្ចំ វធរោគនិឌ្ឌំ[៣]
កាយំ ឥមំ មច្ចុរាជស្ស[៤] បទ្ទុតំ
វិបស្សមានោ វីតភយោ វិហស្សំ
ឯកោ វនេ តំ នុ កទា ភវិស្សតិ ។
កទា នុហំ ភយជននឹ ទុក្ខាវហំ
តណ្ហាលតំ ពហុវិធានុវត្តនឹ
បញ្ញាមយំ តិខិណាមសឹ គហេត្វា
ឆេត្វា វសេ តម្បិ កទា ភវិស្សតិ ។

---

១ ម. និរាសោ ។ ២ ឱ. ម. ហន្ត្វា ។ ៣ ឱ. ម. វធរោគនីឡំ ។ ៤ ឱ. ម. មច្ចុជរាយុបទ្ទុតំ ។

# ថេរគាថា បញ្ញាសនិបាត

[២៦៣] *កាលណាហ្ន៎ អាត្មាអញនឹងបានជាបុគ្គលម្នាក់ឯង មិនមានតណ្ហាជាគម្រប់ពីរ នឹងឃើញនូវភពទាំងអស់ ថាជារបស់មិនទៀង នៅក្នុងជ្រោះភ្នំទាំងឡាយ គំនិតនោះ អាត្មាអញបានត្រិះរិះហើយថា កាលណាហ្ន៎ បំណងនេះនឹងសម្រេច ។ កាលណាហ្ន៎ អាត្មាអញបានបួស ទ្រទ្រង់នូវផ្ទាំងសំពត់ដែលកាត់ដាច់ ស្លៀកសំពត់ជ្រលក់ដោយទឹកចត់ ហើយជាអ្នកមិនមានសេចក្តីប្រកាន់ខ្លួនថា របស់អញ ជាបុគ្គលមិនមានសេចក្តីប្រាថ្នា ហើយបានលះនូវរាគៈ ទោសៈ មោហៈ ដោយប្រការដូច្នោះ ជាបុគ្គលដល់នូវសេចក្តីសុខ ហើយចូលទៅនៅក្នុងព្រៃធំ ។ កាលណាហ្ន៎ អាត្មាអញនឹងពិចារណាឃើញនូវកាយមិនទៀងនេះ ជាសម្បុករបស់មរណៈនិងរោគ ដែលមច្ចុបៀតបៀនហើយ ជាបុគ្គលប្រាសចាកភ័យ នៅម្នាក់ឯងក្នុងព្រៃ គំនិតនោះកាលណា នឹងសម្រេច ។ កាលណាហ្ន៎ អាត្មាអញនឹងបានកាន់ដាវដ៏មុត គឺមគ្គប្បញ្ញា ហើយក្របែលនូវវល្លិ៍ គឺតណ្ហា ដែលជាធម្មជាតិញុំាងភ័យឲ្យកើត ជាគ្រឿងនាំមកនូវសេចក្តីទុក្ខ ប្រព្រឹត្តតាមអារម្មណ៍ដ៏ច្រើន ឲ្យលុះក្នុងអំណាច* (*របស់ខ្លួនបាន*) *គំនិតនោះ កាលណានឹងសម្រេច ។*

១០៧

ថេរគាថាយ បញ្ញាសនិបាតោ

កទា នុ បញ្ញាមយមុគ្គតេជំ
សត្ថំ ឥសីនំ អហមាទយិត្វា[១]
មារំ សសេនំ សហសា ភញ្ជិស្សំ
សីហាសនេ តន្នុ កទា ភវិស្សតិ ។
កទា នុហំ សព្ភិ សមាគមេសុ
ទិដ្ឋោ ភវេ ធម្មគរូហិ តាទិហិ
យថាវទស្សីហិ ជិតិន្ទ្រិយេហិ[២]
បធានិយោ តន្នុ កទា ភវិស្សតិ ។
កទា នុ មំ តន្ទិខុទាបិបាសា
វាតាតបា កីដសិរីសបា វា
និពាធយិស្សន្តិ ន តំ គិរិព្វជេ
អត្តត្ថិយំ តន្នុ កទា ភវិស្សតិ ។
កទា នុ ខោ យំ វិទិតំ មហេសិនា
ចត្តារិ សច្ចានិ សុទុទ្ទសានិ
សមាហិតត្តោ សតិមា អគច្ឆំ
បញ្ញាយ តំ តន្នុ កទា ភវិស្សតិ ។

១ ឱ. ម. សហាសទិយិត្វា ។ ២ ម. ជីវិតិន្ទ្រិយេហិ ។

កាលណាហ្ន៎ អាត្មាអញនឹងបានកាន់យកនូវសស្ត្រាដ៏មុតថ្លា គឺប្រាជ្ញា របស់ឥសីទាំងឡាយ ហើយនឹងបំបាក់នូវមារព្រម ទាំងសេនាមារដោយឆាប់រហ័ស លើសីហាសនៈ (ថេរាសនៈ) បំណងនោះ កាលណានឹងសម្រេច ។ កាលណាហ្ន៎ ពួកលោកអ្នកសប្បុរស ជាអ្នកគោរពក្នុងធម៌ ប្រកបដោយតាទិ-គុណ អ្នកឃើញតាមពិត មានឥន្ទ្រិយឈ្នះហើយ មើលឃើញអញ ថាជាអ្នកមានព្យាយាម ក្នុងសមាគមទាំងឡាយ បំណងនោះ កាលណានឹងសម្រេច ។ កាលណាហ្ន៎ សេចក្ដីខ្ជិល ការឃ្លាន ការស្រេក ខ្យល់ កម្ដៅថ្ងៃ ស្រាំង ស្រួយ ពស់តូច ពស់ធំ នឹងមិនបៀតបៀន នូវអាត្មាអញនោះ អ្នកមានប្រយោជន៍ចំពោះខ្លួន ក្នុងភ្នំ ឬប្រកភ្នំ បំណងនោះ កាលណានឹងសម្រេច ។ សច្ចៈ ៤ យ៉ាងណា ដែលឃើញបានដោយក្រ ដែលព្រះមហេសីសម្មាសម្ពុទ្ធ បានត្រាស់ដឹងហើយ កាលណាហ្ន៎ អាត្មាអញ នឹងបានជាអ្នកមានចិត្តតម្កល់មាំ មានស្មារតី បានត្រាស់ដឹង នូវសច្ចៈទាំង ៤ នោះដោយបញ្ញា បំណងនោះ កាលណា នឹងសម្រេច ។

កទា នុ រូបេ អមិតេ ច សទ្ទេ
គន្ធេ រសេ ផុសិតព្វេ ច ធម្មេ
អាទិត្តតោហំ សមថេហិ យុត្តោ
បញ្ញាយ ទក្ខំ[១] តទិទំ កទា មេ ។
កទា នុហំ ទុព្វចនេន វុត្តោ
តតោនិមិត្តំ វិមនោ ន ហេស្សំ
អថោ បសត្ថោបិ តតោនិមិត្តំ
តុដ្ឋោ ន ហេស្សំ តទិទំ កទា មេ ។
កទា នុ កដ្ឋេ ច តិណេ លតា ច
ខន្ធេ ឥមេហំ អមិតេ ច ធម្មេ
អជ្ឈត្តិកានេវ ច ពាហិរានិ ច
សមំ តុលេយ្យំ តទិទំ កទា មេ ។
កទា នុ មំ ចាវុសកាលមេឃោ
នវេន តោយេន សចីវរំ វនេ
ឥសិប្បយាតម្ហិ បថេ វជន្តំ
ឱវស្សតេ តន្នុ កទា ភវិស្សតិ ។

---

១ ម. បញ្ញាយ ទដ្ឋុំ ។

កាលណាហ្ន៎ អាត្មាអញនឹងបានប្រកបដោយសមថៈទាំងឡាយ ហើយបានឃើញដោយបញ្ញា នូវរូប សំឡេង ក្លិន រស ផោដ្ឋព្វៈនិងធម្មារម្មណ៍ទាំងឡាយ កំណត់មិនបាន ថាជារបស់ដែលភ្លើងឆេះហើយ បំណងរបស់អាត្មាអញនោះ កាលណានឹងសម្រេច ។ កាលណាហ្ន៎ អាត្មាអញ ត្រូវគេពោលពាក្យអាក្រក់មករក មិនគប្បីទោមនស្ស ព្រោះសម្ដីនោះជាហេតុ ឬថា ទោះបី គេសរសើរ ក៏មិនត្រេកអរ ព្រោះការសរសើរនោះជាហេតុ បំណងរបស់អាត្មាអញនោះ កាលណានឹងសម្រេច ។ កាលណាហ្ន៎ អាត្មាអញនឹងពិចារណាឃើញ នូវកំណាត់ឈើទាំងឡាយផង ស្មៅទាំងឡាយផង វល្លិ៍ទាំងឡាយផង ខន្ធ ៥ ទាំងឡាយនេះផង ធម៌ទាំងឡាយ ទាំងខាងក្នុង ខាងក្រៅ មានប្រមាណមិនបានផង ឲ្យស្មើៗ គ្នា(ដោយសេចក្ដីមិនទៀងជាដើម និងមិនមានខ្លឹមសារ) បំណងរបស់អាត្មាអញនោះ កាលណានឹងសម្រេច ។ កាលណាហ្ន៎ ភ្លៀងពុំដួកាលមានទឹកថ្មី ត្រជាក់ បង្អុរធ្លាក់មក ត្រូវលើអាត្មាអញ ព្រមទាំងចីវរ ដែលកំពុងដើរក្នុងផ្លូវ ដែលពួកលោកអ្នកស្វែងរកគុណធំ (មានព្រះពុទ្ធជាដើម) ត្រាច់ទៅក្នុងព្រៃ បំណងរបស់អាត្មាអញនោះ កាលណា នឹងសម្រេច ។

កទា មយូរស្ស សិខណ្ឌិនោ វនេ
ទិជស្ស សុត្វា គិរិគព្ភរេ រុតំ
បច្ចុដ្ឋហិត្វា អមតស្ស បត្តិយា
សញ្ចិន្តយេ តន្នុ កទា ភវិស្សតិ ។
កទា នុ គង្គំ យមុនំ សរស្សតឹ
បាតាលខិត្តំ វឡវាមុខញ្ច
អសជ្ជមានោ បតរេយ្យមិទ្ធិយា
វិភឹសនំ តំ នុ កទា ភវិស្សតិ ។
កទា នុ នាគោវ សង្គាមចារី
បទាលយេ កាមគុណេសុ ឆន្ទំ
និព្ពជ្ជយំ សព្វសុភំ និមិត្តំ
ឈានេ យុត្តោ(១) តន្នុ កទា ភវិស្សតិ ។
កទា ឥណដ្ដោវ ទលិទ្ទកោ និធឹ
អារាធយិត្វា ធនិកេហិ បីឡិតោ
តុដ្ឋោ ភវិស្សំ អធិគម្ម សាសនំ
មហេសិនោ តន្នុ កទា ភវិស្សតិ ។
ពហូនិ វស្សានិ តយាម្ហិ យាចិតោ

១ ឱ. ម. យុតោ ។

កាលណាហ្ន៎ អាត្មាអញនឹងបានឮសូរសំឡេងក្ងោក ជាសត្វមានកំប៉ោយ កើតអំពីអណ្ឌៈ ជាសត្វកើតពីរដង យំក្នុងប្រកភ្នំ ក្នុងព្រៃ ហើយក្រោកឡើងធ្វើទុកក្នុងចិត្ត (ដោយលក្ខណៈមានអនិច្ចលក្ខណៈជាដើម) ដើម្បីឲ្យបានសម្រេច ដល់ព្រះនិព្វាន បំណងនោះ កាលណានឹងសម្រេច ។ កាលណាហ្ន៎ អាត្មាអញ គប្បីឆ្លងនូវទន្លេគង្គា យមុនា សរស្សតី និងមហាសមុទ្រដ៏ជ្រៅ ដូចជាធ្លាក់ទៅក្នុងបាតាល ជាគ្រឿងញុំាងភ័យឲ្យកើត ដោយឫទ្ធិមិនទើសទាក់ បំណងនោះ កាលណានឹងសម្រេច ។ កាលណាហ្ន៎ អាត្មាអញ គប្បីវៀរនូវសុភនិមិត្តទាំងអស់ ប្រកបក្នុងឈាន ហើយទម្លាយនូវសេចក្តីប្រាថ្នាក្នុងកាមគុណទាំងឡាយ ដូចជាដំរី ត្រាច់ទៅក្នុងសង្រ្គាម បំណងនោះ កាលណា នឹងសម្រេច ។ កាលណាហ្ន៎អាត្មាអញបានដឹងសាសនាព្រះពុទ្ធ អ្នកស្វែងរកគុណដ៏ធំហើយត្រេកអរ ដូចជាបុរសកម្សត់ ចំពាក់បំណុលគេ ដែលពួកម្ចាស់ទ្រព្យមកតឹងទារ ក៏បាននូវកំណប់ទ្រព្យ ហើយត្រេកអរ បំណងនោះ កាលណានឹងសម្រេច ។ អ្នកអង្វរយើងច្រើនឆ្នាំហើយ

អគារវាសេន អលំ នុ តេ ឥទំ
តំ ជានិ មំ បព្វជិតំ សមានំ
កឹការណំ ចិត្ត តុវំ និយុញ្ជសិ ។
ននុ អហំ ចិត្ត តយាម្ហិ យាចិតោ
គិរិព្វជេ ចិត្រឆទា វិហង្គមា
មហិន្ទឃោសត្ថនិតាភិគជ្ជិនោ
តេ តំ រមិស្សន្តិ វនម្ហិ ឈាយិនំ ។
កុលម្ហិ មិត្តេ ច បិយេ ច ញាតកេ
ខិឌ្ឌារតឹ កាមគុណញ្ច លោកេ
សព្វំ បហាយ ឥមមជ្ឈុបាគតោ
អថោបិ ត្វំ ចិត្ត ន មយ្ហ តុស្សសិ ។
មមេវ ឯតំ ន ហិ តំ បរេសំ
សន្នាហកាលេ បរិទេវិតេន កឹ
សព្វំ ឥទំ ចលំ ឥតិ បេក្ខមានោ
អភិនិក្ខមឹ អមតំ បទំ ជិគីសំ ។
សុវុត្តវាទី[១] ទ្វិបទានមុត្តមោ
មហាភិសក្កោ នរទម្មសារថិ

១ ម. សុយុត្តវាទី ។

នេះជាការគួរនៅគ្រប់គ្រងផ្ទះ របស់អ្នកឬ ម្នាលចិត្ត ឥឡូវនេះ ហេតុអ្វីក៏អ្នកនៅតែប្រកបយើងដែលជាអ្នកបួសហើយនោះ ។ ម្នាលចិត្ត ក្រែងអ្នកអង្វរយើងឬ ពួកក្ងោក ជាសត្វបក្សីមានស្លាបដ៏វិចិត្រ ទៅតាមអាកាស ជាសត្វស្រែកយំរំពងកក្រើកដី ក្នុងញកភ្នំ ពួកក្ងោកទាំងនោះ នឹងត្រេកអរចំពោះអ្នកជាអ្នកចម្រើនឈាន ក្នុងព្រៃ ។ ម្នាលចិត្ត អ្នកលះបង់ត្រកូលផង ពួកមិត្រផង ពួកញាតិជាទីស្រឡាញ់ផងសេចក្ដីត្រេកអរនឹងល្បែងផង កាមគុណទាំងអស់ក្នុងលោកផង ហើយចូលមកនៅក្នុងព្រៃនេះ ម្ល៉ឹងហើយ អ្នកនៅតែមិនត្រេកអរនឹងយើង ។ ចិត្តរបស់យើងនេះ មិនមែនជាប្រយោជន៍ដល់ជនទាំងឡាយដទៃឡើយ ប្រយោជន៍អ្វី ដោយការខ្សឹកខ្សួលក្នុងកាលដែលខ្លួនប្រុងប្រៀប (ដើម្បីច្បាំងនឹងកិលេសមារ) យើងសម្លឹងមើល នូវភពបីទាំងអស់នេះ ថាជារបស់នាំឲ្យញាប់ញ័រ ទើបចេញមកស្វែងរកអមតបទ ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គជាបុគ្គលប្រសើរជាងសត្វជើង ២ ជាមហាពេទ្យជាធម្មសារថី របស់សត្វ អ្នកពោលនូវពាក្យសុភាសិត

ថេរគាថាយ បញ្ញាសនិបាតោ

ចិត្តំ ចលំ មក្កដសន្និភំ ឥតិ
អវីតរាគេន សុទុន្និវារិយំ ។
កាមា ហិ ចិត្រា មធុរា មនោរមា
អវិទ្វសុ យត្ថ សិតា បុថុជ្ជនា
តេ ទុក្ខមិច្ឆន្តិ បុនព្ភវេសិនោ
ចិត្តេន នីតា និរយេ និរង្កតា ។
មយូរកោញ្ចាភិរុទម្ហិ កាននេ
ទីបីហិ ព្យគ្ឃេហិ បុរក្ខតោ វសំ
កាយេ អបេក្ខំ ជហ មា បរាធយ(១)
ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។
ភាវេហិ ឈានានិ ច ឥន្ទ្រិយានិ ច
ពលានិ ពោជ្ឈង្គសមាធិភាវនា
តិស្សោ ច វិជ្ជា ផុស ពុទ្ធសាសនេ
ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។
ភាវេហិ មគ្គំ អមតស្ស បត្តិយា
និយ្យានិកំ សព្វទុក្ខក្ខយោគធំ
អដ្ឋង្គិកំ សព្វកិលេសសោធនំ

---
១ ឱ. ម. វិរាយេ ។

ចិត្ត ជាធម្មជាតញាប់ញ័រ ដូចស្វា បុគ្គលមិនទាន់ប្រាសចាក រាគៈ មិនងាយនឹងរារាំងបាន ។ ក៏កាមទាំងឡាយ ជារបស់ ដ៏វិចិត្រ ជារបស់ផ្អែម ជាទីរីករាយនៃចិត្ត ជារបស់ដែល ពួកបុថុជ្ជន អ្នកល្ងង់ខ្លៅ ជាប់ចំពាក់ ពួកបុថុជ្ជននោះ ជាអ្នក ស្វែងរកភពថ្មី តែងប្រាថ្នានូវសេចក្ដីទុក្ខ (បុថុជ្ជនទាំងនោះ)ត្រូវ ចិត្តរបស់ខ្លួនឯង ដឹកនាំទៅទម្លាក់ក្នុងនរក ធ្វើឲ្យឃ្លាតចាក សេចក្ដីសុខ ។ អ្នកកាលនៅក្នុងព្រៃ ជាកន្លែងឮសូរសព្ទក្ងោក និងក្រៀលឃំ មានទាំងខ្លាដំបង ខ្លាធំ ចោមរោម ចូរអ្នក លះបង់ នូវសេចក្ដីអាឡោះអាល័យ ក្នុងកាយចេញ ចូរ កុំឲ្យ(ខណៈ) ឃ្លាតទៅបាន ម្នាលចិត្ត អ្នកគួរតែប្រកបយើង (ក្នុងសម្មាប្រតិបត្តិ) ក្នុងកាលមុន ដោយប្រការដូច្នោះ វិញ ។ អ្នកចូរចម្រើនឈាន ឥន្ទ្រិយ ពលៈ ពោជ្ឈង្គ និង សមាធិភាវនា ចូរសម្រេចនូវវិជ្ជា ៣ ក្នុងសាសនារបស់ព្រះពុទ្ធ ម្នាលចិត្ត អ្នកប្រកបយើង ក្នុងកាលមុន ដោយប្រការ ដូច្នេះ ។ អ្នកចូរចម្រើននូវមគ្គ ជាមគ្គនាំសត្វឲ្យរួចចាកវដ្តទុក្ខ ជាហេតុចុះកាន់ការអស់ទុក្ខទាំងពួង ប្រកបដោយអង្គ ៨ ប្រការ ជាគ្រឿងជម្រះ នូវកិលេសទាំងពួង ដើម្បីដល់នូវព្រះនិព្វាន

ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។
ទុក្ខន្តិ ខន្ធេ បដិបស្ស យោនិសោ
យតោ ច ទុក្ខំ សមុទេតិ តំ ជហ
ឥធេវ ទុក្ខស្ស ករោហិ អន្តំ
ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។
អនិច្ចំ ទុក្ខន្តិ វិបស្ស យោនិសោ
សុញ្ញំ អនត្តាតិ អឃំ វធន្តិ ច
មនោវិចារេ ឧបរុន្ធ ចេតសោ
ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។
មុណ្ឌោ វិរូបោ អភិសាបមាគតោ
កបាលហត្ថោវ កុលេសុ ភិក្ខស្សុ[១]
យុញ្ជស្សុ សត្ថុ វចនេ មហេសិនោ
ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។
សុសំវុតត្តោ វិសិខន្តរំ ចរំ
កុលេសុ កាមេសុ អសង្គមានសោ
ចន្ទោ យថា ទោសិនបុណ្ណមាសិយា
ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។

១ ឱ. ម. ភិក្ខសុ ។

ម្នាលចិត្ត អ្នកប្រកបយើងក្នុងកាលមុន ដោយប្រការដូច្នេះ ។ អ្នកចូរមើលឧបាទានក្ខន្ធ ថាជាទុក្ខ ដោយឧបាយនៃបញ្ញា កាលណា តណ្ហាញុំាងទុក្ខឲ្យកើតឡើង អ្នកចូរលះបង់នូវតណ្ហានោះចោលចេញ ចូរធ្វើនូវទីបំផុតនៃទុក្ខ ក្នុងអត្តភាពនេះឲ្យបាន ម្នាលចិត្ត អ្នកប្រកបយើងក្នុងកាលមុន ដោយប្រការដូច្នេះ ។ អ្នកចូរឃើញឲ្យច្បាស់ ដោយឧបាយនៃប្រាជ្ញា ថាជារបស់មិនទៀងផង ជាទុក្ខផង ថាជារបស់សោះសូន្យ មិនមែនខ្លួនប្រាណផង ថាជារបស់លាមកជាគ្រឿងសម្លាប់ផង ហើយចូរបិទ នូវការពិចារណាក្នុងចិត្ត ដោយចិត្តរបស់ខ្លួន ម្នាលចិត្ត អ្នកប្រកបយើង ក្នុងកាលមុន ដោយប្រការដូច្នេះ ។ អ្នកជាស្រមណ៍កំណោរ មានភេទប្លែកពីគ្រហស្ថហើយ ជាអ្នកត្រាច់ទៅដើម្បីអាហារ មានអម្បែងក្នុងដៃ សុំគេក្នុងត្រកូលទាំងឡាយ ចូរអ្នកប្រកបតាមព្រះពុទ្ធដីការបស់ព្រះសាស្តា អ្នកស្វែងរកគុណដ៏ធំវិញ ម្នាលចិត្ត អ្នកប្រកបយើងក្នុងកាលមុន ដោយប្រការដូច្នេះ ។ អ្នកចូរសង្រួមឲ្យល្អ ដើរទៅក្នុងចន្លោះច្រក មិនមានចិត្តជាប់ចំពាក់ ក្នុងត្រកូល ក្នុងកាមទាំងឡាយ ដូចព្រះចន្ទ្រពេញបូណ៌ មិនមានមន្ទិលសៅហ្មង ម្នាលចិត្ត អ្នកប្រកបយើង ក្នុងកាលមុន ដោយប្រការដូច្នេះ ។

១១៣

### ថេរគាថាយ បញ្ញាសនិបាតោ

អារញ្ញិកោ ហោហិ ច បិណ្ឌបាតិកោ
សោសានិកោ ហោហិ ច បំសុកូលិកោ
នេសជ្ជិកោ ហោហិ សទា ធុតេ រតោ
ឥតិស្សុ មំ ចិត្ត បុរេ និយុញ្ជសិ ។
រោបេត្វា រុក្ខានិ យថា ផលេសី
មូលេ តរុំ ឆេត្តុ តមេវ ឥច្ឆសិ
តថូបមំ ចិត្ត ឥទំ ករោសិ
យម្មំ អនិច្ចម្ហិ ចលេ និយុញ្ជសិ ។
អរូប ទូរង្គម ឯកចារិ
ន តេ ករិស្សំ វចនំ ឥទានិហំ
ទុក្ខា ហិ កាមា កដុកា មហព្ភយា
និព្វានមេវាភិមនោ ចរិស្សំ ។
នាហំ អលក្ខ្យា អហិរីកតាយ វា
ន ចិត្តហេតូ ន ច ទូរកន្តនា
អាជីវហេតូ ច អហំ ន និក្ខមឹ
កតោ ច តេ ចិត្ត បដិស្សវោ មយា ។
អប្បិច្ឆតា សប្បុរិសេហិ វណ្ណិតា
មក្ខប្បហានំ វូបសមោ ទុក្ខស្ស

អ្នកចូរជាបុគ្គលប្រព្រឹត្តនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ប្រព្រឹត្តនៅក្នុងព្រៃស្មសាន ទ្រទ្រង់សំពត់បង្សុកូល ប្រព្រឹត្តអង្គុយ (មិនដេក) ត្រេកអរក្នុងធុតង្គគុណសព្វកាល ម្នាលចិត្ត អ្នកប្រកបយើង ក្នុងកាលជាដំបូង ដោយប្រការដូច្នេះ ។ បុរសអ្នកស្វែងរកផ្លៃឈើ ដាំដើមឈើទាំងឡាយ ហើយប្រាថ្នាដើម្បីកាប់នូវដើមឈើនោះ ត្រង់គល់ មានឧបមាដូចម្តេចមិញ ម្នាលចិត្ត អ្នកធ្វើហេតុនេះ ក៏មានឧបមេយ្យដូច្នោះ អ្នកប្រកបយើង ក្នុងសេចក្តីញាប់ញ័រ មិនទៀងទាត់ ។ ម្នាលអរូប (ចិត្ត) ទៅកាន់ទីឆ្ងាយ ត្រាច់ទៅតែម្នាក់ឯងឥឡូវនេះ យើងលែងធ្វើតាមសម្តីអ្នកហើយ ព្រោះថាកាមទាំងឡាយ ជាទុក្ខ ក្តៅផ្សា មានភ័យធំ យើងនឹងមានចិត្តឧទ្ទិសទៅរកព្រះនិព្វានហើយ ។ យើងមិនមែនចេញបួស ព្រោះតែឥតបុណ្យ ព្រោះតែឥតសេចក្តីអៀនខ្មាស ព្រោះហេតុតែលុះក្នុងអំណាចរបស់ចិត្ត ព្រោះហេតុតែដើរផ្លូវឆ្ងាយ ឬព្រោះហេតុតែការចិញ្ចឹមជីវិតទេ ម្នាលចិត្ត ការប្តេជ្ញា យើងបានធ្វើដល់អ្នកហើយ ។ ភាពជាបុគ្គលប្រាថ្នាតិចការលះបង់ នូវសេចក្តីលុបគុណគេ ការរម្ងាប់នូវទុក្ខ(ទាំងនេះ) សប្បុរសទាំងឡាយ (មានព្រះពុទ្ធជាដើម) សរសើរហើយ

ឥតិស្សុ មំ ចិត្ត តទា និយុញ្ជសិ
ឥទានិ ត្វំ គច្ឆសិ បុព្វចិណ្ណំ ។
តណ្ហាវិជ្ជា ច បិយាបិយញ្ច
សុភានិ រូបានិ សុខា ច វេទនា
មនោបិយា[១] កាមគុណា ច វន្តា
វន្តេ អហំ អាវសិតុំ[២] ន ឧស្សហេ ។
សព្វត្ថ តេ ចិត្ត វចោ កតំ មយា
ពហូសុ ជាតីសុ ន មេសិ កោបិតោ
អជ្ឈត្តសម្ភវោ កតញ្ញុតាយ តេ
ទុក្ខេ ចិរំ សំសរិតំ តយា កតេ ។
ត្វញ្ញេវ នោ ចិត្ត ករោសិ ព្រាហ្មណោ
ត្វំ ខត្តិយេ រាជទិសី ករោសិ
វេស្សា ច សុទ្ទា ច ភវាម ឯកទា
ទេវត្តនំ វាបិ តវេវ វាហសា ។
តវេវ ហេតូ អសុរា ភវាមសេ
ត្វំ មូលកំ នេរយិកា ភវាមសេ
អថោ តិរច្ឆានគតាបិ ឯកទា

---

១ ឱ. ម. មនាបិយា ។ ២ ឱ. អាគមិតុំ ។ ម. អាវមិតុំ ។

ម្នាលចិត្ត អ្នកបានប្រកបយើង ក្នុងកាលណោះ ដោយប្រការដូច្នេះ ឥឡូវនេះ អ្នកដល់នូវ (សេក្តីប្រាថ្នាធំ) ដែលខ្លួនធ្លាប់ប្រព្រឹត្តមកហើយ ។ តណ្ហា អវិជ្ជា សេចក្តីស្រឡាញ់សេចក្តីមិនស្រឡាញ់ រូបទាំងឡាយដ៏ល្អ សុខវេទនាទាំងឡាយ និងកាមគុណទាំងឡាយជាទីពេញចិត្ត (ទាំងនេះ) យើងលះបង់អស់ហើយ យើងមិនអាចនៅគ្រប់គ្រងកិលេសធម៌ ដែលយើងលះបង់អស់ហើយទេ ។ ម្នាលចិត្ត យើងបានធ្វើតាមពាក្យអ្នកគ្រប់ជាតិទាំងឡាយច្រើនហើយ អ្នកតាមយើងមិនទាន់ទេ ការប្រឡូកប្រឡំខាងក្នុង អ្នកបានធ្វើឲ្យកក្រើក ព្រោះតែអ្នកដឹងគុណ ដែលអ្នកដទៃធ្វើហើយ អ្នកធ្វើឲ្យយើងត្រាច់ទៅក្នុងសង្សារទុក្ខ អស់កាលយូរហើយ ។ ម្នាលចិត្ត អ្នកធ្វើយើងឲ្យជាព្រាហ្មណ៍ អ្នកធ្វើយើងឲ្យជាខត្តិយៈ ជាស្តេច ជាឥសី ជួនណា យើងកើតជាវេស្សៈ ឬជាសុទ្ទៈ មួយទៀត អ្នកធ្វើនូវភាពជាទេវតា (ដល់យើង) ព្រោះហេតុតែអ្នក ។ យើងជាអសុរ ព្រោះហេតុតែអ្នក យើងជាសត្វនរក ក៏ព្រោះអ្នកជាហេតុ មួយវិញទៀត ជួនកាល យើងកើតជាតិរច្ឆាន

បេតត្តនំ ភាបិ តវេវ ភាហសា ។
ន ឆូន ទុព្ភិស្សសិ មំ បុនប្បុនំ
មុហុំ មុហុំ ភារណិកំវ ទស្សហំ[1]
ឧម្មត្តកោវេ មយា បលោភសិ
កិញ្ចាបិ តេ ចិត្ត វិរាជិតំ[2] មយា ។
ឥទំ បុរេ ចិត្តមចារិ ចារិកំ
យេនិច្ឆកំ យត្ថកាមំ យថាសុខំ
តទជ្ជហំ និគ្គហិស្សាមិ យោនិសោ
ហត្ថឹ បភិន្នំ វិយ អង្កុសគ្គហោ ។
សត្ថា ច មេ លោកមិមំ អជិដ្ឋហិ
អនិច្ចតោ អទ្ធុវតោ អសារតោ
បក្ខន្ទ មំ ចិត្ត ជិនស្ស សាសនេ
តារេហិ ឱឃា មហតោ សុទុត្តរា ។
ន តេ ឥទំ ចិត្ត យថាបុរាណកំ
នាហំ អលំ តុយ្ហ វសេ និវត្តិតុំ
មហេសិនោ បព្ពជិតោម្ហិ សាសនេ

១ ឱ. ម. ទស្សយំ ។ ២ ឱ. ម. វិរាធិតំ ។

កើតជាប្រេត ព្រោះហេតុតែអ្នក ។ អ្នកនឹងប្រទូស្តយើង រឿយ ៗ មិនបានទេ អ្នកធ្លាប់ប្រលោមយើង ដូចជាបុគ្គលឆ្កួត ឬដូចជាបុរស បង្ហាញនូវហេតុនៃលោករឿយៗ ម្នាលចិត្ត យើងបានកម្ចាត់បង់អ្នកជ្រះស្រឡះហើយ ។ កាលពីដើម ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមចំណង់ តាមប្រាថ្នា តាមសប្បាយ ថ្ងៃនេះ យើងនឹងផ្ចញ់ផ្ចាល់ចិត្តនោះ ដោយ ឧបាយនៃប្រាជ្ញា ដូចហ្មដំរីកាន់កង្វេរ បង្ខឹកដំរីចុះប្រេង ។ (ព្រះសម្មាសម្ពុទ្ធ) ជាគ្រូនៃយើង ទ្រង់តាំងទុកនូវលោកនេះ ថាជារបស់មិនទៀង ជារបស់មិនមាំមួន ជារបស់រកខ្លឹមសារ គ្មាន ម្នាលចិត្ត អ្នកចូរញ៉ាំងយើងឲ្យស្ទុះទៅ ក្នុងសាសនា នៃ ព្រះជិនស្រីវិញ អ្នកចូរញ៉ាំងយើងឲ្យឆ្លងផុតចាកជំនន់ដ៏ធំ ដែលគេឆ្លងបានដោយកម្រវិញ ។ ម្នាលចិត្ត ផ្ទះគឺអត្តភាពនេះ ដូចជារបស់ចាស់ មិនមានដល់អ្នកទៀតទេ យើងមិនគួរនឹង ប្រព្រឹត្តទៅ ក្នុងអំណាច របស់អ្នកឡើយ យើងជាអ្នកបួស ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះអង្គស្វែងរកនូវគុណដ៏ធំ

ន មាទិសា ហោន្តិ វិនាសធារិនោ ។
នគា សមុទ្ទា សរិតា វសុន្ធរា
ទិសា ចតស្សោ វិទិសា អធោទិសា
សព្វេ អនិច្ចា តិភវា ឧបទ្ទុតា
កុហឹ គតោ ចិត្ត សុខំ រមិស្សសិ ។
ធី[១] ធី បរំ កឹ មម ចិត្ត កាហសិ
ន តេ អលំ ចិត្ត វសានុវត្តកោ
ន ជាតុ ភស្តំ ឧភតោ មុខំ ឆុបេ
ធិរត្ថុ បូរំ នវសោតសន្ទនិ ។
វរាហឯណេយ្យវិគាឡ្ហសេវិតេ
បព្ភារកូដេ បកតេវ សុន្ទរេ
នវម្ពុនា ចាវុសសិត្តកាននេ
តហឹ គុហាគេហគតោ រមិស្សសិ ។
សុនីលគីវា សុសិខា សុបេខុណា
សុចិត្តបត្តច្ឆទនា វិហង្គមា
សុមញ្ជុឃោសត្ថនិតាភិគជ្ជិនោ
តេ តំ រមិស្សន្តិ វនម្ហិ ឈាយិនំ ។

---
១ ម. វីតប្បរំ ។

ពួកបុគ្គលដូចយើង មិនមែនជាអ្នកទ្រទ្រង់ នូវសេចក្ដីវិនាស ឡើយ ។ ភ្នំ សមុទ្រ ស្ទឹង ផែនដី ទិសធំទាំង ៤ ទិសតូច ទិសខាងក្រោម ភព ៣ ទាំងអស់ ជារបស់មិនទៀង ត្រូវ រាគាទិក្កិលេសបៀតបៀនហើយ ម្នាលចិត្ត អ្នកទៅក្នុងទីណា នឹងត្រេកអរសប្បាយបាន ។ ម្នាលចិត្ត ថ្វីយ ៗ អ្នកនឹងធ្វើអំពើ អ្វីដទៃទៀតដល់យើង ម្នាលចិត្ត យើងមិនគួរប្រព្រឹត្តទៅតាម អំណាចអ្នកឡើយ (ដូច) បុគ្គលមិនហ៊ានពាល់ទៃ ដែលមាន មាត់ទាំងពីរខាង ថ្វីយ (រូបនេះ) សឹងពេញ (ដោយរបស់មិន ស្អាត) សម្រាប់ហូរចេញនូវវត្ថុមិនស្អាតតាមមុខដំបៅទាំង ៩ ។ អ្នកនៅក្នុងផ្ទះគឺគុហា ត្រេកអរក្នុងញកភ្នំ កំពូលភ្នំ ជាទីដ៏ល្អ តាមប្រក្រតី មានព្រៃដែលទឹកភ្លៀងថ្មីធ្លាក់ចុះ ជាទីដែលពួក ជ្រូកនិងទ្រាយចុះឡើងអាស្រ័យនៅហើយនោះ ។ ហ្វូងបក្សី (ក្ងោក) មានកខៀវល្អ មានសិរល្អ មានតួស្វាបល្អ មានរោម ស្លាបដ៏វិចិត្រល្អ មានសំឡេងស្រែកយំ ឮសូរពីរោះក្រៃលែង នោះ នឹងត្រេកអរចំពោះអ្នក ចម្រើនឈាន ក្នុងព្រៃ(នោះឯង)។

១១៧



វុដ្ឋម្ហិ ទេវេ ចតុរង្គុលេ តិណេ
សម្បុប្ផិតេ មេឃនិកម្ហិ កាននេ
នគន្តរេ វិដបិសមោ សយិស្សំ
តំ មេ មុទុ ហេហិតិ តូលសន្និភំ ។
តថា តុ ការិស្សាមិ[១] យថាបិ ឥស្សរោ
យំ លព្ភតិ តេនបិ ហោតុ មេ អលំ
តំ តំ ការិស្សាមិ យថា អតន្ទិតោ
ពិឡារភស្តំវ យថា សុមទ្ទិតំ ។
តថា តុ ការិស្សាមិ យថាបិ ឥស្សរោ
យំ លព្ភតិ តេនបិ ហោតុ មេ អលំ
វីរិយេន តំ មយ្ហ វសានយិស្សំ
គជំវ មត្តំ កុសលង្កុសគ្គហោ ។
តយា សុទន្តេន អវត្ថិតេន[២] ហិ
ហយេន យោគ្គាចរិយោវ ឧជ្ជុនា
បហោមិ មគ្គំ បដិបជ្ជិតុំ សិវំ
ចិត្តានុរក្ខីហិ សទា និសេវិតំ ។

១ ឱ. ម. កស្សាមិ ។ ២ ឱ. ម. អវដ្ឋិតេន ។

កាលភ្លៀងបង្អុរចុះមកហើយ កាលស្មៅដុះឡើងប្រវែង ៤ ធ្នាប់ កាលព្រៃមានសម្បុរដូចមេឃ មានផ្ការីកស្គុះស្គាយហើយ យើងក៏ប្រហែលនឹងដើមឈើ នឹងដេកត្រង់ចន្លោះនៃព្រៃភ្នំ ឯកន្ទេលដេករបស់យើងនោះ នឹងមានសម្ផស្សទន់ដូចជាសំឡី ។ បុរសជាឥស្សរៈ (ធ្វើទាសកម្មករឲ្យលុះក្នុងអំណាចខ្លួន) យ៉ាងណាមិញ (ម្នាលចិត្ត) យើងនឹងធ្វើ (អ្នកឲ្យលុះក្នុងអំណាច) យ៉ាងនោះ យើងបានបច្ច័យណា បច្ច័យនោះសូមឲ្យល្មមដល់យើង (ម្នាលចិត្ត) ព្រោះហេតុនោះ បុគ្គលមិនខ្ជិលយ៉ាងណា យើងនឹងធ្វើអ្នក យ៉ាងនោះ ឲ្យដូចស្បែកសំពោចដែលគេសម្ងាប់ល្អហើយ ។ បុរសជាឥស្សរៈ(ធ្វើទាសកម្មករឲ្យលុះក្នុងអំណាចខ្លួន) យ៉ាងណាមិញ យើងនឹងធ្វើ (អ្នកឲ្យលុះក្នុងអំណាចខ្លួន) ក៏យ៉ាងនោះដែរ យើងបានបច្ច័យណា បច្ច័យនោះសូមឲ្យល្មមដល់យើង (ម្នាលចិត្ត) យើងនឹងដឹកនាំអ្នកឲ្យលុះក្នុងអំណាចរបស់យើង ដោយសេចក្តីព្យាយាម ដូចហ្មដំរីដ៏ប៉ិនប្រ៉ៅ កាន់កង្វេរពង្រាបដំរីចុះប្រេង ។ យើងអាចដើរទៅកាន់ផ្លូវដ៏ក្សេម ដែលពួកលោកអ្នករក្សាចិត្ត ធ្លាប់សេពហើយសព្វកាល ដោយសារអ្នក ដែលទូន្មានល្អហើយ តាំងមាំហើយ ដូចហ្មសេះ បង្ហាត់សេះ (ឲ្យទៅកាន់ទីតាមបំណង) ដោយសារសេះស្លូតត្រង់ ។

អារម្មណេ តំ ពលសា និពន្ធិស្សំ[១]
នាគំវ ថម្ភម្ហិ ទឡ្ហាយ រជ្ជុយា
តម្មេ សុគុត្តំ សតិយា សុភាវិតំ
អនិស្សិតំ សព្វភវេសុ ហេហិសិ ។
បញ្ញាយ ឆេត្វា វិបថានុសារិនំ
យោគេន និគ្គយ្ហ បថេ និវេសិយ
ទិស្វា សមុទយំ វិភវញ្ច សម្ភវំ
ទាយាទកោ ហេហិសិ អគ្គវាទិនោ ។
ចតុព្វិបល្លាសវសំ អធិដ្ឋិតំ
គាមណ្ឌលំវ បរិនេសិ ចិត្ត មំ
ននុ សញ្ញោជនពន្ធនច្ឆិទំ
សំសេវសេ ការុណិកំ មហាមុនឹ ។
មិគោ យថា សេរិ សុចិត្តកាននេ
រម្មំ គិរឹ ចាវិសិ អព្ភមាលិនំ[២]
អនាកុលេ តត្ថ នគេ រមិស្សសិ
អសំសយំ ចិត្ត បរាភវិស្សសិ ។

១ ឱ. ម. និពន្ធិសំ ។ ២ ម. បាវុស អព្ភមាលិនឹ ។

(ហ្មដំរីចង្រៀក) ដំរីនឹងសសរ ដោយខ្សែដ៏មាំ យ៉ាងណា យើងនឹងចងអ្នកទុក ក្នុងកម្មដ្ឋានារម្មណ៍ ដោយកម្លាំងភាវនា យ៉ាងនោះដែរ (ម្នាលចិត្ត) អ្នកនោះដែលយើងគ្រប់គ្រងហើយ ចម្រើនល្អហើយ ដោយសតិ នឹងទៅជាអ្នកមានតណ្ហានិស្ស័យ ជាដើមមិនអាស្រ័យ ក្នុងភពទាំងពួងឡើយ ។ អ្នកបើបានផ្តាច់ ដំណើរទៅកាន់ផ្លូវខុស ដោយប្រាជ្ញា រួចផ្ចញ់ផ្ចាល់ដោយ ព្យាយាម ឲ្យតម្កល់នៅក្នុងផ្លូវ វិបស្សនាវិញ ហើយឃើញនូវ សេចក្តីកើត សេចក្តីវិនាសនិងសេចក្តីចម្រើននោះ នឹងបានជា ទាយាទនៃព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលពាក្យដ៏ប្រសើរ ។ ម្នាលចិត្ត អ្នកទង់ទាញយើងឲ្យលុះអំណាចនៃវិបល្លាស ៤[១] ដូចជាកូនក្មេងអ្នកស្រុក ក្រែងអ្នកបានសេពគប់ នឹងព្រះ មហាមុនីប្រកបដោយសេចក្តីករុណា ជាអ្នកផ្តាច់នូវចំណង គឺសំយោជនៈហើយឬ ។ ម្រឹគមានសេរី ចូលទៅកាន់ភ្នំ ជាទី ត្រេកអរ ដេរដាសដោយរបៀបពពក ក្នុងព្រៃដ៏វិចិត្រល្អ យ៉ាងណា អ្នកនឹងត្រេកអរក្នុងភ្នំនោះ ដែលមិនរើកវរ ក៏យ៉ាង នោះដែរ ម្នាលចិត្ត អ្នកនឹងវិនាស ឥតមានសង្ស័យឡើយ ។

១ វិបល្លាស ៤ គឺសម្គាល់ថាទៀង ក្នុងរបស់មិនទៀង ១ សម្គាល់ថាល្អ ក្នុងរបស់មិនល្អ ១ សម្គាល់ថាសុខ ក្នុងរបស់មិនមែនសុខ ១ សម្គាល់ថាខ្លួន ក្នុងសភាពមិនមែនខ្លួន ១ ។ អដ្ឋកថា។

ថេរគាថាយ បញ្ញាសនិបាតោ

យេ តុយ្ហ ឆន្ទេន វសេន វត្តិនោ
នរា ច នារី ច អនុភោន្តិ យំ សុខំ
អវិទ្ទសុ មារវសានុវត្តិនោ
ភវាភិនន្ទី តវ ចិត្ត សេវកាតិ ។

តាលបុដោ ថេរោ ។

## ឧទ្ទានំ

បញ្ញាសម្ហិ និបាតម្ហិ ឯកោ តាលបុដោ សុចិ
គាថាយោ តត្ថ បញ្ញាស បុន បញ្ច ច ឧត្តរីតិ ។

បញ្ញាសនិបាតោ សមត្តោ ។

---

ម្នាលចិត្ត ជនប្រុសស្រីទាំងឡាយណា ជាអ្នកប្រព្រឹត្តទៅតាមសេចក្ដីប្រាថ្នា ទៅតាមអំណាចរបស់អ្នក រមែងទទួលសេចក្ដីសុខណា ជនប្រុសស្រីទាំងនោះ ជាអ្នកល្ងង់ខ្លៅ ប្រព្រឹត្តទៅតាមអំណាចនៃមារ ជាអ្នកត្រេកអរនឹងភព ជាសេវកៈរបស់អ្នក (រមែងបាននូវសេចក្ដីសុខនោះគឺសាមិសសុខ) ។

ព្រះតាលបុដត្ថេរ ។

# ឧទ្ទាន

ក្នុងបញ្ញាសនិបាតនោះ ព្រះតាលបុដត្ថេរ អ្នកបរិសុទ្ធ ១ អង្គ ពោលនូវគាថាទាំងឡាយ ៥៥ ។

ចប់ បញ្ញាសនិបាត ។

# ថេរគាថាយ សដ្ឋិកនិបាតោ

[២៦៤] អារញ្ញិកា បិណ្ឌបាតិកា   ឧញ្ឆាបត្តាគតេ រតា
ទាលេមុ មច្ចុនោ សេនំ   អជ្ឈត្តំ សុសមាហិតា ។
អារញ្ញិកា បិណ្ឌបាតិកា   ឧញ្ឆាបត្តាគតេ រតា
ធុនាមុ[១] មច្ចុនោ សេនំ   នឡាគារំវ កុញ្ជរោ ។
រុក្ខមូលិកា សាតតិកា   ឧញ្ឆាបត្តាគតេ រតា
ទាលេមុ មច្ចុនោ សេនំ   អជ្ឈត្តំ សុសមាហិតា ។
រុក្ខមូលិកា សាតតិកា   ឧញ្ឆាបត្តាគតេ រតា
ធុនាមុ មច្ចុនោ សេនំ   នឡាគារំវ កុញ្ជរោ ។
អដ្ឋិកង្កលកុដិកេ   មំសន្ហារុបសិព្វិតេ
ធិរត្ថុ បូរេ ទុគ្គន្ធេ   បរគត្តេ មមាយសេ ។
គូថភស្តេ តចោនទ្ធេ   ឧរគណ្ឌិបិសាចិនិ
នវ សោតានិ តេ កាយេ   យានិ សន្ទន្តិ សព្វទា ។

---

១ ឱ. ម. ធុនាម ។

# ថេរគាថា សដ្ឋិកនិបាត

[២៦៤] *ពួកយើង ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ត្រេកអរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ជាអ្នកមានចិត្តតាំងមាំល្អខាងក្នុង ចូរទម្លាយនូវសេនារបស់មច្ចុ (កិលេស) ។ ពួកយើង ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ត្រេកអរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ចូរកម្ចាត់បង់នូវសេនារបស់មច្ចុ ដូចដំរីកម្ចាត់កម្ចាយនូវផ្ទះបបុស ។ ពួកយើងជាអ្នកប្រព្រឹត្តនៅក្រោមម្លប់ឈើ មានព្យាយាមប្រព្រឹត្តទៅរឿយៗ ត្រេកអរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ជាអ្នកមានចិត្តតាំងមាំល្អខាងក្នុង ចូរទម្លាយនូវសេនារបស់មច្ចុ ។ ពួកយើងជាអ្នកប្រព្រឹត្តនៅក្រោមម្លប់ឈើ មានព្យាយាមប្រព្រឹត្តទៅរឿយ ៗ ត្រេកអរក្នុងវត្ថុដែលមាននៅក្នុងបាត្រ ដោយការស្វែងរក ចូរកម្ចាត់បង់នូវសេនារបស់មច្ចុ ដូចដំរីកម្ចាត់បង់នូវផ្ទះបបុស ។ (នៃស្រីផ្កាមាស) ថ្វីយ នាងរាប់អានខ្ទមអ្នកដទៃ ដែលជាខ្ទមគឺរាងឆ្អឹងបែបចម្លឹង ៗ មានសាច់និងសរសៃរួបរឹតហើយ ពេញ(ដោយគ្រឿងមិនស្អាត) មានក្លិនស្អុយ ។ ម្នាលនាងមានពកឮដ៏ទ្រូង ដូចបិសាចក្នុងកាយរបស់នាង ដែលពេញដោយលាមក ស្រោបដោយស្បែក (នេះ) មានទ្វារសម្រាប់បង្ហូរចេញ ៩ តែងហៀរហូរគ្រប់ពេល ។*

## ១២១



តវ សរីរំ នវសោតំ ទុគ្គន្ធកំ បរិវជ្ជេយ្យ(១)
ភិក្ខុ បរិវជ្ជយតេ តំ មីឡ្ហំវ យថា សុចិកាមោ ។
ឯវញ្ចេ តំ ជនោ ជញ្ញា យថា ជានាមិ តំ អហំ
អារកា បរិវជ្ជេយ្យ គូថដ្ឋានំវ ចាវុសេ ។
ឯវមេតំ មហាវីរ យថា សមណ ភាសសិ
ឯត្ថ ចេកេ វិសីទន្តិ បង្កម្ហិវ ជរគ្គវោ ។
អាកាសម្ហិ ហលិទ្ទាយ យោ មញ្ញេថ រជេតវេ
អញ្ញេន វាបិ រង្គេន វិឃាតុទយមេវ តំ ។
តទាកាសសមំ ចិត្តំ អជ្ឈត្តំ សុសមាហិតំ
មា ចាបចិត្តេ អាសាទិ(២) អគ្គិក្ខន្ធំវ បក្ខិមា ។
បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ
អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
អនេកាការសម្បន្នេ សារិបុត្តម្ហិ និព្វុតេ ។

១ ឱ. ទុគ្គន្ធំ ករិបរិពន្ធ ។ ម. ទុគ្គន្ធំ ករិបរិពន្ធំ ។ ២ ឱ. ម. អាហរិ ។

ភិក្ខុគប្បីរៀបចំនូវសរីរៈនាង ដែលមានមុខហូរ ៩ មានក្លិនអាក្រក់ បុគ្គលអ្នកចង់ស្អាត ដើរវាងគូថៈ យ៉ាងណាមិញ ភិក្ខុចៀសវាងនូវសរីរៈរបស់នាង ក៏យ៉ាងនោះដែរ ។ អាត្មាដឹងនូវសរីរៈនោះយ៉ាងណា បើមហាជនដឹងនូវសរីរៈនោះយ៉ាងនោះ គប្បីតែចៀសវាងសរីរៈនោះអំពីចម្ងាយ ដូចគេចៀសវាងកន្លែងគូថៈក្នុងកាលដែលភ្លៀងបង្អុរចុះ ។

បពិត្រសមណៈ លោកមានថេរវាចាយ៉ាងណា បពិត្រលោកអ្នកមានព្យាយាមច្រើន ហេតុនុ៎ះក៏យ៉ាងនឹងមែនហើយ តែគង់មានជនពួកខ្លះ លិចនៅក្នុងសរីរៈនុ៎ះដែរ ដូចគោចាស់លិចនៅក្នុងភក់ ។

នរណាសម្គាល់ដើម្បីជ្រលក់នូវអាកាស ដោយរមៀត ឬដោយគ្រឿងជ្រលក់ឯទៀត ការធ្វើរបស់បុគ្គលនោះ នាំឲ្យតែកើតសេចក្ដីលំបាកទេ ។ ចិត្តដែលតម្កល់នៅល្អក្នុងសន្តាននោះ ក៏ស្មើគ្នានឹងអាកាស នាងកុំត្រេកអរ (នឹងយើង) ដោយចិត្តលាមក ដូចសត្វស្វាប (មមាច) ត្រេកអរនឹងគំនរភ្លើងឡើយ ។ នាងចូរមើលរាងកាយដែលធ្វើឲ្យវិចិត្រហើយ ជាទីប្រជុំនៃដំបៅ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយ ឈឺជានិច្ច ដែលពួកជនពាលប្រាថ្នាដោយច្រើន សេចក្ដីទៀងទាត់និងការមាំមួនរបស់រាងកាយនេះ មិនមានឡើយ ។

កាលព្រះសារីបុត្រ បរិបូណ៌ដោយអាការដ៏ច្រើន បរិនិព្វានហើយ សេចក្ដីស្ញប់ស្ញែង សេចក្ដីព្រឺរោម ក៏កើតមានឡើងថា ។

អនិច្ចា វត សង្ខារា    ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ    តេសំ វូបសមោ សុខោ ។
សុខុមំ តេ បដិវិជ្ឈន្តិ    វាលគ្គំ ឧសុនា យថា
តេ បញ្ចក្ខន្ធេ បស្សន្តិ    បរតោ នោ ច អត្តតោ ។
តេ ច បស្សន្តិ សង្ខារេ    បរតោ នោ ច អត្តតោ
បច្ចព្យាធឹសុ និបុណំ    វាលគ្គំ ឧសុនា យថា ។
(សត្តិយា វិយ ឱមដ្ឋោ    ឌយ្ហមានេវ មត្ថកេ
កាមរាគប្បហានាយ    សតោ ភិក្ខុ បរិព្វជេ) ។
សត្តិយា វិយ ឱមដ្ឋោ    ឌយ្ហមានេវ មត្ថកេ
ភវរាគប្បហានាយ    សតោ ភិក្ខុ បរិព្វជេ ។
ចោទិតោ ភាវិតត្តេន    សរីរន្តិមធារិនា
មិគារមាតុ បាសាទំ    បាទង្គុដ្ឋេន កម្បយឹ ។

ឱហ្ន៎ សង្ខារទាំងឡាយ មិនទៀងទេ មានការកើតឡើងនិងការវិនាសទៅជាធម្មតា កើតឡើងហើយតែងរលត់វិញ ការរម្ងាប់នូវសង្ខារទាំងនោះ ទើបនាំមកនូវសុខ ។ ពួកព្រះយោគីណា ពិចារ-ណា ឃើញច្បាស់នូវខន្ធទាំង ៥ ថាជារបស់ដទៃ ទាំងមិនមែនជារបស់ខ្លួន ពួកព្រះយោគីនោះ តែងចាក់ធ្លុះនូវធម៌ដ៏សុខុមបាន ដូចបុគ្គលបាញ់ចុងរោមកន្ទុយ ដោយព្រួញ ។ មួយទៀត ពួកព្រះយោគីណាពិចារណាឃើញច្បាស់ នូវសង្ខារទាំងឡាយ ថាជារបស់ដទៃ ទាំងមិនមែនជារបស់ខ្លួន ពួកព្រះយោគីនោះ ឈ្មោះថា បានចាក់ធ្លុះនូវធម៌ដ៏ល្អិត ដូចបុគ្គលបាញ់ចុងរោមកន្ទុយដោយព្រួញ ។

(ភិក្ខុអ្នកមានស្មារតី គប្បីវៀរ ដើម្បីលះបង់នូវកាមរាគ ដូចជាគេបោះឬពួយនឹងលំពែង ទម្លុះពីលើមកក្រោម ពុំនោះសោតដូចជាគេលត់ភ្លើងកំពុងឆេះឰដ៏ក្បាល) ។ ភិក្ខុអ្នកមានស្មារតីគប្បីវៀរ ដើម្បីលះបង់នូវភវរាគ ដូចជាគេបោះ ឬ ពួយនឹងលំពែង ទម្លុះពីលើមកក្រោម ពុំនោះសោត ដូចជាគេលត់ភ្លើងដែលកំពុងឆេះឰដ៏ក្បាល ។

ខ្ញុំ លុះព្រះសាស្តាចារ្យ ព្រះអង្គមានព្រះកាយអប់រំហើយ ព្រះអង្គទ្រទ្រង់ នូវសរីរៈជាទីបំផុត ទ្រង់បានដាស់តឿនហើយ ក៏ញុំាងមិគារមាតុប្រាសាទ ឲ្យកក្រើកបាន ដោយចុងមេជើង ។

១២៣

ថេរគាថាយ សឌ្ឍិកនិបាតោ

ន យិទំ សិថិលមារព្ភ  ន យិទំ អប្បេន ថាមសា
និព្វានមធិគន្តព្វំ  សព្វគន្ថបមោចនំ ។
អយញ្ច ទហរោ ភិក្ខុ  អយមុត្តមបោរិសោ
ធារេតិ អន្តិមំ ទេហំ  ជេត្វា មារំ សវាហនំ ។
វិវរមនុបតន្តិ វិជ្ជុតា  វេភារស្ស ច បណ្ឌវស្ស ច
នគវិវរគតោ[១] ច ឈាយតិ  បុត្តោ អប្បដិមស្ស តាទិនោ ។
ឧបសន្តោ ឧបរតោ  បន្តសេនាសនោ មុនិ
ទាយាទោ ពុទ្ធសេដ្ឋស្ស  ព្រហ្មុនា អភិវន្ទិតោ ។
ឧបសន្តំ ឧបរតំ  បន្តសេនាសនំ មុនឹ
ទាយាទំ ពុទ្ធសេដ្ឋស្ស  វន្ទ ព្រាហ្មណ កស្សបំ ។
យោ ច ជាតិសតំ គច្ឆេ  សព្វា ព្រាហ្មណជាតិយោ
សោត្តិយោ វេទសម្បន្នោ  មនុស្សេសុ បុនប្បុនំ ។
អជ្ឈាយកោបិ ចេ អស្ស  តិណ្ណំ វេទាន បារគូ
ឯតស្ស វន្ទនាយេតំ  កលំ នាគ្ឃតិ សោឡសឹ ។

---
១ ម. នភវិវរគតោ ។

បុគ្គលប្រារព្ធការងារណាមួយធូរៗ ឬដោយកម្លាំងព្យាយាមស្តួចស្តើង មិនអាចបានដល់ព្រះនិព្វាន ដែលជាគ្រឿងរួចចាកគន្ធធម៌ទាំងពួងទេ ។ ភិក្ខុកំលោះនេះក្តី បុរសដ៏ឧត្តមនេះក្តី បានឈ្នះនូវមារព្រមទាំងសេនានៃមារហើយទ្រទ្រង់នូវរាងកាយ ជាទីបំផុតបាន ។ ផ្ទេកបន្ទោរទាំងឡាយ រមែងធ្លាក់ក្នុងចន្លោះ នៃភ្នំឈ្មោះវេភារៈនិងភ្នំឈ្មោះបណ្ឌវៈ ឯបុត្រនៃព្រះពុទ្ធជាតាទិបុគ្គល រកបុគ្គលប្រៀបស្មើមិនបាន លោកនៅក្នុងចន្លោះភ្នំ រមែងដុត (នូវធម៌ជាសត្រូវ) ។ មហាព្រហ្មថ្វាយបង្គំហើយ នូវមុនិអ្នកស្ងប់ស្ងាត់ ត្រេកអរនឹងការស្ងប់រម្ងាប់ នៅក្នុងសេនាសនៈដ៏ស្ងាត់ ជាទាយាទរបស់ព្រះពុទ្ធដ៏ប្រសើរ ។ ម្នាលព្រាហ្មណ៍ អ្នកចូរថ្វាយបង្គំព្រះកស្សប ជាមុនី អ្នកស្ងប់ស្ងាត់ ត្រេកអរនឹងការស្ងប់ស្ងាត់ នៅក្នុងសេនាសនៈដ៏ស្ងាត់ ជាទាយាទរបស់ព្រះពុទ្ធដ៏ប្រសើរចុះ ។ បើបុគ្គលណា ទៅយកកំណើតជាព្រាហ្មណ៍គ្រប់ ៗ ជាតិ អស់ ១០០ ជាតិ បុគ្គលនោះ ឈ្មោះថាព្រាហ្មណ៍ បរិបូណ៌ដោយវេទ ក្នុងពួកមនុស្សរឿយ ៗ ។ តែបើទុកជាព្រាហ្មណ៍នោះ ជាអ្នកចេះចាំមន្ត ដល់នូវត្រើយ នៃវេទទាំង ៣ ក៏ដោយចុះ ក៏នៅតែមិនដល់មួយចំណិតនៃចំណែក ដែលគេចែក ១៦ ។ ដង នៃការថ្វាយបង្គំចំពោះព្រះមហាកស្សបត្ថេរនុ៎ះឡើយ ។

យោ សោ អដ្ឋ វិមោក្ខានិ បុរេភត្តំ អផុស្សយិ[១]
អនុលោមំ បដិលោមំ តតោ បិណ្ឌាយ គច្ឆតិ
តាទិសំ ភិក្ខុំ មាសាទិ[២] មាត្តានំ ខណិ ព្រាហ្មណ
អភិប្បសាទេហិ មនំ អរហន្តម្ហិ តាទិនេ
ខិប្បំ បញ្ជលិកោ វន្ទ មា តេ វិជដិ មត្ថកំ ។
ន សោ បស្សតិ សទ្ធម្មំ សំសារេន បុរក្ខតោ
អធង្គមំ ជិម្ហបថំ កុមគ្គមនុធាវតិ ។
កិមីវ មិឡ្ហបលិត្តោ សង្ខារេ អធិមុច្ឆិតោ
បគាឡ្ហោ លាភសក្ការេ តុច្ឆោ គច្ឆតិ បោដ្ឋិលោ ។
ឥមញ្ច បស្ស អាយន្តំ សារីបុត្តំ សុទស្សនំ
វិមុត្តំ ឧភតោ ភាគេ អជ្ឈត្តំ សុសមាហិតំ ។
វិសល្លំ ខីណសំយោគំ តេវិជ្ជំ មច្ចុហាយិនំ
ទក្ខិណេយ្យំ មនុស្សានំ បុញ្ញក្ខេត្តមនុត្តរំ ។
ឯតេ សម្ពហុលា ទេវា ឥទ្ធិមន្តោ យសស្សិនោ
ទស ទេវសហស្សានិ សព្វេ ព្រហ្មបុរោហិតា
មោគ្គល្លានំ នមស្សន្តា តិដ្ឋន្តិ បញ្ជលីកតា

១ ឱ. ម. អបស្សយិ ។ ២ ឱ. ម. មាហរិ ។

ភិក្ខុណាបានវិមោក្ខ ៨ ក្នុងវេលាមុនភត្ត ជាអនុលោមបដិលោម លុះចេញចាកនិរោធសមាបត្តិនោះហើយ ទើបទៅ ដើម្បីបិណ្ឌបាត ម្នាលព្រាហ្មណ៍ អ្នកចូរត្រេកអរនឹងភិក្ខុបែបនោះ អ្នកកុំគាស់រំលើងខ្លួនឡើយ អ្នកចូរធ្វើចិត្តឲ្យត្រេកអរចំពោះព្រះអរហន្ត ជាតាទិបុគ្គល ចូរប្រណម្យអញ្ជលី ថ្វាយបង្គំឲ្យឆាប់ កុំឲ្យក្បាលអ្នកបែកជា ៧ ភាគឡើយ ។ បោដ្ឋិលភិក្ខុនោះ ត្រូវចំណង គឺសង្សារវដ្តរួបរឹតហើយ មិនបានឃើញនូវព្រះសទ្ធម្ម ស្ទុះទៅរកមិច្ឆាជីវៈ ជាផ្លូវដែលមិនគួរទៅ ជាផ្លូវវៀច ផ្លូវអាក្រក់ ។ តុច្ឆបោដ្ឋិលភិក្ខុ ជប់ចុះ ក្នុងសង្ខារ (ដែលប្រឡាំដោយកិលេស ជាគ្រឿងមិនស្អាត) លិចចុះ ក្នុងលាភៈ និងសក្ការៈ ដូចជាដង្កូវប្រឡាក់ដោយលាមក ។

អ្នកចូរមើលព្រះសារីបុត្រ ដ៏មានអាយុនេះ លោកជាអ្នកឃើញដោយប្រពៃ ជាអ្នកផុតចាកចំណែកទាំងពីរ[១] ជាអ្នកមានចិត្តតម្កល់មាំក្នុងសន្តាន មិនមានសរគឺរាគៈជាដើម មានសំយោជនៈអស់ហើយ បានសម្រេចវិជ្ជា ៣ ញាំងមច្ចុរាជឲ្យវិនាស ជាទក្ខិណេយ្យបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់មនុស្សទាំងឡាយ ។

ពួកទេវតាជាច្រើនចំនួនមួយហ្មឺនអង្គ មានឫទ្ធិមានយស ទេវតាទាំងអស់នុ៎ះទាំងពួកព្រហ្មបុរោហិត ឈរប្រណម្យនមស្ការព្រះមោគ្គល្លាន

១ គឺរួចចាករូបកាយដោយអរូបសមាបត្តិ ១ ចាកនាមកាយដោយមគ្គ ១ ។

ថេរគាថាយ សដ្ឋិកនិបាតោ

នមោ តេ បុរិសាជញ្ញ   នមោ តេ បុរិសុត្តម
យស្ស តេ អាសវា ខីណា   ទក្ខិណេយ្យោសិ មារិស ។
បូជិតោ នរទេវេន   ឧប្បន្នោ មរណាភិភូ
បុណ្ឌរីកំវ តោយេន   សង្ខារេ នោបលិម្បតិ ។

យស្ស មុហុត្តេ សហស្សធា លោកោ
សំវិទិតោ សព្រហ្មកប្បោ វសី
ឥទ្ធិគុណេ ចុតូបបាតេ កាលេ
បស្សតិ ទេវតា ស ភិក្ខុ ។

សារីបុត្តោវ បញ្ញាយ   សីលេន ឧបសមេន ច
យោបិ បារង្គតោ ភិក្ខុ   ឯតាវបរមោ សិយា ។
កោដិសតសហស្សស្ស   អត្តភាវំ ខណេន និម្មិនេ
អហំ វិកុព្វនាសុ កុសលោ   វសីភូតោម្ហិ ឥទ្ធិយា ។

សមាធិវិជ្ជាវសី បារមីគតោ
មោគ្គល្លានគោត្តោ អសិតស្ស សាសនេ
ធីរោ សមុច្ឆិន្ទិ សមាហិតិន្ទ្រិយោ
នាគោ យថា បូតិលតំវ ពន្ធនំ ។

ថា បពិត្រលោកជាបុរសអាជានេយ្យ យើងខ្ញុំសូមនមស្ការ ចំពោះលោក បពិត្រលោកជាបុរសដ៏ឧត្តម យើងខ្ញុំសូមនមស្ការ ចំពោះលោក បពិត្រលោកនិទ៌ុក្ខ លោកមានអាសវៈអស់ហើយ លោកជាទក្ខិណេយ្យបុគ្គល ។

(ព្រះមោគ្គល្លាន) ដែលនរជននិងទេវតាបូជាហើយ លោកកើត (ដោយអរិយជាតិ) ជាអ្នកគ្របសង្កត់នូវសេចក្ដីស្លាប់បាន មិនជាប់ចំពាក់ក្នុងសង្ខារ ដូចជាផ្កាឈូកស មិនប្រឡាក់ដោយទឹក ។

ព្រះមោគ្គល្លានណា ជ្រាបនូវឱកាសលោកមួយពាន់ ក្នុងកាលមួយរំពេច ព្រះមោគ្គល្លាននោះ ស្មើនឹងមហាព្រហ្ម ជាអ្នកស្ទាត់ក្នុងឥទ្ធិគុណនិងចុតូបបាតៈ លោកជាភិក្ខុ ឃើញពួកទេវតាក្នុងកាលគួរ ។

ព្រះសារីបុត្តត្ថេរ (ប្រសើរ) ដោយប្រាជ្ញា ដោយសីល ដោយឧបសមៈ ទុកជាភិក្ខុណា ជាអ្នកដល់នូវត្រើយ ភិក្ខុនោះ គប្បីជាអ្នកមានគុណយ៉ាងក្រៃលែង ដូច្នេះឯង ។

ចំណែកអាត្មា អាចនិម្មិតនូវអត្តភាពមួយសែនកោដិបានដោយមួយរំពេច ជាអ្នកឈ្លាសវៃក្នុងឫទ្ធិគឺការធ្វើផ្សេង ៗ ជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិ ។ អាត្មា ជាមោគ្គល្លានគោត្រ ដល់នូវទីបំផុតដោយសមាធិនិងភាវៈស្ទាត់ក្នុងវិជ្ជា ជាអ្នកប្រាជ្ញ មានឥន្ទ្រិយតាំងមាំ ក្នុងសាសនា (នៃព្រះសាស្ដា) ប្រាសចាកតណ្ហានិស្ស័យជាដើម បានកាត់នូវចំណងគឺកិលេស ដូចដំរីផ្ដាច់ទន្ទីង ដែលគេធ្វើដោយវល្លិ៍ស្អុយ ។

បរិចិណ្ណោ មយា សត្ថា ។ បេ ។ ភវនេត្តិ សមូហតា ។

យស្ស ចត្ថាយ បព្វជិតោ    អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ    សព្វសំយោជនក្ខយោ ។
កីទិសោ និរយោ អាសិ    យត្ថ ទុស្សី អបច្ចថ
វិធុរំ សាវកមាសជ្ជ    កកុសន្ធញ្ច ព្រាហ្មណំ ។
សតំ អាសិ អយោសង្កូ    សព្វេ បច្ចត្តវេទនា
ឦទិសោ និរយោ អាសិ    យត្ថ ទុស្សី អបច្ចថ
វិធុរំ សាវកមាសជ្ជ    កកុសន្ធញ្ច ព្រាហ្មណំ ។
យោ ឯតមភិជានាតិ    ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ    កណ្ហា ទុក្ខំ និគច្ឆសិ ។
មជ្ឈេ សាគរស្មឹ តិដ្ឋន្តិ    វិមានា កប្បដ្ឋាយិនោ
វេឡុរិយវណ្ណា រុចិរា[១]    អច្ចិមន្តោ បភស្សរា
អច្ឆរា តត្ថ នច្ចន្តិ    បុថូ នានត្តវណ្ណិយោ
យោ ឯតមភិជានាតិ ។ បេ ។ កណ្ហា ទុក្ខំ និគច្ឆសិ ។

---
១ ម. រុចិយា ។

ព្រះសាស្តា ខ្ញុំបម្រើហើយ ។ បេ ។ តណ្ហាដែលជាធម្មជាតិនាំសត្វទៅកាន់ភព ខ្ញុំបានដកហើយ ។ កុលបុត្រចេញចាកផ្ទះហើយទៅបួស ក្នុងសំណាក់បុគ្គលមិនមានផ្ទះ ដើម្បីប្រយោជន៍ណា ប្រយោជន៍គ្រឿងអស់សំយោជនៈគ្រប់យ៉ាងនោះ ក៏ខ្ញុំបានសម្រេចហើយ ។ ទុស្សីមារ បៀតបៀនទូវព្រាហ្មណ៍គឺអគ្គសាវ័កឈ្មោះវិធូរផង នូវព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកកុសន្ធៈផង ហើយឆេះនៅក្នុងនរកណា នរកនោះ ដូចម្តេចទៅ ។ ទុស្សីមារ បៀតបៀនទូវព្រាហ្មណ៍គឺសាវ័កឈ្មោះវិធូរផង នូវព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកកុសន្ធៈផង ហើយឆេះនៅក្នុងនរកណា នរកនោះប្រាកដដូច្នេះ គឺកង្វារដែក ១០០ កើតវេទនាផ្សេងៗ គ្នាគ្រប់យ៉ាង ។ ភិក្ខុណា ជាសាវ័ករបស់ព្រះពុទ្ធ ដឹងជាក់លាក់នូវផលនៃកម្មនោះ ម្នាលមារមានចិត្តខ្មៅ អ្នកបៀតបៀននូវភិក្ខុបែបនោះហើយ នឹងដល់នូវសេចក្តីទុក្ខមិនខាន ។ វិមានទាំងឡាយណាតាំងនៅអស់មួយកប្ប ឋិតនៅក្នុងកណ្តាលសាគរ មានពណ៌ដូចជាកែវពិទូរ្យ ដ៏រុងរឿង មានពន្លឺភ្លឺផ្លេក មានពួកស្រីអប្សរដ៏ច្រើន មានវណ្ណៈផ្សេង ៗ រាំក្នុងវិមានទាំងនោះ ភិក្ខុណា ដឹងជាក់លាក់នូវផលនៃកម្មនោះ ។ បេ ។ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។

១២៧

ថេរគាថាយ សដ្ឋិកនិបាតោ

យោ ច ពុទ្ធេន ចោទិតោ ភិក្ខុសង្ឃស្ស បេក្ខតោ
មិគារមាតុ បាសាទំ បាទង្គុដ្ឋេន កម្បយិ ។
យោ ឯតមភិជានាតិ ។ បេ ។ កណ្ហ ទុក្ខំ និគច្ឆសិ ។
យោ វេជយន្តបាសាទំ បាទង្គុដ្ឋេន កម្បយិ
ឥទ្ធិពលេនុបត្ថទ្ធោ សំវេជេសិ ច ទេវតា ។
យោ ឯតមភិជានាតិ ។ បេ ។ កណ្ហ ទុក្ខំ និគច្ឆសិ ។
យោ វេជយន្តបាសាទេ សក្កំ សោ បរិបុច្ឆតិ
អបិ អាវុសោ ជានាសិ តណ្ហក្ខយវិមុត្តិយោ
តស្ស សក្កោ វិយាកាសិ បញ្ហំ បុដ្ឋោ យថាតថំ
យោ ឯតមភិជានាតិ ។ បេ ។ កណ្ហ ទុក្ខំ និគច្ឆសិ ។
យោ ព្រហ្មានំ បរិបុច្ឆតិ[១] សុធម្មាយំ អភិតោសភំ[២]
អជ្ជាបិ តេ អាវុសោ សា ទិដ្ឋិ យា តេ ទិដ្ឋិ បុរេ អហុ
បស្សសិ វីតិវត្តន្តំ ព្រហ្មលោកេ បភស្សរំ
តស្ស ព្រហ្មា វិយាកាសិ[៣] បញ្ហំ បុដ្ឋោ យថាតថំ

---

១ ម. បុច្ឆតិ ។ ២ ម. ចិតោសភំ ។ ៣ ឱ. ម. វិយាកាសិ ។

មួយទៀត ភិក្ខុណា ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ដាស់តឿនហើយ កាលភិក្ខុសង្ឃកំពុងមើល (ភិក្ខុនោះ) បានធ្វើមិគារមាតុប្រាសាទឲ្យកក្រើកញាប់ញ័រ ដោយចុងមេជើង ។ ភិក្ខុណាដឹងជាក់លាក់នូវផលនៃកម្មនោះបាន ។ បេ ។ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។ ភិក្ខុណាធ្វើវេជយន្តប្រាសាទ ឲ្យកក្រើកញាប់ញ័រដោយចុងមេជើង ភិក្ខុនោះ ជាអ្នកអង់អាចដោយកម្លាំងឫទ្ធិ ធ្វើពួកទេវតាឲ្យសង្វេគហើយ ។ ភិក្ខុណាដឹងជាក់លាក់នូវផលនៃកម្មនុ៎ះបាន ។ បេ ។ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។ ភិក្ខុណា (គង់លើ) វេជយន្តប្រាសាទ ភិក្ខុនោះក៏សួរសក្កទេវរាជថា ម្នាលអាវុសោ អ្នកដឹងនូវការអស់ និងការផុតស្រឡះចាកតណ្ហាដែរឬទេ សក្កទេវរាជលុះព្រះថេរៈសួរប្រស្នាហើយ ក៏ឆ្លើយដោះស្រាយតាមសេចក្តីពិតដល់លោក ភិក្ខុណាដឹងជាក់លាក់នូវផលនៃកម្មនុ៎ះ ។ បេ ។ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។ ភិក្ខុណា ជាបុគ្គលញៀវក្លាសួរប្រស្នានឹងព្រហ្ម ក្នុងសភាឈ្មោះសុធម្មាថា ម្នាលអាវុសោ សេចក្តីយល់ណារបស់អ្នក ដែលមានហើយ ក្នុងកាលពីដើម សេចក្តីយល់របស់អ្នកនោះ នៅដូចថ្ងៃនេះឬ អ្នកឃើញពន្លឺរស្មី (នៃព្រះមានបុណ្យនិងសាវ័ក) គ្របសង្កត់ក្នុងព្រហ្មលោកដែរឬទេ ព្រហ្មលុះព្រះថេរសួរប្រស្នាហើយ ក៏ឆ្លើយដោះសារតាមសេចក្តីពិតដល់លោកថា

ន មេ មារិស សា ឥទ្ធិ យា មេ ឥទ្ធិ បុរេ អហុ ។
បស្សាមិ វីតិវត្តន្តំ ព្រហ្មលោកេ បភស្សរំ
សោហមជ្ជ កាចំ វជ្ជំ អហំ និច្ចាម្ហិ បស្សតោ ។
យោ ឯតមភិជានាតិ ។បេ។ កណ្ហ ទុក្ខំ និគច្ឆសិ ។
យោ មហានេរុនោ កូដំ វិមោក្ខេន អបស្សយិ
វនំ បុព្វវិទេហានំ យេ ច ភូមិសយា នរា
យោ ឯតមភិជានាតិ ។បេ។ កណ្ហ ទុក្ខំ និគច្ឆសិ ។
ន វេ អគ្គិ ចេតយតិ អហំ បាលំ ឌហាមីតិ
ពាលោ ច ជលិតមគ្គឹ អាសជ្ជ នំ បឌយ្ហតិ
ឯវមេវ តុវំ មារ អាសជ្ជ នំ តថាគតំ
សយំ ឌហិស្សមត្តានំ ពាលោ អគ្គឹវ សម្ផុសំ ។
អបុញ្ញំ បសវី[១] មាពេ អាសជ្ជ នំ តថាគតំ
កិន្នុ មញ្ញសិ បាបិម ន មេ បាបំ វិបច្ចតិ ។

---

១ ម. បស្សាមិ ។

បពិត្រលោកនិទ៌ុក្ខ សេចក្តីយល់ណារបស់ខ្ញុំ ដែលមានហើយក្នុងកាលពីដើម សេចក្តីយល់របស់ខ្ញុំនោះ មិនមានទេ ។ ខ្ញុំឃើញពន្លឺរស្មី (របស់ព្រះមានបុណ្យនិងសាវក) គ្របសង្កត់ក្នុងព្រហ្មលោក ខ្ញុំនោះនឹងលះបង់នូវពាក្យរបស់ខ្ញុំដែលយល់ឃើញថា អាត្មាអញជាបុគ្គលទៀងទាត់ (នោះ) ក្នុងថ្ងៃនេះហើយ ។ ភិក្ខុណា ដឹងជាក់លាក់នូវផលនៃកម្មនោះ ។ បេ ។ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។ ភិក្ខុណា បានឃើញកំពូលភ្នំមហាសិនេរុផង ឃើញជម្ពូទ្វីបផង ឃើញបុព្វវិទេហទ្វីបផង ឃើញពួកមនុស្សដេកលើផែនដី (នៅក្នុងអបរគោយានទ្វីប និងឧត្តរកុរុទ្វីប) ផង ដោយឈានវិមោក្ខ ភិក្ខុណា ដឹងជាក់លាក់នូវផលនៃកម្មនោះ ។ បេ ។ ម្នាលមារមានចិត្តខ្មៅ អ្នកនឹងដល់នូវសេចក្តីទុក្ខ ។ ធម្មតាភ្លើង មិនដែលគិតថា អញនឹងឆេះរលោកមនុស្សពាលទេ តែប្រសិនជាមនុស្សពាលពាល់ភ្លើង ដែលឆេះហើយ (ភ្លើង) ក៏ឆេះរលោកនូវបុគ្គលពាលនោះឯង ម្នាលមារ អ្នកបៀតបៀននូវព្រះតថាគតនោះ មុខជានឹងឆេះរលោកខ្លួនឯងវិញ ដូចមនុស្សពាលពាល់ភ្លើង យ៉ាងនោះដែរ ។ ម្នាលមារមានចិត្តបាបមារឯង បៀតបៀននូវព្រះតថាគតនោះ មុខជានឹងបានសោយបាប អ្នកសម្គាល់ថា បាបនឹងមិនឲ្យផលដល់អញ ឬអ្វី ។

ការតោ តេ មិយ្យតេ ចាបំ    ចិររត្តាយ អន្តក
មារ និព្ពិន្ទ ពុទ្ធម្ហា    អាសំ មាកាសិ ភិក្ខុសុ ។
ឥតិ មារំ អតជ្ជេសិ    ភិក្ខុ ភេសកឡាវនេ
តតោ សោ ទុម្មនោ យក្ខោ តត្ថេវន្តរធាយតីតិ ។

ឥត្ថំ សុទំ អាយស្មា មហាមោគ្គល្លានោ ថេរោ គាថាយោ អភាសិត្ថាតិ ។

## ឧទ្ទានំ ភវតិ

សដ្ឋិកម្ហិ និបាតម្ហិ    មោគ្គល្លានោ មហិទ្ធិកោ
ឯកោវ ថេរោ គាថាយោ    អដ្ឋសដ្ឋី ភវន្តិ តាតិ ។

សដ្ឋិកោ និបាតោ និដ្ឋិតោ[១] ។

---

១ ឱ. ម. និដ្ឋិតោតិ នត្ថិ ។

ម្នាលមារមានចិត្តលាមក បាបរបស់អ្នកកាលធ្វើ រមែងប្រព្រឹត្តទៅ (មិនជាប្រយោជន៍) អស់កាលដ៏យូរ ម្នាលមារ អ្នកចូរនឿយណាយ ចាកបុគ្គលអ្នកត្រាស់ដឹងនូវសច្ចៈទាំង ៤ ប្រការ អ្នកកុំធ្វើនូវសេចក្តី ប៉ុនប៉ុង ដើម្បីបៀតបៀនភិក្ខុឡើយ ។

ភិក្ខុ (មោគ្គល្លានត្ថេរ) បានគម្រាមមារ ក្នុងភេសកឡាវ័នដោយ ប្រការដូច្នេះហើយ មារជាយក្ខនោះ ក៏អាក់អន់ចិត្ត ហើយបាត់ទៅ ក្នុងទីនោះឯង ព្រោះហេតុតែសេចក្តីគម្រាម (នៃព្រះមោគ្គល្លាន) ។

ឮថា ព្រះមហាមោគ្គល្លានត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងឡាយ ដោយប្រការដូច្នេះឯង ។

## ឧទ្ទាន

ព្រះមោគ្គល្លានត្ថេរ មានឫទ្ធិច្រើន តែមួយអង្គឯង សម្តែងនូវគាថា ទាំងឡាយ ក្នុងសដ្ឋិកនិបាត គាថាទាំងនោះមានចំនួន ៦៨ គាថា ។

ចប់ សដ្ឋិកនិបាត ។

# ថេរគាថាយ មហានិបាតោ

[២៦៩] និក្ខន្តំ វត មំ សន្តំ  អគារស្មា អនគារិយំ
វិតក្កា ឧបធាវន្តិ  បគព្ភា កណ្ហតោ ឥមេ
ឧគ្គបុត្តា មហិស្សាសា  សិក្ខិតា ទឡ្ហធម្មិនោ
សមន្តា បរិកិរេយ្យុំ  សហស្សំ អបលាយិនំ ។
សចេបិ ឯត្តកា ភិយ្យោ  អាគមិស្សន្តិ ឥត្ថិយោ
នេវ មំ ព្យាធយិស្សន្តិ  ធម្មេស្វម្ហិ បតិដ្ឋិតោ ។
សក្ខី ហិ មេ សុតំ ឯតំ[១] ពុទ្ធស្សាទិច្ចពន្ធុនោ
និព្វានគមនំ មគ្គំ  តត្ថ មេ និរតោ មនោ ។
ឯវញ្ចេ មំ វិហរន្តំ  បាបិម ឧបគច្ឆសិ[២]
តថា មច្ចុ ករិស្សាមិ  ន មេ មគ្គំ ឧទិក្ខសិ ។
អរតឹ រតិញ្ច បហាយ
សព្វសោ គេហសិតញ្ច វិតក្កំ
វនថំ ន ករេយ្យ កុហិញ្ចិ
និព្វនថោ អវនថោ[៣] ស ហិ ភិក្ខុ ។

១ ឱ. ឯតំ ។ ម. មតំ ។ ២ ឱ. ម. ឧបគច្ឆសិ ។ ៣ ម. និព្វនកោ អវនកោ ។

# ថេរគាថា មហានិបាត

[២៦៥] *វិតក្កៈទាំងឡាយនេះ ជាសភាវៈឃ្នើសឃ្នង ព្រោះជារបស់លាមក តែងគ្របសង្កត់អាត្មាអញ ដែលចេញចាកផ្ទះ បួសក្នុងព្រះពុទ្ធសា-សនា(ដូច)ពួកខ្មាន់ធ្នូដ៏ប្រសើរ ជាកូនអ្នកខ្ពង់ខ្ពស់ សិក្សាស្ទាត់ហើយ មានធ្នូដ៏មាំ គប្បីបាញ់ប្រសាចនូវព្រួញ ទាំងពាន់ជុំវិញខ្លួន (សត្រូវ) មិនឲ្យរត់រួចបាន ។ បើពួកស្រីបុណ្ណោះ (ឬ) លើសជាងនេះ នឹងមក ក៏គង់បៀតបៀនអាត្មាអញមិនបាន (ព្រោះ) អាត្មាអញបាន តាំងមាំនៅក្នុងធម៌ទាំងឡាយហើយ ។ ព្រះពុទ្ធដីការបស់ព្រះពុទ្ធ ជាអាទិច្ចពន្ធុ អាត្មាអញបានស្តាប់ម្តងហើយ ចិត្តរបស់អាត្មាអញ ត្រេកអរ ក្នុងផ្លូវជាទីទៅកាន់ព្រះនិព្វាននោះហើយ ។ ម្នាលមារ លាមក បើអ្នកចូលមកបំបាក់យើង ដែលកំពុងចុះចិត្តស៊ប់ក្នុង វិបស្សនាយ៉ាងនេះ អ្នកមិនបានឃើញផ្លូវរបស់យើង យ៉ាងណា យើងនឹងធ្វើអ្នកឲ្យដល់នូវសេចក្តីស្លាប់ យ៉ាងនោះដែរ ។*

*បុគ្គលណា លះបង់នូវសេចក្តីអផ្សុក នូវសេចក្តីត្រេកអរ នូវសេចក្តីត្រិះរិះ ដែលអាស្រ័យនូវផ្ទះ ដោយប្រការទាំងពួង មិនធ្វើនូវសេចក្តីប្រាថ្នាក្នុងវត្ថុណាមួយ ជាអ្នកមិនមានសេចក្តីប្រាថ្នា ព្រោះមិនមានសេចក្តីប្រាថ្នា បុគ្គលនោះឈ្មោះថា ភិក្ខុ ។*

១៣១



យមិទំ បថវិញ្ច វេហាសំ
រូបគតំ ជគតោគធំ កិញ្ចិ
បរិជិយ្យតិ សព្វមនិច្ចំ
ឯវំ សមេច្ច ចរន្តិ មុតត្តា ។
ឧបធីសុ ជនា គធិតាសេ
ទិដ្ឋសុតេ បដិឃេ ច មុតេ ច
ឯត្ថ វិនោទយ ឆន្ទមនេជោ
យោ ហេត្ថ ន លិម្បតិ មុនិ តមាហុ ។
អថ សដ្ឋិសិតា សវិតក្កា
បុថុជ្ជនតាយ អធម្មនិវិដ្ឋា
ន ច វគ្គគតស្ស កុហិញ្ចិ
នោ បន ទុដ្ឋុល្លភាណី[១]ស ភិក្ខុ ។
ទព្វោ ចិររត្តំ សមាហិតោ
អកុហកោ និបកោ អបិហាលុ
សន្តំ បទមជ្ឈគមា មុនី
បដិច្ច បរិនិព្វុតោ កង្ខតិ កាលំ ។

១ ឱ. បទុល្លគាហី ។ ម. បទុល្លគាហិ ។

ក្នុងលោកនេះ វត្ថុណាមួយ នៅលើផែនដីក្តី លើអាកាសក្តី ដែលរាប់ចូលក្នុងភព ៣ មានសភាវៈវិនាសទៅ វត្ថុទាំងអស់នោះជារបស់មិនទៀង រមែងទ្រុឌទ្រោមទៅ អ្នកប្រាជ្ញទាំងឡាយ រមែងយល់ច្បាស់យ៉ាងនេះ ។ ពួកជនរមែងជាប់ចំពាក់ក្នុងឧបធិ គឺរូបនិងសំឡេង ដែលឃើញហើយ ឮហើយផង គឺក្លិន រសនិងផោដ្ឋព្វៈ ដែលទង្គិចហើយប៉ះពាល់ហើយផង អ្នកចូរជាបុគ្គលមិនមានសេចក្តីញាប់ញ័រ បន្ទោបង់នូវសេចក្តីប្រាថ្នា ក្នុងកាមទាំងនោះចេញ ព្រោះបុគ្គលណាមិនជាប់ក្នុងកាមគុណនុ៎ះ ពួកអ្នកប្រាជ្ញទើបហៅបុគ្គលនោះ ថាជាមុនី ។ បុគ្គលអន្ធពាលមានវិតក្កៈ អាស្រ័យនូវទិដ្ឋិ ៦៨ រមែងជាអ្នកតាំងនៅមាំហើយក្នុងអធម៌ ព្រោះតែខ្លួនជាបុថុជ្ជន បុគ្គលណាមិនលុះក្នុងពួកនៃមិច្ឆាទិដ្ឋិ ក្នុងវត្ថុណាមួយ ទាំងជាអ្នកមិននិយាយអាក្រក់ បុគ្គលនោះ ឈ្មោះថា ភិក្ខុ ។ អ្នកប្រាជ្ញមានចិត្តតម្កល់មាំ អស់កាលយូរហើយ ជាអ្នកមិនកុហក មានប្រាជ្ញាល្អិត មិនមានតណ្ហា ជាអ្នកបរិបូណ៌ដោយមោនេយ្យធម៌ រំលត់កិលេស ហើយបានសម្រេចនូវសន្តបទ ព្រោះអាស្រ័យ (ព្រះនិព្វាន) រង់ចាំតែបរិនិព្វានកាល ។

មានំ បជហស្សុ គោតម
មានបថញ្ច បជហស្សុ អសេសំ
មានបថស្មឹ សមុច្ឆិតោ
វិប្បដិសារី ហុត្វា ចិររត្តំ ។
មក្ខេន មក្ខិតា បជា
មានហតា និរយំ បតន្តិ
សោចន្តិ ជនា ចិររត្តំ
មានហតា និរយំ ឧបបន្នា ។
ន ហិ សោចតិ ភិក្ខុ កទាចិ
មគ្គជិនោ(១) សម្មាបដិបន្នោ
កិត្តិញ្ច សុខញ្ចានុភោតិ
ធម្មទសោតិ តមាហុ តថត្តំ ។
តស្មា អខិលោ ឥធ បធានវា
នីវរណានិ បហាយ វិសុទ្ធោ
មានញ្ច បហាយ អសេសំ
វិជ្ជាយន្តករោ សមិតាវី ។

១ ម. មគ្គជិតោ ។

ម្នាលអ្នកជាគោត្រនៃព្រះគោតម អ្នកចូរលះបង់នូវមានះផង ចូរលះបង់នូវផ្លូវនៃមានះ កុំឲ្យមានសេសសល់ផង (ព្រោះ) បុគ្គលជ្រប់នៅ ក្នុងផ្លូវនៃមានះហើយ រមែងមានសេចក្តីក្តៅក្រហាយ អស់កាលយូរ ។ ពួកសត្វដែលត្រូវសេចក្តីលុបគុណគ្របសង្កត់ ត្រូវមានះបៀតបៀនហើយ រមែងធ្លាក់ទៅក្នុងនរក ពួកជនដែលមានះបៀតបៀនហើយ រមែងទៅកើតក្នុងនរក សោកសៅ អស់កាលយូរ ។ ភិក្ខុអ្នកឈ្នះកិលេសដោយមគ្គ អ្នកប្រតិបត្តិដោយប្រពៃ រមែងមិនសោកសៅ ក្នុងកាលណាមួយឡើយ ភិក្ខុណា បាននូវកិត្តិយសផង បាននូវសេចក្តីសុខផង ពួកបណ្ឌិតតែងហៅភិក្ខុនោះ ថាជាអ្នកឃើញធម៌ ដោយពិត ។ ហេតុនោះ ភិក្ខុអ្នកមិនរឹងរូស មានព្យាយាមក្នុងសាសនានេះ លះបង់នូវនីវរណៈទាំងឡាយ ជាអ្នកបរិសុទ្ធ លះបង់នូវមានះ មិនឲ្យមានសេសសល់ រមែងជាអ្នកធ្វើនូវទីបំផុតនៃវិជ្ជា ជាអ្នកស្ងប់រម្ងាប់កិលេស ។

១៣៣

## ថេរគាថាយ មហានិបាតោ

កាមរាគេន ឌយ្ហាមិ    ចិត្តំ មេ បរិឌយ្ហតិ
សាធុ និព្វាបនំ ព្រូហិ    អនុកម្បាយ គោតម ។
សញ្ញាយ វិបរិយេសា    ចិត្តន្តេ បរិឌយ្ហតិ
និមិត្តំ បរិវជ្ជេហិ    សុភំ រាគូបសញ្ហិតំ ។
អសុភាយ ចិត្តំ ភាវេហិ    ឯកគ្គំ សុសមាហិតំ
សតិ កាយគតា ត្យត្ថុ    និព្វិទាពហុលោ ភវ ។
អនិមិត្តញ្ច ភាវេហិ    មានានុសយមុជ្ជហ
តតោ មានាភិសមយា    ឧបសន្តោ ចរិស្សសិ ។
តមេវ វាចំ ភាសេយ្យ    យាយត្តានំ ន តាបយេ
បរេ ច ន វិហឹសេយ្យ    សា វេ វាចា សុភាសិតា ។
បិយវាចមេវ ភាសេយ្យ    យា វាចា បដិនន្ទិតា
យំ អនាទាយ បាបានិ    បរេសំ ភាសតេ បិយំ ។
សច្ចំ វេ អមតា វាចា    ឯស ធម្មោ សនន្តនោ
សច្ចេ អត្ថេ ច ធម្មេ ច    អាហុ សន្តោ បតិដ្ឋិតា ។
យំ ពុទ្ធោ ភាសតី វាចំ    ខេមំ និព្វានបត្តិយា
ទុក្ខស្សន្តកិរិយាយ    សា វេ វាចានមុត្តមា ។

ខ្ញុំក្តៅក្រហាយ ចិត្តរបស់ខ្ញុំ អន្ទះអន្ទែង ព្រោះតែកាមរាគ បពិត្រព្រះអានន្ទ ជាគោតមគោត្រ សូមលោកមេត្តាសម្តែងនូវធម៌ជាគ្រឿងញុំាងកាមរាគនោះឲ្យរលត់ ដោយសេចក្តីអនុគ្រោះចុះ ។ ចិត្តរបស់លោកអន្ទះអន្ទែង ព្រោះតែវិបល្លាសនៃសញ្ញា លោកចូរលះបង់នូវសុភនិមិត្ត ដែលប្រកបដោយកាមរាគចោលចេញ ។ លោកចូរចម្រើនឯកគ្គតាចិត្ត ឲ្យតម្កល់មាំល្អ ក្នុងអសុភសញ្ញា ទាំងកាយគតាសតិ ក៏ចូរឲ្យមានដល់លោក លោកចូរមានសេចក្តីនឿយណាយឲ្យច្រើនចុះ ។ ចូរចម្រើនអនិមិត្ត គឺអនិច្ចានុបស្សនា ចូរផ្តាច់នូវមានានុស័យ តទៅលោកនឹងបានស្ងប់រម្ងាប់ ព្រោះលះបង់មានះ ។ បុគ្គល មិនគប្បីញុំាងខ្លួនឲ្យក្តៅក្រហាយ ដោយវាចាណា គប្បីពោលតែវាចានោះ បុគ្គលមិនគប្បីបៀតបៀន ពួកបុគ្គលដទៃ ដោយវាចាណា វាចានោះឯងជាសុភាសិត ។ វាចាណា ដែលគេទទួលត្រេកអរ បុគ្គលគប្បីពោលតែវាចាជាទីស្រឡាញ់នោះឯង បុគ្គលកុំកាន់យកពាក្យអាក្រក់ ពោលតែពាក្យដែលជាទីពេញចិត្តនៃពួកជនដទៃ ។ ពាក្យពិត ជាពាក្យមិនស្លាប់ នេះជាធម៌មានមកពីបុរាណពួកសប្បុរស តាំងមាំក្នុងសច្ចៈផង ក្នុងអត្ថៈផង ក្នុងធម្មៈផង ។ ព្រះពុទ្ធទ្រង់ពោលវាចាណា ជាវាចាក្សេម ដើម្បីដល់នូវព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ វាចានោះឯង ជាវាចាឧត្តម ជាងវាចាទាំងឡាយ ។

គម្ភីរបញ្ញោ មេធាវី មគ្គាមគ្គស្ស កោវិទោ
សារីបុត្តោ មហាបញ្ញោ ធម្មំ ទេសេតិ ភិក្ខុនំ ។
សង្ខិត្តេនបិ ទេសេតិ វិត្ថារេនបិ ភាសតិ
សាលិកាយេវ និគ្ឃោសោ បដិភាណំ ឧទិយ្យតិ ។
តស្ស តំ ទេសយន្តស្ស សុណន្តា មធុរំ គិរំ
សរេន រជនីយេន សវនីយេន វគ្គុនា
ឧទគ្គចិត្តា មុទិតា សោតំ ឱទេន្តិ ភិក្ខវោ ។
អជ្ជ បណ្ណរសេ វិសុទ្ធិយា ភិក្ខូ បញ្ចសតា សមាគតា
សំយោជនពន្ធនច្ឆិទា អនីឃា ខីណបុនព្ភវា ឥសី[១] ។
ចក្កវត្តី យថា រាជា អមច្ចបរិវារិតោ
សមន្តា អនុបរិយេតិ សាគរន្តំ មហឹ ឥមំ ។
ឯវំ វិជិតសង្គាមំ សត្ថវាហំ អនុត្តរំ
សាវកា បយិរុបាសន្តិ តេវិជ្ជា មច្ចុហាយិនោ ។
សព្វេ ភគវតោ បុត្តា បលាបោ[២] ឯត្ថ ន វិជ្ជតិ
តណ្ហាសល្លស្ស ហន្តារំ វន្ទេ អាទិច្ចពន្ធុនំ ។

---

១ ម. ឥតិ ។ ២ ម. បលាសោត្ថ ន វិជ្ជតិ ។

សារីបុត្រ ជាបុគ្គលមានប្រាជ្ញាជ្រាលជ្រៅ ជាអ្នកប្រាជ្ញ យល់ផ្លូវ និងមិនមែនផ្លូវ មានប្រាជ្ញាច្រើន រមែងសម្តែងធម៌ដល់ពួកភិក្ខុ ។ សារីបុត្រសម្តែងធម៌ដោយសង្ខេបក៏បាន សម្តែងដោយពិស្តារក៏បាន លោកមានសំឡេងគឹកកងពីរោះ ដូចសំឡេងសាលិកា ទាំងមានបដិភាណផុសផុល ។ កាលសារីបុត្រកំពុងសម្តែងធម៌នោះ ពួកភិក្ខុកំពុងស្តាប់សំឡេងដ៏ពីរោះ ក៏មានចិត្តអណ្តែតអណ្តូង ត្រេកអរ ផ្ចង់សោតប្បសាទទៅរកសំឡេង ដែលគួរត្រេកអរ គួរចង់ស្តាប់ គួរប្រាថ្នា ។

ពួកភិក្ខុ ៥០០ រូប ជាអ្នកផ្តាច់បង់នូវចំណង គឺសំយោជនៈ ជាអ្នកមិនមានទុក្ខ មានភពថ្មីអស់ហើយ ជាអ្នកស្វែងរកគុណ បានមកជួបជុំគ្នា ដើម្បីវិសុទ្ធិបវារណាក្នុងថ្ងៃ ១៥ នេះ ។ ព្រះរាជាចក្រពត្តិ មានអាមាត្យចោមរោម យាងប្រទក្សិណផែនដីដែលមានសាគរជាទីបំផុតនេះ ដោយជុំវិញ យ៉ាងណា ។ ពួកសាវ័កមានវិជ្ជា ៣ អ្នកបំផ្លាញនូវមច្ចុរាជ រមែងអង្គុយជិត (ព្រះសាស្តា) ព្រះអង្គជាបុគ្គលប្រសើរ លើសលុប ឈ្នះសង្គ្រាម គឺកិលេស អ្នកដឹកនាំ នូវពួកក្រុម ក៏យ៉ាងនេះដែរ ។ ពួកសាវ័កទាំងអស់ ជាបុត្រនៃព្រះមានព្រះភាគ សភាវៈសោះសូន្យ ក្នុងពួកនោះមិនមានឡើយ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះសាស្តា ជាផៅពង្សនៃព្រះអាទិត្យ ព្រះអង្គជាអ្នកបំផ្លាញនូវសរ គឺតណ្ហា ។

១៣៨

ថេរគាថាយ មហានិបាតោ

បរោសហស្សំ ភិក្ខូនំ សុគតំ បយិរុបាសតិ
ទេសេន្តំ វិរជំ ធម្មំ និព្វានំ អកុតោភយំ ។
សុណន្តិ ធម្មំ វិបុលំ សម្មាសម្ពុទ្ធទេសិតំ
សោភតិ វត សម្ពុទ្ធោ ភិក្ខុសង្ឃបុរក្ខតោ ។
នាគនាមោសិ ភគវា ឥសីនំ ឥសិសត្តមោ
មហាមេឃោវ ហិត្វាន សាវកេ អភិវស្សសិ ។
ទិវាវិហារា និក្ខម្ម សត្ថុទស្សនកម្យតា
សាវកោ តេ មហាវីរ បាទេ វន្ទតិ វង្គីសោ ។

ឧម្មគ្គបថំ មារស្ស
អភិភុយ្យ ចរតិ បភិជ្ជ ខិលានិ
តំ បស្សថ ពន្ធបមុញ្ចករំ
អសិតំវ ភាគសោ បវិភជ្ជ ។
ឱឃស្ស ហិ និត្ថរណត្ថំ
អនេកវិហិតំ មគ្គំ អក្ខាសិ
តស្មិញ្ច អមតេ អក្ខាតេ
ធម្មទសា ឋិតា អសំហិរា ។

ពួកភិក្ខុច្រើនជាងពាន់ អង្គុយជិតព្រះសុគត ដែលកំពុងសម្តែងធម៌ជាគ្រឿងប្រាសចាករាគៈគឺព្រះនិព្វាន ឥតមានភ័យអំពីទីណា ។ ពួកសាវ័កស្តាប់ធម៌ដ៏ធំទូលាយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងហើយ ឱហ្ន៎ព្រះសម្ពុទ្ធ មានភិក្ខុចោមរោមហើយ ល្អណាស់តើ ។ បពិត្រព្រះមានព្រះភាគ ព្រះអង្គមានព្រះនាមថានាគ ជាឥសីគម្រប់ ៧[១] នៃឥសីទាំងឡាយ ព្រះអង្គជាអ្នកបង្អុរនូវធម៌ស្រោចពួកសាវ័ក មានសភាពដូចជាមហាមេឃបង្អុរនូវភ្លៀង ។ បពិត្រព្រះអង្គមានព្យា-យាមធំ វង្គីសៈជាសាវ័ក ចេញចាកទីនៅក្នុងវេលាថ្ងៃ ព្រោះមានសេចក្តីប្រាថ្នាចង់គាល់ព្រះសាស្តា ថ្វាយបង្គំព្រះបាទា របស់ព្រះអង្គ ។

ព្រះមានព្រះភាគ ទ្រង់គ្របសង្កត់ផ្លូវខុសគឺកិលេសមារ បានប្រព្រឹត្តទម្លាយបង្គោលគឺកិលេស អ្នកទាំងឡាយចូរមើលព្រះពុទ្ធនោះ ព្រះអង្គធ្វើឲ្យរួចចាកចំណង មិនអាស្រ័យតណ្ហា ទ្រង់ចែករលែកធម៌ តាមចំណែក ។ ព្រោះថា ព្រះអង្គបានប្រាប់ផ្លូវច្រើនប្រការ ដើម្បីជាគ្រឿងរលាស់ឱឃៈចោល កាលទ្រង់សម្តែងប្រាប់អមតមហានិព្វាននោះហើយ ពួកជនក៏បានឃើញច្បាស់នូវធម៌ តម្កល់នៅនឹង មិនមានអ្នកណាដឹកនាំទៅបាន ។

១ រាប់តាំងពី ព្រះវិបស្សិសម្មាសម្ពុទ្ធឥសីមក ។

១៣៦



បជ្ជោតករោ អតិវិជ្ឈ
សព្វបិតីនំ អតិក្កមមទ្ធំ(១)
ញត្វា ច សច្ឆិកត្វា ច
អគ្គំ សោ ទេសយិ ទសទ្ធានំ ។
ឯវំ សុទេសិតេ ធម្មេ
កោ បមាទោ វិជានតំ ធម្មំ
តស្មា ហិតស្ស ភគវតោ សាសនេ
អប្បមត្តោ សទា នមស្សមនុសិក្ខេ ។

ពុទ្ធានុពុទ្ធោ យោ ថេរោ  កោណ្ឌញ្ញោ តិព្វនិក្កមោ
លាភី សុខវិហារានំ  វិវេកានំ អភិណ្ហសោ ។
យំ សាវកេន បត្តព្វំ  សត្ថុសាសនការិនា
សព្វស្ស តំ អនុប្បត្តំ  អប្បមត្តស្ស សិក្ខតោ ។
មហានុភាវោ តេវិជ្ជោ  ចេតោបរិយកោវិទោ
កោណ្ឌញ្ញោ ពុទ្ធទាយាទោ  បាទេ វន្ទតិ សត្ថុនោ ។
នគស្ស បស្សេ អាសីនំ  មុនឹ ទុក្ខស្ស បារគុំ
សាវកា បយិរុបាសន្តិ  តេវិជ្ជា មច្ចុហាយិនោ ។

១ ឱ. អតិក្កមមទ្ធា ។ ម។ អតិក្កមមទ្ធ ។

ព្រះពុទ្ធនោះអ្នកធ្វើនូវពន្លឺ ទ្រង់ធ្លុះរកវិញ្ញាណដ្ឋិតិរបស់សត្វទាំងអស់បានត្រាស់ដឹងផង ធ្វើឲ្យជាក់ច្បាស់ផង ទ្រង់យាងកន្លងផ្លូវឆ្ងាយបាន ហើយសម្តែងធម៌ដ៏ប្រសើរដល់ពួកបញ្ចវគ្គិយភិក្ខុ អ្នកមានសទ្ធាត្រាស់ដឹងធម៌មុនគេបង្អស់ ។ កាលបើធម៌ដែលព្រះតថាគត សម្តែងល្អយ៉ាងនេះហើយ សេចក្តីប្រមាទដូចម្តេចនឹងមានដល់ពួកជនដែលជាអ្នកដឹងច្បាស់នូវធម៌បាន ព្រោះហេតុនោះបុគ្គលមិនគប្បីជាអ្នកប្រមាទ ក្នុងសាសនា របស់ព្រះមានព្រះភាគនោះឡើយ គប្បីនមស្ការសិក្សាតាម សព្វ ៗ កាល ។ អញ្ញាកោណ្ឌញ្ញត្ថេរ ជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធ មានសេចក្តីព្យាយាមមាំមួន ជាអ្នកបាននូវវិវេក ជាគ្រឿងនៅជាសុខរឿយ ៗ ។ កិច្ចណាដែលសាវ័ក អ្នកធ្វើតាមសាសនានៃព្រះសាស្តា គប្បីសម្រេច កិច្ចនោះ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ អ្នកមិនប្រហែសធ្វេសសិក្សា បានសម្រេចទាំងអស់ហើយ ។ អញ្ញាកោណ្ឌញ្ញត្ថេរ មានអានុភាពច្រើន បានសម្រេចវិជ្ជា ៣ ស្ទាត់ក្នុងចេតោបរិយញ្ញាណជាពុទ្ធទាយាទ ថ្វាយបង្គំព្រះបាទានៃព្រះសាស្តា ។

ពួកសាវ័ក បានសម្រេចវិជ្ជា ៣ ជាអ្នកសាបសូន្យចាកមច្ចុរាជនាំគ្នាអង្គុយជិតព្រះមុនី ព្រះអង្គជាអ្នកដល់ នូវត្រើយនៃទុក្ខទ្រង់គង់នៅ (ដោយចេតោបរិយញ្ញាណ) ខាងភ្នំឥសិគិលិ ។

១៣៧

ថេរគាថាយ មហានិបាតោ

ចេតសា អនុបរិយេតិ មោគ្គល្លានោ មហិទ្ធិកោ
ចិត្តំ នេសំ សមន្វេសំ វិប្បមុត្តំ និរូបធឹ ។
ឯវំ សព្វង្គសម្បន្នំ មុនឹ ទុក្ខស្ស បារគុំ
អនេកាការសម្បន្នំ បយិរុបាសន្តិ គោតម ។

ចន្ទោ យថា វិគតវលាហកេ នភេ
វិរោចតិ វីតមលោវ ភាណុមា
ឯវំបិ អង្គីរស ត្វំ មហាមុនិ
អតិរោចសិ យសសា សព្វលោកំ ។

កាវេយ្យមត្តា វិចរិម្ហា បុព្វេ គាមា គាមំ បុរា បុរំ
អថទ្ទសាម សម្ពុទ្ធំ សព្វធម្មាន បារគុំ ។
សោ មេ ធម្មមទេសេសិ មុនិ ទុក្ខស្ស បារគូ
ធម្មំ សុត្វា បសីទិម្ហ សទ្ធា[១] នោ ឧទបជ្ជថ ។
តស្សាហំ វចនំ សុត្វា ខន្ធេ អាយតនានិ ច
ធាតុយោ ច វិទិត្វាន បព្វជឹ អនគារិយំ ។

---
១ ម. អទ្ធានោ ។

ព្រះមោគ្គល្លានត្ថេរ មានឫទ្ធិច្រើន យកចិត្តទុកដាក់ស្ទះស្វែងរកចិត្តដែលផុតចាកកិលេស ជាចិត្តមិនមានឧបធិ របស់ព្រះខីណាសវភិក្ខុទាំងឡាយនុ៎ះ ។ បពិត្រព្រះគោតម ពួកសាវ័ក តែងអង្គុយជិតព្រះអង្គ ជាព្រះមុនី បរិបូណ៌ដោយអវយវៈគ្រប់យ៉ាង ព្រះអង្គដល់នូវត្រើយនៃទុក្ខ ព្រះអង្គបរិបូណ៌ដោយអាការៈច្រើនប្រការ យ៉ាងនេះ ។

ព្រះចន្ទ្រ រុងរឿង ឰដ៏នភាល័យ ដែលប្រាសចាកពពក
ព្រះអាទិត្យ ប្រាសចាកមន្ទិល យ៉ាងណាមិញ បពិត្រ
ព្រះមហាមុនី ព្រះនាមអង្គីរសៈ ព្រះអង្គរុងរឿង ផ្សាយទៅ
កាន់លោកទាំងមូល ដោយយសបរិវារ ក៏យ៉ាងនោះដែរ ។

កាលពីដើម យើងខ្ញុំពួកកវីរាប់អាន បានដើរចេញពីស្រុកមួយទៅស្រុកមួយ ពីបុរីមួយ ទៅបុរីមួយ វេលានោះ យើងខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គបានដល់ នូវត្រើយនៃធម៌ទាំងពួង ។ ព្រះមុនីនោះ ព្រះអង្គជាអ្នកដល់នូវត្រើយនៃទុក្ខ បានសម្តែងធម៌ដល់ខ្ញុំ យើងខ្ញុំ លុះបានស្តាប់ធម៌ហើយ ក៏មានចិត្តជ្រះថ្លា មានសទ្ធាកើតឡើង ។ ខ្ញុំបានស្តាប់ ព្រះពុទ្ធដីកា នៃព្រះមុនីនោះហើយក៏បានដឹងច្បាស់ នូវខន្ធ អាយតនៈ និងធាតុទាំងឡាយហើយចេញចាកផ្ទះ បួសក្នុងសំណាក់ នៃបុគ្គលមិនមានផ្ទះ ។

១៣៨



ពហូនំ វត អត្ថាយ ឧប្បជ្ជន្តិ តថាគតា
ឥត្ថីនំ បុរិសានញ្ច យេ តេ សាសនការកា ។
តេសំ ខោ វត អត្ថាយ ពោធិមជ្ឈគមា មុនិ
ភិក្ខូនំ ភិក្ខុនីនញ្ច យេ និយាមគតំទសា ។
សុទេសិតា ចក្ខុមតា ពុទ្ធេនាទិច្ចពន្ធុនា
ចត្តារិ អរិយសច្ចានិ អនុកម្បាយ បាណិនំ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។
ឯវមេតេ តថា វុត្តា ទិដ្ឋា មេ តេ យថា តថា
សទត្ថោ មេ អនុប្បត្តោ កតំ ពុទ្ធស្ស សាសនំ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
សុវិភត្តេសុ ធម្មេសុ យំ សេដ្ឋំ តទុបាគមឹ ។
អភិញ្ញាបារមិប្បត្តោ សោតធាតុវិសោធិតោ
តេវិជ្ជោ ឥទ្ធិបត្តោម្ហិ ចេតោបរិយកោវិទោ ។

ឱហ្ន៎ ព្រះតថាគតទាំងឡាយកើតឡើង ដើម្បីប្រយោជន៍ដល់ស្រីនិង ប្រុសដ៏ច្រើន ដែលជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ។ ពួកភិក្ខុ និងពួកភិក្ខុនីណា បានឃើញ នូវកំណត់ ដែលគេកត់ទុកហើយ ព្រះមុនី បានត្រាស់ដឹងពោធិញ្ញាណ ដើម្បីប្រយោជន៍ ដល់ពួក ភិក្ខុនិងពួកភិក្ខុនីទាំងនោះឯង ។ អរិយសច្ចទាំង ៤ ប្រការ គឺទុក្ខ ១ ការកើតនៃទុក្ខ ១ ការកន្លងផុតនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ ជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ ១ ព្រះពុទ្ធ ជាវង្សនៃព្រះអាទិត្យ មានចក្ខុគឺប្រាជ្ញា ទ្រង់បានសម្តែងទុកល្អ ហើយ ដើម្បីអនុគ្រោះដល់សត្វទាំងឡាយ ។ ធម៌គឺអរិយសច្ច ទាំងឡាយនេះ ជាធម៌ពិត ព្រះពុទ្ធទ្រង់សម្តែងហើយ យ៉ាងនេះ អរិយសច្ចទាំងនោះ ខ្ញុំបានឃើញតាមពិត ប្រយោជន៍ខ្លួន ខ្ញុំបាន សម្រេចហើយ ទាំងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើ ហើយ ។ ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ កិច្ចណាដ៏ ប្រសើរក្នុងធម៌ទាំងឡាយ ដែលព្រះពុទ្ធទ្រង់សម្តែងវែកញែកហើយ ដោយប្រពៃ ខ្ញុំក៏បានសម្រេចកិច្ចនោះហើយ ។ ខ្ញុំបានសម្រេច អភិញ្ញាបារមី បានជម្រះនូវសោតធាតុ បាននូវវិជ្ជា ៣ បាន សម្រេចឫទ្ធិ ជាអ្នកឈ្លាសវៃ ក្នុងចេតោបរិយញ្ញាណ ។

១៣៩



បុច្ឆាមិ សត្ថារមនោមបញ្ញំ
ទិដ្ឋេវ ធម្មេ យោ វិចិកិច្ឆានំ ឆេត្តា
អគ្គាឡវេ កាលមកាសិ ភិក្ខុ
ញាតោ យសស្សី អភិនិព្វុតត្តោ ។
និគ្រោធកប្បោ ឥតិ តស្ស នាមំ
តយា កតំ ភគវា ព្រាហ្មណស្ស
សោ តំ នមស្សំ អចរិ មុត្យបេក្ខោ
អារទ្ធវិរិយោ ទឡ្ហធម្មទស្សី ។
តំ សាវកំ សក្ក មយម្បិ សព្វេ
អញ្ញាតុមិច្ឆាម សមន្តចក្ខុ
សមវុដ្ឋិតា[១] នោ សវនាយ សោតំ
តុវំ នុ សត្ថា ត្វមនុត្តរោសិ ។
ឆិន្ទេវ នោ វិចិកិច្ឆំ ព្រូហិ មេតំ
បរិនិព្វុតំ វេទយ ភុរិបញ្ញ
មជ្ឈេវ នោ ភាស សមន្តចក្ខុ
សក្កោវ ទេវាន សហស្សនេត្តោ ។

១ ឱ. ម. សមវដ្ឋិតា ។

ខ្ញុំព្រះអង្គសូមទូលសួរព្រះសាស្ដា ជាបុគ្គលមានប្រាជ្ញាមិនថោកថយ ភិក្ខុណា បានផ្ដាច់បង់វិចិកិច្ឆាក្នុងអត្តភាពនេះ មានកេរ្ដិ៍ឈ្មោះល្បីល្បាញ សម្បូរដោយយស មានចិត្តរំលត់ក្ដៅក្រហាយ បានធ្វើមរណកាល ក្នុងអគាឡវចេតិយ ។ បពិត្រព្រះមានព្រះភាគ នាមនៃភិក្ខុ ជាព្រាហ្មណ៍នោះ ព្រះអង្គឲ្យឈ្មោះថា និគ្រោធកប្បៈ លោកនោះមានព្យាយាមតឹងតែង ជាអ្នកយល់ឃើញធម៌មុតមាំ ប្រាថ្នានូវព្រះនិព្វាន បានប្រព្រឹត្តនមស្ការព្រះអង្គ ។ បពិត្រព្រះអង្គ ជាសក្កៈមានចក្ខុជុំវិញ យើងខ្ញុំទាំងអស់គ្នា ប្រាថ្នាចង់ដឹងសាវ័កនោះ យើងខ្ញុំប្រុងសោតៈដើម្បីស្ដាប់ ព្រះអង្គជាសាស្ដារបស់យើងខ្ញុំ ព្រះអង្គជាបុគ្គលប្រសើរបំផុត ។ សូមព្រះអង្គទ្រង់កាត់សេចក្ដីសង្ស័យរបស់យើងខ្ញុំ សូមព្រះអង្គប្រាប់នូវសាវ័កនោះ បពិតព្រះអង្គមានបញ្ញាដូចផែនដី មានចក្ខុជុំវិញ ព្រះអង្គទ្រង់ជ្រាបនូវព្រាហ្មណ៍ដែលបរិនិព្វានហើយ សូមសម្ដែងក្នុងកណ្ដាលនៃពួកយើងខ្ញុំ ដូចជាសក្កទេវរាជ មានព្រះនេត្រមួយពាន់ (សម្ដែងក្នុងកណ្ដាល) នៃទេវតាទាំងឡាយ ។

យេ កេចិ គន្ថា ឥធ មោហមគ្គា
អញ្ញាណបក្ខា វិចិកិច្ឆដ្ឋានា
តថាគតំ បត្វា ន តេ ភវន្តិ
ចក្ខុំ ហិ ឯតំ បរមំ នរានំ ។
នោ ចេ ហិ ជាតុ បុរិសោ កិលេសេ
វាតោ យថា អព្ភឃនំ វិហានេ
តមោវស្ស និព្វុតោ សព្វលោកោ
ជោតិមន្តោបិ ន បភាសេយ្យុំ ។
ធីរា ច បជ្ជោតករា ភវន្តិ
តន្តំ អហំ ធីរ តថេវ មញ្ញេ
វិបស្សិនំ ជានមុបាគមិម្ហ
បរិសាយ នោ អាវិករោហិ កប្បំ ។
ខិប្បំ គិរំ ឯរយ វគ្គុ វគ្គុំ
ហំសោវ បគ្គយ្ហ សណិកំ និកូជំ
ពិន្ទុស្សរេន សុវិកប្បិតេន
សព្វេវ តេ ឧជ្ជុគតា សុណោម ។

គន្ថៈទាំងឡាយ (មានអភិជ្ឈាគន្ថៈជាដើម) ណាមួយ ជាផ្លូវនាំឲ្យវង្វេង ជាបក្ខពួកនៃការមិនដឹង ជាទីតាំងនៃសេចក្តីសង្ស័យ ក្នុងលោកនេះ គន្ថៈទាំងនោះ មកប៉ះនឹងព្រះតថាគតហើយ រមែងមិនកើតឡើយ ព្រោះបញ្ញាចក្ខុរបស់ព្រះអង្គនុ៎ះឧត្តមជាងជនទាំងឡាយ ។ ប្រសិនបើបុរស (ព្រះមានព្រះភាគ) មិនកម្ចាត់បង់នូវកិលេសទាំងឡាយ ដូចជាខ្យល់កម្ចាត់នូវដុំនៃពពកទេ លោកទាំងមូលដែលអវិជ្ជារួបរឹតហើយ សមនឹងងងឹតដោយពិត សូម្បីអ្នកមានពន្លឺគឺបញ្ញាក៏មិនអាចបំភ្លឺបាន ។ អ្នកប្រាជ្ញទាំងឡាយ ជាអ្នកធ្វើពន្លឺ ខ្ញុំព្រះអង្គសម្គាល់ព្រះអង្គនោះថាជាអ្នកប្រាជ្ញយ៉ាងនោះដែរ យើងខ្ញុំដឹង (នូវធម៌ទាំងអស់) របស់ជនអ្នកចេះដឹងទាំងឡាយ ទើបបានចូលមកជិតសូមព្រះអង្គសម្តែងប្រាប់នូវនិគ្រោធកប្បត្ថេរ (ជាឧបជ្ឈាយ៍) ឲ្យច្បាស់លាស់ ដល់យើងខ្ញុំ ក្នុងកណ្តាលបរិស័ទ ។ បពិត្រព្រះអង្គមានព្រះសូរសៀងដ៏ពីរោះ សូមព្រះអង្គបញ្ចេញឆាប់ ៗ នូវព្រះពុទ្ធដីកាដ៏ពីរោះ ដោយព្រះសូរសៀងមូល ដែលបច្ច័យតាក់តែងល្អហើយ ដូចហង្សដេកកហើយស្រែកតិច ៗ ពួកយើងខ្ញុំទាំងអស់គ្នានោះ មានចិត្តត្រង់ ប្រុងចាំស្តាប់ ។

១៤១



បហីនជាតិមរណំ អសេសំ
និគ្គយ្ហ ធោនំ វទេស្សាមិ[១] ធម្មំ
ន កាមការោ ហិ បុថុជ្ជនានំ
សង្ខេយ្យការោវ តថាគតានំ ។
សម្បន្នវេយ្យាករណំ តវេទំ
សមុជ្ជុបញ្ញស្ស សមុគ្គហីតំ
អយមញ្ជលិ បច្ឆិមោ សុបណាមិតោ
មា មោហយិ ជានមនោមបញ្ញ ។
បរោវរំ អរិយធម្មំ វិទិត្វា
មា មោហយិ ជានមនោមវីរិយ
វារឹ យថា ឃម្មនិឃម្មតត្តោ
វាចាភិកង្ខាមិ សុតំ បវស្ស ។
យទត្ថិកំ[២] ព្រហ្មចរិយំ អចរិ
កប្បាយនោ កច្ចិស្ស តំ អមោឃំ
និព្វាយិ សោ អាទុ សឧបាទិសេសោ
យថា វិមុត្តោ អហុ តំ សុណោម ។

---

១ ម. បដិវេទិយាមិ ។ ២ ឱ. យទត្ថិយំ ។

តថាគតបានផ្ចញ់ផ្ចាល់នូវជាតិ និងមរណៈឲ្យសាបសូន្យមិនឲ្យមានសេសសល់ នឹងសម្ដែងនូវធម៌ ជាគ្រឿងកម្ចាត់បង់នូវបាប មែនពិត បុថុជ្ជនទាំងឡាយ មិនមានការធ្វើបានតាមប្រាថ្នាទេ ព្រះតថាគតទាំងឡាយមានការធ្វើបានតាមបញ្ញា ។

វេយ្យាករណ៍ ដ៏បរិបូណ៌នេះ ព្រះអង្គជាបុគ្គលមានប្រាជ្ញាត្រង់ល្អ ផ្ទួរផ្ទងហើយដោយប្រពៃ ការធ្វើអញ្ជលីជាទីបំផុតនេះ ខ្ញុំព្រះអង្គបានប្រណម្យហើយ ដោយល្អ បពិត្រព្រះអង្គ ជាបុគ្គលមានប្រាជ្ញាធំទូលាយ កាលបើព្រះអង្គជ្រាប សូមកុំធ្វើឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ។ បពិត្រព្រះអង្គជាបុគ្គលមានព្យាយាមមាំ ព្រះអង្គជ្រាបច្បាស់នូវអរិយធម៌ គឺសច្ចៈទាំង ៤ ដ៏ល្អ (ដោយអំណាចលោកិយធម៌) កាលបើទ្រង់ជ្រាបច្បាស់ហើយ សូមកុំធ្វើឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ខ្ញុំព្រះអង្គប្រាថ្នាចង់ស្ដាប់ព្រះពុទ្ធដីកា ដូចជាបុរសមានខ្លួនក្ដៅអន្ទះអន្ទែងក្នុងកាលក្ដៅ ប្រាថ្នាចង់បានទឹក សូមព្រះអង្គបង្អុរនូវសុតៈគឺធម្មទេសនា ។ និគ្រោធកប្បត្ថេរ បានប្រព្រឹត្តនូវព្រហ្មចារ្យប្រកបដោយប្រយោជន៍ណា ការប្រព្រឹត្តព្រហ្មចារ្យរបស់លោកនោះមិនសាបសូន្យទេឬ និគ្រោធកប្បត្ថេរនោះនិព្វានហើយ ដូចអសេក្ខវិមុត្តិ ឬសឧបាទិសេសៈទេ យើងខ្ញុំចង់ស្ដាប់រឿងនោះ ។

អច្ឆេច្ឆិ តណ្ហំ ឥធ នាមរូបេ (តិ ភគវា)
តណ្ហាយ សោតំ ទីឃរត្តានុសយិតំ
អតារិ ជាតិមរណំ អសេសំ
ឥច្ចាព្រវី ភគវា បញ្ចសេដ្ឋោ ។

ឯស សុត្វា បសីទាមិ វចោ តេ ឥសិសត្តម
អមោឃំ កិរ មេ បុដ្ឋំ ន មំ វញ្ចេសិ ព្រាហ្មណោ ។
យថាវាទី តថាការី អហុ ពុទ្ធស្ស សាវកោ
បច្ឆិន្ទ[១] មច្ចុនោ ជាលំ តតំ មាយាវិនោ ទឡ្ហំ ។
អទ្ទស ភគវា អាទឹ ឧចាទានស្ស កប្បិយោ
អច្ចគា វត កប្បាយនោ មច្ចុធេយ្យំ សុទុត្តរំ ។
តំ ទេវទេវំ វន្ទាមិ បុត្តន្តេ ទ្វិបទុត្តម
អនុជាតំ មហាវីរំ នាគំ នាគស្ស ឱរសន្តិ ។

ឥត្ថំ សុទំ អាយស្មា វង្គីសោ ថេរោ គាថាយោ អភាសិត្ថាតិ ។

មហានិបាតោ និដ្ឋិតោ ។

១ ឱ. អច្ឆេច្ឆិ ។ ម. អច្ឆិជ្ជិ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) និគ្រោធកប្បភិក្ខុ បានផ្តាច់បង់នូវសេចក្តីប្រាថ្នាក្នុងនាមរូបនេះអស់ហើយ បានផ្តាច់បង់នូវខ្សែនៃសេចក្តីប្រាថ្នា ជាទីដេកនៅរឿយ ៗ ក្នុងសន្តានអស់រាត្រីកាលដ៏វែង ទាំងបានឆ្លងចាកជាតិនិងមរណៈ ឥតមានសេសសល់ ព្រះមានព្រះភាគ ប្រសើរដោយឥន្ទ្រិយ ៥ (មានសទ្ធិន្ទ្រិយជាដើម) បានត្រាស់ហើយយ៉ាងនេះ ។

បពិត្រព្រះអង្គជាឥសីគម្រប់ ៧ ខ្ញុំព្រះអង្គនេះបានឮព្រះពុទ្ធដីការបស់ព្រះអង្គហើយក៏ជ្រះថ្លា ឯកិច្ចការដែលខ្ញុំព្រះអង្គសួរហើយ មិនសោះសូន្យទេ ព្រះខីណាសវព្រាហ្មណ៍ មិនបញ្ឆោតខ្ញុំព្រះអង្គ ។ សាវ័ករបស់ព្រះពុទ្ធពោលយ៉ាងណា ធ្វើយ៉ាងនោះ បានផ្តាច់នូវសំណាញ់ដ៏មាំដែលមច្ចុអ្នកមានមាយាផ្សាយទៅហើយ ។ ព្រះមានព្រះភាគទ្រង់គួរបានទតឃើញច្បាស់ នូវខាងដើមនៃឧបាទាន កប្បត្ថេរបានកន្លងនូវលំនៅនៃមច្ចុរាជ ដែលគេឆ្លងបានដោយកម្រ ។ បពិត្រព្រះអង្គឧត្តមជាងសត្វជើងពីរ ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំនិគ្រោធកប្បត្ថេរនោះ ជាបុត្ររបស់ព្រះអង្គ ដែលទុកដូចជាទេវតាឧត្តមជាងទេវតា ជាអនុជាតបុត្តមានព្យាយាមធំ ជាបុគ្គលមិនធ្វើបាប ជាឱរសនៃព្រះពុទ្ធនាគ ។ ឮថា វង្គីសត្ថេរ មានអាយុ បានសម្តែងគាថាទាំងឡាយ ដោយប្រការដូច្នោះ ។

ចប់ មហានិបាត ។

---

១៤៣

ថេរគាថាយ មហានិបាតោ

សត្តតិម្ហិ និបាតម្ហិ　　　វង្គីសោ បដិភាណវា
ឯកោវ ថេរោ នត្ថញ្ញោ　　គាថាយោ ឯកសត្តតិ ។
សហស្សំ ហោន្តិ តា គាថា តីណិ សដ្ឋិសតានិ ច
ថេរា ច ទ្វេ សតា សដ្ឋិ　　ចត្តារោ ច បកាសិតា
សីហនាទំ នទិត្វាន　　　ពុទ្ធបុត្តា អនាសវា
ខេមន្តំ បាបុណិត្វាន　　　អគ្គិក្ខន្ធាវ និព្វុតាតិ ។

ថេរគាថា និដ្ឋិតា ។

ថេរគាថា មហានិបាត

ក្នុងសត្តតិនិបាត ព្រះវង្គីសត្ថេរ អ្នកមានបដិភាណ តែ ១ អង្គឯង ឥតមានព្រះថេរៈឯទៀតឡើយ (បានសម្តែង) នូវគាថាទាំងឡាយ ៧១ ។ គាថាទាំងនោះ មាន ១.៣៦០ ព្រះថេរៈទាំងអស់ ២៦៤ អង្គ ជាបុត្ររបស់ព្រះពុទ្ធ មិនមានអាសវៈ បានបន្លឺសីហនាទសម្តែងហើយ បានដល់នូវទីបំផុតដ៏ក្សេមក្សាន្ត និព្វានហើយ ដូចជាគំនរភ្លើងរលត់ហើយ ។

ចប់ ថេរគាថា ។

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស ថេរីគាថា

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ថេរីគាថាយ ឯកនិបាតោ

[២៦៦] សុខំ សុចាហិ ថេរីកេ កត្វា ចោឡេន ចារុតា

ឧបសន្តោ ហិ តេ រាគោ សុក្ខឌាកំវ កុម្ភិយំ ។

ឥត្ថំ សុទំ អញ្ញតរា ថេរី អបញ្ញាតា ភិក្ខុនី គាថំ អភាសិត្ថាតិ ។

[២៦៧] មុត្តេ មុញ្ចស្សុ[១] យោគេហិ ចន្ទោ រាហុគ្គហោ ឥវ

វិប្បមុត្តេន ចិត្តេន អនណា ភុញ្ជាហិ បិណ្ឌកំ ។

ឥត្ថំ សុទំ ភគវា មុត្តំ សិក្ខមានំ ឥមាយ គាថាយ អភិណ្ហំ ឱវទតិ ។

---

១ ឱ. ម. មុច្ចស្សុ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ថេរីគាថា

---

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## ថេរីគាថា ឯកនិបាត

[២៦៦] *ម្នាលថេរី នាងចូរដេកលក់ស្រួល នាងចូរធ្វើ (ចីវរបី) ដោយ*

*សំពត់ (បង្សុកូល) ហើយស្លៀកដណ្ដប់ចុះ ព្រោះរាគៈរបស់នាង*

*ស្ងប់រម្ងាប់ហើយ ដូចជាបន្លែស្ងួតក្នុងឆ្នាំង ។*

*ឮថា ភិក្ខុនីមួយរូបជាថេរី មិនប្រាកដ (ដោយនាមនិងគោត្រជាដើម)*

*បានពោលគាថា មានបការៈដូច្នេះ ។*

[២៦៧] *ម្នាលនាងមុត្តា នាងចូររួចចាកយោគៈទាំងឡាយ ដូចជាព្រះចន្ទ្រ*

*ដែលរាហូចាប់ (ហើយរួចអំពីដៃ) នាងមានចិត្តរួចស្រឡះ មិនមាន*

*បំណុលទេ ចូរបរិភោគដុំបាយចុះ ។*

*ឮថា ព្រះមានព្រះភាគ ទ្រង់ទូន្មានរឿយ ៗ នូវសិក្ខមានា ឈ្មោះមុត្តា*

*ដោយគាថា មានបការៈដូច្នេះ ។*

## ថេរីគាថាយ ឯកនិបាតោ

[២៦៨] បុណ្ណេ បូរស្សុ ធម្មេហិ   ចន្ទោ បណ្ណរសេរិវ
បរិបុណ្ណាយ បញ្ញាយ   តមោក្ខន្ធំ បទាលយ ។

បុណ្ណា ។

[២៦៩] តិស្សេ សិក្ខស្សុ សិក្ខាយ   មា តំ យោគា ឧបច្ចគុំ
សព្វយោគវិសំយុត្តា   ចរ លោកេ អនាសវា ។

តិស្សា ។

[២៧០] តិស្សេ យុញ្ជស្សុ ធម្មេហិ   ខណោ តំ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ   និរយម្ហិ សមប្បិតា ។

អញ្ញតរា តិស្សា ។

[២៧១] ធីរេ និរោធំ ផុសេហិ   សញ្ញាវូបសមំ សុខំ
អារាធយេហិ និព្វានំ   យោគក្ខេមំ អនុត្តរំ ។

ធីរា ។

[២៧២] ធីរា ធីរេហិ ធម្មេហិ   ភិក្ខុនី ភាវិតិន្ទ្រិយា
ធារេហិ អន្តិមំ ទេហំ   ជេត្វា មារំ សវាហនំ ។

អញ្ញតរា ធីរា ។

[២៦៨] ម្នាលនាងបុណ្ណា នាងចូរពេញដោយពោធិបក្ខិយធម៌ទាំងឡាយ ដូចជាព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត នាងចូរទម្លាយនូវគំនរងងឹត គឺមោហៈ ដោយបញ្ញាដ៏បរិបូណ៌ ។

បុណ្ណាថេរី ។

[២៦៩] ម្នាលនាងតិស្សា ចូរនាងសិក្សាតាមសិក្ខា កុំឲ្យយោគៈទាំងឡាយគ្របសង្កត់នាងបាន នាងចូរជាស្រីប្រាសចាកយោគៈទាំងអស់ មិនមានអាសវៈ ប្រព្រឹត្តនៅក្នុងលោក ។

តិស្សាថេរី ។

[២៧០] ម្នាលនាងតិស្សា ចូរនាងប្រកបដោយធម៌ទាំងឡាយ ខណៈកុំកន្លងនាងឡើយ ព្រោះពួកជនដែលខណៈកន្លងហើយ រមែងសោកស្តាយពេញប្រៀប ក្នុងនរក ។

តិស្សាថេរីមួយរូប ។

[២៧១]ម្នាលនាងធីរា នាងចូរពាល់ត្រូវនូវនិរោធជាសុខ ជាទីរម្ងាប់នូវសញ្ញា នាងចូរត្រេកអរនឹងព្រះនិព្វាន ដ៏ក្សេមចាកយោគៈ ប្រសើរបំផុត ។

ធីរាថេរី ។

[២៧២] ធីរាភិក្ខុនី មានឥន្ទ្រិយអប់រំហើយ ដោយធម៌ទាំងឡាយ ជាប្រធាននៃព្យាយាម នាងចូរផ្ចាញ់នូវមារ ព្រមទាំងវាហនៈ ហើយទ្រទ្រង់នូវរាងកាយជាទីបំផុត ។

ធីរាថេរីមួយរូប ។

[២៧៣] សទ្ធាយ បព្វជិត្វាន មិត្តេ មិត្តរតា ភវ
ភាវេហិ កុសលេ ធម្មេ យោគក្ខេមស្ស បត្តិយា ។

មិត្តា ។

[២៧៤] សទ្ធាយ បព្វជិត្វាន ភទ្រេ ភទ្ររតា ភវ
ភាវេហិ កុសលេ ធម្មេ យោគក្ខេមំ អនុត្តរំ ។

ភទ្រា ។

[២៧៥] ឧបសមេ តរេ ឱឃំ មច្ចុធេយ្យំ សុទុត្តរំ
ធារេហិ អន្តិមំ ទេហំ ជេត្វា មារំ សវាហនំ ។

ឧបសមា ។

[២៧៦] សុមុត្តា សាធុ មុត្តម្ហិ តីហិ ខុជ្ជេហិ មុត្តិយា
ឧទុក្ខលេន មុសលេន បតិនា ខុជ្ជកេន ច
មុត្តម្ហិ ជាតិមរណា ភវនេត្តិ សមូហតា ។

មុត្តា ។

[២៧៣] ម្នាលនាងមិត្តា នាងបួសដោយសទ្ធាហើយ ចូរជាអ្នកត្រេកអរក្នុងកល្យាណមិត្រ ចូរចម្រើននូវកុសលធម៌ទាំងឡាយ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ។

មិត្តាថេរី ។

[២៧៤] ម្នាលនាងភទ្រា នាងបួសដោយសទ្ធាហើយ ចូរជាអ្នកត្រេកអរក្នុងធម៌ដ៏ចម្រើន (មានសីលជាដើម) នាងចូរចម្រើននូវកុសលធម៌ទាំងឡាយ (ដើម្បីដល់) នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដ៏ប្រសើរបំផុត ។

ភទ្រាថេរី ។

[២៧៥] ម្នាលនាងឧបសមា នាងគប្បីឆ្លងអន្លង់គឺសង្សារ ជាទីនៅនៃម្រឹត្យុ ដែលពួកសត្វឆ្លងបានដោយកម្រក្រៃពេក ចូរនាងផ្ចាញ់នូវមារព្រមទាំងវាហនៈ ហើយទ្រទ្រង់នូវរាងកាយ ជាទីបំផុត ។

ឧបសមាថេរី ។

[២៧៦] ខ្ញុំជាអ្នករួចដោយល្អ រួចដោយប្រពៃ ព្រោះការរួចចាកអាការគមបីយ៉ាង គឺត្បាល់[១] ១ អង្រែ[២] ១ ប្ដីគម[៣] ១ ខ្ញុំជាអ្នករួចចាកជាតិនិងមរណៈហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំដកចេញហើយ ។

មុត្តាថេរី ។

១ ស្ត្រីកាលលូកដៃផាត់ប្រមូលគ្រាប់ស្រូវក្នុងត្បាល់ ត្រូវបង្អោនខ្នងឲ្យកោងដូចមនុស្សគម ។ ២ លើកអង្រែបុកស្រូវ ក៏ត្រូវបង្អោនខ្នងដូចគ្នា ។ ៣ ចំណែកស្វាមីជាមនុស្សគមដែរ ។

១៤៧

ថេរីគាថាយ ឯកនិបាតោ

[២៧៧] ឆន្ទជាតា អវសាយី(១) មនសា ច ផុដ្ឋា(២) សិយា
កាមេសុ អប្បដិពទ្ធចិត្តា ឧទ្ធំ សោតាតិ វុច្ចតិ ។

ធម្មទិន្នា ។

[២៧៨] ករោថ ពុទ្ធសាសនំ យំ កត្វា នានុតប្បតិ
ខិប្បំ បាទានិ ធោវិត្វា ឯកមន្តេ និសីទថ ។

វិសាខា ។

[២៧៩] ធាតុយោ ទុក្ខតោ ទិស្វា មា ជាតិ(៣) បុនរាគមិ
ភវេ ឆន្ទំ វិរាជេត្វា ឧបសន្តា ចរិស្សសិ ។

សុមនា ។

[២៨០] កាយេន សំវុតា អាសឹ វាចាយ ឧទ ចេតសា
សមូលំ តណ្ហំ អព្ភុយ្ហ សីតិភូតម្ហិ និព្វុតា ។

ឧត្តរា ។

---

១ ឱ. អវសាយេ ។ ម. អវសាយិ ។ ២ ឱ. ផុដា ។ ៣ ម. ជាតឹ ។

ថេរីគាថា ឯកនិបាត

[២៧៧] នាងថេរីណា មានចំណង់កើតហើយ (ដើម្បីផលដ៏ប្រសើរ) ញុំាងសមណកិច្ចឲ្យសម្រេចហើយ គប្បីជាអ្នកពាល់ត្រូវ (នូវព្រះនិព្វាន ) ដោយមគ្គចិត្ត (បើខាងក្រោម) មានចិត្តមិនជាប់ទាក់ទងក្នុងកាមទាំងឡាយ (នាងថេរីនោះ) បណ្ឌិតតែងហៅថាឧទ្ធំសោតា (អ្នកមានខ្សែគឺមគ្គ និងខ្សែគឺសង្សារក្នុងខាងលើ) ។

ធម្មទិន្នាថេរី ។

[២៧៨] អ្នកទាំងឡាយ ចូរធ្វើតាមព្រះពុទ្ធសាសនា ដែលគេធ្វើហើយមិនក្តៅក្រហាយតាមក្រោយ ចូរលាងជើងទាំងឡាយ ឲ្យឆាប់ហើយអង្គុយក្នុងទីសមគួរ ។

វិសាខាថេរី ។

[២៧៩] នាងឃើញធាតុទាំងឡាយ ថាជាទុក្ខ កុំមកកាន់កំណើតថ្មីទៀតឡើយ នាងរំសាយចំណង់ក្នុងភពចេញ ទើបស្ងប់រម្ងាប់បាន ។

សុមនាថេរី ។

[២៨០] ខ្ញុំជាអ្នកសង្រួមដោយកាយ ដោយវាចា ដោយចិត្ត បានដកតណ្ហា ព្រមទាំងឫស (ឬព្រមទាំងអវិជ្ជា) ជាអ្នកមានចិត្តត្រជាក់សម្រេចអនុបាទិសេសនិព្វានធាតុ ។

ឧត្តរាថេរី ។

[២៨១] សុខំ ត្វំ វុឌ្ឍិកេ សេហិ     កត្វា ចោឡេន ចារុតា
ឧបសន្តោ ហិ តេ រាគោ     សីតិភូតាសិ និព្ពុតា ។

សុមនា វុឌ្ឍបព្វជិតា ។

[២៨២] បិណ្ឌបាតំ ចរិត្វាន     ទណ្ឌមាលម្ព[១] ទុព្វលា
វេធមានេហិ គត្តេហិ     តត្ថេវ និបតឹ ឆមា
ទិស្វា អាទីនវំ កាយេ     អថ ចិត្តំ វិមុច្ចិ មេ ។

ធម្មា ។

[២៨៣] ហិត្វា ឃរេ បព្វជិត្វា     ហិត្វា បុត្តំ បសុំ បិយំ
ហិត្វា រាគញ្ច ទោសញ្ច     អវិជ្ជញ្ច វិរាជិយ
សមូលំ តណ្ហំ អព្ពុយ្ហ     ឧបសន្តម្ហិ និព្ពុតា ។

សង្ឃា ។

ឯកនិបាតោ សមត្តោ ។

---

១ ឱ. ម. ទណ្ឌមោលុព្ភ ។

[២៨១] ម្នាលនាងចម្រើនដោយសីលាទិគុណ នាងចូរដេកស្រួល នាងចូរធ្វើ (ចីវរ) ដោយសំពត់ (បង្សុកូល) ស្លៀកដណ្តប់ ព្រោះថាបើរាគៈរបស់នាងស្ងប់រម្ងាប់ហើយ នាងនឹងជាស្ត្រីមានចិត្តត្រជាក់រលត់កិលេស ។

សុមនាថេរីបួសឯចាស់ ។

[២៨២] ខ្ញុំមានកម្លាំងថយ កាន់ឈើច្រត់ ដើរទៅបិណ្ឌបាត មានខ្លួនញេងញោង ដួលលើផែនដីក្នុងទីនោះឯង លំដាប់នោះ ចិត្តរបស់ខ្ញុំក៏រួចស្រឡះ (ចាកកិលេស) ព្រោះឃើញទោសក្នុងកាយ ។

ធម្មាថេរី ។

[២៨៣] ខ្ញុំបានលះបង់ផ្ទះ លះកូនជាទីស្រឡាញ់ និងសត្វចិញ្ចឹម ហើយមកបួស បានលះរាគៈនិងទោសៈ រំសាយអវិជ្ជាគឺមោហៈ បានដកតណ្ហា ព្រមទាំងឫស ជាស្រីស្ងប់រម្ងាប់ ហើយបានសម្រេចអនុបាទិសេសនិព្វានធាតុ ។

សង្ឃាថេរី ។

ចប់ ឯកនិបាត ។

១៤៩

# ថេរីគាថាយ ទុកនិបាតោ

[២៨៤] អាតុរំ អសុចឹ បូតឹ បស្ស នន្ទេ សមុស្សយំ
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ ។
អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ
តតោ មានាភិសមយា ឧបសន្តា ចរិស្សសិ ។

ឥត្ថំ សុទំ ភគវា នន្ទំ សិក្ខមានំ ឥមាហិ គាថាហិ អភិណ្ហំ ឱវទតិ ។

នន្ទា ។

[២៨៥] យេ ឥមេ សត្ត ពោជ្ឈង្គា មគ្គា និព្វានបត្តិយា
ភាវិតា តេ មយា សព្វេ យថា ពុទ្ធេន ទេសិតា ។
ទិដ្ឋោ ហិ មេ សោ ភគវា អន្តិមោយំ សមុស្សយោ
វិក្ខីណោ ជាតិសំសារោ នត្ថិទានិ បុនព្ភវោ ។

ជន្តា[១] ។

[២៨៦] សុមុត្តិកេ សុមុត្តិកា សាធុ មុត្តិកម្ហិ មុសលស្ស
អហិរិកោ មេ ឆត្តកំ វាបិ ឧក្ខលិកា មេ ទលិទ្ទភាវាតិ ។

---

១ ឱ. ម. ជេន្តី ។

# ថេរីគាថា ទុកនិបាត

[២៨៤] ម្នាលនាងនន្ទា នាងចូរមើល (រាងកាយនេះ) មានជំងឺជានិច្ច មិនស្អាត ជារបស់ស្អុយ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំឡើងហើយ ចូរនាងអប់រំចិត្តដោយអសុភសញ្ញាឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំល្អ ។ ចូរនាងចម្រើននូវអនិមិត្ត ចូរលះចោលនូវមានានុស័យ នាងនឹងបានស្ងប់រម្ងាប់ ព្រោះបានលះនូវមានះនោះ ។

ឮថា ព្រះមានព្រះភាគ ទ្រង់ទូន្មានរឿយ ៗ នូវសិក្ខមានា ឈ្មោះនន្ទា ដោយគាថាទាំងនេះ ដោយប្រការដូច្នេះ ។

នន្ទាថេរី ។

[២៨៥] ពោជ្ឈង្គប្រាំពីរនេះណា ជាឧបាយដើម្បីដល់ នូវព្រះនិព្វាន ពោជ្ឈង្គទាំងអស់នោះ ខ្ញុំបានចម្រើន តាមលំអាន ដែលព្រះពុទ្ធទ្រង់សម្តែងហើយ ។ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ខ្ញុំបានឃើញហើយ រាងកាយនេះ មានក្នុងទីបំផុត ជាតិសង្សារ (នៃខ្ញុំ) អស់រលីងហើយ ឥឡូវនេះ ភពថ្មី មិនមានទៀតឡើយ ។

ជន្តាថេរី ។

[២៨៦] អញរួចស្រឡះ ផុតស្រឡះ រួចល្អហើយចាកអង្រែ (ប្តីរបស់អញ) មិនមានសេចក្តីអៀនខ្មាស (អញមិនគាប់ចិត្ត) ទាំងឆត្រ (ក៏មិនគាប់ចិត្ត) អញដែរ អញ(ផុតស្រឡះ)ចាកឆ្នាំង ចាកភាពជាអ្នកកម្សត់ ។

រាគញ្ច អហំ ទោសញ្ច    វិច្ឆិន្ទន្តី វិហរាមិ
សារុក្ខមូលមុបគម្ម អហោ    សុខន្តិ សុខតោ ឈាយាមិ ។

អញ្ញតរា ថេរីភិក្ខុនី អបញ្ញាតា ។

[២៨៧] យាវ កាសិជនបទោ    សុង្កោ មេ តត្តកោ អហុ
តំ កត្វា និគមោ អគ្ឃំ    អគ្ឃេនគ្ឃំ[១] ឋបេសិ មំ ។
អថ និព្វិន្ទហំ រូបេ    និព្វិន្ទញ្ច វិរជ្ជហំ
មា បុន ជាតិសំសារំ    សន្ធាវេយ្យំ បុនប្បុនំ
តិស្សោ វិជ្ជា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។

អឌ្ឍកាសី ។

[២៨៨] កិញ្ចាបិ ខោម្ហិ កិសិកា    គិលានា ពាឡ្ហទុព្វលា
ទណ្ឌមោលុព្ភ គច្ឆាមិ    បព្វតំ អភិរូហិយ ។
សង្ឃាដឹ និក្ខិបិត្វាន    បត្តកញ្ច និកុជ្ជិយ
សេលេ ខម្ភេសឹ អត្តានំ    តមោក្ខន្ធំ បទាលិយ ។

ចិត្តា ។

[២៨៩] កិញ្ចាបិ ខោម្ហិ ទុក្ខិតា    ទុព្វលា គតយោព្វនា
ទណ្ឌមោលុព្ភ គច្ឆាមិ    បព្វតំ អភិរូហិយ ។

---

១ បាលីនេះគួរថា “អឌ្ឍេនគ្ឃំ” ប្រែថា មានតម្លៃដោយថ្លៃពាក់កណ្តាល ។ ទើបសមនឹងឈ្មោះថា “អឌ្ឍកាសី” ។

អញបានផ្តាច់ផ្តិលរាគៈនិងទោសៈហើយ អញនោះចូលទៅរកគល់ឈើ ហើយចម្រើនឈាន ជាសុខថា ឱសុខណាស់តើ ។

ថេរីភិក្ខុនីមួយរូប មាននាមនិងគោត្រមិនប្រាកដ ។

[២៨៧] ស្ងួយក្នុងជនបទឈ្មោះកាសី មានចំនួនប៉ុន្មាន ស្ងួយរបស់ខ្ញុំ ក៏មានចំនួនប៉ុណ្ណោះដែរ អ្នកនិគមបានធ្វើ (ទ្រព្យចំនួន ៥០០) នោះឲ្យជាថ្លៃ ហើយតាំងទុកនូវខ្ញុំ (ដោយឈ្មោះថាអឌ្ឍកាសី) ដែលមានថ្លៃដោយថ្លៃ ។ ក្នុងកាលជាខាងក្រោយមក ខ្ញុំក៏បាននឿយណាយក្នុងរូប កាលបើនឿយណាយ ក៏រសាយចិត្តថា សូមកុំឲ្យខ្ញុំអន្ទោលទៅកាន់ជាតិសង្សារវៀយ ៗ ទៀត វិជ្ជា ៣ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ សាសនាព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

អឌ្ឍកាសីថេរី ។

[២៨៨] ពិតមែនតែខ្ញុំជាស្រីស្គម មានជំងឺ មានកម្លាំងថយខ្លាំង ច្រត់ដំបងឡើងទៅលើភ្នំ ។ ដាក់នូវសង្ឃាដី ផ្កាប់នូវបាត្រទុក (អង្គុយ) លើភ្នំ អាចទម្លាយនូវគំនរងងឹត គឺមោហៈបាន ហើយសង្កត់សង្កិននូវខ្លួន (ដោយការទម្លាយនូវគំនរងងឹត គឺមោហៈនោះឯង) ។

ចិត្តាថេរី ។

[២៨៩] ពិតមែនហើយតែខ្ញុំ ជាអ្នករងទុក្ខ មានកម្លាំងថមថយ មានវ័យកន្លងជ្រុលហើយ ច្រត់ដំបង ឡើងទៅលើភ្នំ ។

និក្ខិបិត្វាន សង្ឃាដឹ   បត្តកញ្ច និកុជ្ជិយ
និសិន្នា ចម្ហិ សេលម្ហិ   អថ ចិត្តំ វិមុច្ចិ មេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។

មេត្តិកា ។

[២៩០] ចាតុទ្ទសី(១) បញ្ចទសី   យា ច បក្ខស្ស អដ្ឋមី
បាដិហារិកបក្ខញ្ច   អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបគច្ឆឹ   ទេវកាយាភិនន្ទិនី ។
សាជ្ជ ឯកេន ភត្តេន   មុណ្ឌា សង្ឃាដិបារុតា
ទេវកាយំ ន បត្ថេហំ   វិនេយ្យ ហទយេ ទរំ ។

មិត្តា ។

[២៩១] ឧទ្ធំ បាទតលា អម្ម   អធោ ចេ កេសមត្ថកា
បច្ចវេក្ខស្សុមំ កាយំ   អសុចឹ បូតិគន្ធិកំ ។
ឯវំ វិហារមានាយ   សព្វោ រាគោ សមូហតោ
បរិឡាហោ សមុច្ឆិន្នោ   សីតិភូតម្ហិ និព្វុតា(២) ។

អភយមាតា ។

[២៩២] អភយេ ភិទុរោ កាយោ   យត្ថ សត្តា បុថុជ្ជនា
និក្ខិបិស្សាមិមំ ទេហំ   សម្បជានា បដីសតា(៣) ។

---

១ ម. ចាតុទ្ទសឹ បញ្ចទសឹ ។ ២ ម. និព្វុតិ ។ ៣ ឱ. សតិមតី ។ ម. សតិមតា ។

ដាក់នូវសង្ឃាដី ផ្កាប់នូវបាត្រ អង្គុយលើភ្នំ លំដាប់នោះ ចិត្តរបស់ខ្ញុំរួចស្រឡះហើយ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនាព្រះពុទ្ធខ្ញុំក៏បានធ្វើហើយ ។

មេត្តិកាថេរី ។

[២៩០] ខ្ញុំជាអ្នកត្រេកអរនឹងពួកទេវតា (ក្នុងឋានចាតុម្មហារាជិកា) បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី ១៤ តិថីទី ១៥ និងតិថីទី ៨ នៃបក្សផង និងបាដិហារិកបក្ខៈផង ។ ថ្ងៃនេះ ខ្ញុំនោះមានកត្តតែម្តងកោរសក់ ដណ្តប់សង្ឃាដី មិនគប្បីប្រាថ្នា នូវពួកទេវតា (ណាមួយ) ទេ គប្បីបន្ទោបង់ នូវសេចក្តីក្រវល់ក្រវាយក្នុងហឫទ័យ (តែប៉ុណ្ណោះ) ។

មិត្តាថេរី ។

[២៩១] បពិត្រមាតា សូមលោកពិចារណារាងកាយនេះ ជារបស់មិនស្អាតមានក្លិនស្អុយ ខាងលើអំពីបាទដើង ខាងក្រោមអំពីចុងសក់ ។ កាលខ្ញុំប្រព្រឹត្តយ៉ាងនេះ បានដករាគៈទាំងពួងហើយ បានផ្តាច់សេចក្តីក្រវល់ក្រវាយអស់ហើយ ជាអ្នកមានចិត្តត្រជាក់ រលត់ទុក្ខហើយ ។

អភយមាតាថេរី ។

[២៩២] ម្នាលនាងអភយា ពួកបុថុជ្ជនជាប់ចំពាក់ ក្នុងរាងកាយណារាងកាយ (នោះ) ជាសភាពបែកធ្លាយ អាត្មាអញជាអ្នកដឹងខ្លួនមានស្មារតីតាំងស៊ប់ នឹងដាក់ចុះ នូវរាងកាយនេះចោលចេញ ។

ពហូហិ ទុក្ខធម្មេហិ អប្បមាទរតាយ មេ
តណ្ហាក្ខយោ អនុប្បត្តោ កាតំ ពុទ្ធស្ស សាសនំ[១] ។

អភយត្ថេរី ។

[២៩៣] ចតុក្ខត្តុំ បញ្ចក្ខត្តុំ វិហារា ឧបនិក្ខមឹ
អលទ្ធា ចេតសោ សន្តឹ ចិត្តេ អវសវត្តិនិ ។
តស្សា មេ អដ្ឋមី រត្តិ យតោ តណ្ហា[២] សមូហតា
ពហូហិ ទុក្ខធម្មេហិ អប្បមាទរតាយ មេ
តណ្ហាក្ខយោ អនុប្បត្តោ កាតំ ពុទ្ធស្ស សាសនំ ។

សាមា ។

ទុកនិបាតោ សមត្តោ ។

---

១ ឱ. ម. សាសនន្តិ ។ ២ ឱ. ម. តណ្ហា មយ្ហំ ។

អាត្មាអញត្រូវទុក្ខធម៌ ជាច្រើនពាល់ត្រូវហើយ ជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។

អភយាថេរី ។

[២៩៣] អាត្មាអញ មិនទាន់បានសេចក្តីស្ងប់រម្ងាប់នៃចិត្ត មិនលុះអំណាចក្នុងការនាចិត្ត បានចេញទៅខាងក្រៅអំពីលំនៅ ៤ ដង ៥ ដង ។ អាត្មាអញនោះ ត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ បានដកតណ្ហាហើយក្នុងរាត្រីទី ៨ អាត្មាអញ ជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេច នូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។

សាមាថេរី ។

ចប់ ទុកនិបាត ។

១៨៣

# ថេរីគាថាយ តិកនិបាតោ

[២៩៧] បណ្ណវីសតិ វស្សានិ យតោ បព្វជិតាយ មេ
នាភិជានាមិ ចិត្តស្ស សមំ លទ្ធំ កុទាចនំ ។
អលទ្ធា ចេតសោ សន្តឹ ចិត្តេ អវសវត្តិនិ
តតោ សំវេគមាបាទឹ សរិត្វា ជិនសាសនំ ។
ពហូហិ ទុក្ខធម្មេហិ អប្បមាទរតាយ មេ
តណ្ហាក្ខយោ អនុប្បត្តោ កតំ ពុទ្ធស្ស សាសនំ
អជ្ជ មេ សត្តមី រត្តិ យតោ តណ្ហា វិសោសិតា ។

អញ្ញតរា សាមា ។

[២៩៨] ចតុក្ខត្តុំ បញ្ចក្ខត្តុំ វិហារា ឧបនិក្ខមឹ
អលទ្ធា ចេតសោ សន្តឹ ចិត្តេ អវសវត្តិនិ ។
សា ភិក្ខុនឹ ឧបាគច្ឆឹ[១] យា មេ សទ្ធាយិកា អហុ
សា មេ ធម្មមទេសេសិ ខន្ធាយតនធាតុយោ ។
តស្សា ធម្មំ សុណិត្វាន យថា មំ អនុសាសិ សា
សត្តាហំ ឯកបល្លង្កេ និសីទឹ បីតិសុខមប្បិតា[២] ។
អដ្ឋមិយា បាទេ បសារេសឹ តមោក្ខន្ធំ បទាលិយ ។

ឧត្តមា ។

---

១ ម. សា ភិក្ខុនី ឧបាគច្ឆិ ។ ២ ឱ. ម. បីតិសុខសមប្បិតា ។

# ថេរីគាថា តិកនិបាត

[២៩៤] តាំងពីកាលអាត្មាអញបួសមកបាន ២៥ ឆ្នាំហើយ អាត្មាអញមិនទាន់បានស្គាល់នូវសេចក្ដីស្ងប់ចិត្តម្ដងទេ ។ អាត្មាអញមិនបានសេចក្ដីស្ងប់ចិត្ត មិនលុះអំណាចក្នុងការនាចិត្ត តែតមកអាត្មាអញរឭកដល់សាសនា នៃព្រះជិនស្រី ក៏បានដល់នូវសេចក្ដីសំវេគ ។ អាត្មាអញ ត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ ជាអ្នកត្រេកអរក្នុងសេចក្ដីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធ អាត្មាអញ បានធ្វើហើយ ថ្ងៃនេះជារាត្រី ទី ៧ របស់អាត្មាអញ ជារាត្រីដែលតណ្ហារីងស្ងួត ។

សាមាថេរី ដទៃទៀត ។

[២៩៥] អាត្មាអញ មិនបានសេចក្ដីស្ងប់រម្ងាប់ចិត្ត មិនលុះក្នុងអំណាចការនាចិត្ត បានចេញទៅ ខាងក្រៅអំពីលំនៅ ៤ ដង ៥ ដង ។ អាត្មាអញនោះ បានចូលទៅរកភិក្ខុនី ដែលអាត្មាអញគួរជឿ (បដាចារាថេរី) ភិក្ខុនីនោះបានសម្ដែងធម៌ គឺខន្ធអាយតនៈធាតុ ដល់អាត្មាអញ ។ លុះអាត្មាអញ បានស្ដាប់ធម៌របស់លោក តាមទំនងដែលលោកបានប្រៀនប្រដៅ អាត្មាអញក៏ឆ្អែតដោយបីតិនិងសុខៈ អង្គុយលើបល្ល័ង្កមួយ អស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៨ អាត្មាអញបានទម្លាយគំនរងងឹត គឺមោហៈ ហើយសណ្ដូកជើងទាំងគូ ។

ឧត្តមាថេរី ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរីគាថា

[២៩៦] យេ ឥមេ សត្ត ពោជ្ឈង្គា មគ្គា និព្វានបត្តិយា
ភាវិតា តេ មយា សព្វេ យថា ពុទ្ធេន ទេសិតា ។
សុញ្ញតស្សានិមិត្តស្ស លាភិនីហំ យទិច្ឆិតំ
ឱរសា ធីតា ពុទ្ធស្ស និព្វានាភិរតា សទា ។
សព្វេ កាមា សមុច្ឆិន្នា យេ ទិព្វា យេ ច មានុសា
វិក្ខីណោ ជាតិសំសារោ នត្ថិ ទានិ បុនព្ភវោ ។

អញ្ញតរា ឧត្តមា ។

[២៩៧] ទិវា វិហារា និក្ខម្ម គិជ្ឈកូដម្ហិ បព្វតេ
នាគំ ឱគាហមុត្តិណ្ណំ នទីតីរម្ហិ អទ្ទសំ ។
បុរិសោ អង្កុសមាទាយ ទេហិ បាទន្តិ យាចតិ
នាគោ បសារយិ បាទំ បុរិសោ នាគមារុហិ ។
ទិស្វា អទន្តំ ទមិតំ មនុស្សានំ វសំ គតំ
តតោ ចិត្តំ សមាធេមិ ខលុ តាយ វនំ គតា ។

ទន្តិកា ។

[២៩៦] *ពោជ្ឈង្គទាំង ៧ ណា ជាឧបាយដើម្បីដល់នូវព្រះនិព្វាន ពោជ្ឈង្គទាំងអស់នោះ អាត្មាអញបានចម្រើនហើយ តាមលំអានដែលព្រះពុទ្ធសម្តែងហើយ ។ អាត្មាអញជាឱរសធីតា របស់ព្រះពុទ្ធ ជាអ្នកត្រេកអរចំពោះព្រះនិព្វាន ក្នុងកាលទាំងពួង ជាអ្នកបានសុញ្ញតសមាបត្តិនិងអនិមិត្តសមាបត្តិតាមប្រាថ្នា ។ កាមទាំងអស់ ទោះជាទិព្វក្តី ជារបស់មនុស្សក្តី អាត្មាអញបានកាត់ផ្តាច់ផ្តិលហើយ ជាតិសង្សារ របស់អាត្មាអញ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។*

ឧត្តមាថេរី មួយរូប ។

[២៩៧] *អាត្មាអញបានចេញទៅ អំពីទីសម្រាក ក្នុងវេលាថ្ងៃ លើភ្នំឈ្មោះគិជ្ឈកូដ ហើយបានឃើញដំរីដែលចុះឡើង ក្បែរឆ្នេរស្ទឹង (ឈ្មោះចន្ទភាគា) ។ បុរសកាន់កង្វេរ បង្គាប់ថា ឯងចូរជូនជើងមក ដំរីក៏ជូនជើង ហើយបុរសក៏ឡើងជិះដំរី ។ អាត្មាអញបានឃើញដំរីដែលគេមិនទាន់ទូន្មាន គេអាចទូន្មានឲ្យលុះក្នុងអំណាចរបស់ពួកមនុស្សបាន ហើយក៏ទៅកាន់ព្រៃ តាមកិរិយារបស់ដំរីនោះ ក៏បានធ្វើចិត្តឲ្យនឹងធឹង ព្រោះឃើញដំរីនោះ ។*

ទន្តិកាថេរី ។

[២៩៨] អម្ម ជីវាតិ វនម្ហិ កន្ទសិ អត្តានំ អភិកន្ទ ឧព្វិរិ
ចុល្លាសីតិសហស្សានិ សព្វា ជីវសនាមិកា
ឯតម្ហាឡាហនេ ទឌ្ឍា តាសំ កមនុសោចសិ ។
អព្ពុហិ[១] វត មេ សល្លំ ទុទ្ទសំ ហទយនិស្សិតំ
យំ មេ សោកបរេតាយ ធីតុសោកំ ព្យបានុទិ ។
សាជ្ជ អព្វូឡ្ហសល្លាហំ និច្ឆាតា បរិនិព្វុតា
ពុទ្ធំ ធម្មញ្ច សង្ឃញ្ច ឧបេមិ សរណំ មុនឹ ។
ឧព្វិរិ ។

[២៩៩] កឹ មេ កតា រាជកុលេ មនុស្សា មជ្ជំ បិតាវ អច្ឆរេ
យេ សុត្តំ ន ឧចាសន្តិ ទេសេន្តឹ[២] ពុទ្ធសាសនំ ។
តញ្ច អប្បដិវានិយំ អសេចនកមោជវំ
បិវន្តិ មញ្ញេ សប្បញ្ញា វលាហកមិវទ្ធគូ ។

១ ម. អព្ពុតំ ។ ២ ម. ទេសេន្តំ ។

[២៩៨] ម្នាលនាងឧព្វិរី នាងកន្ទក់កន្ទេញ ក្នុងព្រៃថា ម្នាលជីវៈ មាសម្ដាយ ដូច្នេះ នាងចូរដឹងខ្លួន កូនស្រីរបស់នាងទាំងអស់ ៨៤០០០ មានឈ្មោះថា ជីវៈដូចគ្នា ត្រូវគេដុតក្នុងឈាបនដ្ឋាននេះ បណ្ដាកូនស្រីទាំងនោះ តើនាងសោកចំពោះកូនស្រីណា ។

សរគឺសេចក្ដីសោក អាស្រ័យនូវហឫទ័យរបស់ខ្ញុំព្រះអង្គ ជារបស់ដែលគេឃើញបានដោយក្រ បានរដកចេញហើយ ព្រះអង្គបានបន្ទោបង់នូវសេចក្ដីសោកព្រោះកូនស្រី របស់ខ្ញុំព្រះអង្គ ដែលត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ។ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គនោះមានសររដកហើយ ជាអ្នកមិនមានសេចក្ដីស្រេកឃ្លាន បានរំលត់ទុក្ខហើយ ខ្ញុំព្រះអង្គ សូមដល់ព្រះពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ។

ឧព្វិរីថេរី ។

[២៩៩] ពួកមនុស្ស ក្នុងក្រុងរាជគ្រឹះនេះ សម្ងំធ្វើកិច្ចអ្វី ដូចជាបុគ្គលសម្ងំផឹកទឹកឃ្មុំ ក៏មិននាំគ្នាចូលទៅរកនាងសុក្កាថេរី ដែលកំពុងប្រកាសព្រះពុទ្ធសាសនា ។ ពួកបណ្ឌិតបុរស ប្រកបដោយប្រាជ្ញាទំនងជាបានក្រេបផឹក នូវធម៌នោះ ជាធម៌មិនគប្បីដឹកនាំបុគ្គលឲ្យត្រឡប់ថយ ជាធម៌មិនលាយឡំ មានឱជារស ដូចជាពួកអ្នកដើរផ្លូវឆ្ងាយ បានក្រេបផឹកនូវទឹកភ្លៀង ។

សុក្កា សុក្កេហិ ធម្មេហិ វីតរាគា សមាហិតា
ធារេតិ អន្តិមំ ទេហំ ជេត្វា មារំ សវាហនំ ។

សុក្កា ។

[៣០០] នត្ថិ និស្សរណំ លោកេ កឹ វិវេកេន កាហសិ
ភុញ្ជាហិ កាមរតិយោ មាហុ បច្ឆានុតាបិនី ។
សត្តិសូលូបមា កាមា ខន្ធានំ អធិកុដ្ដនា
យំ ត្វំ កាមរតឹ ព្រូសិ អរតិទានិ សា មមំ ។
សព្វត្ថ វិហតា នន្ទិ តមោក្ខន្ធោ បទាលិតោ
ឯវំ ជានាហិ បាបិម និហតោ ត្វមសិ អន្តក ។

សេលា ។

[៣០១] យន្តំ ឥសីហិ បត្តព្វំ ឋានំ ទុរភិសម្ភវំ
ន តំ ទ្វង្គុលិបញ្ញាយ សក្កា បប្បោតុមិត្ថិយា ។

*ព្រះនាងសុក្កាថេរី មានលោកុត្តរធម៌ ដ៏បរិសុទ្ធល្អ ជាស្រីប្រាសចាក រាគៈហើយ ជាអ្នកនឹងធឹង ឈ្នះមារព្រមទាំងវាហនៈ ហើយ ទ្រទ្រង់រាងកាយ មានក្នុងទីបំផុត ។*

សុក្កាថេរី ។

[៣០០] *ការរលាស់ខ្លួនចេញ* (ចាកភព) *ក្នុងលោក របស់នាងមិនមានទេ នាងនឹងធ្វើអ្វីដោយវិវេក នាងចូរបរិភោគនូវតម្រេកដែលអាស្រ័យនូវ កាមទាំងឡាយ កុំឲ្យក្តៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ ។ កាមទាំងឡាយ មានឧបមាដោយលំពែងនិងដែកសូល ជាគ្រឿង កាប់ចិញ្ច្រាំ នូវឧបាទានក្ខន្ធទាំងឡាយ អ្នកឯងពោល(សំដៅ)តម្រេក ក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ ជាទីអផ្សុកដល់អាត្មា ទេតើ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង យើងបានកម្ចាត់ ចេញហើយ គំនរងងឹត យើងបានទម្លុះទម្លាយហើយ ម្នាលមារ មានចិត្តបាប អ្នកឯងចូរដឹងយ៉ាងនេះចុះ ម្នាលមារចោកទាប អ្នកឯងយើងកម្ចាត់ចេញបានហើយ ។*

សេលាថេរី ។

[៣០១] *ពួកឥសី* (មានព្រះពុទ្ធជាដើម) *គប្បីដល់ នូវឋានៈណា ដែល បុគ្គលដទៃ មិនងាយនឹងបានសម្គាល់ ស្ត្រីមិនអាចនឹងដល់ នូវឋានៈ នោះ ដោយប្រាជ្ញាប្រវែងពីរធ្នាប់បានទេ ។*

១៤៧

ថេរីគាថាយ តិកនិបាតោ

ឥត្ថិភាវោ នោ កឹ កយិរា ចិត្តម្ហិ សុសមាហិតេ
ញាណម្ហិ វត្តមានម្ហិ សម្មា ជម្មំ វិបស្សតោ ។
សព្វត្ថ វិហតា នន្ទិ តមោក្ខន្ធោ បជាលិតោ
ឯវំ ជាជាហិ ចាបិម និហតោ ត្វមសិ អន្តក ។

សោមា ។

តិកនិបាតោ និដ្ឋិតោ ។

កាលបើចិត្តរបស់បុគ្គល អ្នកឃើញច្បាស់នូវធម៌ ដោយប្រពៃ បានតម្កល់មាំហើយ កាលបើញាណកំពុងតែប្រព្រឹត្តទៅ តើស្ត្រីភាព ហេតុម្តេចមិនគប្បីធ្វើនូវឋានៈនោះបាន ។ សេចក្តីរីករាយក្នុងអារម្មណ៍ ទាំងពួង យើងបានកម្ចាត់ចេញហើយ គំនរងងឹត យើងបានទម្លុះ ទម្លាយហើយ ម្នាលមារមានចិត្តបាប អ្នកឯងចូរដឹងយ៉ាងនេះចុះ ម្នាលមារជោកទាប អ្នកឯង យើងកម្ចាត់ចេញបានហើយ ។

សោមាថេរី ។

ចប់ តិកនិបាត ។

# ថេរីគាថាយ ចតុក្កនិបាតោ

[៣០] បុត្តោ ពុទ្ធស្ស ទាយាទោ កស្សបោ សុសមាហិតោ
បុព្វេនិវាសំ សោ[១] វេទិ សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ អភិញ្ញាវោសិតោ មុនិ
ឯតាហិ តីហិ វិជ្ជាហិ តេវិជ្ជោ ហោតិ ព្រាហ្មណោ ។
តថេវ ភទ្ទកាបិលានី[២] តេវិជ្ជា មច្ចុហាយិនី
ធារេតិ អន្តិមំ ទេហំ ជេត្វា មារំ សវាហនំ ។
ទិស្វា អាទីនវំ លោកេ ឧភោ បព្វជិតា មយំ
ត្យម្ហ ខីណាសវា ទន្តា សីតិភូតម្ហ និព្វុតាតិ ។

ភទ្ទកាបិលានី ។

ចតុក្កនិបាតោ និដ្ឋិតោ ។

---

១ ឱ. ម. យោ ។ ២ ឱ. ភទ្ទាកបិលានី ។ ម. ភទ្ទាកាបិលានិ ។

# ថេរីគាថា ចតុក្កនិបាត

[៣០២] *ព្រះថេរៈឈ្មោះកស្សប ជាបុត្តពុទ្ធទាយាទ មានចិត្តតម្កល់មាំល្អ លោកបានដឹងនូវបុព្វេនិវាស ទាំងឃើញឋានសួគ៌និងអបាយ លំដាប់អំពីនោះមក លោកបានដល់នូវធម៌ជាទីអស់ទៅនៃជាតិ បានសម្រេចនូវអភិញ្ញា ជាអ្នកប្រាជ្ញ ជាព្រាហ្មណ៍ បានសម្រេចវិជ្ជា ៣ ដោយវិជ្ជា ៣ នេះ ។ ព្រះថេរីឈ្មោះ ភទ្ទកាបិលានី ក៏យ៉ាងនោះដែរ បានសម្រេចវិជ្ជា ៣ ញុំាងមច្ចុឲ្យសាបសូន្យ ឈ្នះមារព្រមទាំងវាហនៈ ហើយទ្រទ្រង់រាងកាយ ជាទីបំផុត ។ យើងទាំងពីររូប បានឃើញទោសក្នុងលោក ហើយមកបួស យើងទាំងនោះ ជាព្រះខីណាស្រព បានទូន្មានខ្លួនហើយ ជាអ្នកមានចិត្តត្រជាក់ បាននិព្វានហើយ ។*

ភទ្ទកាបិលានីថេរី ។

ចប់ ចតុក្កនិបាត ។

១៨៩

# ថេរីគាថាយ បញ្ចកនិបាតោ

[៣០៣] បណ្ណវីសតិ វស្សានិ យតោ បព្វជិតា អហំ
អច្ឆរាសង្ឃាតមត្តម្បិ ចិត្តស្សុបសមជ្ឈគំ ។
អលទ្ធា ចេតសោ សន្តឹ កាមរាគេន វស្សុតា
ពាហា បគ្គយ្ហ កន្ទន្តី វិហារំ បាវិសឹ អហំ ។
សា ភិក្ខុនឹ ឧបាគច្ឆឹ[1] យា មេ សទ្ធាយិកា អហុ
សា មេ ធម្មមទេសេសិ ខន្ធាយតនធាតុយោ ។
តស្សា ធម្មំ សុណិត្វាន ឯកមន្តេ ឧបាវិសឹ
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ ។
ចេតោ បរិច្ចញាណញ្ច សោតធាតុ វិសោធិតា
ឥទ្ធិបិ មេ សច្ឆិកតា បត្តោ មេ អាសវក្ខយោ
ឆ មេភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

អញ្ញតរា ភិក្ខុនី អប្បញ្ញាតា ។

[៣០៤] មត្តា វណ្ណេន រូបេន សោភគ្គេន យសេន ច
យោព្វនេន ចុបត្ថទ្ធា អញ្ញា សមតិមញ្ញិហំ ។
វិភូសេត្វា ឥមំ កាយំ សុចិត្តំ ពាលលាបនំ[2]
អដ្ឋាសឹ វេសិទ្វារម្ហិ លុទ្ទោ បាសមិវោឌ្ឌិយា[3]

---

១ ម. តំ ភិក្ខុនឹ ឧបាគច្ឆិ ។ ២ ឱ. ពាលាលបនំ ។ ៣ ឱ. បាសមិវោឌ្ឌិយ ។ ម. បាសមិវោឌ្ឌិយំ ។

# ថេរីគាថា បញ្ចកនិបាត

[៣០៣] តាំងពីកាលអាត្មាអញបួសមកបាន ២៥ វស្សាហើយ មិនបាន សេចក្ដីស្ងប់ចិត្ត សូម្បីត្រឹមមួយផ្ទាត់ម្រាមដៃ ។ អាត្មាអញមានចិត្ត ទទឹកដោយកាមរាគ មិនបានសេចក្ដីស្ងប់ចិត្ត ផ្គងដើមដៃកន្ទក់កន្ទេញ ហើយចូលទៅកាន់លំនៅ ។ អាត្មាអញនោះ ចូលទៅរកភិក្ខុនី (ធម្មទិន្នាថេរី) ជាស្ត្រីដែលអាត្មាអញគួរជឿ លោកបានសម្ដែងធម៌ គឺខន្ធ អាយតនៈ ធាតុ ដល់អាត្មាអញ ។ លុះអាត្មាអញបានស្ដាប់ ធម៌របស់លោកហើយ បានចូលទៅក្នុងទីសមគួរ ដឹងនូវបុព្វេនិវាស បានជម្រះទិព្វចក្ខុ ។ ចេតោបរិយញ្ញាណនិងសោតធាតុ អាត្មាអញ បានជម្រះហើយ ឫទ្ធិ អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ហើយ ការអស់ ទៅនៃអាសវៈ អាត្មាអញបានសម្រេចហើយ អភិញ្ញា ៦ អាត្មាអញ បានធ្វើឲ្យច្បាស់ហើយ ព្រះពុទ្ធសាសនាអាត្មាអញក៏បានធ្វើហើយ ។

ភិក្ខុនីមួយរូប មាននាមនិងគោត្រមិនប្រាកដ ។

[៣០៤] អាត្មាអញស្រវឹង រឹងត្អឹង ដោយការសរសើរគុណផង ដោយរូបសម្បត្តិផង ដោយលម្អដ៏លើសផង ដោយយសផង ដោយវ័យផង បានមើលងាយពួកស្រីដទៃ ។ អាត្មាអញស្អិតស្អាង រាងកាយនេះ ឲ្យវិចិត្រល្អ ឲ្យជាទីរាក់ទាក់នៃជនពាល ហើយ ឈរក្បែរទ្វារផ្ទះ នៃស្រីពេស្យា ដូចជាព្រានម្រឹគ ដាក់អន្ទាក់ ។

បិឡន្ធនំ វិទស្សេន្តី[១] គុយ្ហំ បកាសិតំ ពហុំ
អកាសឹ វិវិធំ មាយំ ឧជ្ជគ្ឃន្តី ពហុំ ជនំ ។
សាជ្ជ បិណ្ឌំ ចរិត្វាន មុណ្ឌា សង្ឃាដិបារុតា
និសិន្នា រុក្ខមូលម្ហិ អវិតក្កស្ស លាភិនី ។
សព្វេ យោគា សមុច្ឆិន្នា យេ ទិព្វា យេ ច មានុសា
ខេបេត្វា អាសវេ សព្វេ សីតិភូតម្ហិ និព្វុតា ។

វិមលា បុរាណគណិកា ។

[៣០៩] អយោនិសោមនសិការា កាមរាគេន អទ្ទិតា[២]
អហោសិ ឧទ្ធតា បុព្វេ ចិត្តេ អវសវត្តិនី ។
បរិយុដ្ឋិតា កិលេសេហិ សុខសញ្ញានុវត្តិនី
សមំ ចិត្តស្ស នាលភឹ រាគចិត្តវសានុគា ។
កិសា បណ្ឌុ វិវណ្ណា ច សត្ត វស្សានិ ចារិហំ
នាហំ ទិវា វា រត្តឹ វា សុខំ វិន្ទឹ សុទុក្ខិតា ។
តតោ រជ្ជុំ គហេត្វាន បាវិសឹ វនមន្តរំ

១ ឱ. ម. វិទំសេន្តី ។ ២ ឱ. អទ្ទិកា ។ ម. អឌ្ឌិតា ។

*អាត្មាអញសម្តែងគ្រឿងប្រដាប់និងអវយវៈដ៏កំបាំង ឲ្យជាក់ច្បាស់ជាច្រើន សើចក្អាកក្អាយ បានធ្វើមាយាច្រើនយ៉ាង (ដើម្បី)ញ៉ាំងជនពាលជាច្រើន (ឲ្យស្រើបស្រាល) ។ ក្នុងថ្ងៃនេះអាត្មាអញនោះ បានកោរសក់ ដណ្តប់សង្ឃាដី ដើរទៅបិណ្ឌបាត រួចអង្គុយក្រោមម្លប់ឈើ ជាអ្នកបានទូវធម៌ដែលមិនមានវិតក្កៈ។ គ្រឿងប្រកបទាំងពួងទោះជាទិព្វក្តី ជារបស់មនុស្សក្តី អាត្មាអញបានផ្តាច់ផ្តិលហើយ អាត្មាអញបានញ៉ាំងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកមានចិត្តត្រជាក់ រំលត់ទុក្ខហើយ ។*

វិមលាថេរី ជាស្រីពេស្យាពីដើម ។

[៣០៥] *កាលពីដើម អាត្មាអញត្រូវកាមរាគៈបៀតបៀន ជាអ្នកមានចិត្តរវើរវាយ មិនលុះក្នុងអំណាចការនាចិត្តព្រោះធ្វើទុកក្នុងចិត្តមិនជាឧបាយនៃប្រាជ្ញា ។ អាត្មាអញ លុះត្រូវកិលេសទាំងឡាយរួបរឹតហើយ ជាអ្នកប្រព្រឹត្តតាមសេចក្តីសម្គាល់ក្នុងកាមថាជាសុខ ជាអ្នកលុះក្នុងអំណាចនៃចិត្តដែលប្រកបដោយរាគៈ ក៏មិនបានទូវសេចក្តីស្ងប់ចិត្តឡើយ ។ អាត្មាអញទៅជាស្គម ស្លេកស្លាំង ស្អាប់សម្បុរ ប្រព្រឹត្តមកអស់ ៧ ឆ្នាំហើយ អាត្មាអញដល់នូវសេចក្តីទុក្ខក្រៃពេក មិនបានសេចក្តីសុខ ទាំងថ្ងៃទាំងយប់ ។ ព្រោះមិនមានសេចក្តីសុខនោះ អាត្មាអញ ក៏បានកាន់ខ្សែរចូលទៅក្នុងចន្លោះព្រៃ (ដោយគិតថា)*

ថេរីគាថាយ បញ្ចកនិបាតោ

វរម្មេ ឥធ ឧព្វន្ធំ យញ្ច ហីនំ បុនាចរេ ។
ទឡ្ហបាសំ ករិត្វាន រុក្ខសាខាយ ពន្ធិយ
បក្ខិបឹ បាសំ គិវាយំ អថ ចិត្តំ វិមុច្ចិ មេ ។

សីហា ។

[៣០៦] អាតុរំ អសុចឹ បូតឹ បស្ស នន្ទេ សមុស្សយំ
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ ។
យថា ឥទំ តថា ឯតំ យថា ឯតំ តថា ឥទំ
ទុគ្គន្ធំ បូតិកំ វាតិ ពាលានំ អភិនន្ទិតំ ។
ឯវមេតំ អវេក្ខន្តី រត្តិន្ទិវមតន្ទិតា
តតោ សកាយ បញ្ញាយ អភិនិព្វិជ្ឈ ទក្ខិសំ ។
តស្សា មេ អប្បមត្តាយ វិចិនន្តិយា យោនិសោ
យថាភូតំ អយំ កាយោ ទិដ្ឋោ សន្តរពាហិរោ ។
អថ និព្វិន្ទហំ កាយេ អជ្ឈត្តញ្ច វិរជ្ជហំ
អប្បមត្តា វិសំយុត្តា ឧបសន្តម្ហិ និព្វុតា ។

នន្ទា ។

អាត្មាអញចង់កក្នុងទីនេះប្រសើរ ត្រង់វិលទៅកាន់ភេទថោកទាបវិញ មិនប្រសើរឡើយ ។ អាត្មាអញបានធ្វើអន្ទាក់យ៉ាងមាំ ចងនឹងមែកឈើ ដាក់អន្ទាក់ត្រង់ក ក៏ស្រាប់តែចិត្តរបស់អាត្មាអញរួចស្រឡះ ។

សីហាថេរី ។

[៣០៦] ម្នាលនាងនន្ទា នាងចូរមើលរាងកាយ ដែលមានជំងឺជានិច្ច មិនស្អាត ជារបស់ពុករលួយ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំឡើងហើយ (នេះ) នាងចូរអប់រំចិត្តដោយអសុភសញ្ញា ឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំល្អ ។ សរីរៈនេះយ៉ាងណា សរីរៈរបស់នាងហ្នឹងក៏យ៉ាងនោះដែរ សរីរៈរបស់នាងហ្នឹងយ៉ាងណា សរីរៈនេះក៏យ៉ាងនោះដែរ នាងកុំខ្ជិលច្រអូស ខំពិចារណារាងកាយនុ៎ះ ទាំងយប់ទាំងថ្ងៃ យ៉ាងនេះឯងថា សរីរៈ (នេះ) ដែលពួកជនពាលរីករាយ ជារបស់ពុករលួយ មានក្លិនអាក្រក់ ។ លំដាប់អំពីនោះ ខ្ញុំក៏បានពិនិត្យឃើញដោយប្រាជ្ញារបស់ខ្លួន ។ ខ្ញុំនោះមិនធ្វេសប្រហែស ខំពិចារណាដោយឧបាយនៃប្រាជ្ញា ក៏បានឃើញកាយនេះ ទាំងខាងក្នុងទាំងខាងក្រៅ តាមពិត ។ ខាងក្រោយមក ខ្ញុំនឿយណាយក្នុងកាយ រសាយក្នុងសន្តាន ជាអ្នកមិនធ្វេសប្រហែស ក៏បានប្រាសចាកយោគៈ មានចិត្តស្ងប់ មានទុក្ខរលត់ហើយ ។

នន្ទាថេរី ។

[៣០៧] អគ្គឹ ចន្ទញ្ច សុរិយញ្ច   ទេវតា ច នមស្សិហំ
នទីតិត្ថានិ គន្ត្វាន   ឧទកំ ឱរុហាមិហំ ។
ពហុវតសមាទានា   អឌ្ឍំ សីសស្ស ឱលិខឹ
ឆមាយ សេយ្យំ កប្បេមិ   រត្តិភត្តំ ន ភុញ្ជិហំ ។
វិភូសមណ្ឌនរតា   ន្ហាបនុច្ឆាទនេហិ ច
ឧបកាសឹ ឥមំ កាយំ   កាមរាគេន អទ្ទិតា ។
តតោ សទ្ធំ លភិត្វាន   បព្វជឹ អនគារិយំ
ទិស្វា កាយំ យថាភូតំ   កាមរាគោ សមូហតោ ។
សព្វេ ភវា សមុច្ឆិន្នា   ឥច្ឆា ច បត្ថនា បិ ច
សព្វយោគវិសំយុត្តា   សន្តឹ បាបុណឹ ចេតសោ ។

នន្ទុត្តរា ថេរី ។

[៣០៨] សទ្ធាយ បព្វជិត្វាន   អគារស្មា អនគារិយំ
វិចរិហំ តេន តេន   លាភសក្ការឧស្សុកា ។

[៣០៧] *អាត្មាអញបានថ្វាយបង្គំភ្លើងផង ព្រះចន្ទ្រផង ព្រះអាទិត្យផង ពួកទេវតាផង រួចហើយ អាត្មាអញទៅកាន់កំពង់នៃស្ទឹងទាំងឡាយ ហើយចុះទៅក្នុងទឹក ។ អាត្មាអញសមាទាននូវវ័តច្រើនយ៉ាង គឺកោរក្បាលពាក់កណ្ដាល សម្រេចការដេកលើផែនដី មិនបាន បរិភោគបាយក្នុងវេលាយប់ ។ អាត្មាអញត្រេកអរក្នុងការស្អិតស្អាង និងការប្រដាប់ លុះកាមរាគៈបៀតបៀនហើយ ក៏បានទំនុកបម្រុងកាយ នេះ ដោយគ្រឿងងូត និងគ្រឿងអប់ ។ ក្នុងកាលខាងក្រោយ មក ខ្ញុំបាននូវសទ្ធា (ក្នុងសំណាក់ នៃព្រះមហាមោគ្គល្លានត្ថេរ) ហើយបួសក្នុងធម្មវិន័យ កាមរាគៈ ខ្ញុំបានដកចេញហើយ ព្រោះបាន ឃើញនូវរាងកាយ តាមពិត ។ ភពទាំងអស់ផង សេចក្ដីប្រាថ្នាផង សេចក្ដីតាំងចិត្តទុកផង អាត្មាអញបានផ្ដាច់ផ្ដិលហើយ អាត្មាអញបាន ប្រាសចាកយោគៈទាំងពួងហើយ បានដល់នូវសេចក្ដីស្ងប់ចិត្ត ។*

នន្ទុត្តរាថេរី ។

[៣០៨] *អាត្មាអញចេញអំពីផ្ទះ ហើយមកបួសក្នុងធម្មវិន័យ ដោយសទ្ធា ខ្វល់ខ្វាយក្នុងលាភៈនិងសក្ការៈ ប្រព្រឹត្តដោយហេតុ (ដែលញ៉ាំង លាភឲ្យកើតឡើង មានពាហុសច្ចៈនិងធម្មកថាជាដើម)នោះ ៗ ។*

១៦៣

ថេរីគាថាយ បញ្ចកនិបាតោ

វិញ្ចិត្វា បរមំ អត្ថំ ហីនមត្ថំ អសេវិហំ
កិលេសានំ វសំ គន្ត្វា សាមញ្ញត្ថំ និវជ្ឈិហំ ។
តស្សា មេ អហុ សំវេគោ និសិន្នាយ វិហារកេ
ឧម្មគ្គបដិបន្នម្ហិ តណ្ហាយ វសមាគតា ។
អប្បកំ ជីវិតំ មយ្ហំ ជរា ព្យាធិ ច មទ្ទតិ
បុរាយំ ភិជ្ជតិ កាយោ ន មេ កាលោ បមជ្ជិតុំ ។
យថាភូតមវេក្ខន្តី ខន្ធានំ ឧទយព្វយំ
វិមុត្តចិត្តា ឧដ្ឋាសឹ កតំ ពុទ្ធស្ស សាសនំ ។

មិត្តកាលី ។

[៣០៩] អគារស្មឹ វសន្តីហំ ធម្មំ សុត្វាន ភិក្ខុនោ
អទ្ទសំ វិរជំ ធម្មំ និព្វានំ បទមច្ចុតំ ។
សាហំ បុត្តំ ធីតរញ្ច ធនធញ្ញញ្ច ឆឌ្ឌិយ
កេសេ ឆេទាបយិត្វាន បព្វជឹ អនគារិយំ ។
សិក្ខមានា អហំ សន្តី ភាវេន្តី មគ្គមញ្ជសំ
បហាសឹ រាគទោសញ្ច តទេកដ្ឋេ ច អាសវេ ។

អាត្មាអញបានលះប្រយោជន៍ដ៏ឧត្តមចោល ហើយសេពនូវប្រយោជន៍ ថោកទាប លុះក្នុងអំណាចនៃកិលេសទាំងឡាយ មិនត្រេកអរនឹង ប្រយោជន៍នៃសមណៈ ។ សេចក្តីសង្វេគ ក៏មានដល់អាត្មាអញនោះ ដែលអង្គុយក្នុងលំនៅថាអាត្មាអញដើរផ្លូវខុសលុះក្នុងអំណាចតណ្ហា ។ ជីវិតរបស់អាត្មាអញមានប្រមាណតិច ជរានិងព្យាធិតែងញាំញី មុន កាយនេះនឹងបែកធ្លាយ មិនមែនជាកាលគួរ អាត្មាអញធ្វេសប្រហែស ឡើយ ។ អាត្មាអញកាលពិចារណា នូវការកើតឡើង និងការសូន្យ ទៅនៃខន្ធទាំងឡាយ តាមពិត ក៏មានចិត្តរួចស្រឡះ ហើយចេញ (ចាកកិលេសទាំងពួង) ពុទ្ធសាសនា អាត្មាអញបានធ្វើហើយ ។

មិត្តកាលីថេរី ។

[៣០៩] អាត្មាអញកាលនៅក្នុងផ្ទះ បានស្តាប់ធម៌របស់ភិក្ខុហើយឃើញ ធម៌ ប្រាសចាកធូលីគឺកិលេស ជាធម៌នាំសត្វឲ្យចេញចាកតណ្ហា ជាហេតុនាំឲ្យបានសេចក្តីសុខ មិនឃ្លាត ។ អាត្មាអញនោះបានបោះ បង់ចោលនូវកូនប្រុសផង កូនស្រីផង ទ្រព្យនិងស្រូវផង បានឲ្យគេ កោរសក់ ហើយមកបួសក្នុងធម្មវិន័យ ។ អាត្មាអញកាលនៅជា សិក្ខមានាបានញុំាងមគ្គខាងលើឲ្យកើត បានលះរាគៈនិងទោសៈផង អាសវៈទាំងឡាយដែលតាំងនៅជាមួយគ្នានឹងរាគៈទោសៈនោះផង ។

ភិក្ខុនី ឧបសម្បជ្ជ    បុព្វជាតិមនុស្សរឹ
ទិព្វចក្ខុំ វិសោធិតំ    វិមលំ សាធុភាវិតំ ។
សង្ខារេ បរតោ ទិស្វា    ហេតុជាតេ បលោកិនេ
បហាសឹ អាសវេ សព្វេ    សីតិភូតម្ហិ និព្វុតា ។

សកុលា ។

[៣១០] ទស បុត្តេ វិជាយិត្វា    អស្មឹ រូបសមុស្សយេ
តតោហំ ទុព្វលា ជិណ្ណា    ភិក្ខុនឹ ឧបសង្កមឹ ។
សា មេ ធម្មមទេសេសិ    ខន្ធាយតនធាតុយោ
តស្សា ធម្មំ សុណិត្វាន    កេសេ ឆេត្វាន បព្វជឹ
តស្សា មេ សិក្ខមានាយ    ទិព្វចក្ខុំ វិសោធិតំ
បុព្វេនិវាសំ ជានាមិ    យត្ថ មេ វុសិតំ បុរេ ។
អនិមិត្តញ្ច ភាវេមិ    ឯកគ្គា សុសមាហិតា
អនន្តរា វិមោក្ខាសឹ    អនុបាទាយ និព្វុតា ។
បញ្ចក្ខន្ធា បរិញ្ញាតា    តិដ្ឋន្តិ ឆិន្នមូលកា
ធិតិរត្ថុ ជរេ ជម្មិ    នត្ថិ ទានិ បុនព្ភវោ ។

សោណា ។

លុះអាត្មាអញបានឧបសម្បទាជាភិក្ខុនីហើយ ក៏រឭកឃើញនូវបុព្វជាតិ ទាំងទិព្វចក្ខុមិនមានមន្ទិល ដែលពួកសប្បុរសចម្រើនហើយ ក៏អាត្មាអញបានជម្រះហើយ ។ អាត្មាអញបានឃើញសង្ខារទាំងឡាយដែលកើតអំពីហេតុ មានសភាពទ្រុឌទ្រោម ថាជារបស់ដទៃ ហើយបានលះអាសវៈទាំងអស់ ជាអ្នកមានចិត្តត្រជាក់ បានរលត់ទុក្ខហើយ ។

សកុលាថេរី ។

[៣១០] អាត្មាអញបានសម្រាលកូនដប់ ក្នុងសរីរៈគឺរូបនេះ ព្រោះហេតុនោះ អាត្មាអញមានកម្លាំងថយ គ្រាំគ្រា បានចូលទៅរកភិក្ខុនីមួយរូប ។ លោកបានសម្ដែងធម៌ គឺខន្ធ អាយតនៈ ធាតុ ដល់អាត្មាអញ លុះអាត្មាអញបានស្ដាប់ធម៌របស់លោកហើយ ក៏បានកោរសក់បួស អាត្មាអញនោះ កំពុងសិក្សា (សិក្ខាបី) បានជម្រះទិព្វចក្ខុ ដឹងនូវបុព្វេនិវាស ដែលអាត្មាអញបានអាស្រ័យនៅហើយក្នុងកាលមុន ។ អាត្មាអញមានអារម្មណ៍តែមួយ មានចិត្តតម្កល់មាំ ចម្រើនអនិមិត្ត-វិមោក្ខ ជាអ្នកបានវិមោក្ខក្នុងលំដាប់ (នៃមគ្គដ៏ប្រសើរ)រលត់កិលេសហើយ ព្រោះមិនប្រកាន់ ។ បញ្ចក្ខន្ធ អាត្មាអញបានកំណត់ហើយ មានឫសផ្ដាច់ផ្ដិលហើយ អាត្មាអញមិនមានតណ្ហាដែលកើតអំពីវត្ថុដែលតាំងនៅ ឥឡូវនេះ ភពថ្មីមិនមាន ។

សោណាថេរី ។

[៣១១] លូនកេសី បង្កធរី ឯកសាដី បុរេ ចរឹ
អវជ្ជេ វជ្ជមតិនី វជ្ជេ ចាវជ្ជទស្សិនី
ទិវាវិហារា និក្ខម្ម គិជ្ឈកូដម្ហិ បព្វតេ
អទ្ទសំ វិរជំ ពុទ្ធំ ភិក្ខុសង្ឃបុរក្ខតំ
និហច្ច ជានុំ វន្ទិត្វា សម្មុខា អញ្ជលី អហំ ។
ឯហិ ភទ្ទេតិ អវច សា មេ អាសូបសម្បទា ។
ចិណ្ណា អង្គា ច មគធា វជ្ជី កាសី ច កោសលា
អនណា បណ្ណាសវស្សានិ រដ្ឋបិណ្ឌំ អភុញ្ជិហំ ។
បុញ្ញំ ច បសវិ[១] ពហុំ សប្បញ្ញោយំ[២] ឧបាសកោ
យោ ភទ្ទាយ ចីវរមទាសិ មុត្តាយ សព្វគន្ថេហិ ។

ភទ្ទា កុណ្ឌលា[៣] ។

[៣១២] នង្គលេហិ កសំ ខេត្តំ ពីជានិ បវបំ ឆមា
បុត្តទារានិ បោសេន្តា ធនំ វិន្ទន្តិ មាណវា ។

---

១ ឱ. បសវឹ ។ ម. បុញ្ញវត បសវឹ ។ ២ ឱ. សប្បញ្ញោវតាយំ ។ ៣ ឱ. ភទ្ទា បុរាណនិគណ្ឋី ។ ម. ភទ្ទា បុរាណនិគណ្ឋិ ។

[៣១១]អាត្មាអញមានសក់ដកហើយ (ដោយបន្ទាត្នោត) ទ្រទ្រង់ភក់ មានសំពត់សាដកតែមួយ ប្រព្រឹត្តក្នុងកាលមុន មានសេចក្តីសម្គាល់ថាទោសក្នុងរបស់ដែលមិនមានទោស  ទាំងមានសេចក្តីយល់ឃើញថាមិនមានទោសក្នុងរបស់ដែលមានទោស ចេញទៅអំពីទីសម្រាកក្នុងវេលាថ្ងៃបានឃើញព្រះពុទ្ធទ្រង់ប្រាសចាកធូលីគឺរាគាទិក្កិលេស មានភិក្ខុសង្ឃហែហម លើភ្នំគិជ្ឈកូដ ក៏លុតជង្គង់ថ្វាយបង្គំ ប្រណម្យអញ្ជលីក្នុងទីចំពោះព្រះភក្ត្រ ។ ព្រះមានព្រះភាគបានត្រាស់ថា ម្នាលនាង នាងចូរមកចុះ ឧបសម្បទានោះក៏សម្រេចដល់ខ្ញុំ ។ អាត្មាអញបានដើរទៅកាន់ជនបទឈ្មោះអង្គៈ មគធៈ វជ្ជី កាសី និងកោសលៈ ជាអ្នកមិនមានបំណុល បានបរិភោគដុំបាយរបស់ជនអ្នកនៅក្នុងដែន (នោះ ៗ) អស់ ៥០ ឆ្នាំ ។ ឧបាសកណាបានឲ្យចីវរដល់នាងភទ្ទា ដែលរួចចាកគន្ថៈទាំងពួង ឧបាសកនោះ ប្រកបដោយបញ្ញា  បានសោយបុណ្យច្រើន  ។

ភទ្ទាកុណ្ឌលាថេរី ។

[៣១២] ពួកមាណពភ្ជួរស្រែដោយនង្គ័លទាំងឡាយ ហើយព្រោះពូជទាំងឡាយលើផែនដី តែងបាននូវទ្រព្យចិញ្ចឹមកូននិងប្រពន្ធទាំងឡាយ ។

កិមហំ សីលសម្បន្នា សត្ថុ សាសនការិកា
និព្វានំ នាធិគច្ឆាមិ អកុសីតា អនុទ្ធតា ។
បាទេ បក្ខាលយិត្វាន ឧទកេសុ ករោមហំ
បាទោទកញ្ច ទិស្វាន ថលតោ និន្នមាគតំ
តតោ ចិត្តំ សមាធេសឹ អស្សោ ភទ្រោវ ជានិយោ[១]
តតោ ទីបំ គហេត្វាន វិហារំ បាវិសឹ អហំ
សេយ្យំ ឱលោកយិត្វា មញ្ចកម្ហិ ឧបាវិសឹ ។
តតោ សូចឹ គហេត្វាន វដ្ដឹ ឱកស្សយាមហំ
បជ្ជោតស្សេវ[២] និព្វានំ វិមោក្ខោ អហុ ចេតសោ ។

បដាចារា ។

[៣១៣] មុសលានិ គហេត្វាន ធញ្ញំ កោដ្ដេន្តិ មាណវា
បុត្តទារានិ បោសេន្តា ធនំ វិន្ទន្តិ មាណវា ។
ករោថ ពុទ្ធសាសនំ យំ កត្វា នានុតប្បតិ
ខិប្បំ បាទានិ ធោវិត្វា ឯកមន្តេ និសីទថ
ចេតោសមថមនុយុត្តា ករោថ ពុទ្ធសាសនំ ។

---

១ ឱ. ម. អស្សំ ភទ្រំវ ជានិយំ ។ ២ ឱ. ម. បទីបស្សេវ ។

អាត្មាអញបរិបូណ៌ដោយសីល មិនខ្ជិល មិនរវើរវាយ ធ្វើតាម សាសនារបស់ព្រះសាស្តា ដូចម្តេចក៏មិនបានព្រះនិព្វាន ។ អាត្មា អញលាងជើងក្នុងទឹក ឃើញទឹកសម្រាប់លាងជើងហូរអំពីទីទួលមក កាន់ទីទាប ហើយធ្វើ (ឲ្យជានិមិត្ត) ក្នុងទឹកទាំងឡាយ លំដាប់ពី នោះមក អាត្មាអញក៏បានតម្កល់ចិត្តមាំ ដូចសេះអាជានីយដ៏ចម្រើន ។ លំដាប់នោះ អាត្មាអញកាន់ប្រទីប ចូលទៅកាន់លំនៅ រមិលមើល ដំណេក ហើយអង្គុយលើគ្រែតូច ។ ក្នុងកាលនោះ អាត្មាអញ កាន់វនុកទ្វារ ហើយពន្លឺមចុះនូវប្រឆេះ (នៃប្រទីប) ចិត្តក៏បាន រួចស្រឡះចាកកិលេស ដូចជាការរលត់នៃប្រទីប ។

បដាចារាថេរី ។

[៣១៣] ពួកមាណព កាន់អង្រែទាំងឡាយបុកស្រូវ តែងបាននូវទ្រព្យ ទាំងឡាយ ចិញ្ចឹមកូននិងប្រពន្ធ ។ ពួកនាង ចូរធ្វើនូវពុទ្ធសាសនា ដែលគេធ្វើហើយមិនក្តៅក្រហាយតាមក្រោយ ចូរលាងជើងទាំង ឡាយឲ្យឆាប់ ហើយអង្គុយក្នុងទីសមគួរ ប្រកបរឿយ ៗ នូវសេចក្តី ស្ងប់ចិត្ត ហើយចូរធ្វើនូវពុទ្ធសាសនាចុះ ។

តស្សា តា វចនំ សុត្វា   បដាចារាយ សាសនំ
បាទេ បក្ខាលយិត្វាន   ឯកមន្តំ ឧបាវិសុំ
ចេតោសមថមនុយុត្តា   អកំសុ ពុទ្ធសាសនំ ។
រត្តិយា បុរិមេ យាមេ   បុព្វជាតិមនុស្សរុំ
រត្តិយា មជ្ឈិមេ យាមេ   ទិព្វចក្ខុំ វិសោធយុំ
រត្តិយា បច្ឆិមេ យាមេ   តមោក្ខន្ធំ បទាលយុំ ។
ឧដ្ឋាយ បាទេ វន្ទឹសុ   កតា តេ អនុសាសនី
ឥន្ទំវ ទេវា តិទសា   សង្គាមេ អបរាជិតំ
បុរក្ខិត្វា វិហរិស្សាម[១]   តេវិជ្ជម្ហា អនាសវា ។
ឯតិមា តឹសមត្តា   ថេរីភិក្ខុនិយោ បដាចារាយ
សន្តិកេ អញ្ញំ ព្យាករឹសុ[២]។

[៣១៤] ទុគ្គតាហំ បុរេ អាសឹ   វិធវា ច អបុត្តិកា
វិនា មិត្តេហិ ញាតីហិ   ភត្តចោលស្ស នាធិគំ ។

---

១ ឱ. ម. វិហិស្សាម ។ ២ ឱ. ម. ព្យាកិសុ ។

ភិក្ខុនីទាំងនោះ បានស្តាប់ពាក្យប្រៀនប្រដៅរបស់បដាចារាថេរី នោះហើយ ក៏លាងជើង ហើយចូលទៅក្នុងទីសមគួរ ប្រកប រឿយ ៗ នូវសមថធម៌ បានធ្វើនូវ (កិច្ចក្នុង) ពុទ្ធសាសនា ។ ក្នុងបឋមយាមនៃរាត្រី ពួកព្រះថេរីក៏បានរឭកឃើញនូវបុព្វជាតិ ក្នុងមជ្ឈិមយាមនៃរាត្រី បានជម្រះនូវទិព្វចក្ខុ ក្នុងបច្ឆិមយាមនៃរាត្រី ក៏បានទម្លាយនូវគំនរងងឹត ។ ពួកព្រះថេរីទាំងនោះ ក្រោកឡើង ថ្វាយបង្គំបាទា (នៃបដាចារាថេរី ហើយពោលថា) ពាក្យប្រៀន ប្រដៅរបស់នាង យើងបានធ្វើតាមហើយ ពួកទេវតានៅក្នុងឋាន ត្រៃត្រិង្ស (ហែហម) ព្រះឥន្ទ្រ ដែលបានឈ្នះក្នុងសង្គ្រាមយ៉ាង ណា ពួកយើង ជាអ្នកមានវិជ្ជា ៣ មិនមានអាសវៈ នឹងនៅហែហម (នាងយ៉ាងនោះ) ។ ពួកភិក្ខុនីជាថេរី ចំនួន ៣០ រូបនេះ បានធ្វើ ឲ្យច្បាស់លាស់នូវព្រះអរហត្ត ក្នុងសំណាក់នៃបដាចារាថេរី ។

[៣១៤] កាលពីដើម អាត្មាអញជាស្រីទុគ៌ត ជាស្រីមេម៉ាយ មិន មានកូន ព្រាត់ប្រាសចាកមិត្រ ចាកញាតិទាំងឡាយ មិនដែល បានបាយ និងសំពត់ (បរិភោគប្រើប្រាស់គ្រប់គ្រាន់) ទេ ។

១៦៨



បត្តំ ទណ្ឌំ ច គណ្ហិត្វា ភិក្ខមានា កុលាកុលំ
សីតុណ្ហេន ច ឧយ្ហន្តី សត្ត វស្សានិ ចារិហំ ។
ភិក្ខុនឹ បុន ទិស្វាន អន្នបានស្ស លាភិនឹ
ឧបសង្កម្ម អវោចំ បព្វជឹ អនគារិយំ ។
សា ច មំ អនុកម្បាយ បព្វាជេសិ បដាចារា
តតោ មំ ឱវទិត្វាន បរមត្ថេ និយោជយិ ។
តស្សាហំ វចនំ សុត្វា អកាសឹ អនុសាសនឹ
អមោឃោ អយ្យាយ ឱវាទោ តេវិជ្ជម្ហិ អនាសវា ។

ចន្ទា ។

បញ្ចកនិបាតោ សមត្តោ ។

១៦៨



*អាត្មាអញកាន់ភាជន៍ដីនិងឈើច្រត់ ដើរសូមអំពីត្រកូលមួយទៅកាន់ត្រកូលមួយ ត្រូវត្រជាក់និងក្តៅបៀតបៀន ដើរទៅអស់ ៧ ឆ្នាំ ។ លុះកាលជាខាងក្រោយមក អាត្មាអញបានឃើញភិក្ខុនី (បដាចារាថេរី) ជាស្រីបានបាយនិងទឹក ហើយចូលទៅនិយាយ សូមបួសក្នុងធម្មវិន័យ ។ ឯបដាចារាភិក្ខុនីនោះ បានបំបួសអាត្មាអញ ដោយសេចក្តីអនុគ្រោះ ខាងក្រោយអំពីនោះមក លោកបានទូន្មានអាត្មាអញ ដឹកនាំក្នុងប្រយោជន៍យ៉ាងសំខាន់ ។ អាត្មាអញបានស្តាប់ពាក្យរបស់លោកក៏បានធ្វើតាមពាក្យប្រៀនប្រដៅ ឯឱវាទរបស់ព្រះថេរីជាម្ចាស់មិនឥតអំពើឡើយ ខ្ញុំជាអ្នកមានវិជ្ជា ៣ មិនមានអាសវៈ ។*

ចន្ទាថេរី ។

ចប់ បញ្ចកនិបាត ។

---

# ថេរីគាថាយ ឆក្កនិបាតោ

[៣១៨] យស្ស មគ្គំ ន ជានាសិ អាគតស្ស គតស្ស វា
តំ កុតោ អាគតំ បុត្តំ មម បុត្តោតិ រោទសិ ។
មគ្គញ្ច ខោស្ស ជានាសិ អាគតស្ស គតស្ស វា
ន នំ សមនុសោចេសិ ឯវំធម្មា ហិ បាណិនោ ។
អយាចិតោ តតោគច្ឆិ អននុញ្ញាតោ ឥតោ គតោ
កុតោចិ នូន អាគន្ត្វា វសិត្វា កតិបាហកំ ។
ឥតោបិ អញ្ញេនគតោ តតោ អញ្ញេន គច្ឆតិ
បេតោ មនុស្សរូបេន សំសរន្តោ គមិស្សតិ
យថាគតោ តថា គតោ កា តត្ថ បរិទេវនា ។
អព្ពុយ្ហិ វត មេ សល្លំ ទុទ្ទសំ ហទយនិស្សិតំ
យា មេ សោកបរេតាយ បុត្តសោកំ ព្យបានុទិ ។

# ថេរីគាថា ឆក្កនិបាត

[៣១៥] នាងមិនដឹងផ្លូវរបស់សត្វណា ដែលមក ឬទៅទេ ហើយយំរកកូន ដែល(មិនដឹងជា)មកអំពីទីណានោះថា ឱកូនអាត្មាអញអើយ ។ ទុកជានាងដឹងផ្លូវរបស់កូននោះ ដែលមក ឬទៅ ក៏មិនគប្បីសោករកកូននោះឡើយ ព្រោះសត្វមានយ៉ាងនេះជាធម្មតា ។ (សត្វនោះ) មិនមានអ្នកណាមួយអង្វរ ឲ្យមកអំពីបរលោកនោះ ទាំងមិនមានអ្នកណាមួយអនុញ្ញាតឲ្យទៅអំពីលោកនេះឡើយ ទំនងជាមកអំពីទីណាមួយ (មាននរកជាដើម) មកអាស្រ័យនៅ (ក្នុងទីនេះ ) អស់ពីរបីថ្ងៃ ។ សត្វសូម្បីទៅអំពីភពនេះ មកកាន់ភពដទៃ ទៅអំពីភពនោះ ទៅកាន់ភពដទៃ ចែកឋានទៅហើយ ដោយសភាពជាមនុស្ស នឹងអន្ទោលទៅ បើមកយ៉ាងណា ក៏ទៅយ៉ាងនោះ ការខ្សឹកខ្សួល ព្រោះតែសត្វនោះ មានប្រយោជន៍អ្វី ។

លោកម្ចាស់បានដកព្រួញគឺសេចក្តីសោក ដែលឃើញដោយកម្រ អាស្រ័យនូវហឫទ័យរបស់ខ្ញុំ លោកម្ចាស់បានបន្ទោបង់សេចក្តីសោកព្រោះកូនរបស់ខ្ញុំ ដែលត្រូវសេចក្តីសោកគ្របសង្កត់ហើយ ។

សាធុ អព្វុឡ្ហសល្លាហំ　　និច្ឆាតា បរិនិព្វុតា
ពុទ្ធំ ធម្មញ្ច សង្ឃញ្ច　　ឧបេមិ សរណំ មុនឹ ។

បញ្ចសតា បដាចារា ។

[៣១៦] បុត្តសោកេនាហំ អដ្ដា　　ខិត្តចិត្តា វិសញ្ញិនី
នគ្គា បកិណ្ណកេសី ច　　ពេធំ តេន(១) វិចារិហំ ។
វីថិសង្ការកូដេសុ　　សុសានេ រថិយាសុ ច
អចរឹ តីណិ វស្សានិ　　ខុប្បិចាសាសមប្បិតា ។
អថទ្ទសាមិ សុគតំ　　នគរំ មិថិលំ គតំ
អទន្តានំ ទមេតារំ　　សម្ពុទ្ធំ អកុតោភយំ ។
សចិត្តំ បដិលទ្ធាន　　វន្ទិត្វាន ឧបាវិសឹ
សោ មេ ធម្មមទេសេសិ　　អនុកម្បាយ គោតមោ ។
តស្ស ធម្មំ សុណិត្វាន　　បព្វជឹ អនគារិយំ
យុញ្ជន្តី សត្ថុ វចនេ　　សច្ឆាកាសឹ បទំ សិវំ ។

---
១ ឱ. ម. តេន តេន ។

ក្នុងថ្ងៃនេះ ខ្ញុំនោះ មានព្រួញរដកហើយ មិនមានសម្រេកគម្មាន មានទុក្ខរលត់ហើយ ខ្ញុំសូមដល់នូវព្រះពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ។

បដាចារាថេរី ៥០០[១] ។

[៣១៦] អាត្មាអញត្រូវសេចក្តីសោកព្រោះកូនបៀតបៀនហើយ មានចិត្តរាយមាយ ប្រាសចាកសញ្ញា មានកាយអាក្រាត មានសក់រាត់រាយ អាត្មាអញដើរទ្រហោយំ ។ អាត្មាអញពោរពេញដោយសេចក្តីស្រេកឃ្លាន បានដើរទៅលើគំនរសម្រាមក្បែរថ្នល់ផង ក្នុងព្រៃស្មសានផង ក្នុងច្រករហកផង អស់ ៣ ឆ្នាំ ។ ក្នុងកាលជាខាងក្រោយមក អាត្មាអញបានចួបប្រទះនឹងព្រះសុគត ព្រះអង្គទូន្មាននូវពួកសត្វដែលមានខ្លួនមិនទាន់បានទូន្មាន ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង មិនមានភ័យអំពីទីណា កំពុងស្តេចទៅកាន់ក្រុងមិថិលា ។ អាត្មាអញ ត្រឡប់បាននូវចិត្តជាប្រក្រតី ហើយក៏ចូលទៅជិតថ្វាយបង្គំ ឯព្រះគោតមនោះ បានសម្តែងធម៌ដល់អាត្មាអញ ដោយសេចក្តីអនុគ្រោះ ។ លុះអាត្មាអញបានស្តាប់ធម៌ របស់ព្រះអង្គហើយ ក៏បានបួសក្នុងធម្មវិន័យ ប្រកបព្យាយាមក្នុងសាសនានៃព្រះសាស្តា បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបទ ដ៏ជាទីក្សេម ។

១ បានជាហៅបដាចារាដែរ ព្រោះបានស្តាប់ឱវាទរបស់នាងបដាចារាថេរី ។

សព្វេ សោកា សមុច្ឆិន្នា បហីនា ឯតទន្តិកា
បរិញ្ញាតា ហិ មេ វត្ថូ យតោ សោកាន សម្ភវោ ។

វាសិដ្ឋី ។

[៣១៧] ទហរា ត្វំ រូបវតី អហំបិ ទហរោ យុវា
បញ្ចង្គិកេន តុរិយេន ឯហិ ខេមេ រមាមសេ ។
ឥមិនា បូតិកាយេន អាតុរេន បភង្គុនា
អដ្ដិយាមិ ហរាយាមិ កាមតណ្ហា សមូហតា ។
សត្តិសូលូបមា កាមា ខន្ធានំ អធិកុដ្ដនា
យំ ត្វំ កាមរតឹ ព្រូសិ អរតិទានិ សា មមំ ។
សព្វត្ថ វិហតា នន្ទិ តមោក្ខន្ធោ បទាលិតោ
ឯវំ ជានាហិ បាបិម និហតោ ត្វមសិ អន្តក ។
នក្ខត្តានិ នមស្សន្តា អគ្គឹ បរិចរំ វនេ
យថាភុច្ចមជានន្តា ពាលា សុទ្ធឹ អមញ្ញថ ។

សេចក្តីសោកទាំងឡាយទាំងពួង អាត្មាអញផ្តាច់ផ្តិលហើយ បាន លះបង់ហើយ ឲ្យមានទីបំផុតត្រឹមព្រះអរហត្តនេះ ព្រោះថាវត្ថុទាំង-ឡាយដែលជាដែនកើតនៃសេចក្តីសោក អាត្មាអញកំណត់ហើយ ។

វាសិដ្ឋីថេរី ។

[៣១៧] ហៃនាងខេមា នាងនៅក្មេង ជាស្រីមានរូប យើងសោតក៏នៅក្មេង កំលោះ នាងចូរមក យើងនឹងត្រេកត្រអាលដោយតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ។

អាត្មានឿយណាយ ធុញទ្រាន់ ដោយកាយស្អុយ ដែលមានជំងឺជានិច្ច ពុកផុយនេះ កាមតណ្ហា អាត្មាបានដកចេញហើយ ។ កាមទាំងឡាយ មានឧបមាដោយលំពែងនិងអណ្តោត ជាទីកាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកនិយាយចំពោះតម្រេកក្នុងកាមណាឥឡូវនេះ តម្រេកក្នុងកាមនោះ មិនជាទីត្រេកអរនៃអាត្មាទេ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ចេញហើយ គំនរងងឹត អាត្មាក៏បានទម្លាយហើយ ម្នាលមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯងអាត្មាបានកម្ចាត់ចេញហើយ ។ ពួកជនពាល មិនដឹងតាមពិត សំពះនក្ខត្តឫក្សទាំងឡាយ បូជាភ្លើងក្នុងព្រៃ ហើយសម្គាល់ថាជាការបរិសុទ្ធ ។

អហញ្ច ខោ ធមស្សន្តី សម្ពុទ្ធំ បុរិសុត្តមំ
បរិមុត្តា សព្វទុក្ខេហិ សត្ថុសាសនការិកា ។

ខេមា ។

[៣១៨] អលង្កតា សុវសនា មាលិនី ចន្ទនោក្ខិតា
សព្វាភរណសញ្ឆន្នា ទាសីគណបុរក្ខិតា ។
អន្នំ បានំ ច អាទាយ ខជ្ជំ ភោជ្ជំ អនប្បកំ
គេហតោ និក្ខមិត្វាន ឧយ្យានមភិហារយឹ ។
តត្ថ រមិត្វា កីឡិត្វា អាគច្ឆន្តី សកំ ឃរំ
វិហារំ ទដ្ឋុំ បាវិសឹ សាកេតេ អញ្ជនំ វនំ ។
ទិស្វាន លោកបជ្ជោតំ វន្ទិត្វាន ឧបាវិសឹ
សោ មេ ធម្មមទេសេសិ អនុកម្បាយ ចក្ខុមា ។
សុត្វា ច ខោ មហេសិស្ស សច្ចំ សម្បដិវិជ្ឈហំ
តត្ថេវ វិរជំ ធម្មំ ផុសយឹ អមតំ បទំ ។

ចំណែកខាងអាត្មា នមស្ការព្រះសម្ពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា បានរួចស្រឡះហើយចាកទុក្ខទាំងពួង ។

ខេមាថេរី ។

[៣១៨] អាត្មាអញមានខ្លួនស្អិតស្អាង មានគ្រឿងស្លៀកពាក់ល្អ ទ្រទ្រង់ផ្កាកម្រង លាបស្រឡាបដោយខ្លឹមចន្ទន៍ បិទបាំងជិតដោយគ្រឿងអាភរណៈគ្រប់យ៉ាង មានពួកទាសីហែហមហើយ ។ អាត្មាអញ បានយកបាយទឹក បង្អែមនឹងចម្អាបដ៏ច្រើន ចេញទៅអំពីគ្រឹហា នាំចូលទៅកាន់ឧទ្យាន ។ អាត្មាអញត្រេកអរ លេងក្នុងឧទ្យាននោះ រួចហើយក៏មកកាន់ផ្ទះរបស់ខ្លួន បានឃើញវិហារ ហើយក៏ចូលទៅកាន់វិហារ ក្នុងព្រៃអញ្ជន ជិតក្រុងសាកេត ។ អាត្មាអញបានឃើញព្រះពុទ្ធ ជាប្រទីបនៃលោក ហើយចូលទៅថ្វាយបង្គំឯព្រះអង្គជាបុគ្គលមានចក្ខុ បានសម្តែងធម៌ដល់អាត្មាអញដោយសេចក្តីអនុគ្រោះ ។ លុះអាត្មាអញបានស្តាប់ធម៌របស់ព្រះមហេសីហើយ ក៏បានចាក់ធ្លុះនូវសច្ចៈ បានសម្រេចនូវនិព្វានបទ ឈ្មោះអមតៈ ជាធម៌មិនមានធូលី គឺកិលេស ក្នុងវិហារនោះឯង ។

ថេរីគាថាយ ឆក្កនិបាតោ

តតោ វិញ្ញាតសទ្ធម្មា បព្វជឹ អនគារិយំ
តិស្សោ វិជ្ជា អនុប្បត្តា អមោឃំ ពុទ្ធសាសនំ ។

សុជាតា ។

[៣១៩] ឧច្ចេ កុលេ អហំ ជាតា ពហុវិត្តេ មហទ្ធនេ
វណ្ណរូបេន សម្បន្នា ធីតា មេឃិស្ស[១] អត្រជា ។
បត្ថិតា រាជបុត្តេហិ សេដ្ឋិបុត្តេហិ គិជ្ឈិតា
បិតុ មេ បេសយិ ទូតំ ទេថ មយ្ហំ អនោបមំ ។
យត្តកំ តុលិតា ឯសា តុយ្ហំ ធីតា អនោបមា
តតោ អដ្ឋគុណំ ទស្សំ ហិរញ្ញរតនានិ ច ។
សាហំ ទិស្វាន សម្ពុទ្ធំ លោកជេដ្ឋំ អនុត្តរំ
តស្ស បាទានិ វន្ទិត្វា ឯកមន្តំ ឧបាវិសឹ ។
សោ មេ ធម្មមទេសេសិ អនុកម្បាយ គោតមោ
និសិន្នា អាសនេ តស្មឹ ផុសយឹ តតិយំ ផលំ ។

---
១ ឱ. ម. មជ្ឈស្ស ។

លំដាប់ពីនោះ អាត្មាអញបានដឹងច្បាស់នូវព្រះសទ្ធម្ម ហើយបួសក្នុងធម្មវិន័យ បានសម្រេចត្រៃវិជ្ជា ព្រះពុទ្ធសាសនា មិនឥតអំពើឡើយ ។

សុជាតាថេរី ។

[៣១៩] អាត្មាអញ កើតក្នុងត្រកូលខ្ពង់ខ្ពស់ ដែលមានគ្រឿងឧបករណ៍ជាទីរីករាយច្រើន មានទ្រព្យច្រើន ជាស្រីបរិបូណ៌ដោយសម្បុរនិងរូប ជាធីតាបង្កើតនៃសេដ្ឋី ឈ្មោះមេឃិ ។ ពួកព្រះរាជបុត្រក៏ចង់បាន ពួកសេដ្ឋិបុត្រក៏ជាប់ចិត្ត ទើបប្រើទូតទៅ (ក្នុងសំណាក់) បិតារបស់អាត្មាអញ (ថា) សូមអ្នកឲ្យនាងអនោបមាដល់ខ្ញុំ ។ ធីតារបស់អ្នកឈ្មោះអនោបមានុ៎ះ (លក្ខណញ្ញូជន) កាត់ថ្លៃចំនួនទ្រព្យប៉ុន្មាន ខ្ញុំសូមជូនប្រាក់និងកែវជា ៨ គុណ អំពីទ្រព្យនោះ ។ អាត្មាអញនោះបានឃើញព្រះសម្ពុទ្ធ ជាចម្បងនៃលោក ព្រះអង្គប្រសើរបំផុត ក៏ចូលទៅក្នុងទីសមគួរ ថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ។ ព្រះគោតមនោះ បានសម្តែងធម៌ដល់អាត្មាអញដោយសេចក្តីអនុគ្រោះ អាត្មាអញអង្គុយលើអាសនៈនោះ ហើយបានសម្រេចនូវផលទី ៣ ។

តតោ កេសានិ ឆេត្វាន បព្វជឹ អនគារិយំ

សាជ្ជ មេ សត្តមី រត្តិ យតោ តណ្ហា វិសោសិតា ។

អនោបមា ។

[៣២០] ពុទ្ធវីរ នមោ ត្យត្ថុ សព្វសត្តានមុត្តម

យោ មំ ទុក្ខា បមោចេសិ អញ្ញញ្ច ពហុកំ ជនំ ។

សព្វទុក្ខំ បរិញ្ញាតំ ហេតុតណ្ហា វិសោសិតា

ភាវិតដ្ឋង្គិកោ[១] មគ្គោ និរោធោ ផុសិតោ មយា ។

មាតា បុត្តោ បិតា ភាតា អយ្យិកា ច បុរេ អហុំ

យថាភុច្ចំ អជានន្តី សំសរិហំ អនិព្វិសំ

ទិដ្ឋោ ហិ មេ សោ ភគវា អន្តិមោយំ សមុស្សយោ

វិក្ខីណោ ជាតិសំសារោ នត្ថិទានិ បុនព្ភវោ ។

អារទ្ធវីរិយេ បហិតត្តេ និច្ចំ ទឡ្ហបរក្កមេ

សមគ្គេ សាវកេ បស្ស ឯសា ពុទ្ធាន វន្ទនា ។

---

១ ឱ. ម. អរិយដ្ឋង្គិកោ ។

លំដាប់ពីនោះមក អាត្មាអញបានកោរសក់ទាំងឡាយ ហើយបួសក្នុងធម្មវិន័យ រាត្រីគម្រប់ ៧ របស់អាត្មាអញ ក្នុងថ្ងៃនេះ ជារាត្រីដែលតណ្ហារីងស្ងួត ។

អនោបមាថេរី ។

[៣២០] បពិត្រព្រះពុទ្ធ មានព្យាយាម អ្នកខ្ពង់ខ្ពស់ ជាងសព្វសត្វទាំងឡាយ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ដែលទ្រង់បានប្រោសខ្ញុំព្រះអង្គនិងជនដទៃច្រើនគ្នា ឲ្យរួចចាកទុក្ខ ។ សេចក្តីទុក្ខទាំងពួង ខ្ញុំព្រះអង្គបានកំណត់ដឹងហើយ តណ្ហាជាដើមចម (នៃទុក្ខ) ខ្ញុំព្រះអង្គបានធ្វើឲ្យរីងស្ងួតហើយ មគ្គប្រកបដោយអង្គ ៨ ខ្ញុំព្រះអង្គបានចម្រើនហើយ និរោធធម៌ ខ្ញុំព្រះអង្គបានសម្រេចហើយ ។ មាតាបិតា បុត្រ បងប្អូននិងជីដូនជីតា ដែលមានក្នុងកាលមុន ខ្ញុំព្រះអង្គក៏មិនដឹងតាមពិត មិនបាន (នូវទីពឹងក្នុងសមុទ្រគឺសង្សារ) បានអន្ទោលទៅ (យកកំណើតផ្សេងៗ) ព្រះមានព្រះភាគអង្គនោះ ខ្ញុំព្រះអង្គបានឃើញហើយ រាងកាយ (របស់ខ្ញុំព្រះអង្គ) នេះជាទីបំផុតហើយ ជាតិសង្សារអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមាន ។ សូមព្រះអង្គទតនូវពួកសាវ័ក អ្នកមានព្យាយាមតឹងតែងមានចិត្តស្ទុងទៅរកព្រះនិព្វាន មានព្យាយាមមាំជានិច្ច ជាអ្នកព្រមព្រៀងគ្នា នេះជាការថ្វាយបង្គំចំពោះព្រះពុទ្ធទាំងឡាយ ។

ពហូនំ វត អត្ថាយ　　មាយា ជនយិ គោតមំ
ព្យាធិមរណតុន្នានំ　　ទុក្ខក្ខន្ធំ ព្យបានុទិ ។

មហាបជាបតី គោតមី ។

[៣២១] កុត្តេ យជត្តំ បព្វជ្ជា　　ហិត្វា បុត្តំ សមុស្សយំ
តមេវ អនុព្រូហេហិ　　មា ចិត្តស្ស វសំ គមិ ។
ចិត្តេន វញ្ចិតា សត្តា　　មារស្ស វិសយេ រតា
អនេកជាតិសំសារំ　　សន្ធាវន្តិ អវិទ្ទសុ ។
កាមច្ឆន្ទញ្ច ព្យាបាទំ　　សក្កាយទិដ្ឋិមេវ ច
សីលព្វតបរាមាសំ　　វិចិកិច្ឆញ្ច បញ្ចមំ ។
សំយោជនានិ ឯតានិ　　បជហិត្វាន ភិក្ខុនី
ឱរម្ភាគមនីយានិ　　នយិទំ បុនរេហិសិ ។
រាគំ មានំ អវិជ្ជញ្ច　　ឧទ្ធច្ចញ្ច វិវជ្ជិយ
សំយោជនានិ ឆេត្វាន　　ទុក្ខស្សន្តំ ករិស្សសិ ។
ខេបេត្វា ជាតិសំសារំ　　បរិញ្ញាយ បុនព្ភវំ
ទិដ្ឋេវ ធម្មេ និច្ឆាតា　　ឧបសន្តា ចរិស្សសិ ។

គុត្តា ។

ឱន៎ ព្រះនាងមាយា បានបង្កើតព្រះគោតម ដើម្បីជាប្រយោជន៍ដល់ពួកជនច្រើនគ្នា (ព្រោះថា) ព្រះគោតមបានបន្ទោបង់នូវគំនរទុក្ខនៃពួកជន ដែលត្រូវព្យាធិនិងមរណៈចាក់ដោត ។

មហាបជាបតិគោតមីថេរី ។

[៣២១]ម្នាលនាងគុត្តា ការណ៍ដែលនាងលះបង់កូននិងគំនរទ្រព្យ ហើយបួសដើម្បីប្រយោជន៍ណា នាងចូរចម្រើនឲ្យរឿយៗ នូវប្រយោជន៍នោះឯង នាងកុំលុះអំណាចនៃចិត្តឡើយ ។ ពួកសត្វ ត្រូវចិត្តបញ្ឆោតហើយ ត្រេកអរក្នុងវិស័យនៃមារ មិនដឹងថា អាត្មាអញត្រាច់រង្គាត់ទៅកាន់សង្សារអស់ជាតិមិនតែមួយ ។ កាមច្ឆន្ទៈ ព្យាបាទៈ សក្កាយទិដ្ឋិ សីលព្វតបរាមាសៈ និងវិចិកិច្ឆាជាគម្រប់ ៥ ។ ម្នាលភិក្ខុនី លុះនាងលះនូវសំយោជនៈ ជាចំណែកខាងក្រោមទាំងនោះហើយ ទើបលែងវិលមកកាន់កាមភពនេះទៀត ។ នាងបើខំសង្កត់សង្កិនកាត់ផ្តាច់នូវសំយោជនៈទាំងឡាយ គឺរូបរាគៈ អរូបរាគៈ មានះ អវិជ្ជា ឧទ្ធច្ចៈហើយ នឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខបាន ។ នាងបើញុំាងជាតិសង្សារឲ្យអស់ ហើយកំណត់ដឹងនូវភពថ្មី នឹងទៅជាអ្នកមិនមានតណ្ហា ប្រព្រឹត្តស្ងប់រម្ងាប់ ក្នុងបច្ចុប្បន្ន ពិតប្រាកដបាន ។

គុត្តាថេរី ។

[៣៤២] ចតុក្ខត្តុំ បញ្ចក្ខត្តុំ វិហារា ឧបនិក្ខមឹ
អលទ្ធា ចេតសោ សន្តឹ ចិត្តេ អវសវត្តិនី ។
ភិក្ខុនឹ ឧបសង្កម្ម សក្កច្ចំ បរិបុច្ឆហំ
សា មេ ធម្មមទេសេសិ ធាតុអាយតនានិ ច
ចត្តារិ អរិយសច្ចានិ ឥន្ទ្រិយានិ ពលានិ ច
ពោជ្ឈង្គដ្ឋង្គិកំ មគ្គំ ឧត្តមត្ថស្ស បត្តិយា ។
តស្សាហំ វចនំ សុត្វា ករោន្តី អនុសាសនឹ
រត្តិយា បុរិមេ យាមេ បុព្វជាតិមនុស្សរឹ
រត្តិយា មជ្ឈិមេ យាមេ ទិព្វចក្ខុំ វិសោធយឹ
រត្តិយា បច្ឆិមេ យាមេ តមោក្ខន្ធំ បទាលយឹ
បីតិសុខេន ច កាយំ ផរិត្វា វិហរឹ តទា
សត្តមិយា បាទេ បសារេសឹ[១] តមោក្ខន្ធំ បទាលិយ ។

វិជយា ។

ឆក្កនិបាតោ សមត្តោ ។

១ ឱ. ម. បសារេមិ ។

[៣២២] អាត្មាអញមិនលុះអំណាចក្នុងភាវនាចិត្ត មិនបានសេចក្តីស្ងប់ចិត្ត បានចេញអំពីលំនៅ ៤ លើក ៥ លើក ។ អាត្មាអញបានចូលទៅរកភិក្ខុនី (ព្រះថេរីឈ្មោះខេមា) ហើយសាកសួរដោយគោរព លោកបានសម្តែងធម៌ គឺ ធាតុ អាយតនៈ អរិយសច្ច ៤ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គ អដ្ឋង្គិកមគ្គ ដល់អាត្មាអញ ដើម្បីដល់នូវប្រយោជន៍ដ៏ឧត្តម ។ លុះអាត្មាអញបានស្តាប់ពាក្យរបស់ភិក្ខុនីនោះហើយ ក៏បានធ្វើតាមពាក្យប្រៀនប្រដៅ របស់លោក ក្នុងបុរិមយាម នៃរាត្រី បានរឭកឃើញនូវបុព្វជាតិ ក្នុងមជ្ឈិមយាម នៃរាត្រី បានជម្រះនូវទិព្វចក្ខុ ក្នុងបច្ឆិមយាមនៃរាត្រីបានទម្លាយនូវគំនរងងឹត វេលានោះ អាត្មាអញបានជ្រួតជ្រាបកាយដោយបីតិនិងសុខៈ ទម្លាយនូវគំនរងងឹត ហើយលាតជើងទាំងគូ ក្នុងរាត្រីទី ៧ ។

វិជយាថេរី ។

ចប់ ឆក្កនិបាត ។

១៧៧

# ថេរីគាថាយ សត្តកនិបាតោ

[៣៦៣] មុសលានិ គហេត្វាន ធញ្ញំ កោដ្ដេន្តិ មាណវា
បុត្តទារានិ បោសេន្តា ធនំ វិន្ទន្តិ មាណវា ។
ឃដេថ ពុទ្ធសាសនេ យំ កត្វា នានុតប្បតិ
ខិប្បំ បាទានិ ធោវិត្វា ឯកមន្តំ និសីទថ ។
ចិត្តំ ឧបដ្ឋបេត្វាន ឯកគ្គំ សុសមាហិតំ
បច្ចវេក្ខថ សង្ខារេ បរតោ នោ ច អត្តតោ ។
តស្សាហំ វចនំ សុត្វា បដាចារានុសាសនឹ
បាទេ បក្ខាលយិត្វាន ឯកមន្តេ ឧបាវិសឹ ។
រត្តិយា បុរិមេ យាមេ បុព្វជាតិមនុស្សរឹ
រត្តិយា មជ្ឈិមេ យាមេ ទិព្វចក្ខុំ វិសោធយឹ ។
រត្តិយា បច្ឆិមេ យាមេ តមោក្ខន្ធំ បទាលយឹ
តេវិជ្ជា អថ វុដ្ឋាមិ កតា តេ អនុសាសនី ។
សក្កំវ ទេវា តិទសា សង្គាមេ អបរាជិតំ
បុរក្ខត្វា វិហារាមិ តេវិជ្ជម្ហិ អនាសវា ។

ឧត្តរា ។

# ថេរីគាថា សត្តកនិបាត

[៣២៣] ពួកមាណព កាន់អង្រែទាំងឡាយបុកស្រូវ ពួកមាណពរមែងបាននូវទ្រព្យ ចិញ្ចឹមកូននិងប្រពន្ធទាំងឡាយ ។ នាងទាំង-ឡាយចូរព្យាយាមធ្វើអំពើ ដែលធ្វើហើយ មិនក្តៅក្រហាយតាមក្រោយ ក្នុងព្រះពុទ្ធសាសនា ចូរលាងជើងទាំងឡាយ ឲ្យធាប់ហើយអង្គុយក្នុងទីសមគួរ ។ នាងទាំងឡាយ ចូរតាំងចិត្ត តម្កល់ឲ្យមាំ ឲ្យមានអារម្មណ៍តែមួយ ហើយពិចារណានូវសង្ខារទាំងឡាយថាជារបស់ដទៃ ទាំងមិនមែនជារបស់ខ្លួន ។

អាត្មាបានស្តាប់ពាក្យរបស់ព្រះថេរីនោះ គឺជាពាក្យប្រៀនប្រដៅរបស់ព្រះថេរីឈ្មោះបដាចារា ហើយបានលាងជើង រួចចូលទៅអង្គុយក្នុងទីសមគួរ ។ ក្នុងបុរិមយាមនៃរាត្រីអាត្មាបានរឭកឃើញនូវបុព្វជាតិ ក្នុងមជ្ឈិមយាមនៃរាត្រី អាត្មាបានជម្រះនូវទិព្វចក្ខុ ។ ក្នុងបច្ឆិមយាមនៃរាត្រី អាត្មាបានទម្លាយនូវគំនរងងឹត ជាស្រីបាននូវត្រៃវិជ្ជា បានក្រោកចេញ (អំពីអាសនៈ) ក្នុងកាលជាខាងក្រោយពាក្យប្រៀនប្រដៅ របស់លោកម្ចាស់ ខ្ញុំបានប្រព្រឹត្តហើយ ។ ពួកទេវតាក្នុងឋានត្រៃត្រិង្ស (ហែហម) នូវសក្កទេវរាជដែលឈ្នះក្នុងសង្គ្រាមយ៉ាងណា ខ្ញុំបាននូវត្រៃវិជ្ជា មិនមានអាសវៈក៏ហែហម (លោកម្ចាស់) យ៉ាងនោះដែរ ។

ឧត្តរាថេរី ។

[៣២៤] សតឹ ឧបដ្ឋបេត្វាន ភិក្ខុនី ភាវិតិន្ទ្រិយា
បដិវិជ្ឈឹ បទំ សន្តំ សង្ខារូបសមំ សុខំ ។
កឹ នុ ឧទ្ទិស្ស មុណ្ឌាសិ សមណី វិយ ទិស្សសិ
ន ច រោចេសិ បាសណ្ឌេ កិមិទំ ចរសិ មោមុហា ។
ឥតោ ពហិទ្ធា បាសណ្ឌា ទិដ្ឋិយោ ឧបនិស្សិតា
ន តេ ធម្មំ វិជានន្តិ ន តេ ធម្មស្ស កោវិទា ។
អត្ថិ សក្យកុលេ ជាតោ ពុទ្ធោ អប្បដិបុគ្គលោ
សោ មេ ធម្មមទេសេសិ ទិដ្ឋីនំ សមតិក្កមំ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។
តស្សាហំ វចនំ សុត្វា វិហរឹ សាសនេ រតា
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
សព្វត្ថ វិហតា នន្ទិ តមោក្ខន្ធោ បទាលិតោ
ឯវំ ជានាហិ បាបិម និហតោ ត្វមសិ អន្តក ។

ចាលា ។

[៣២៤] អាត្មាជាភិក្ខុនី បានចម្រើននូវឥន្ទ្រិយ ផ្គងស្មារតី បានចាក់ធ្លុះនូវព្រះនិព្វាន ជាទីស្ងប់ រម្ងាប់នូវសង្ខារ ជាសុខក្រៃលែង ។ នាងជាស្ត្រីកំណោរ ប្រាកដដូចជាសមណី តើឧទ្ទិសចំពោះលទ្ធិណា នាងមិនគាប់ចិត្តនឹងលទ្ធិទាំងឡាយ ហេតុអ្វីក៏នាងជាស្ត្រីវង្វេងប្រព្រឹត្តបែបនេះ ។

លទ្ធិទាំងឡាយ ខាងក្រៅអំពីសាសនានេះ អាស្រ័យនូវទិដ្ឋិទាំងឡាយ ពួកជន(ប្រកាន់លទ្ធិ)នោះ មិនដឹងច្បាស់នូវធម៌ ពួកជននោះមិនវាងវៃក្នុងធម៌ ។ មាន (ព្រះរាជបុត្រមួយអង្គ) កើតក្នុងសក្យត្រកូល បានត្រាស់ជាព្រះពុទ្ធ មិនមានបុគ្គលផ្ទឹមបាន ព្រះអង្គបានសម្តែងប្រាប់អាត្មានូវអរិយសច្ចធម៌ ជាធម៌ប្រព្រឹត្តកន្លងនូវទិដ្ឋិ គឺទុក្ខ ១ ហេតុនាំឲ្យកើតទុក្ខ ១ ទីដែលប្រព្រឹត្តកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ អាត្មាបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះអង្គហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាបានធ្វើហើយ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ហើយ គំនរងងឹត អាត្មាបានទម្លាយហើយ ម្នាលមារកំបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯងយើងកម្ចាត់ចេញហើយ ។

ចាលាថេរី ។

១៧៩

## ថេរីគាថាយ សត្តកនិបាតោ

[៣៦៤] សតិមតី ចក្ខុមតី    ភិក្ខុនី ភាវិតិន្ទ្រិយា
បដិវិជ្ឈឹ បទំ សន្តំ    អកាបុរិសសេវិតំ
កឹ នុ ជាតឹ ន រោចេសិ    ជាតោ កាមានិ ភុញ្ជតិ
ភុញ្ជាហិ កាមរតិយោ    មាហុ បច្ឆានុតាបិនី ។
ជាតស្ស មរណំ ហោតិ    ហត្ថបាទាន ឆេទនំ
វធពន្ធបរិក្ខេបំ[១]    ជាតោ ទុក្ខំ និគច្ឆតិ ។
អត្ថិ សក្យកុលេ ជាតោ    សម្ពុទ្ធោ អបរាជិតោ
សោ មេ ធម្មមទេសេសិ    ជាតិយា សមតិក្កមំ
ទុក្ខំ ទុក្ខសមុប្បាទំ    ទុក្ខស្ស ច អតិក្កមំ
អរិយដ្ឋង្គិកំ មគ្គំ    ទុក្ខូបសមគាមិនំ ។
តស្សាហំ វចនំ សុត្វា    វិហរឹ សាសនេ រតា
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។

---
១ ឱ. ម. វធពន្ធបរិក្លេសំ ។

[៣២៥] អាត្មាជាភិក្ខុនី មានស្មារតី មានចក្ខុគឺបញ្ញា មានឥន្ទ្រិយចម្រើន ហើយ បានចាក់ធ្លុះនូវព្រះនិព្វាន ជាទីស្ងប់ ដែលបុរសថោកទាប មិនដែលបានសេពហើយ ។

នាងមិនគាប់ចិត្តនឹងជាតិទេឬ សត្វដែលកើតហើយ តែងបរិ-ភោគកាមទាំងឡាយ នាងចូរបរិភោគនូវតម្រេកក្នុងកាមទាំងឡាយ កុំឲ្យមានសេចក្ដីស្ដាយក្រោយ ។

សេចក្ដីស្លាប់ និងការកាត់នូវដៃជើង រមែងមានដល់សត្វដែល កើតហើយ សត្វដែលកើតហើយរមែងដល់នូវសេចក្ដីទុក្ខ មានការ សម្លាប់និងការចងជាកំណត់ ។ មាន (ព្រះរាជបុត្រមួយព្រះអង្គ)កើត ក្នុងសក្យត្រកូល បានត្រាស់ជាព្រះពុទ្ធ ព្រះអង្គផ្ចាញ់នូវមារមាន កិលេសមារជាដើម ព្រះអង្គបានសម្ដែងប្រាប់អាត្មានូវអរិយសច្ចធម៌ ជាធម៌កន្លងនូវជាតិ គឺទុក្ខ ១ ហេតុនាំឲ្យកើតទុក្ខ ១ ទីដែលប្រព្រឹត្ត កន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាដំណើរទៅ កាន់ទីរំលត់ទុក្ខ ១ ។ អាត្មាបានស្ដាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជាអាត្មាបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាបានធ្វើហើយ ។

១៨០



សព្វត្ថ វិហតា នន្ទិ  តមោក្ខន្ធោ បទាលិតោ
ឯវំ ជានាហិ បាបិម  និហតោ ត្វមសិ អន្តក ។

ឧបចាលា ។

សត្តកនិបាតោ សមត្តោ ។

---

១៨០



សេចក្តីរីករាយ ក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ចេញហើយ គំនរងងឹត អាត្មាបានទម្លាយចេញហើយ ម្នាលមារកំបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯង យើងកម្ចាត់ចេញហើយ ។

ឧបចាលាថេរី ។

ចប់ សត្តកនិបាត ។

១៨១

# ថេរីគាថាយ អដ្ឋកនិបាតោ

[៣៦៦] ភិក្ខុនី សីលសម្បន្នា ឥន្ទ្រិយេសុ សុសំវុតា
អធិគច្ឆេ បទំ សន្តំ អសេចនកមោជវំ ។
តាវតឹសា ច យាមា ច តុសិតា ចាបិ ទេវតា
និម្មានរតិនោ ទេវា យេ ទេវា វសវត្តិនោ
តត្ថ ចិត្តំ បណិធេហិ យត្ថ តេ វុសិតំ បុរេ ។
តាវតឹសា ច យាមា ច តុសិតា ចាបិ ទេវតា
និម្មានរតិនោ ទេវា យេ ទេវា វសវត្តិនោ
កាលំ កាលំ ភវាភវំ សក្កាយស្មឹ បុរក្ខតា
អវីតិវត្តា សក្កាយំ ជាតិមរណសារិនោ ។
សព្វោ អាទីបតោ លោកោ សព្វោ លោកោ បរិទីបតោ
សព្វោ បជ្ជលិតោ លោកោ សព្វោ លោកោ បកម្បិតោ។
អកម្បិតំ អតុលិយំ អបុថុជ្ជនសេវិតំ
ពុទ្ធោ ធម្មំ មេ ទេសេសិ តត្ថ មេ និរតោ មនោ ។

# ថេរីគាថា អដ្ឋកនិបាត

[៣៦៦] ភិក្ខុនី បរិបូណ៌ដោយសីល សង្រួមដោយប្រពៃ ក្នុងឥន្ទ្រិយទាំងឡាយ គប្បីបាននូវព្រះនិព្វាន ជាទីស្ងប់ មានឱជៈមិនប្រេបូកប្រេបល់ដោយវត្ថុអ្វីមួយ ។

ពួកទេវតាណា នៅក្នុងឋានតាវត្តិង្សក្តី នៅក្នុងឋានយាមៈក្តី នៅក្នុងឋានតុសិតក្តី ពួកទេវតា នៅក្នុងឋាននិម្មានរតីក្តី ពួកទេវតា នៅក្នុងឋានបរនិម្មិតវសវត្តីក្តី នាងចូរតាំងចិត្តទៅរកពួកទេវតាទាំងនោះ ដែលនាងធ្លាប់នៅហើយក្នុងកាលមុន ។

ពួកទេវតាណា នៅក្នុងឋានតាវត្តិង្សក្តី នៅក្នុងឋានយាមៈក្តី នៅក្នុងឋានតុសិតក្តី ពួកទេវតានៅក្នុងឋាននិម្មានរតីក្តី ពួកទេវតា នៅក្នុងឋានបរនិម្មិតវសវត្តីក្តី (ទេវតាទាំងនោះចេញ) អំពីភពទៅកាន់ភពសព្វ ៗ កាល តម្កល់នៅក្នុងសក្កាយគឺខន្ធបញ្ចកៈ មិនប្រព្រឹត្តកន្លងនូវសក្កាយ ជាអ្នកអន្ទោលទៅកាន់ជាតិនិងមរណៈ ។ លោកទាំងមូលឆេះ លោកទាំងមូលច្រាលរន្ទាល លោកទាំងមូលសន្ធោសន្ធៅ លោកទាំងមូលញាប់ញ័រ (ដោយភ្លើង ១១ មានរាគៈជាដើម ) ។ ព្រះពុទ្ធបានសម្តែងធម៌ប្រាប់អាត្មា ជាធម៌ដែលមិនកម្រើក មិនមានអ្វីផ្ទឹមបាន ដែលបុថុជ្ជនសេព មិនបានហើយ ចិត្តរបស់អាត្មាត្រេកអរចំពោះ ក្នុងធម៌នោះ ។

តស្សាហំ វចនំ សុត្វា      វិហរឹ សាសនេ រតា
តិស្សោ វិជ្ជា អនុប្បត្តា      កតំ ពុទ្ធស្ស សាសនំ ។
សព្វត្ថ វិហតា នន្ទិ      តមោក្ខន្ធោ បទាលិតោ
ឯវំ ជានាហិ បាបិម      និហតោ ត្វមសិ អន្តក ។

សីសូបចាលា ។

អដ្ឋកនិបាតោ សមត្តោ ។

អាត្មាបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះអង្គហើយ ក៏ត្រេកអរក្នុងសាសនា ត្រៃវិជ្ជា អាត្មាបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាបានធ្វើហើយ ។ សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ចេញហើយ គំនរងងឹត អាត្មាបានទម្លាយចេញហើយ ម្នាលមារកំបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯង យើងកម្ចាត់ចេញហើយ ។

សីសូបចាលាថេរី ។

ចប់ អដ្ឋកនិបាត ។

១៨៣

# ថេរីគាថាយ នវកនិបាតោ

[៣៦៧] មា សុ តេ វឌ្ឍ លោកម្ហិ វនថោ អហុ កុទាចនំ

មា បុត្តក បុនប្បុនំ អហុ ទុក្ខស្ស ភាគិមា ។

សុខំ ហិ វឌ្ឍ មុនយោ អនេជា ឆិន្នសំសយា

សីតិភូតា ទមប្បត្តា វិហរន្តិ អនាសវា ។

តេហានុចិណ្ណំ ឥសីភិ មគ្គំ ទស្សនបត្តិយា

ទុក្ខស្សន្តកិរិយាយ ត្វំ វឌ្ឍ អនុព្រូហយ ។

វិសារទាវ ភណសិ ឯតមត្ថំ ជនេត្តិ មេ

មញ្ញាមិ នូន មាមិកេ វនថោ តេ ន វិជ្ជតិ ។

យេ កេចិ វឌ្ឍ សង្ខារា ហីនឧក្កដ្ឋមជ្ឈិមា

អណូបិ អណុមត្តោបិ វនថោ មេ ន វិជ្ជតិ ។

សព្វេ មេ អាសវា ខីណា អប្បមត្តស្ស ឈាយតោ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

# ថេរីគាថា នវកនិបាត

[៣៦៧] ហៃវឌ្ឍៈ ព្រៃ គឺកិលេស កុំមានដល់លោក ក្នុងកាលណា ៗ ឡើយ ហៃកូន លោកកុំមានចំណែកនៃសេចក្តីទុក្ខរឿយ ៗ ឡើយ ។ ហៃវឌ្ឍៈ ព្រោះថា អ្នកប្រាជ្ញទាំងឡាយ លោកមិនមានតណ្ហា កាត់សេចក្តីសង្ស័យ ជាអ្នកត្រជាក់ត្រជំ ដល់នូវសេចក្តីរាបសា មិនមានអាសវៈ តែងនៅជាសុខ ។ ហៃវឌ្ឍៈ ចូរលោកចម្រើនឲ្យរឿយ ៗ ដើម្បីដល់ នូវការឃើញមគ្គ ដែលពួកឥសីនោះ ធ្លាប់សន្សំមកហើយ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខ ។

បពិត្រមាតា លោកក្លៀវក្លា ប្រាប់សេចក្តីនេះ ដល់ខ្ញុំ បពិត្រមាតា ខ្ញុំសម្គាល់ថា ព្រៃ គឺកិលេស របស់លោក មិនមានដោយពិត ។

ហៃវឌ្ឍៈ សង្ខារទាំងឡាយ ឯណានីមួយដ៏ថោកទាប ឧត្តម និងកណ្តាល ព្រៃ គឺកិលេស សូម្បីតូចឆ្មារក្តី សូម្បីបន្តិចបន្តួចក្តី នៃខ្ញុំមិនមានឡើយ ។ ខ្ញុំជាអ្នកមិនប្រមាទ បានចម្រើនឈាន មានអាសវៈទាំងពួងអស់ហើយ ត្រៃវិជ្ជា ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

ឧឡារំ វត មេ មាតា    បតោទំ សមវស្សរិ
បរមត្ថសញ្ហិតា គាថា    យថាបិ អនុកម្បិកា ។
តស្សាហំ វចនំ សុត្វា    អនុសិដ្ឋឹ ជនេត្តិយា
ធម្មសំវេគមាបាទឹ    យោគក្ខេមស្ស បត្តិយា ។
សោហំ បធានបហិតត្តោ    រត្តិន្ទិវមតន្ទិតោ
មាតរា ចោទិតោ សន្តោ    អផុសឹ សន្តិមុត្តមំ ។

វឌ្ឍមាតា ។

នវកនិបាតោ សមត្តោ ។

មាតារបស់ខ្ញុំ បានចាក់ជន្លួញ ដ៏លើសលុប គឺគាថាប្រកប ដោយប្រយោជន៍យ៉ាងសំខាន់ ៗ ដោយពិត ដូចជាពួកជនអ្នក អនុគ្រោះ ។ ខ្ញុំបានស្តាប់ពាក្យប្រៀនប្រដៅរបស់លោកដែលជា មាតាបង្កើតហើយក៏ដល់នូវធម្មសង្វេគ ដើម្បីដល់នូវព្រះនិព្វានជាទី ក្សេមចាកយោគៈ ។ ខ្ញុំនោះ មានចិត្តស្ទុះទៅរកព្រះនិព្វាន ដោយ សម្មប្បធាន មិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ ជាអ្នកដែលមាតា ដាស់តឿនហើយ ក៏ស្ងប់រម្ងាប់បានសម្រេចនូវព្រះនិព្វានដ៏ខ្ពង់ខ្ពស់ ។

វឌ្ឍមាតាថេរី ។

ចប់ នវកនិបាត ។

# ថេរីគាថាយ ឯកាទសកនិបាតោ

[៣២៨] កល្យាណមិត្តតា មុនិនា លោកំ អាទិស្ស វណ្ណិតា
កល្យាណមិត្តេ ភជមានោ អបិ ពាលោ បណ្ឌិតោ អស្ស ។
ភជិតព្វា សប្បុរិសា បញ្ញា តថាបិ វឌ្ឍតិ
ភជន្តានំ ភជមានោ យោ កោចិ ខត្តិយានិកោ
សប្បុរិសេ សព្វេហិបិ ទុក្ខេហិ ចេវ មោចយេ[១]
ទុក្ខញ្ចេវ វិជានេយ្យ ទុក្ខស្ស ច សមុទយំ
និរោធជ្ឈង្គិកមគ្គំ[២] ចត្តារិ អរិយសច្ចានិ ច ។
ទុក្ខោ ឥត្ថិភាវោ អក្ខាតោ បុរិសទម្មសារថិនា ។
សបត្តិកម្បិ ហិ ទុក្ខំ អប្បេកច្ចា សកឹ វិជាតាយោ
គលកេ អបកន្តន្តិ សុខុមាលិយោ វិសានិ ខាទន្តិ
ជនមារកមជ្ឈគតា ឧភោ ព្យសនានុភោន្តិបិ ។
ឧបវិជញ្ញា គច្ឆន្តី អទ្ទសាហំ បតឹ មតំ
បន្ថេ វិជាយិត្វាន អប្បត្តាហំ សកំ គេហំ ។

១ ឱ. ម. មុច្ចេយ្យ ។ ២ ឱ. ម. និរោធញ្ច អដ្ឋង្គិកំ មគ្គំ ។

# ថេរីគាថា ឯកាទសកនិបាត

[៣២៨] ភាពនៃកល្យាណមិត្តចំពោះសត្វលោក ព្រះមុនី ទ្រង់សរសើរហើយ បុគ្គលកាលគប់រកនូវពួកកល្យាណមិត្ត សូម្បីខ្លួនជាបុគ្គលពាល ក៏គង់បានទៅជាបណ្ឌិត ។ បុគ្គលគួរគប់រកនូវពួកសប្បុរស ប្រាជ្ញានៃពួកបុគ្គលដែលរាប់រក (នូវសប្បុរស) រមែងចម្រើនដោយពិត បុគ្គល ឯណានីមួយ មានក្សត្រជាដើម កាលគប់រកនូវពួកសប្បុរស គប្បីរួចចាកទុក្ខទាំងអស់ផង គប្បីដឹងនូវអរិយសច្ចទាំង ៤ ផង គឺ ទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ ទុក្ខនិរោធសច្ច ១ មគ្គសច្ច ប្រកបដោយអង្គ ៨ ប្រការ ១ ។ ព្រះមានព្រះភាគ ជាសារថីទូន្មាននូវបុរស ទ្រង់ត្រាស់ថា ឥត្ថីភាព នាំមកនូវសេចក្តីទុក្ខ ។ មែនពិត ការនៅរួមជាមួយនឹងស្វាមី នាំមកនូវទុក្ខ ស្រីពួកខ្លះ សម្រាលបុត្រតែម្តង ដាច់បំពង់ស្បូន (ស្លាប់) ក៏មាន (ស្រីពួកខ្លះ) ជាសុខុមាលជាតិ មានគភ៌រវាងពាក់កណ្តាល ប្រាថ្នាសម្លាប់កូនក្នុងគភ៌ ស៊ីថ្នាំពិស ដល់នូវសេចក្តីវិនាស ទាំងពីរនាក់(កូននិងម្តាយ)ក៏មាន ។ ខ្ញុំកាលទៅរកទីសម្រាល (កូន) បានឃើញប្តីស្លាប់ ខ្ញុំទៅមិនទាន់ដល់ផ្ទះរបស់ខ្លួន ក៏សម្រាល (កូន) កណ្តាលផ្លូវ ។

ទ្វេ បុត្តា កាលកតា បតិ ច បន្ថេ មតោកបណិកាយ
មាតា បិតា ច ភាតា ច ឌយ្ហន្តិ ឯកចិតកាយំ ។
ខីណាកុលម្ហិ[១] កបណេ អនុភូតំ តេ ទុក្ខំ អបរិមាណំ
អស្សូ ច តេ បវត្តំ ហិ ពហូនិ ជាតិសហស្សានិ ។
បស្សឹ[២] តំ សុសានមជ្ឈេ អថោបិ ខាទិតានិ បុត្តមំសានិ
ហតកុលិកា សព្វគរហិតា មតបតិកា អមតំ អធិគច្ឆឹ ។
ភាវិតោ មេ អយំ មគ្គោ អរិយោដ្ឋង្គិកោ អមតគាមី
និព្វានំបិ សច្ឆិកតំ ធម្មាទាសំ អវេក្ខិំហំ[៣] ។
អហម្ហិ កន្តសល្លា ឱហិតភារា កតំ មេ ករណីយំ
កិសាគោតមី ថេរី សុវិមុត្តចិត្តា ឥមំ ភណីតិ ។

កីសាគោតមី ។

ឯកាទសកនិបាតោ សមត្តោ ។

---

១ ឱ. ខីណកុលីនេ ។ ម. ខីណកុលិនេ ។ ២ ម. បស្សិតុំ ។ ៣ ឱ. អបេក្ខិហំ ។

កូនទាំងពីរក៏ធ្វើមរណកាល ប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងផ្លូវ ខ្ញុំជាស្រីកំព្រា ឯមាតា បិតា និងបងប្អូនប្រុស ក៏ត្រូវគេដុតក្នុងជើងថ្ករជាមួយគ្នា ។ នាងរងទុក្ខប្រមាណមិនបាន ក្នុងត្រកូលដែលអស់ភោគសម្បត្តិ ជាត្រកូលកំព្រា ទឹកភ្នែករបស់នាងប្រព្រឹត្តទៅអស់ពាន់ជាតិជាច្រើន ។ ខ្ញុំឃើញនាង (កើតជា)ចចកញី ស៊ីសាច់មនុស្សក្នុងកណ្តាលព្រៃស្មសាន មួយទៀតសាច់កូនក៏នាងបានស៊ីហើយ (ក្នុងអត្តភាពនេះ) ខ្ញុំមានវង្សត្រកូលសាបសូន្យ ត្រូវអ្នកផងតិះដៀល មានប្តីក៏ស្លាប់ តែបានត្រាស់ដឹងនូវអមតៈ ។ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានឈ្មោះអមតៈនេះ ខ្ញុំបានចម្រើនហើយ ទាំងព្រះនិព្វាន ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយដែរ ខ្ញុំបានឃើញហើយនូវកញ្ចក់គឺធម៌ ។ ខ្ញុំមានសរគឺរាគាទិក្កិលេសកាត់ហើយ មានភារៈដាក់ចុះហើយ កិច្ចដែលគួរធ្វើ ខ្ញុំបានធ្វើរួចស្រេចហើយ នាងកីសាគោតមីថេរី មានចិត្តផុតស្រឡះហើយ (ចាកកិលេស) បាន ពោលនូវសេចក្តីនេះ ។

កីសាគោតមីថេរី ។

ចប់ ឯកាទសកនិបាត ។

---

# ថេរីគាថាយ ទ្វាទសកនិបាតោ

[៣២៩] ឧភោ មាតា ច ធីតា ច    មយំ អសុំ សបត្តិយោ
តស្សា មេ អហុ សំវេគោ    អព្ភុតោ លោមហំសនោ ។
ធិរត្ថុ កាមា អសុចី    ទុគ្គន្ធា ពហុកណ្ដកា
យត្ថ មាតា ច ធីតា ច    សភរិយា មយំ អហុំ ។
កាមេស្វាទីនវំ ទិស្វា    នេក្ខម្មំ ទដ្ឋុខេមតោ[១]
សា បព្វជឹ រាជគហេ    អគារស្មា អនគារិយំ ។
បុព្វេនិវាសំ ជានាមិ    ទិព្វចក្ខុំ វិសោធិតំ
ចេតោបរិយញ្ញាណញ្ច    សោតធាតុ វិសោធិតា ។
ឥទ្ធិបិ មេ សច្ឆិកតា    បត្តោ មេ អាសវក្ខយោ
ឆ មេ អភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។
ឥទ្ធិយា អភិនិម្មិត្វា    ចតុរស្សំ រថំ អហំ
ពុទ្ធស្ស បាទេ វន្ទិត្វា    លោកនាថស្ស សិរីមតោ ។
សុបុប្ផិតគ្គំ ឧបគម្ម បាទបំ
ឯកា តុវំ តិដ្ឋសិ រុក្ខមូលេ
ន ចាបិ តេ ទុតិយោ អត្ថិ កោចិ
ន ត្វំ ពាលេ ភាយសិ ធុត្តកានំ ។

១ ឱ. ទឡ្ហខេមតោ ។

# ថេរីគាថា ទ្វាទសកនិបាត

[៣២៩] យើងទាំងពីរនាក់ គឺមាតានិងធីតា មានប្តីជាមួយគ្នា (ភរិយារួមប្តី) សេចក្តីតក់ស្លុត សេចក្តីព្រឺរោម អស្ចារ្យចំឡែក កើតមានដល់ខ្ញុំនោះ ។ ថ្វីយ កាមទាំងឡាយ ជារបស់មិនស្អាត មានក្លិនអាក្រក់ដូចជាបន្លាច្រើនយ៉ាង ដែលនាំយើងទាំងពីរនាក់ គឺមាតា និងធីតាឲ្យជាភរិយាជាមួយគ្នា ។ លុះខ្ញុំឃើញទោសក្នុងកាមទាំងឡាយហើយឃើញនេក្ខម្មៈថាជារបស់ក្សេមទើបចេញចាកផ្ទះក្នុងក្រុងរាជគ្រឹះ កួលកាន់ផ្នួស ។ ខ្ញុំដឹងនូវបុព្វេនិវាស ឯទិព្វចក្ខុ និងចេតោបរិយញ្ញាណ ខ្ញុំជម្រះហើយ ទិព្វសោតធាតុ ខ្ញុំជម្រះហើយដែរ ។ ទាំងឫទ្ធិ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ការអស់ទៅនៃអាសវៈ ខ្ញុំបានដល់ហើយ អភិញ្ញា ៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ ខ្ញុំនិម្មិតនូវរថទឹមសេះ ៤ ដោយឫទ្ធិ ហើយថ្វាយបង្គំព្រះបាទទាំងគូនៃព្រះពុទ្ធ ដ៏មានសិរី ជាទីពឹងនៃសត្វលោក ។ នាងជាស្រីម្នាក់ឯងចូលមកកាន់ដើមរាំងភ្នំ ដែលនៅចុងមានផ្ការីកស្គុះស្គាយ ហើយឈរនៅទៀបគល់ឈើ បុគ្គលណាមួយជាគម្រប់ពីររបស់នាងក៏មិនមាន នៃស្ត្រីពាល នាងមិនខ្លាចពួកអ្នកលេងទេឬ ។

សតំ សហស្សានំបិ ធុត្តកានំ

សមាគតា ឯទិសកា ភវេយ្យុំ

លោមំ ន ឥញ្ជេ នបិ សម្បវេធេ

កឹ មេ តុវំ មារ ករិស្សសេកោ ។

ឯសា អន្តរធាយាមិ    កុច្ឆឹ វា បវិសាមិ តេ

ភមុកន្តរេបិ តិដ្ឋាមិ    តិដ្ឋន្តឹ មំ ន ទក្ខសិ ។

ចិត្តម្ហិ វសីភូតាហំ    ឥទ្ធិបាទា សុភាវិតា

ឆ មេ អភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនំ ។

សត្តិសូលូបមា កាមា    ខន្ធានំ អធិកុដ្ដនា

យំ ត្វំ កាមរតឹ ព្រូសិ    អរតិទានិ សា មម ។

សព្វត្ថ វិហតា នន្ទិ    តមោក្ខន្ធោ បទាលិតោ

ឯវំ ជានាហិ បាបិម    និហតោ ត្វមសិ អន្តកាតិ ។

ឧប្បលវណ្ណា ។

ទ្វាទសកនិបាតោ សមត្តោ ។

បើទុកជាអ្នកលេងទាំងឡាយ មួយរយឬមួយពាន់ ជាបុគ្គលមានសភាពយ៉ាងនេះមកចួបជុំគ្នា ក៏រោម(របស់យើង) មិនព្រឺព្រួច មិនញាប់ញ័រ នៃមារ អ្នកម្នាក់ឯង នឹងធ្វើនូវអ្វីដល់យើងកើត។ យើងនេះនឹងបាត់ទៅ ឬនឹងចូលទៅ កាន់ផ្ទៃរបស់អ្នកក៏បាន ឬបើទុកជាឈរនៅក្បែរចន្លោះចិញ្ចើមរបស់អ្នក ក៏អ្នកមើលមិនឃើញយើងឈរដែរ ។ យើងជាស្ត្រីស្ទាត់ក្នុងអធិចិត្ត ឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយដោយប្រពៃ អភិញ្ញា ៦ យើងបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនា យើងបានធ្វើហើយ ។ កាមទាំងឡាយប្រៀបដោយលំពែងនិងឈើស្រួច សម្រាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកពោលនូវតម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះមិនមែនជាតម្រេករបស់យើងឡើយ ។ សេចក្តីរីករាយក្នុងកាមទាំងអស់ យើងបានកម្ចាត់ចេញហើយ គំនរនៃងងឹត (អវិជ្ជា) យើងបានទម្លាយចោលហើយ នៃមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ នៃមារថោកទាប អ្នក យើងកម្ចាត់ចេញហើយ ។

ឧប្បលវណ្ណាថេរី ។

ចប់ ទ្វាទសកនិបាត ។

---

១៨៩

# ថេរីគាថាយ សោឡសកនិបាតោ

[៣៣០] ឧទកហារី អហំ សីតេ    សទា ឧទកមោតរឹ
អយ្យានំ ទណ្ឌភយភីតា    វាចាទោសភយដ្ដិតា ។
កស្ស ព្រាហ្មណ ត្វំ ភីតោ    សទា ឧទកមោតរិ
វេធមានេហិ គត្តេហិ    សីតំ វេទយសេ ភុសំ ។
ជានន្តី ច តុវំ ភោតិ    បុណ្ណិកេ បរិបុច្ឆសិ
ករោន្តំ កុសលំ កម្មំ    រុន្ធន្តំ កម្មបាបកំ ។
យោ ច វុឌ្ឍោ ទហរោ វា    បាបកម្មំ បកុព្វតិ
ឧទកាភិសេចនា សោបិ    បាបកម្មា បមុច្ចតិ ។
កោ នុ តេ ឥទមក្ខាសិ    អជានន្តស្ស ជានកោ
ឧទកាភិសេចនា នាម    បាបកម្មា បមុច្ចតិ
សគ្គំ នូន គមិស្សន្តិ    សព្វេ មណ្ឌូកកច្ឆបា
នាគា ច សុំសុមារា ច    យេ ចញ្ញេ ឧទកេ ចរា ។
ឱរព្ភិកា សូករិកា    មច្ឆិកា មិគពន្ធកា
ចោរា ច វជ្ឈឃាតា ច    យេ ចញ្ញេ ឧទកេ ចរា ។
ឧទកាភិសេចនា តេមិ    បាបកម្មា បមុច្ចរេ ។
សចេ ឥមា នទិយោ តេ    បាបំ បុព្វេ កតំ វិហេយ្យុំ[១]

១ ម. ពហុំ ។

# ថេរីគាថា សោឡសកនិបាត

[៣៣០] ខ្ញុំជាស្ត្រីអ្នកដងទឹក មានការខ្លាចទណ្ឌភ័យនៃជនជាម្ចាស់ទាំងឡាយ ត្រូវភ័យអំពីវាចានិងទោសបៀតបៀន ហើយចុះទឹករាល់ពេល ក្នុងកាលត្រជាក់រងា ។ ម្នាលព្រាហ្មណ៍ អ្នកខ្លាចអ្នកណា ទើបចុះទឹករាល់ពេល មានខ្លួនញាប់ញ័រ ទទួលរងរងាដ៏ក្រៃលែង ។

ម្នាលនាងបុណ្ណិកាដ៏ចម្រើន នាងដឹង (ថាខ្ញុំ) កំពុងធ្វើកុសលកម្ម ជាគ្រឿងបិទនូវបាបកម្មដែរ ម្តេចក៏សួរដេញដោល ។ បុគ្គលណា ទោះចាស់ក្តី ក្មេងក្តី ធ្វើបាបកម្ម បុគ្គលនោះ រមែងរួចចាកបាបកម្ម ព្រោះការស្រោចស្រប់ដោយទឹក ។

អ្នកល្ងង់ណាហ្ន៎ បាននិយាយពាក្យនេះ ទៅរកអ្នកដែលល្ងង់ដែរ (ថាបុគ្គល) រមែងរួចចាកបាបកម្ម ព្រោះការស្រោចស្រប់ដោយទឹក (បើដូច្នោះ) កង្កែប អណ្តើក នាគ ក្រពើ ឬសត្វដទៃណាមួយ ដែលត្រាច់ទៅក្នុងទឹកទាំងអស់ នឹងទៅកាន់ឋានសួគ៌ដោយពិត ។ ពួកជនអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក នេសាទត្រី អ្នកចាប់ម្រឹគ ពួកចោរ ពួកពេជ្ឈឃាត ឬពួកជនឯទៀត ដែលមានកម្មដ៏លាមក ពួកជនទាំងនោះ ក៏រួចចាកបាបកម្ម ព្រោះការស្រោចស្រប់ដោយទឹក ។ ប្រសិនបើស្ទឹងទាំងនោះ អាចបន្សាត់ចោលនូវបាប ដែលអ្នកធ្វើក្នុងកាលមុនបាន

បុញ្ញំបិមា វហេយ្យុំ តេ　　តេន ត្វំ បរិពាហិរោ អស្ស ។
យស្ស ព្រាហ្មណ ត្វំ ភីតោ　　សទា ឧទកមោតរិ
តមេវ ព្រហ្មេ មាកាសិ　　មា តេ សីតំ ឆវឹ ហនេ ។
កុមគ្គបដិបន្នំ មំ　　អរិយមគ្គំ សមានយិ
ឧទកាភិសេចនំ ភោតិ　　ឥមំ សាដកំ ទទាមិ តេ ។
តុយ្ហេវ សាដកោ ហោតុ　　នាហមិច្ឆាមិ សាដកំ ។
សចេ ភាយសិ ទុក្ខស្ស　　សចេ តេ ទុក្ខមប្បិយំ
មាកាសិ បាបកំ កម្មំ　　អាវិ វា យទិ វា រហោ ។
សចេ ច បាបកំ កម្មំ　　ករិស្សសិ ករោសិ វា
ន តេ ទុក្ខា បមុត្យត្ថិ　　ឧបេច្ចាបិ បលាយតោ ។
សចេ ភាយសិ ទុក្ខស្ស　　សចេ តេ ទុក្ខមប្បិយំ
ឧបេហិ ពុទ្ធំ សរណំ　　ធម្មំ សង្ឃញ្ច តាទិនំ
សមាទិយាហិ សីលានិ　　តន្តេ មោក្ខាយ ហេស្សតិ[១] ។
ព្រហ្មពន្ធុ បុរេ អាសឹ　　អជ្ជម្ហិ សច្ចំ ព្រាហ្មណោ
តេវិជ្ជោ វេទសម្បន្នោ　　សោត្ថិយោ ចម្ហិ ន្ហាតកោ ។

បុណ្ណិកា ។

សោឡសកនិបាតោ សមត្តោ ។

---

១ ឱ. ម. អត្ថាយ ហេហិតិ ។

ស្ទឹងទាំងនោះ ក៏អាចបន្សាត់ចោលនូវបុណ្យរបស់អ្នកបានដែរ ព្រោះហេតុនោះ ខ្លួនអ្នកនឹងទៅជាបុគ្គលក្រៅស្រឡះ ។ ម្នាលព្រាហ្មណ៍ អ្នកខ្លាច ចំពោះបាបកម្មណា ហើយចុះត្រាំទឹក គ្រប់ ៗ ពេល ម្នាលព្រាហ្មណ៍ អ្នកកុំធ្វើនូវបាបនោះវិញ កុំ(ចុះត្រាំទឹក) ឲ្យរងាបៀតបៀននូវសម្បុរសេរីរៈរបស់អ្នកឡើយ ។

នាងដឹកនាំខ្ញុំដែលដើរផ្លូវខុស ឲ្យដើរទៅតាមផ្លូវដ៏ប្រសើរ ម្នាលនាងដ៏ចម្រើន ខ្ញុំសូមជូនសាដកសម្រាប់ស្រោចស្រប់ទឹកនេះដល់នាង ។

សំពត់សាដកចូរនៅជារបស់អ្នកដដែលចុះ ខ្ញុំមិនត្រូវការសំពត់សាដក (របស់អ្នក)ទេ ។ បើអ្នកខ្លាចសេចក្តីទុក្ខបើសេចក្តីទុក្ខមិនជាទីស្រឡាញ់នៃអ្នកទេ អ្នកកុំធ្វើបាបកម្ម ទោះបីក្នុងទីវាលក្តី ក្នុងទីកំបាំងក្តី ។ បើអ្នកនឹងធ្វើ ឬកំពុងធ្វើនូវបាបកម្ម សូម្បីអ្នកហោះរត់ទៅក៏មិនរួចចាកទុក្ខ ។ បើអ្នកខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខមិនជាទីស្រឡាញ់របស់អ្នកទេ អ្នកចូរដល់នូវព្រះពុទ្ធជាតាទិបុគ្គលផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងចុះ ចូរសមាទានសីលទាំងឡាយចុះ ការដល់នូវទីពឹងនិងការសមាទានសីលនោះ នឹងញ៉ាំងអ្នកឲ្យរួចចាក (ទុក្ខ) ។

ពីដើមខ្ញុំជាព្រាហ្មណ៍តែពូជ ថ្ងៃនេះខ្ញុំជាព្រាហ្មណ៍ពិត មានត្រៃវិជ្ជា បរិបូណ៌ដោយវេទ ជាអ្នកមានសួស្តី ជាអ្នកលាងបាប ។

បុណ្ណិកាថេរី ។

ចប់ សោឡសកនិបាត ។

# ថេរីគាថាយ វីសតិនិបាតោ

[៣៣១] កាឡកា ភមរវណ្ណសទិសា
វេល្លិតគ្គា មម មុទ្ធជា អហុំ
តេ ជរាយ សាណវាកសទិសា
សច្ចវាទិវចនំ អនញ្ញថា ។
វាសិតោវ សុរភិករណ្ឌកោ
បុប្ផបូរំ មម ឧត្តមង្គភូតោ
តំ ជរាយ សសលោមគន្ធិកំ
សច្ចវាទិវចនំ អនញ្ញថា ។
កាននំវ សហិតំ សុរោបិតំ
កោច្ឆសូចិវិចិត្តគ្គសោភិតំ
តំ ជរាយ វិរឡំ តហឹ តហឹ
សច្ចវាទិវចនំ អនញ្ញថា ។
សណ្ហកន្ធកសុវណ្ណមណ្ឌិតំ[១]
សោភតេ សុ វេណីហិ អលង្កតំ
តំ ជរាយ ខលិតំ[២] សិរំ កតំ

---

១ កណ្ហកន្ធកំ សុវណ្ណមណ្ឌិតន្តិ អដ្ឋកថាយំ ទិស្សតិ ។ ២ ឱ. ខលតិ ។

# ថេរីគាថា វីសតិនិបាត

[៣៣១] កាលពីដើមសក់របស់ខ្ញុំមានចុងង មានពណ៌ខ្មៅ ប្រាកដស្មើដោយពណ៌នៃស្វាបកន្ទង់ ឥឡូវនេះ សក់ទាំងឡាយនោះប្រាកដស្មើដោយសម្បកធ្មៃ និងសម្បកក្រចៅ ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ (កាលពីដើម) សំណុំសក់របស់ខ្ញុំ ពេញដោយផ្កា ហាក់ដូចជាប្រអប់ដាក់គ្រឿងក្រអូបដែលគេអប់ (ឥឡូវនេះ) សំណុំសក់នោះ មានក្លិនដូចជាក្លិន នៃរោមទន្សាយ ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ (កាលពីដើម) សក់របស់ខ្ញុំវិចិត្រដោយក្រាសនិងស្នៀតសក់ល្អលើសលប់ ដូចជាព្រៃឫស្សីដុះស្អាប់ល្អ (ឥឡូវនេះ) សក់នោះ ល្បោះរង្វើល ក្នុងសីសប្រទេសនោះ ៗ ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ (កាលពីដើមសក់របស់ខ្ញុំ) ល្អិត មានក្លិនក្រអូប ស្អិតស្អាងដោយក្រាសមាស ប្រដាប់ដោយផ្នួងទាំងឡាយដ៏ល្អត្រកាល (ឥឡូវនេះ) សក់នោះថ្លែក ព្រោះតែជរា

សច្ចវាទិវចនំ អនញ្ញថា ។

ចិត្តការសុកតាវ លេខិតា

សោភតេ សុ ភមុកា បុរេ មម

តា ជរាយ វលីហិ បលម្ពិតា

សច្ចវាទិវចនំ អនញ្ញថា ។

ភស្សរា សុរុចិរា យថា មណិ

នេត្តាហេសុំ អភិនីលមាយតា

តេ ជរាយភិហតា ន សោភតេ

សច្ចវាទិវចនំ អនញ្ញថា ។

សណ្ហតុង្គសទិសី ច[១] នាសិកា

សោភតេ សុ អភិយោព្វនំ បតិ

សា ជរាយ ឧបកូលិតា វិយ

សច្ចវាទិវចនំ អនញ្ញថា ។

កង្កណំវ[២] សុកតំ សុនិដ្ឋិតំ

សោភតេ សុ មម ភណ្ណចាឡិយោ បុរេ

តា ជរាយ វលីហិ បលម្ពិតា

១ សណ្ហាបិត្តសទិសី វាតិ អដ្ឋកថាយំ ទិស្សតិ ។ ២ កកាណំវាតំ អដ្ឋកថាយំ ទិស្សតិ ។

ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ (កាលពីដើម) ចិញ្ចើមទាំងឡាយ របស់ខ្ញុំ ស្អាតល្អ ដូចជាគំនូសដែលជាងរចនាល្អ (ឥឡូវនេះ) ចិញ្ចើមទាំងនោះ យុរយារ ដោយអាការជ្រួញជ្រីវ ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ (កាលពីដើម) ភ្នែកទាំងឡាយ មានសម្បុរថ្លា ខៀវស្រងាត់ រុងរឿង ល្អក្រឡង់ ដូចជាកែវមណី (ឥឡូវនេះ) ភ្នែកទាំងនោះ ត្រូវជរាញាំញី ក៏បែរជាមិនល្អ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ ច្រមុះ (របស់ខ្ញុំ) ប្រាកដស្មើដោយដំបារមាស ដែលគេមូរដ៏ល្អ ល្អក្នុងកាលនៃខ្លួននៅក្រមុំ (ឥឡូវនេះ) ច្រមុះនោះ ហាក់ដូចជាទ្រុឌទ្រោម ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ស្លឹកត្រចៀកទាំងឡាយ របស់ខ្ញុំល្អ ហាក់ដូចជាដំបារមាស ដែលជាងធ្វើល្អហើយ ដែលសម្រេចហើយដោយប្រពៃ (ឥឡូវនេះ) ស្លឹកត្រចៀកទាំងនោះ យុរយារ ដោយអាការជ្រួញជ្រីវ ព្រោះតែជរា

សច្ចវាទិវចនំ អនញ្ញថា ។
បត្តលិមកុលវណ្ណសទិសា
សោភតេ សុ ទន្តា បុរេ មម
តេ ជរាយ ខណ្ឌា យវបីតកា
សច្ចវាទិវចនំ អនញ្ញថា ។
កាននស្មឹ វនសណ្ឌចារិណី[១]
កោកិលាវ មធុរំ និកូជិតំ
តំ ជរាយ ខលិតំ តហឹ តហឹ
សច្ចវាទិវចនំ អនញ្ញថា ។
សណ្ហកម្ពុគីវ[២] សុប្បមជ្ជិតា
សោភតេ សុ គីវា បុរេ មម
សា ជរាយ ភគ្គា វិនាមិតា[៣]
សច្ចវាទិវចនំ អនញ្ញថា ។
វដ្ដបលិឃសទិសោបមា ឧភោ
សោភតេ សុ ពាហា បុរេ មម

---

១ កាននម្ហិ វនសណ្ឌវាទិនីតិ អដ្ឋកថាយំ ទិស្សតិ ។ ២ ឱ. សណ្ហកម្បុរិវ ។ ម. សណ្ហកម្ពុរិវ ។ ៣ ឱ. វិនាសិតា ។

ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ធ្មេញទាំងឡាយ របស់ខ្ញុំល្អណាស់ ប្រាកដស្មើដោយពណ៌នៃផ្កាច្រនៀងក្រពុំ (ឥឡូវនេះ) ធ្មេញទាំងនោះ បាក់ មានពណ៌លឿង ដូចជាស្រូវដំណើប ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ (កាលពីដើម) សម្តីដែលខ្ញុំនិយាយ ពីរោះ ដូចជាសម្តីមេតាវៅ ដែលហើរទៅកាន់ព្រៃស្រោង ក្នុងព្រៃ (ឥឡូវនេះ) សម្តីនោះស្អកស្អា ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ករបស់ខ្ញុំល្អ ដូចជាស័ង្ខមាស ដែលជាងខាត់ហើយដោយល្អ (ឥឡូវនេះ) កនោះបាក់ ឱន ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើមដើមដៃទាំងពីររបស់ខ្ញុំ ល្អដូចជាសសរខឿន ដែលជាងលញ់ហើយ

តា ជរាយ យថា ចាដលិប្បលិតា[១]
សច្ចវាទិវចនំ អនញ្ញថា ។
សណ្ហមុទ្ទិកា សុវណ្ណមណ្ឌិតា
សោភតេ សុ ហត្ថា បុរេ មម
តេ ជរាយ តថា មូលមូលិកា
សច្ចវាទិវចនំ អនញ្ញថា ។
បីនវដ្ដសហិតុគ្គតា ឧភោបិ
សោភតេ សុ ថនកា បុរេ មម
ថេវីតិ វ[២] លម្ពន្តេនោទកា
សច្ចវាទិវចនំ អនញ្ញថា ។
កញ្ចនស្ស ផលកំវ សុមដ្ឋំ
សោភតេ សុ កាយោ បុរេ មម
សោ វលីហិ សុខុមាហិ ឱតតោ
សច្ចវាទិវចនំ អនញ្ញថា ។
នាគភោគសទិសោបមា ឧភោ
សោភតេ សុ ឩរូ បុរេ មម
តា ជរាយ យថា វេឡុនាឡិយោ

១ ឱ. បាដលំ ទុព្វលិកា ។ ២ ឱ. តេរិន្ទីវ ។

(ឥឡូវនេះ) ដើមដៃទាំងនោះ ដូចជាស័ង្ខបែកហើយ ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ដៃទាំងឡាយរបស់ខ្ញុំមានចិញ្ចៀនល្អ ប្រដាប់ដោយមាស សមរម្យល្អ(ឥឡូវនេះ) ដៃទាំងនោះ ដូចជាមើមដំឡូងយារ ព្រោះតែជរាព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ដោះទាំងពីរ របស់ខ្ញុំ ពេញលេញ មូលក្បុំកៀកគ្នា មានសណ្ឋានដ៏ត្រង់ ល្អណាស់ (ឥឡូវនេះ ដោះទាំងនោះ) មិនមានទឹក (ជ្រាយ) បាក់សំយុងចុះ ដូចជាបំពង់ទឹក ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម កាយរបស់ខ្ញុំល្អស្រស់ ដូចជាផែនក្តារមាស ដែលគេខាត់ហើយដោយប្រពៃ (ឥឡូវនេះ) កាយនោះប្រែប្រួល ដោយអាការជ្រួញជ្រីវដ៏ល្អិត ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ភ្លៅទាំងពីររបស់ខ្ញុំ ល្អល្អះ ដូចជាប្រមោយនៃដំរីដ៏ប្រសើរ (ឥឡូវនេះ) ភ្លៅទាំងនោះ ដូចជាថ្នាំងឫស្សី ព្រោះតែជរា

សច្ចវាទិវចនំ អនញ្ញថា ។
សណ្ហនូបុរសុវណ្ណមណ្ឌិតា
សោភតេ សុ ជង្ឃា បុរេ មម
តា ជរាយ តិលទណ្ឌការិវ
សច្ចវាទិវចនំ អនញ្ញថា ។
តូលបុណ្ណសទិសោបមា ឧភោ
សោភតេ សុ បាទា បុរេ មម
តេ ជរាយ ផុដិកា វលីមតា
សច្ចវាទិវចនំ អនញ្ញថា ។
ឯទិសោ អហុ អយំ សមុស្សយោ
ជជ្ជរោ ពហុទុក្ខានមាលយោ
សោបលេបបតិតោ ជរាឃរោ
សច្ចវាទិវចនំ អនញ្ញថា ។

អម្ពបាលី ។

[៣៣២] សមណាតិ ភោតិ មំ វិបស្សិ សមណាតិ បដិពុជ្ឈសិ
សមណានមេវ កិត្តេសិ សមណី នូន ភវិស្សសិ ។
វិបុលំ អន្នញ្ច បានញ្ច សមណានំ បវេច្ឆសិ

ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ស្មង់ទាំងឡាយរបស់ខ្ញុំ ប្រដាប់ដោយស្រោមជាវិការៈនៃមាស ដែលគេប៉ាក់ជិតស្និទ្ធល្អណាស់ (ឥឡូវនេះ) ស្មង់ទាំងនោះ ដូចជាដើមល្ង ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ កាលពីដើម ជើងទាំងពីរ របស់ខ្ញុំល្អ ដូចជាទ្រនាប់ជើង ដែលគេញាត់ហើយដោយប៉ុយរកា (ឥឡូវនេះ) ជើងទាំងនោះ ប្រេះបែកជ្រួញជ្រីវ ព្រោះតែជរា ព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។ គ្រោងកាយ មានសភាពដូច្នេះនេះ គ្រាំគ្រា ជាលំនៅនៃសេចក្តីទុក្ខច្រើនប្រការ គ្រោងកាយនោះ ដូចជាផ្ទះចាស់ដែលមានគ្រឿងបូកលាបជ្រុះចុះ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិត មិនប្រែប្រួល ។

អម្ពបាលីថេរី ។

[៣៣២] (បិតាសួរនាងរោហិណីថា) នែនាងដ៏ចម្រើន នាងជួបនឹងខ្ញុំ ពោលថាសមណៈ នាងភ្ញាក់ឡើងក៏ពោលថាសមណៈ នាងសរសើរចំពោះពួកសមណៈតែម្យ៉ាង នាងនឹងជាសមណីដោយពិត ។ នាងតែងផ្តត់ផ្គង់ បាយ ទឹក ដ៏ច្រើន ចំពោះពួកសមណៈ

១៩៦



រោហិណិទានិ បុច្ឆាមិ  កេន តេ សមណា បិយា។
អកម្មកាមា អលសា  បរទត្តូបជីវិនោ
អាសំសុកា សាទុកាមា  កេន តេ សមណា បិយា ។
ចិរស្សំ វត មំ តាត  សមណានំ បរិបុច្ឆសិ
តេសន្តេ កិត្តយិស្សាមិ  បញ្ញាសីលបរក្កមំ ។
កម្មកាមា អនលសា  កម្មសេដ្ឋស្ស ការកា
រាគទោសំ បជហន្តិ  តេន មេ សមណា បិយា ។
តីណិ បាបស្ស មូលានិ  ធុនន្តិ សុចិការិនោ
សព្វបាបំ បហីនេសំ  តេន មេ សមណា បិយា ។
កាយកម្មំ សុចិនេសំ  វចីកម្មញ្ច តាទិសំ
មនោកម្មំ សុចិនេសំ  តេន មេ សមណា បិយា ។
វិមលា សង្ខមុត្តាវ  សុទ្ធា សន្តរពាហិរា

នៃនាងរោហិណី ឥឡូវនេះ យើងសួរនាង ចុះនាងមានសេចក្តីស្រឡាញ់ពួកសមណៈ តើដោយហេតុដូចម្តេច ។ ពួកសមណៈជាអ្នកមិនប្រាថ្នាក្នុងការងារ ខ្ជិលច្រអូស រស់នៅដោយសារទានដែលបុគ្គលដទៃឲ្យ ជាអ្នកប៉ុនប៉ងប្រាថ្នាតែអាហារមានរសឆ្ងាញ់ទេ ចុះនាងមានសេចក្តីស្រឡាញ់ពួកសមណៈ តើដោយហេតុដូចម្តេច ។

(នាងរោហិណីតបថា) បពិត្របិតា អ្នកដេញដោលសួរខ្ញុំ អំពីពួកសមណៈអស់កាលយូរណាស់ហើយ ខ្ញុំនឹងសម្តែង នូវបញ្ញា សីលនិងសេចក្តីខ្មីឃ្មាត របស់សមណៈទាំងនោះ ដល់អ្នក ។ ពួកសមណៈជាអ្នកប្រាថ្នានូវការងារ មិនខ្ជិលច្រអូស ធ្វើចំពោះតែការងារដ៏ប្រសើរ រមែងលះបង់ នូវរាគៈ និងទោសៈ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈជាអ្នកធ្វើនូវកម្មស្អាត រមែងកម្ចាត់បង់នូវឫសនៃបាប[១] ទាំងបី សមណៈទាំងនុ៎ះ បានលះបង់នូវបាបទាំងអស់ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ កាយកម្មរបស់សមណៈទាំងនោះស្អាត វចីកម្មស្អាតដូចគ្នា ទាំងមនោកម្មរបស់សមណៈទាំងនោះក៏ស្អាត ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈ ប្រាសចាកមន្ទិល ស្អាតទាំងខាងក្នុងទាំងខាងក្រៅ ដូចជាស័ង្ខដែលខាត់ហើយ

១ ឫសគល់នៃបាប ៣ យ៉ាងគឺ លោភៈ ១ ទោសៈ ១ មោហៈ ១ ។ អដ្ឋកថា ។

១៩៧

## ថេរីគាថាយ វីសតិនិបាតោ

បុណ្ណា សុក្កោហិ ធម្មេហិ[១] តេន មេ សមណា បិយា ។
ពហុស្សុតា ធម្មធរា អរិយា ធម្មជីវិនោ
អត្ថំ ធម្មញ្ច ទេសេន្តិ តេន មេ សមណា បិយា ។
ពហុស្សុតា ធម្មធរា អរិយា ធម្មជីវិនោ
ឯកគ្គចិត្តា សតិមន្តោ តេន មេ សមណា បិយា ។
ទូរង្គមា សតិមន្តោ មន្តភាណី អនុទ្ធតា
ទុក្ខស្សន្តំ បជានន្តិ តេន មេ សមណា បិយា ។
យស្មា គាមា បក្កមន្តិ ន វិលោកេន្តិ កិញ្ចនំ
អនបេក្ខាវ គច្ឆន្តិ តេន មេ សមណា បិយា ។
ន តេសំ កោដ្ឋេ ឱសេន្តិ[២] ន កុម្ភី ន កឡោបិយំ
បរិនិដ្ឋិតមេសានា តេន មេ សមណា បិយា ។
ន តេ ហិរញ្ញំ គណ្ហន្តិ ន សុវណ្ណំ ន រូបិយំ

១ ឱ. ម. សុក្កាន ធម្មានំ ។ ២ ម. ឱបេន្តិ ។

ពេញដោយធម៌សទាំងឡាយ ខ្ញុំមានសេចក្តីស្រឡាញ់ ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈ ជាពហុស្សូត ទ្រទ្រង់នូវធម៌ ជាអរិយៈ រស់នៅដោយធម៌ តែងសម្តែងនូវអត្ថនិងធម៌ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈ ជាពហុស្សូត ទ្រទ្រង់នូវធម៌ ជាអរិយៈ រស់នៅដោយធម៌ មានចិត្តប្រសើរ មានអារម្មណ៍តែមួយ មានស្មារតី ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈទៅកាន់ទីឆ្ងាយបាន(តាមសេចក្តីពេញចិត្ត) មានស្មារតី ពោលដោយឧបាយប្រាជ្ញា មិនរាយមាយ តែងដឹងនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខ ខ្ញុំមានសេចក្តីស្រលាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈចៀសចេញទៅអំពីស្រុកណា រមែងមិនរមិលអ្វីមួយ (ក្នុងស្រុកនោះ) ចេញទៅឥតអាល័យ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ សមណៈទាំងនោះ មិនទុកដាក់ (សម្បត្តិ) ក្នុងជង្រុក មិនទុកដាក់ផ្នាំងអំបែង មិនទុកដាក់ល្អីកញ្ជើ ស្វែងរកចំពោះតែភោជន ដែលសម្រេចហើយ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ សមណៈទាំងនោះ មិនទទួលនូវហិរញ្ញវត្ថុ (កហាបណៈ) មិនទទួលនូវមាស មិនទទួលនូវប្រាក់

បច្ចុប្បន្នេន យាបេន្តិ　　តេន មេ សមណា បិយា ។

នានាកុលា បព្វជិតា　　នានាជនបទេហិ ច

អញ្ញមញ្ញំ បិយាយន្តិ　　តេន មេ សមណា បិយា ។

អត្ថាយ វត នោ ភោតិ　　កុលេ ជាតាសិ គេហិណិ

សទ្ធា ពុទ្ធេ ច ធម្មេ ច　　សង្ឃេ ច តិព្វគារវា ។

តុវំ ហេតំ បជានាសិ　　បុញ្ញក្ខេត្តំ អនុត្តរំ

អម្ហំបិ ឯតេ សមណា　　បដិគ្គណ្ហន្តិ ទក្ខិណំ

បតិដ្ឋិតោ ហេត្ថ យញ្ញោ　　វិបុលោ នោ ភវិស្សតិ ។

សចេ ភាយសិ ទុក្ខស្ស　　សចេ តេ ទុក្ខមប្បិយំ

ឧបេហិ ពុទ្ធំ សរណំ　　ធម្មំ សង្ឃញ្ច តាទិនំ

សមាទិយាហិ សីលានិ　　តន្តេ អត្ថាយ ហេហិតិ ។

ឧបេមិ ពុទ្ធំ សរណំ　　ធម្មំ សង្ឃញ្ច តាទិនំ

សមាទិយាមិ សីលានិ　　តំ មេ អត្ថាយ ហេហិតិ ។

ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយវត្ថុ ដែលកើតឡើងចំពោះមុខ ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។ ពួកសមណៈចេញអំពីត្រកូលផ្សេង ៗ អំពីជនបទផ្សេង ៗ ទៅបួស រមែងរាប់រកគ្នា ទៅវិញទៅមក ខ្ញុំមានសេចក្តីស្រឡាញ់ពួកសមណៈ ដោយហេតុនោះឯង ។

(បិតានិយាយថា) ម្នាលនាងរោហិណីដ៏ចម្រើន នាងកើតក្នុងត្រកូលនៃយើងដើម្បីប្រយោជន៍ពិត នាងជាស្ត្រីមានសទ្ធា មានសេចក្តីគោរពដ៏មុតមាំ ក្នុងព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ។ ដ្បិតនាងស្គាល់នូវបុញ្ញក្ខេត្តនុ៎ះ ជាបុញ្ញក្ខេត្តឧត្តមពិតមែន បើបានសមណៈទាំងនុ៎ះ ទទួលទក្ខិណាទានរបស់ខ្ញុំ ប្រហែលគ្រឿងបូជាដែលខ្ញុំតម្កល់ហើយ ចំពោះសមណៈទាំងនុ៎ះ នឹងមានផលបរិបូណ៌ ។

(នាងរោហិណីពោលថា) បើអ្នកខ្លាចទុក្ខ បើទុក្ខមិនជាទីស្រឡាញ់របស់អ្នកទេ អ្នកចូរដល់នូវព្រះពុទ្ធជាតាទិបុគ្គលផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ចូរសមាទានសីលទាំងឡាយចុះ ការដល់នូវទីពឹងនិងការសមាទានសីលនោះនឹងមានប្រយោជន៍ដល់អ្នក ។

(បិតាពោលថា) ខ្ញុំសូមដល់នូវព្រះពុទ្ធ ជាតាទិបុគ្គលផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមសមាទានសីលទាំងឡាយ ការដល់ទីពឹងនិងសមាទានសីលនុ៎ះ នឹងមានប្រយោជន៍ដល់ខ្ញុំ ។

ព្រហ្មពន្ធុ បុរេ អាសឹ សោ ឥទានិម្ហិ ព្រាហ្មណោ
តេវិជ្ជោ សោត្ថិយោ ចម្ហិ វេទគូ ចម្ហិ ន្ហាតកោ ។

រោហិណី ។

[៣៣៣] លទ្ធិហត្ថោ បុរេ អាសឹ សោទានិ មិគលុទ្ទកោ
អាសាយ បលិថា ឃោរា នាសក្ខឹ ចារមេតុ សេ ។
សុមត្តំ មំ មញ្ញមានា ចាចា បុត្តមតោសយិ
ចាចាយ ពន្ធនំ ឆេត្វា បព្វជិស្សំ បុរេ(១) អហំ ។
មា មេ កុជ្ឈ មហាវីរ មា មេ កុជ្ឈ មហាមុនិ
ន ហិ កោធបរេតស្ស សុទ្ធិ អត្ថិ កុតោ តបោ ។
បក្កមិស្សញ្ច នាលាតោ កោធ នាលាយ វច្ឆតិ
ពន្ធន្តិ ឥត្ថិរូបេន សមណេ ធម្មជីវិនោ ។
ឯហិ កាឡ និវត្តស្សុ ភុញ្ជ កាមេ យថា បុរេ

១ ឱ. បុនោមហំ ។ ម. បុនោបហំ ។

*ក្នុងកាលមុន ខ្ញុំជាព្រាហ្មណ៍តែផៅពង្ស ឥឡូវនេះ ខ្ញុំជាព្រាហ្មណ៍ពិត (មានបាបបន្សាត់ចោលហើយ) ផង មានត្រៃវិជ្ជាផង មានសួស្តីផង ដល់នូវវេទផង ជាអ្នកងូតលាងបាបផង ។*

រោហិណីថេរី ។

[៣៣៣] (*ឧបកៈពោលថា*) *កាលពីដើម ខ្ញុំមានដៃកាន់ដំបង ឥឡូវនេះ ខ្ញុំនោះជាព្រានម្រឹគ មិនអាចបានដល់នូវត្រើយគឺព្រះនិព្វាន ព្រោះសេចក្តីប្រាថ្នាគឺតណ្ហា ព្រោះភក់គឺកាម និងទិដ្ឋិដ៏ខ្លាំងក្លា ។ នាងចាបា ស្មានខ្ញុំ ថាជាមនុស្សស្រវឹងជ្រប់ ទើបលួងកូន*[១] *ខ្ញុំកាត់ចំណងគឺកិលេស របស់នាងចាបា ហើយទៅបួសម្តងទៀត ។*

(*នាងចាបាពោលថា*) *បពិត្រមហាវីរបុរស សូមអ្នក កុំខឹងនឹងខ្ញុំ បពិត្រមហាមុនី សូមអ្នកកុំខឹងនឹងខ្ញុំ សេចក្តីស្អាតមិនមានដល់បុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់ទេ តបធម៌ នឹងមានមកពីណា ។*

(*ឧបកៈពោលថា*) *ខ្ញុំនឹងគេចចេញអំពីស្រុកនាលៈ អ្នកណានឹងនៅក្នុងស្រុកនាលៈនេះបាន បើពួកស្រី ៗ ចងនូវសមណៈទាំងឡាយ ដែលរស់នៅដោយធម៌ ដោយរូបនៃស្ត្រី ។*

(*នាងចាបាពោលថា*) *ម្នាលបុរសខ្មៅ សូមអ្នកអញ្ជើញមកសិនសឹមត្រឡប់វិញសូមបរិភោគនូវកាមទាំងឡាយដូចក្នុងកាលមុនចុះ*

---

១ ដោយពាក្យថា នាងចាបាជាកូនព្រានម្រឹគ ឯងជាកូនឧបកាជីវក ។ អដ្ឋកថា ។

អហំ ច តេ វសីកតា | យេ ច មេ សន្តិ ញាតកា ។
ឯត្តោ ចេវ ចតុព្ភាកំ | យថា ភាសសិ តំ ចាបេ
តយិ រត្តស្ស ចោសស្ស | ឧឡារំ វត តំ សិយា ។
កាឡង្គិនីវ តក្ការី | បុប្ផិតំ គិរិមុទ្ធនិ
ផុល្លំ ទាលិកលដ្ឋីវ | អន្តោទីបេវ ចាដលី
ហរិចន្ទនលិត្តង្គិំ | កាសិកុត្តមធារិនី
តំ មំ រូបវតឹ សន្តឹ | កស្ស ឱហាយ គច្ឆសិ ។
សាកុណិកោវ សកុណំ[១] | យថា ពន្ធិតុមិច្ឆតិ
អាហរិមេន រូបេន | ន មំ ត្វំ ពាធយិស្សសិ ។
ឥមញ្ច មេ បុត្តផលំ | កាឡ ឧប្បាទិតំ តយា
តំ មំ បុត្តវតឹ សន្តឹ | កស្ស ឱហាយ គច្ឆសិ ។
ជហន្តិ បុត្តេ សប្បញ្ញា | តតោ ញាតី តតោ ធនំ
បព្វជន្តិ មហាវីរា | នាគោ ឆេត្វាវ ពន្ធនំ ។

---

១ ឱ. ម. សាកុន្តិកោវ សកុណំ ។

ជនទាំងឡាយណា ជាញាតិរបស់ខ្ញុំ ខ្ញុំនឹងធ្វើជនទាំងនោះ ឲ្យលុះក្នុងអំណាចនៃអ្នក ។

ម្នាលនាងចាបា នាងពោលនូវពាក្យនោះ ឲ្យមានភាគ ៤ អំពីពាក្យនេះក៏ដោយ ពាក្យនោះ គប្បីជាពាក្យធើតឆាយ ចំពោះតែបុរសដែលត្រេកអរ នឹងនាងប៉ុណ្ណោះទេ ។

ម្នាលបុរសខ្មៅ ហេតុអ្វី ទើបអ្នកលះបង់ចោលខ្ញុំ ជាស្ត្រីមានរូបឆោម លាបស្រឡាបអវយវៈដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវកាសិកពស្ត្រដ៏ឧត្តម (សំពត់ដែលគេនាំមកអំពីដែនកាសី) ជាស្ត្រីមានអវយវៈល្អ ដូចជាត្នោតសារដែលរីកលើកំពូលភ្នំ ឬដូចជាវល្លិ៍កេសរីកហើយ ឬក៏ដូចជាឈើច្រនៀង (រីកហើយ) ខាងក្នុងទ្វីប ។

ព្រានសត្វស្លាប ប្រាថ្នាចាប់សត្វស្លាបយ៉ាងណា នាងនឹងបៀតបៀនអញ ដោយរូបដែលស្អិតស្អាង (យ៉ាងនោះ) ពុំបានទេ ។

នែបុរសខ្មៅ ហេតុអ្វីទើបអ្នកលះបង់ចោលនូវផ្លែគឺកូនខ្ញុំ ដែលអ្នកបង្កើតនេះផង លះបង់ខ្ញុំដែលជាស្ត្រីមានកូនប្រាកដដូច្នោះផង ។

មហាវីរបុរសទាំងឡាយ ដែលមានប្រាជ្ញា តែងលះបង់នូវកូនទាំងឡាយ ទាំងពួកញាតិ ទាំងទ្រព្យ ហើយបួស ដូចជាដំរីដ៏ប្រសើរ ផ្តាច់នូវចំណង (ហើយគេចចេញទៅ) ។

ឥទានិ តេ ឥមំ បុត្តំ  ទណ្ឌេន ឆុរិកាយ វា
ភូមិយំ វា និសុម្ភេយ្យំ[១]  បុត្តសោកំ[២] ន គច្ឆសិ ។
សចេ បុត្តំបិ សិគាលានំ  កុក្កុរានំ បទាហិសិ
ន មំ បុត្តកតេ ជម្មិ  បុនរាវត្តយិស្សសិ ។
ហន្ទ ខោទានិ ភទ្ទន្តេ  កុហឹ កាឡ គមិស្សសិ
កតមំ គាមំ និគមំ  នគរំ រាជធានិយោ ។
អហុម្ហ បុព្វេ គណិនោ  អសមណា សមណមានិនោ
គាមេន គាមំ វិចរិម្ហ  នគរេ រាជធានិយោ ។
ឯសោ ហិ ភគវា ពុទ្ធោ  នទឹ នេរញ្ជរំ បតិ
សព្វទុក្ខប្បហានាយ  ធម្មំ ទេសេសិ បាណិនំ
តស្សាហំ សន្តិកេ គច្ឆំ  សោ មេ សត្ថា ភវិស្សតិ ។
វន្ទនំ ទានិ វជ្ជាសិ  លោកនាថំ អនុត្តរំ
បទក្ខិណញ្ច កត្វាន  អាទិសេយ្យាសិ ទក្ខិណំ ។
ឯតំ ខោ លព្ភមម្ហេហិ  យថា ភាសសិ តំ ចាបេ[៣]
វន្ទនំ ទានិ តេ វជ្ជំ  លោកនាថំ អនុត្តរំ
បទក្ខិណញ្ច កត្វាន  អាទិសិស្សាមិ ទក្ខិណំ ។

---

១ ម. និសុម្ភិស្ស ។ ២ ឱ. ម. បុត្តសោកា ។ ៣ ម. ភាសិតុវញ្ចាមេតិ ទិស្សតិ ។

ឥឡូវខ្ញុំនឹងបៀតបៀនកូនអ្នកនេះ ដោយដំបង ឬក្តិចដោយក្រចក ឬ (បោក) លើផែនដី អ្នកមិនដល់នូវការយំស្តាយចំពោះកូនទេឬ ។

នែស្ត្រីលាមក មានកូនតូច បើទុកជានាងឲ្យកូនទៅសត្វចចកនិងពួកឆ្កែ ក៏នាងញុំាងអញឲ្យត្រឡប់វិញពុំបានឡើយ ។

នែបុរសខ្មៅ ណ្ហើយចុះ ឥឡូវនេះ បើអ្នកនឹងទៅក្នុងទីណា គឺស្រុកណា និគមណា នគរណា រាជធានីណា (ក៏ទៅចុះ) ។

កាលពីដើម យើងជាអ្នកមានពួក មិនមែនជាសមណៈ សម្គាល់ថាជាសមណៈហើយចេញពីស្រុកទៅកាន់ស្រុក កាន់នគរ រាជធានី ។ មែនពិត ព្រះសម្ពុទ្ធ ទ្រង់មានជោគអង្គនោះ តែងសម្តែងធម៌ប្រោសពួកសត្វ ដើម្បីលះបង់សេចក្តីទុក្ខទាំងពួង ក្នុងទីជិតស្ទឹងនេរញ្ជរា ខ្ញុំនឹងទៅក្នុងសំណាក់នៃព្រះសម្ពុទ្ធនោះ ព្រះអង្គនឹងជាគ្រូនៃខ្ញុំ ។

ឥឡូវនេះ អ្នកគប្បីទូលរៀបរាប់អំពីកិច្ចថ្វាយបង្គំ (របស់ខ្ញុំ) ចំពោះព្រះលោកនាថ ជាបុគ្គលប្រសើរ រួចហើយធ្វើប្រទក្សិណ ឧទ្ទិសនូវទក្ខិណាទាន ។

ម្នាលនាងចាបា នាងពោលនូវពាក្យនោះ យ៉ាងណា យើងគប្បីបាន (អាចឲ្យ) នូវចំណែកបុណ្យនោះ ឥឡូវនេះ ខ្ញុំនឹងទូលរៀបរាប់នូវកិច្ចថ្វាយបង្គំរបស់នាង ចំពោះព្រះលោកនាថ ជាបុគ្គលប្រសើរ នឹងធ្វើប្រទក្សិណ ឧទ្ទិសនូវទក្ខិណា (បុណ្យ) ។

តតោ ច កាឡោ បក្កាមិ នទី នេរញ្ជរំ បតិ
សោ អទ្ទសាសិ សម្ពុទ្ធំ ទេសេន្តំ អមតំ បទំ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។
តស្ស បាទានិ វន្ទិត្វា កត្វាន នំ បទក្ខិណំ
ចាបាយ អាទិសិត្វាន បព្វជិ អនគារិយំ ។
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

ចាបា ។

[៣៣៤] បេតានិ ភោតិ បុត្តានិ ខាទមានា តុវំ បុរេ
តុវំ ទិវា ច រត្តោ ច អតីវ បរិតប្បសិ ។
សាជ្ជ សព្វានិ ខាទិត្វា សត្ត បុត្តានិ ព្រាហ្មណិ
វាសិដ្ឋិ កេន វណ្ណេន ន ពាឡ្ហំ បរិតប្បសិ ។
ពហូនិ មេ បុត្តសតានិ ញាតិសង្ឃសតានិ ច
ខាទិតានិ អតីតំសេ មម តុយ្ហញ្ច ព្រាហ្មណ ។
សាហំ និស្សរណំ ញត្វា ជាតិយា មរណស្ស ច
ន សោចាមិ ន រោទាមិ ន ចាហំ បរិតប្បាមិ[១] ។

១ ម. បរិតប្បាយឹ ។

លំដាប់នោះឯង បុរសខ្មៅចៀសចេញអំពីទីនោះទៅ បុរសខ្មៅនោះ ក៏បានចួបនឹងព្រះសម្ពុទ្ធ ក្បែរស្ទឹងនេរញ្ជរា កំពុងសម្តែងនូវឧបាយ នៃព្រះនិព្វានឈ្មោះអមតៈ គឺទុក្ខ ១ ហេតុកើតឡើងនៃទុក្ខ ១ ការកន្លង នូវទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរជាដំណើរទៅកាន់ទីរលត់ ទុក្ខ ១ ។ បុរសខ្មៅថ្វាយបង្គំនូវព្រះបាទទាំងឡាយ របស់ព្រះសម្ពុទ្ធ នោះ ហើយធ្វើប្រទក្សិណចំពោះព្រះអង្គ ឧទ្ទិសដល់នាងចាបាហើយ ចូលកាន់ផ្នួស ។ វិជ្ជាបីខ្ញុំបានហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។

ចាបាថេរី ។

[៣៣៤](ព្រាហ្មណ៍ជាបិតាសួរថា) នែនាងដ៏ចម្រើន ក្នុងកាលមុន នាង កាលស៊ីកូនទាំងឡាយ[១] ដែលស្លាប់ហើយ នាងក្តៅក្រហាយក្រៃពេក ទាំងថ្ងៃទាំងយប់ ។ ម្នាលព្រាហ្មណី ជាវាសិដ្ឋគោត្រ ថ្ងៃនេះ នាង ស៊ីកូនទាំងអស់ ៧ នាក់ ព្រោះហេតុអ្វីនាងមិនក្តៅក្រហាយខ្លាំង ។ (វាសិដ្ឋថេរីពោលថា) ម្នាលព្រាហ្មណ៍ កូនទាំងរយ ពួកញាតិ ទាំងរយ ជាច្រើន របស់ខ្ញុំ គឺខ្ញុំនិងអ្នកស៊ីហើយ ក្នុងចំណែក កន្លងទៅហើយ ។ ខ្ញុំនោះដឹងនូវព្រះនិព្វាន ជាគ្រឿងរលាស់ ជាតិនិងមរណៈ ទើបមិនសោក មិនយំ ទាំងមិនក្តៅក្រហាយ ។

១ ពាក្យថា ស៊ីកូន ក្នុងទីនេះ មិនមែនសំដៅយកការស៊ីពិតមែននោះទេសំដៅយកមនុស្ស ដែលមានកូនស្លាប់ ជាពាក្យសម្រាប់ជេរគ្នាដោយអំណាចសេចក្តីខឹង ។ អដ្ឋកថា ។

២០៣

ថេរីគាថាយ វីសតិនិបាតោ

អព្ភុតំ វត វាសិដ្ឋិ    វាចំ ភាសសិ ឯទិសំ
កស្ស ត្វំ ធម្មមញ្ញាយ    គិរំ ភាសសិ ឯទិសំ ។
ឯស ព្រាហ្មណ សម្ពុទ្ធោ    នគរំ មិថិលំ បតិ
សព្ពទុក្ខប្បហានាយ    ធម្មំ ទេសេសិ បាណិនំ ។
តស្សាហំ ព្រាហ្មណ អរហតោ    ធម្មំ សុត្វា និរូបធឹ
តត្ថ វិញ្ញាតសទ្ធម្មា    បុត្តសោកំ ព្យបានុទឹ ។
សោ អហំបិ គមិស្សាមិ    នគរំ មិថិលំ បតិ
អប្បេវ មំ សោ ភគវា    សព្ពទុក្ខា បមោចយេ ។
អទ្ទស ព្រាហ្មណោ ពុទ្ធំ    វិប្បមុត្តំ និរូបធឹ
តស្ស ធម្មមទេសេសិ    មុនិ ទុក្ខស្ស បារគូ
ទុក្ខំ ទុក្ខសមុប្បាទំ    ទុក្ខស្ស ច អតិក្កមំ
អរិយដ្ឋង្គិកំ មគ្គំ    ទុក្ខូបសមគាមិនំ ។
តត្ថ វិញ្ញាតសទ្ធម្មោ    បព្ពជ្ជំ សមរោចយិ
សុជាតោ តីហិ រត្តីហិ    តិស្សោ វិជ្ជា អផស្សយិ ។
ឯហិ សារថិ គច្ឆាហិ    រថំ នីយាទយាហិមំ
អារោគ្យំ ព្រាហ្មណឹ វជ្ជ    បព្ពជិតោទានិ ព្រាហ្មណោ
សុជាតោ តីហិ រត្តីហិ    តិស្សោ វិជ្ជា អផស្សយិ ។

ឱនាងជាវាសិដ្ឋគោត្រ នាងនិយាយសម្ដីបែបនេះ អស្ចារ្យណាស់ នាងដឹងច្បាស់នូវធម៌របស់អ្នកណា ទើបនិយាយសម្ដីបែបនេះ ។

ម្នាលព្រាហ្មណ៍ ព្រះសម្ពុទ្ធអង្គនោះ សម្ដែងធម៌ដល់សត្វទាំង-ឡាយ ដើម្បីលះបង់នូវទុក្ខទាំងពួង ជិតនគរមិថិលា ។ ម្នាលព្រាហ្មណ៍ ខ្ញុំបានស្ដាប់ធម៌របស់ព្រះអរហន្តអង្គនោះ ដែលជាធម៌មិនមានឧបធិក្កិលេស បានដឹងច្បាស់នូវសច្ចធម៌ហើយក្នុងទីនោះ ទើបបន្ទោបង់នូវសេចក្ដីសោកព្រោះកូនបាន ។

ខ្ញុំនោះនឹងទៅក្នុងទីជិតក្រុងមិថិលាដែរ ធ្វើដូចម្ដេចហ្ន៎ ព្រះមានជោគអង្គនោះគប្បីដោះខ្ញុំចាកទុក្ខទាំងពួងបាន ។

ព្រាហ្មណ៍បានចួបនឹងព្រះពុទ្ធ ព្រះអង្គផុតស្រឡះចាក(កិលេស) មិនមានឧបធិកិលេស ព្រះមុនីទ្រង់ដល់នូវត្រើយនៃទុក្ខ បានសម្ដែងប្រាប់ព្រាហ្មណ៍នោះនូវសច្ចធម៌ គឺទុក្ខ ១ ហេតុកើតឡើងនៃទុក្ខ ១ ការកន្លងនូវទុក្ខ ១ មគ្គប្រកបដោយអង្គប្រាំបីដ៏ប្រសើរជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។ សុជាតព្រាហ្មណ៍មានសច្ចធម៌ដឹងច្បាស់ហើយក្នុងទីនោះពេញចិត្តនឹងបព្វជ្ជា បានសម្រេចវិជ្ជាបីដោយរាត្រីបី ។

ព្រាហ្មណ៍ពោលថា ម្នាលសារថី អ្នកចូរមក អ្នកចូរទៅ ចូរនាំរថនេះទៅវិញចុះ រួចចូរប្រាប់ព្រាហ្មណី កុំឲ្យមានមោះមៃថា ឥឡូវនេះ សុជាតព្រាហ្មណ៍បួសហើយ បានសម្រេចវិជ្ជាបី ដោយរាត្រីបី ។

តតោ ចេ រថមាទាយ សហស្សញ្ចាបិ សារថិ
អារោគ្យំ ព្រាហ្មណី អវោច
បព្វជិតោទានិ ព្រាហ្មណោ
សុជាតោ តីហិ វត្ថីហិ តិស្សោ វិជ្ជា អជ្ឈគា ។
ឯតញ្ចាហំ អស្សរថំ សហស្សញ្ចាបិ សារថិ
តេវិជ្ជំ ព្រាហ្មណំ សុត្វា បុណ្ណបត្តំ ទទាមិ តេ ។
តុម្ហេវ ហោតុ អស្សរថោ សហស្សញ្ចាបិ ព្រាហ្មណិ
អហំបិ បព្វជិស្សាមិ វរបញ្ញស្ស សន្តិកេ ។
ហត្ថិគវស្សំ មណិកុណ្ឌលញ្ច
ផីតញ្ចិមំ គេហវិភវំ បហាយ
បិតា បព្វជិតោ តុយ្ហំ ភុញ្ជ ភោគានិ សុជាតិ
តុវំ ទាយាទិកា កុលេ ។
ហត្ថិគវស្សំ មណិកុណ្ឌលញ្ច
រម្មញ្ចិមំ គេហវិភវំ បហាយ
បិតា បព្វជិតោ តុយ្ហំ បុត្តសោកេន អដ្ដិតោ[១]
អហំបិ បព្វជិស្សាមិ ភាតុសោកេន អដ្ដិតា ។

១ ឱ. អទ្ទិតោ ។ ម. អដ្ឋិតោ ។

(លំដាប់នោះ សារថី នាំយករថផង កហាបណៈមួយពាន់ផង ហើយប្រាប់នាងព្រាហ្មណី មិនឲ្យមោះមៃថា ឥឡូវនេះ សុជាត-ព្រាហ្មណ៍បួសហើយ បានសម្រេចវិជ្ជាបី ដោយរាត្រីបីហើយ) ។

(ព្រាហ្មណីពោលថា) ម្នាលសារថី ខ្ញុំសូមឲ្យរថដែលទឹមដោយសេះនេះ និងកហាបណៈមួយពាន់នេះ ជាអំណោយដល់អ្នក ព្រោះបានឮថា ព្រាហ្មណ៍បានត្រៃវិជ្ជា ។

(សារថីពោលថា) ម្នាលព្រាហ្មណី រថដែលទឹមដោយសេះនឹងកហាបណៈ មួយពាន់នេះ ចូរនៅជារបស់នាងដដែលចុះ ខ្ញុំនឹងបួសក្នុងសំណាក់នៃព្រះសាស្តា ព្រះអង្គមានប្រាជ្ញាដ៏ប្រសើរដែរ ។

(ព្រាហ្មណីពោលនឹងនាងសុន្ទរីថា) នៃនាងសុន្ទរី
បិតារបស់នាងលះបង់នូវដំរី គោ សេះ កែវមណីនិង
កុណ្ឌល ទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ នៅក្នុងផ្ទះនេះ
ទៅបួសហើយ នាងចូរប្រើប្រាស់ នូវភោគៈទាំង-
ឡាយចុះ (ព្រោះថា) នាងជាទាយាទក្នុងត្រកូល ។

(នាងសុន្ទរីពោលថា) បិតារបស់ខ្ញុំលះបង់នូវដំរី គោ សេះ កែវមណី កុណ្ឌល និងទ្រព្យសម្បត្តិដែលមានក្នុងផ្ទះនេះ ទៅបួសព្រោះត្រូវសេចក្តីសោកនឹងកូនគ្របសង្កត់ ចំណែកខាងខ្ញុំក៏នឹងបួសដែរ ព្រោះត្រូវសេចក្តីសោកនឹងបងគ្របសង្កត់ ។

២០៤

ថេរីគាថាយ វីសតិនិបាតោ

សោ តេ ឥជ្ឈតុ សង្កប្បោ    តំ ត្វំ បត្ថេសិ សុន្ទរិ
ឧត្តិដ្ឋបិណ្ឌោ ឧញ្ឆោ ច    បំសុកូលញ្ច ចីវរំ
ឯតានិ អភិសម្ភោន្តី    បរលោកេ អនាសវា ។
សិក្ខមានាយ មេ អយ្យេ    ទិព្វចក្ខុំ វិសោធិតំ
បុព្វនិវាសំ ជានាមិ    យត្ថ មេ សុវិតំ បុរេ ។
តុវំ និស្សាយ កល្យាណិ    ថេរីសង្ឃស្ស សោភណេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
អនុជានាហិ មេ អយ្យេ    ឥច្ឆេ សាវត្ថឹ គន្តវេ
សីហនាទំ នទិស្សាមិ    ពុទ្ធសេដ្ឋស្ស សន្តិកេ ។
បស្ស សុន្ទរិ សត្ថារំ    ហេមវណ្ណំ ហរិត្តចំ
អទន្តានំ ទមេតារំ    សម្ពុទ្ធមកុតោភយំ ។
បស្ស សុន្ទរិមាយន្តឹ    វិប្បមុត្តំ និរូបធឹ
វីតរាគំ វិសំយុត្តំ    កតកិច្ចមនាសវំ ។

ថេរីគាថា វីសតិនិបាត

(ព្រាហ្មណីពោលថា) ហៃនាងសុន្ទរី នាងប្រាថ្នានូវតម្រិះណា សូមឲ្យនាងបានសម្រេច នូវតម្រិះនោះ ដុំបាយតាមលំដាប់ផ្ទះក្តី អាហារចំណីក្តី បង្សុកូលចីវរក្តី (ដែលនាងត្រូវស្វែងរក) កាលបើនាងជម្រះនូវវត្ថុទាំងនេះ នឹងបានជាស្រីមិនមានអាសវៈក្នុងបរលោក ។

(នាងសុន្ទរីនិយាយនឹងឧបជ្ឈាយ៍ថា) បពិត្រព្រះនាងជាម្ចាស់ ខ្ញុំនៅជាសិក្ខមានា បានជម្រះទិព្វចក្ខុហើយ កាលពីដើមខ្ញុំធ្លាប់នៅអាស្រ័យក្នុងទីណា ខ្ញុំដឹងនូវបុព្វេនិវាស ក្នុងទីនោះ ។ បពិត្រព្រះនាងជាកល្យាណីដ៏ល្អ របស់ថេរីសង្ឃ វិជ្ជាបី ខ្ញុំបានដល់ហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ព្រោះតែអាស្រ័យនូវព្រះនាង ។ បពិត្រព្រះនាងជាម្ចាស់ ខ្ញុំចង់ទៅកាន់ក្រុងសាវត្ថី សូមព្រះនាងអនុញ្ញាតដល់ខ្ញុំឲ្យទាន ខ្ញុំនឹងបន្លឺនូវសីហនាទ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ ។

ម្នាលនាងសុន្ទរី នាងចូរមើលព្រះសាស្តា ព្រះអង្គមានសម្បុរដូចមាស មានព្រះតចៈពណ៌ដូចមាស ទ្រង់ទូន្មានពួកសត្វដែលគេមិនទាន់ទូន្មាន ព្រះអង្គជាអ្នកត្រាស់ដឹងឯង ឥតមានភ័យអំពីណាឡើយ ។ សូមព្រះអង្គនិមន្តទត នាងសុន្ទរីដែលកំពុងដើរមក ជាស្ត្រីផុតស្រឡះ (ចាកកិលេស) ឥតមានឧបធិ ប្រាសចាកតម្រេក ប្រាសចាកគ្រឿងប្រកប មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។

ពារាណសីតោ និក្ខម្ម　　តវ សន្តិកមាគតា
សាវិកា តេ មហាវីរ　　បាទេ វន្ទតិ សុន្ទរី ។
តុវំ ពុទ្ធោ តុវំ សត្ថា　　តុយ្ហំ ធីតម្ហិ ព្រាហ្មណ
ឱរសា មុខតោ ជាតា　　កតកិច្ចា អនាសវា ។
តស្សា តេ ស្វាគតំ ភទ្ទេ　　តតោ តេ អទុរាគតំ
ឯវំ ហិ ទន្តា អាយន្តិ　　សត្ថុ បាទានិ វន្ទិកា
វីតរាគា វិសំយុត្តា　　កតកិច្ចា អនាសវា ។

សុន្ទរី ។

[៣៣៤] ទហរាហំ សុទ្ធវសនា　　យំ បុរេ ធម្មមស្សុណឹ
តស្សា មេ អប្បមត្តាយ　　សច្ចាភិសមយោ អហុ ។
តតោហំ សព្វកាមេសុ　　ភុសំ អរតិមជ្ឈគំ
សក្កាយស្មឹ ភយំ ទិស្វា　　នេក្ខម្មស្សេវ[១] បិហយេ ។
ហិត្វានាហំ ញាតិគណំ　　ទាសកម្មករានិ ច
គាមខេត្តានិ ផីតានិ　　រមណីយេ បមោទិតេ
បហាយាហំ បព្វជិតា　　សាបតេយ្យំ អនប្បកំ ។

---

១ ឱ. នេក្ខម្មំ យេវ ។ ម. នេក្ខម្មមេវ ។

បពិត្រព្រះអង្គជាមហាវីរបុរស នាងសុន្ទរី ជាសាវិការបស់ព្រះអង្គ ចេញអំពីក្រុងពារាណសី មកកាន់សំណាក់ព្រះអង្គ ថ្វាយបង្គំនូវព្រះបាទទាំងឡាយ ។ បពិត្រព្រះមានព្រះភាគ ជាខីណាសវព្រាហ្មណ៍ ព្រះអង្គជាព្រះពុទ្ធ ព្រះអង្គជាគ្រូ (របស់ខ្ញុំ) ខ្ញុំព្រះអង្គជាធីតារបស់ព្រះអង្គ ជាឱរសកើតអំពីព្រះឱស្ឋមានកិច្ចធ្វើរួចហើយ ឥតមានអាសវៈ ។

ម្នាលនាងដ៏ចម្រើន ដំណើររបស់នាងមកល្អហើយដំណើររបស់នាងមកអំពីទីនោះ មិនឆ្ងាយទេ ព្រោះពួកអ្នកមានឥន្ទ្រិយទូន្មានហើយ ប្រាសចាកតម្រេក ប្រាសចាកគ្រឿងប្រកប មានកិច្ចធ្វើហើយ ឥតមានអាសវៈរមែងមកថ្វាយបង្គំព្រះបាទាព្រះសាស្តាដូចនាងដែរ ។

សុន្ទរីថេរី ។

[៣៣៤] កាលពីដើមខ្ញុំនៅក្រមុំ មានគ្រឿងស្លៀកពាក់ដ៏ស្អាត បានស្តាប់ធម៌ ការត្រាស់ដឹងសច្ចធម៌ក៏កើតមានដល់ខ្ញុំនោះ ជាស្ត្រីមិនប្រហែសធ្វេស ។ ហេតុនោះ ខ្ញុំមិនត្រេកអរក្រៃពេក ក្នុងកាមារម្មណ៍ទាំងអស់ ឃើញភ័យក្នុងសក្កាយ ហើយពេញចិត្តនឹងការចេញសាងផ្នួសតែម្យ៉ាង ។ ខ្ញុំលះបង់ពួកញាតិទាសកម្មករ ស្រុក ស្រែទាំងឡាយដ៏ស្តុកស្តម្ភ (និងគំនរ នៃភោគៈទាំងឡាយ) ដែលគួរត្រេកអរ គួររីករាយ ខ្ញុំលះបង់នូវសម្បត្តិដ៏ច្រើន ហើយបួស ។

ថេរីគាថាយ វីសតិនិបាតោ

ឯវំ សទ្ធាយ និក្ខម្ម សទ្ធម្មេ សុប្បវេទិតេ
ន មេ តំ អស្ស បដិរូបំ អាកិញ្ចញ្ញំ ហិ បត្ថយេ
យោ ជាតរូបរជតំ ឋបេត្វា បុនរាគមេ ។
រជតំ ជាតរូបំ វា នត្ថេតស្សបិ សន្តិយា[១]
ន ឯតំ សមណសារុប្បំ ន ឯតំ អរិយធនំ ។
លោភនំ មទនំ ចេតំ សមោហនំ រជពន្ធនំ[២]
សាសង្កំ ពហុអាយាសំ នត្ថិ ចេត្ថ ធុវំ ឋិតិ ។
ឯត្តារតា[៣] បមត្តា ច សង្កិលិដ្ឋមនា នរា
អញ្ញមញ្ញេន ព្យារុទ្ធា បុថុ កុព្វន្តិ មេធគំ ។
វធោ ពន្ធោ បរិក្កេសោ[៤] ជានិ សោកបរិទ្ទវោ
កាមេសុ អធិបន្នានំ ទិស្សតេ ព្យសនំ ពហុំ ។
តំបិ ញាតី អមិត្តាវ កឹ មំ កាមេសុ យុញ្ជថ
ជានាថ មំ បព្វជិតំ កាមេសុ ភយទស្សិនឹ ។

---

១ ឱ. ន ពោធាយ ន សន្តយេ ។ ម. ន ពោធាយ ន សន្តិយា ។ ២ ឱ. ម. រជវឌ្ឍនំ ។ ៣ ឱ. ម. ឯត្ថរត្តា ។ ៤ ម. បរិត្តោសោ ។

ខ្ញុំចេញ (ចាកផ្ទះ) ដោយសទ្ធាយ៉ាងនេះហើយ (បួស) ក្នុងព្រះសទ្ធម្ម ដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សម្តែងហើយដោយប្រពៃ ខ្ញុំប្រាថ្នានូវសេចក្តីមិនកង្វល់ ព្រោះការត្រឡប់មករកកាមនោះមិនសមគួរដល់ខ្ញុំទេ អ្នកណាលះចោលមាសនិងប្រាក់ហើយគប្បីត្រឡប់មកយកវិញ ។ ប្រាក់ក្តី មាសក្តី របស់បុគ្គលនុ៎ះ មិនមែនមានដើម្បីព្រះនិព្វានជាទីស្ងប់ទេ ការទទួលមាសនិងប្រាក់នុ៎ះ មិនសមគួរដល់សមណៈទេ ការទទួលនូវប្រាក់និងមាសនុ៎ះមិនមែនជាទ្រព្យប្រសើរទេ ។ ការទទួលនូវប្រាក់នឹងមាសនុ៎ះ សុទ្ធតែជាគ្រឿងឲ្យកើតលោភៈ ជាគ្រឿងស្រវឹង ជាគ្រឿងវង្វេង ជាគ្រឿងព័ន្ធព័ទ្ធដោយធូលីគឺកិលេស ប្រកបដោយសេចក្តីរង្កៀស មានសេចក្តីចង្អៀតចង្អល់ច្រើន សេចក្តីទៀងទាត់ឋិតថេរក្នុងទ្រព្យនេះមិនមានទេ ។ ពួកនរជន (ដែលត្រេកអរ) ដោយទ្រព្យប៉ុណ្ណេះឈ្មោះថាជាអ្នកប្រហែសធ្វេស ជាអ្នកមានចិត្តសៅហ្មង ជាអ្នកអាក់អន់ រមែងធ្វើនូវជម្លោះជាច្រើនទៅវិញទៅមក ។ សេចក្តីវិនាសច្រើនប្រការគឺការសម្លាប់ ការចង ការសៅហ្មង សេចក្តីវិនាស សេចក្តីសោក ខ្សឹកខ្សួល រមែងកើតប្រាកដដល់ពួកជន ដែលដេកត្រាំក្នុងកាមទាំងឡាយ ។ អ្នកទាំងឡាយជាញាតិមែន តែហាក់ដូចជាសត្រូវ ល្បួងខ្ញុំនោះក្នុងកាមទាំងឡាយធ្វើអ្វី (ព្រោះ) អ្នកទាំងឡាយជ្រាបនូវខ្ញុំថាជាអ្នកបួស ជាស្ត្រីឃើញនូវភ័យក្នុងកាមទាំងឡាយ ។

ន ហិរញ្ញសុវណ្ណេន បរិក្ខីយន្តិ អាសវា
អមិត្តា វធកា កាមា សបត្តា សល្លពន្ធនា ។
តំបិ ញាតី អមិត្តាវ កឹ មំ កាមេសុ យុញ្ជថ
ជានាថ មំ បព្វជិតំ មុណ្ឌំ សង្ឃាដិបារុតំ ។
ឧត្តិដ្ឋបិណ្ឌោ ឧញ្ឆោ ច បំសុកូលញ្ច ចីវរំ
ឯតំ ខោ មម សារុប្បំ អនគារូបនិស្សយោ ។
វន្តា មហេសីហិ[១] កាមា យេ ទិព្វា យេ ច មានុសា
ខេមដ្ឋានេ វិមុត្តា តេ បត្តា តេ អចលំ សុខំ ។
មាហំ កាមេហិ សង្គច្ឆិំ យេសុ តាណំ ន វិជ្ជតិ
អមិត្តា វធកា កាមា អគ្គិក្ខន្ធូបមា ទុខា ។
អបរិសុទ្ធោ[២] ឯសោ សភយោ សវិឃាតោ សកណ្តកោ
គេធោ សុវិសមោ ចេសោ មហន្តោ មោហនាមុខោ ។

១ ឱ. ម. មហេសិនា ។ ២ ឱ. បរិបន្ថោ ។ ម. បរិពន្ធោ ។

អាសវៈទាំងឡាយមិនមែនអស់ទៅព្រោះប្រាក់និងមាស កាមទាំងឡាយមិនមែនជាមិត្រ ជាសភាវៈសម្លាប់ (នូវប្រយោជន៍) ជាសត្រូវ ជាគ្រឿងចងទុកនូវសរគឺកិលេស ។ អ្នកទាំងឡាយជាញាតិមែនតែហាក់ដូចជាសត្រូវ ល្បួងខ្ញុំនោះក្នុងកាមទាំងឡាយធ្វើអ្វី (ព្រោះ) អ្នកទាំងឡាយជ្រាបនូវខ្ញុំថាជាអ្នកបួស មានក្បាលត្រងោល ដណ្ដប់នូវសង្ឃាដី ។ ដុំបាយតាមលំដាប់ផ្ទះក្ដី អាហារចំណីក្ដី បង្សុកូល-ចីវរក្ដី នេះឯងជាអំពើដ៏សមគួរដល់ខ្ញុំ ជាបរិក្ខារ ជាទីអាស្រ័យរបស់អ្នកបួស ។ លោកអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ខ្ជាក់ចោលនូវកាមទាំងឡាយ ដែលជាទិព្វ និងជារបស់មនុស្ស បុគ្គលអ្នកស្វែងរកនូវគុណធំទាំងនោះ មានចិត្តឱនទៅក្នុងព្រះនិព្វានជាទីដ៏ក្សេម បុគ្គលអ្នកស្វែងរកនូវគុណធំទាំងនោះ បានដល់នូវសេចក្ដីសុខ ឥតកម្រើក ។ ទីជម្រករមែងមិនមានក្នុងកាមទាំងឡាយណា ខ្ញុំមិនសមគប់ ដោយកាមទាំងឡាយនោះទៀតទេ កាមទាំងឡាយមិនមែនជាមិត្រ ដូចជាអ្នកសម្លាប់ ឬដូចជាគំនរភ្លើង នាំមកនូវសេចក្ដីព្រួយ ។ កាមនោះមិនស្អាត ប្រកបដោយភ័យ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ដូចជាបន្លា កាមនុ៎ះជាគ្រឿងញ៉ាម ជាគ្រឿងកង្វល់ក្រៃលែង មានមុខឈមទៅរកសេចក្ដីវង្វេងដ៏ធំ ។

ថេរីគាថាយ វីសតិនិបាតោ

ឧបសគ្គោ ភីមរូបោ ច កាមា សប្បសិរូបមា
យេ ពាលា អភិនន្ទន្តិ អន្ធភូតា បុថុជ្ជនា ។
កាមសំសគ្គសត្តា[១] ហិ ជនា ពហូ លោកេ អវិទ្ទសុ
បរិយន្តំ ជានិជានន្តិ ជាតិយា មរណស្ស ច ។
ទុគ្គតិគមនំ មគ្គំ មនុស្សា កាមហេតុកំ
ពហុំ វេ បដិបជ្ជន្តិ អត្តនោ រោគមាវហំ ។
ឯវំ អមិត្តជននា តាបនា សង្កិលេសិកា
លោកាមិសា ពន្ធនីយា កាមា មរណពន្ធនា ។
ឧម្មាទនា ឧល្លបនា កាមា ចិត្តប្បមាទិនោ
សត្តានំ សង្កិលេសាយ ខិប្បំ មារេន ឱឌ្ឌិតំ ។
អនន្តាទីនវា កាមា ពហុទុក្ខា មហាវិសា
អប្បស្សាទា រណករា សុក្កបក្ខវិសោសនា ។
សាហំ ឯតាទិសំ ហិត្វា ព្យសនំ កាមហេតុកំ
ន តំ បច្ចាគមិស្សាមិ និព្វានាភិរតា សទា ។
រណំ ករិត្វា កាមានំ សីតិភាវាភិកង្ខិនី

១ ឱ. កាមបង្កសត្តា ។ ម. កាមបង្កេន សត្តា ។

កាមគុណជាឧបសគ្គៈផង មានសភាពគួរខ្លាចផង កាមារម្មណ៍ទាំង-ឡាយមាន ឧបមាដូចក្បាលពស់ ពួកបុថុជ្ជនល្ងង់ខ្លៅដូចជាបុគ្គលខ្វាក់ តែងត្រេកត្រអាល ។ ព្រោះថា ពួកជនច្រើនរូបដែលចំពាក់ដោយគ្រឿងចំពាក់គឺកាម រមែងបាន (សេចក្តីទុក្ខ) ក្នុងលោក រមែងមិនដឹងច្បាស់នូវទីបំផុតនៃជាតិនិងមរណៈ ។ មនុស្សទាំងឡាយជាច្រើនតែងដើរទៅកាន់ផ្លូវ ជាទីទៅកាន់ទុគ្គតិ មានកាមជាហេតុ ជាគ្រឿងនាំមកនូវរោគដល់ខ្លួន ។ កាមទាំងឡាយ ជាគ្រឿងញុំាងសត្រូវឲ្យកើតយ៉ាងនេះ ជាហេតុញុំាងសត្វឲ្យក្តៅក្រហាយ នាំមកនូវសេចក្តីសៅហ្មង ជានុយរបស់សត្វលោក ជាទីតាំងនៃគ្រឿងចង ជាចំណងនៃសេចក្តីស្លាប់ ។ កាមទាំងឡាយជាគ្រឿងញុំាងសត្វឲ្យឆ្កួត ឲ្យនិយាយប៉ប៉ាច់ប៉ប៉ោច ញុំាងចិត្តឲ្យភ្ញាំងភ្ញាត់ មារគឺកាមរបស់ពួកសត្វ តែងរួបរឹតដោយសេចក្តីសៅហ្មង យ៉ាងឆាប់រហ័ស ។ កាមទាំងឡាយ មានទោសរកទីបំផុតគ្មាន មានទុក្ខច្រើនយ៉ាង មានពិសដ៏ខ្លាំងក្លា មានរសឆ្ងាញ់តិច ជាគ្រឿងធ្វើនូវចម្បាំង ញុំាងចំណែកនៃធម៌សឲ្យសាបសូន្យទៅ ។ ខ្ញុំនោះលះបង់នូវសេចក្តីវិនាសដែលមានកាមជាហេតុ បែបនេះ ត្រេកអរចំពោះព្រះនិព្វានសព្វ ៗ កាល មិនត្រឡប់មកកាន់កាមនោះវិញទេ ។ ខ្ញុំជាស្ត្រីប្រាថ្នានូវភាពដ៏ត្រជាក់ (ព្រះអរហត្ត) ធ្វើនូវចម្បាំងចំពោះកាមទាំងឡាយ

## ២១០



អប្បមត្តា វិហរិស្សាមិ រតា[១] សំយោជនក្ខយេ ។
អសោកំ វិរជំ ខេមំ អរិយដ្ឋង្គិកំ ឧជុំ
តំ មគ្គំ អនុគច្ឆាមិ យេន តិណ្ណា មហេសិនោ ។
ឥមំ បស្សថ ធម្មដ្ឋំ សុភំ កម្មារធីតរំ
អនេជំ ឧបសម្បជ្ជ រុក្ខមូលម្ហិ ឈាយតិ ។
អជ្ជដ្ឋមី បព្វជិតា សទ្ធា សទ្ធម្មសោភណា[២]
វិនីតា ឧប្បលវណ្ណាយ តេវិជ្ជា មច្ចុហាយិនី ។
សាយំ ភុជិស្សា អនណា ភិក្ខុនី ភាវិតិន្ទ្រិយា
សព្វយោគវិសំយុត្តា កតកិច្ចា អនាសវា ។
តំ សក្កោ ទេវសង្ឃេន ឧបសង្កម្ម ឥទ្ធិយា
នមស្សតិ ភូតបតិ សុភំ កម្មារធីតរន្តិ ។

សុភា កម្មារធីតា ។

វីសតិនិបាតោ សមត្តោ ។

---

១ ឱ. តេសំ ។ ម. តាសំ ។ ២ ម. សទ្ធព្យសោភណា ។

ជាអ្នកមិនប្រមាទ ត្រេកអរចំពោះព្រះនិព្វាន ជាទីអស់ទៅនៃសំយោជនៈ ។ បុគ្គលអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ចូលហើយតាមផ្លូវណា ខ្ញុំនឹងដើរទៅតាមផ្លូវនោះ ជាផ្លូវឥតសោក មានធូលីទៅប្រាសហើយ ជាផ្លូវក្សេម ដ៏ត្រង់ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

(ព្រះមានព្រះភាគត្រាស់ថា) អ្នកទាំងឡាយ ចូរមើលនូវនាងសុភាកម្មារធីតានេះ ជាស្រ្តីឋិតនៅក្នុងធម៌ នាងបានចូលទៅកាន់ឈាន ឥតមានសេចក្តីញាប់ញ័រ ហើយស្ងឹងស្ងាធ៏ទៀបគល់ឈើ ។ នាងសុភាកម្មារធីតា បួសបាន ៨ ថ្ងៃនឹងថ្ងៃនេះហើយ ជាភិក្ខុនីមានសទ្ធា លួក្នុងព្រះសទ្ធម្ម ដែលនាងឧប្បលវណ្ណា ទូន្មានហើយ ជាស្រ្តីមានវិជ្ជា ៣ លះបង់នូវមច្ចុបាន ។ ភិក្ខុនីនេះ ជាអ្នកនៅឥតមានបំណុល មានឥន្រ្ទិយចម្រើនហើយ ប្រាសចាកកិលេសគ្រឿងប្រកបទាំងពួង មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។ ទេវរាជឈ្មោះសក្កៈ ជាម្ចាស់នៃពួកសត្វ ព្រមទាំងពួកទេវតា ចូលទៅនមស្ការចំពោះភិក្ខុនីឈ្មោះសុភាកម្មារធីតានោះ ដោយឫទ្ធិ (របស់ខ្លួន) ។

សុភាកម្មារធីតាថេរី ។

ចប់ វីសតិនិបាត ។

# ថេរីគាថាយ តឹសនិបាតោ

[៣៣៦] ជីវកម្ពវនំ រម្មំ គច្ឆន្តឹ ភិក្ខុនឹ សុភំ
ធុត្តកោ សន្និវារេសិ តមេនំ អព្រវី សុភា ។
កឹ តេ អបរាធិតំ មយា យំ មំ ឱវរិយានុតិដ្ឋសិ(១)
ន ហិ បព្វជិតាយ អាវុសោ បុរិសោ សម្ផុសនាយ កប្បតិ ។
គរុកេ មម សត្ថុ សាសនេ យា សិក្ខា សុគតេន ទេសិតា
បរិសុទ្ធបទំ អនង្គណំ កឹ មំ ឱវរិយានុតិដ្ឋសិ ។
អាវិលចិត្តោ អនាវិលំ សរជោ វីតរជំ អនង្គណំ
សព្វត្ថ វិមុត្តមានសំ កឹ មំ ឱវរិយានុតិដ្ឋសិ ។
ទហរា ច អចាបិយា ចាសិ កិន្តេ បព្វជ្ជា ការិស្សតិ
និក្ខិប កាសាយចីវរំ ឯហិ រមាមសេ សុបុប្ផិតេ វនេ ។
មធុរញ្ច បវន្តិ សព្វសោ កុសុមរជេន សមុដ្ឋិតា(២) ទុមា

---
១ ឱ. ម. ឱវរិយានតិដ្ឋសិ ។ ២ ឱ. សមុទ្ធតា ។

# ថេរីគាថា តឹសនិបាត

[៣៣៦] (សុវណ្ណការបុត្ត) ជាអ្នកលេង រារាំងភិក្ខុនីឈ្មោះសុភា កំពុង ដើរទៅកាន់ជីវកម្ពវ័ន ជាទីរីករាយភិក្ខុនីឈ្មោះសុភា ក៏បានពោល នឹងសុវណ្ណការបុត្តនោះថា ។ កំហុសដូចម្តេច ដែលអាត្មាប្រទូស្ត ដល់អ្នក បានជាអ្នកឈររាំងអាត្មា នៃអាវុសោ បុរសមិនគួរប៉ះពាល់ នូវស្ត្រីជាបព្វជិតទេ ។ សិក្ខាទាំងឡាយក្នុងសាសនា របស់ព្រះ សាស្តា ជាសិក្ខាគួរគោរព ព្រះសុគត បានសម្តែងហើយដល់អាត្មា ហេតុដូចម្តេច ក៏អ្នកមកឈររាំងអាត្មា ដែលជាស្រីមានចំណែកនៃ ធម៌ដ៏បរិសុទ្ធមិនមានទីទួលគឺកិលេស ។ អ្នកជាបុគ្គលមានចិត្តល្អក់ ប្រកបដោយធូលីគឺរាគៈ ហេតុដូចម្តេចក៏អ្នកមកឈររាំងអាត្មា ដែល ជាស្រីមានចិត្តថ្លាស្អាត ប្រាសចាកធូលី គឺរាគៈ មិនមានទីទួលគឺ កិលេស មានចិត្តផុតស្រឡះហើយ (ចាកខន្ធបញ្ចកៈ) ទាំងអស់ ។

(អ្នកលេងពោលថា) នាងជាស្ត្រីនៅក្រមុំផង មិនអាក្រក់ផង បព្វជ្ជានឹងធ្វើប្រយោជន៍អ្វីដល់នាង ចូរនាងបោះចោលកាសាយចីវរ ចេញទៅ ហើយចូរមក យើងនឹងបានត្រេកត្រអាល ក្នុងព្រៃ ដែលមានផ្ការីកល្អ ។ ដើមឈើទាំងឡាយហាក់ដូចជាតាំង ឡើងដោយលម្អងផ្កា បក់ផ្សព្វផ្សាយនូវក្លិនដ៏ក្រអូប សព្វទិស

២១២

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ថេរីគាថា

បឋមវសន្តោ សុខោ ឧតុ ឯហិ រមាមសេ សុបុប្ផិតេ វនេ ។

កុសុមិតសិខរា ច បាទបា អភិគជ្ជន្តិវ មលុតេរិតា

កា តុយ្ហំ រតិ ភវិស្សតិ យទិ ឯកា វនមោគាហិស្សសិ ។

វាឡមិគសង្ឃសេវិតំ កុញ្ជរមត្តករេណុលោឡិតំ

អសហាយិកា គន្តុមិច្ឆសិ រហិតំ ភឹសនកំ មហាវនំ ។

តបនីយកតាវ ធីតិកា វិចរសិ ចិត្តរថេវ អច្ឆរា

កាសិកសុខុមេហិ វគ្គុហិ[១] សោភសិ និវសនេហិនោបមេ ។

អហំ តវ វសានុគោ សិយំ យទិ វិហរេមសិ កាននន្តរេ

ន ហិ មត្ថិ តយា បិយតរោ បាណោ កិន្នរិមន្ទលោចនេ ។

យទិ មេ វចនំ ករិស្សសិ សុខិតា ឯហិ អគារមាវស

---

១ ឱ. វគ្គុហិ ។ ម. វគ្គុភិ ។

(នេះ) *ជាវសន្តរដូវ ជាដំបូង ជារដូវនាំមកនូវសុខ នាងចូរមក យើងនឹងត្រេកត្រអាល ក្នុងព្រៃ ដែលមានផ្ការីកល្អ ។ ដើមឈើទាំង-ឡាយ មានចុងស្គុះស្គាយដោយផ្កា លុះត្រូវខ្យល់បក់មក ក៏ហាក់ដូចជាបន្ទឺសំឡេងឡើង ប្រសិនបើ នាងនឹងចូលទៅក្នុងព្រៃម្នាក់ឯង នាងនឹងត្រេកត្រអាលដូចម្តេចកើត ។ នាងជាស្ត្រីឥតមិត្រសំឡាញ់ ចង់ទៅកាន់ព្រៃធំ ដែលប្រាសចាក*(មនុស្ស)*គួរឲ្យស្ញប់ស្ញែង ជាព្រៃដែលហ្វូងម្រឹគសាហាវនៅអាស្រ័យ ជាព្រៃដែលដំរីចុះប្រេងនិងមេដំរីបុកបែន ។ នាងប្រៀបដូចរូបតុក្កតាដែលសូនដោយមាសឆ្អិន ឬដូចជាស្ត្រីទេពអប្សរ ត្រាច់ទៅក្នុងឧទ្យានឈ្មោះចិត្តរថ ម្នាលនាងជាស្ត្រីល្អឥតឧបមា នាងល្អដោយសំពត់សម្រាប់ស្លៀកដណ្តប់ មានសាច់ដ៏ល្អិតសុខុម ដែលកើតក្នុងដែនកាសី ។ បើនាងនៅក្នុងចន្លោះព្រៃ ខ្ញុំនឹងលុះក្នុងអំណាចនៃនាង ម្នាលនាងជាស្ត្រីមានភ្នែកស្រទន់ដូចកិន្នរី ជីវិត*(របស់ខ្ញុំ)*ជាទីស្រឡាញ់ក្រៃលែងជាងនាងមិនមានទេ ។ បើនាងនឹងធ្វើតាមពាក្យខ្ញុំ នាងចូរមក ចូរនៅគ្រប់គ្រងផ្ទះជាសុខចុះ*

## ថេរីគាថាយ តឹសនិបាតោ

បាសាទនិវាតវាសិនី បរិកម្មន្តេ ករោន្តុ នារិយោ ។
កាសិកសុខុមានិ ធារស្សុ[១] អភិរោបេហិ ច មាលវណ្ណកំ
កញ្ចនមណិមុត្តកំ ពហុំ វិវិធំ អាភរណំ ករោមិ តេ ។
សុធោតរជបច្ឆទំ សុភំ គោណកតូលិកសន្ថតំ នវំ
អភិរុហ សយនំ មហារហំ ចន្ទនមណ្ឌិតំ សារគន្ធិកំ ។
ឧប្បលំ ច ឧទកា ឧគ្គតំ យថា យំ អមនុស្សសេវិតំ
ឯវំ តុវំ ព្រហ្មចារិនិ សកេសុ អង្គេសុ ជរំ គមិស្សសិ ។
កិន្តេ ឥធ សារសម្មតំ កុណបបូរម្ហិ សុសានវឌ្ឍនេ
ភេទនធម្មេ កឡេវរេ យំ ទិស្វា វិមនោ ឧទិក្ខសិ ។
អក្ខីនិ ច តុរិយារិវ កិន្នរិយារិវ បព្វតន្តរេ
តវ មេ នយនានិ ទក្ខិយ ភិយ្យោ កាមរតិ បវឌ្ឍតិ ។

១ ឱ. ម. ធារយេ ។

នាងនឹងនៅក្នុងប្រាសាទមិនមានខ្យល់ ពួកនាងនារី ចូរធ្វើនូវការខ្វល់ខ្វាយបម្រើដល់នាង ។ ចូរនាងទ្រទ្រង់នូវសំពត់ មានសាច់ម៉ដ្ឋដែលនាំមកអំពីដែនកាសី ចូរនាងតែងខ្លួន ដោយផ្កាកម្រងនឹងគ្រឿងលាបចុះ ខ្ញុំនឹងផ្គត់ផ្គង់គ្រឿងអាភរណៈផ្សេង ៗ ច្រើនយ៉ាង ដែលរចនាហើយដោយមាស កែវមណី និងកែវមុក្តា ដល់នាង ។ ចូរនាងឡើងកាន់ដំណេកថ្មីល្អដែលស្អាតគ្មានធូលី ព្រោះជម្រះលាងប្រពៃ ដែលក្រាលដោយកម្រាលរោមចៀម ញាត់ដោយសំឡីមានតម្លៃច្រើន ប្រដាប់ដោយខ្លឹមចន្ទន៍ មានក្លិនក្រអូប ។ នាងជាស្ត្រីប្រព្រឹត្តព្រហ្មចារ្យ នាងនឹងដល់នូវការចាស់គ្រាំគ្រា ត្រង់អវយវៈទាំងឡាយរបស់ខ្លួន ដូចជាផ្កាឧប្បលលូតផុតទឹក ដែលអមនុស្សហួងហែងរក្សា (នឹងជាវត្ថុឥតមានអ្នកណាប្រើប្រាស់កើត) ។

(នាងថេរីពោលថា) ហេតុដូចម្តេច ក៏អ្នកមានគំនិតខុស សម្ងឹងហើយ (អាត្មា) ព្រោះឃើញនូវអារម្មណ៍ដែលសន្មតថាមានខ្លឹម ក្នុងរាងកាយនេះ ដ៏ពេញដោយសាកសព គ្រាន់តែការចម្រើនរបស់ព្រៃស្មសាន ជារាងកាយបែកធ្លាយជាធម្មតា ។

(អ្នកលេងពោលថា) ភ្នែកទាំងឡាយ (របស់នាង) ដូចជាភ្នែកកូនម្រឹគញី ឬដូចជាភ្នែកនៃកិន្នរី ក្នុងចន្លោះនៃភ្នំ តម្រេកក្នុងកាមរបស់ខ្ញុំ រមែងចម្រើនក្រៃលែង ព្រោះឃើញនូវភ្នែករបស់នាង ។

ឧប្បលសិខរោបមានិ តេ  វិមលេ ហាដកសន្និភេ មុខេ
តវ មេ នយនានិ ទក្ខិយ  ភិយ្យោ កាមគុណោ បវឌ្ឍតិ ។
អបិ ទូរគតា សរម្ហសេ  អាយតបម្ហេ វិសុទ្ធទស្សនេ
ន ហិ មត្ថិ តយា បិយតរា  នយនា កិន្នរិមន្ទលោចនេ ។
អបថេន បយាតុមិច្ឆសិ  ចន្ទំ កីឡនកំ គវេសសិ
សិនេរុំ[១] លង្ឃេតុមិច្ឆសិ  យោ ត្វំ ពុទ្ធសុតំ បត្ថេសិ[២] ។
នត្ថិ ហិ លោកេ សទេវកេ  រាគោ យត្ថបិ ទានិ មេ សិយា
នបិ នំ ជានាមិ កីរិសោ  អថ មគ្គេន ហតោ សមូលកោ ។
ឥង្គាលកុយាវ ឧជ្ឈិតោ  វិសបត្តោរិវ អគ្គិតោ កតោ
នបិ នំ បស្សាមិ កីរិសោ  អថ មគ្គេន ហតោ សមូលកោ ។

---

១ ឱ. ម. មេរុំ ។ ២ ឱ. ម. មគ្គយសិ ។

កាមគុណរបស់ខ្ញុំ រមែងចម្រើនឡើងក្រៃលែង ព្រោះឃើញភ្នែករបស់នាង ដែលប្រៀបដោយត្របកនៃផ្កាឧប្បល ត្រង់មុខប្រាសចាកមន្ទិល ប្រាកដស្មើដោយមាស ។ នៃនាងមានរូបស្រស់ស្រោង មានភ្នែកថ្លាស្អាត បើទុកជាយើងទៅកាន់ទីឆ្ងាយ ក៏នៅតែរលឹកឃើញ ម្នាលនាងមានភ្នែកថ្លាដូចភ្នែកកិន្នរី ឥតមានអ្វីមួយ ជាទីស្រឡាញ់នៃខ្ញុំ ជាងភ្នែករបស់នាងទេ ។

(នាងថេរីពោលថា) អ្នកប្រាថ្នានូវធីតា ជាឱរសរបស់ព្រះពុទ្ធ (នេះ) ឈ្មោះថាប្រាថ្នាដើម្បីដើរទៅតាមផ្លូវខុស ឈ្មោះថាស្វែងរកព្រះច័ន្ទមកធ្វើជាល្បែង ឈ្មោះថាប្រាថ្នាដើម្បីលោតឡើងកាន់ភ្នំសិនេរុ ។ ឥឡូវនេះ ប្រសិនបើរាគៈគប្បីមានដល់អាត្មាក្នុងអារម្មណ៍ណា អារម្មណ៍នោះមិនមានក្នុងលោក ព្រមទាំងទេវលោក អាត្មាមិនដឹងនូវដំណើរនោះថា មានភាវៈអ្វីស្មើ (ដោយរាគៈ) ទេ បានជា(រាគៈនោះ) អាត្មាដកចោលទាំងឫស ដោយអរិយមគ្គហើយ ។ (រាគៈនោះ) អាត្មាបានកម្ចាត់ចេញហើយ ដូចជាភាជនៈដាក់នូវថ្នាំពិស ដែលបុគ្គលបោះចោល ក្នុងរងើកភ្លើងហើយ អាត្មាមិនឃើញនូវដំណើរនោះថា មានសភាវៈអ្វីស្មើ (ដោយរាគៈ) ទេ បានជា (រាគៈនោះ) អាត្មាដកចោលទាំងឫស ដោយអរិយមគ្គហើយ ។

យស្សា សិយា អបច្ចវេក្ខិតំ សត្ថា វា អនុសាសិតោ សិយា
ត្វំ តាទិសិកំ បលោភយ ជានន្តី សោ ឥមំ វិហញ្ញសិ ។
មយ្ហំ ហិ អក្កុដ្ឋវន្ទិតេ សុខទុក្ខេ ច សតិ ឧបដ្ឋិតា
សង្ខតមសុភន្តិ ជានិយ សព្វត្ថេវ មនោ ន លិម្បតិ ។
សាហំ សុគតស្ស សាវិកា មគ្គដ្ឋង្គិកយានយាយិនី
ឧទ្ធដសល្លា អនាសវា សុញ្ញាគារគតា រមាមិហំ ។
ទិដ្ឋា ហិ មយា សុចិត្តិតា សោម្ភា[១] ធារុកចិល្លកា នវា
តន្តីហិ ច ខីលកេហិ ច វិនិពទ្ធា វិវិធំ បនច្ចិតា ។
តម្ហុទ្ធដេ តន្តិខីលកេ វិសដ្ឋេ វិកលេ បរិបក្ខតេ
អវិន្ទេ ខណ្ឌសោ កតេ កិម្ហិ តត្ថ មនំ និវេសយេ ។
តថូបមំ ទេហកានិ មំ តេហិ ធម្មេហិ វិនា ន វត្តន្តិ
ធម្មេហិ វិនា ន វត្តន្តិ កិម្ហិ តត្ថ មនំ និវេសយេ ។

---

១ បោត្ថាតិ អដ្ឋកថាយំ ទិស្សតិ ។

ខន្ធបញ្ចកៈដែលស្ត្រីណា មិនបានពិចារណាឃើញ ឬថា ស្ត្រីណា ដែលមិនបានចូលទៅអង្គុយជិតព្រះសាស្តា អ្នកចូរប្រលោមនូវស្ត្រីប្រាកដដូច្នោះចុះ អ្នកនោះ នឹងចង្អៀតចង្អល់ (ព្រោះអាស្រ័យ) ភិក្ខុនីនេះ ជាអ្នកដឹង (អរិយសច្ច) ។ ព្រោះថា ស្មារតីរបស់អាត្មាបានតម្កល់ខ្ជាប់ហើយ ក្នុងបុគ្គលអ្នកជេរ និងអ្នកថ្វាយបង្គំ ក្នុងសុខនិងទុក្ខ ចិត្តរបស់អាត្មាមិនជាប់ក្នុងអារម្មណ៍ទាំងអស់នោះ ព្រោះដឹងច្បាស់ថា សង្ខតារម្មណ៍ ជារបស់មិនស្អាត ។ អាត្មាជាសាវិការបស់ព្រះសុគត ជាអ្នកដើរទៅដោយយានគឺអដ្ឋង្គិកមគ្គ មានសរគឺកិលេសដកចោលហើយ ឥតមានអាសវៈ ជាអ្នកត្រេកអរក្នុងផ្ទះស្ងាត់ ។ ព្រោះថាអាត្មាបានឃើញរូបយន្តឈើជាគ្រោងថ្មីដែលតាក់តែងដ៏វិចិត្រចងរឹតដោយខ្សែសរសៃទាំងឡាយ និងឈើកន្លាស់ទាំងឡាយដូចជាគេរាំដោយអាការផ្សេង ៗ ។ កាលបើខ្សែសរសៃនិងឈើកន្លាស់នោះដាច់រដេកចេញរាត់រាយរលុងរង្គោះបាក់បែកខ្ចាត់ខ្ចាយ កាលបើរូបយន្តរង្គោះដាច់ខ្ចាត់ខ្ចាយហើយ បុគ្គលមិនគប្បីបាន (រូបយន្តនោះ) ទេ បុគ្គលគប្បីតម្កល់ចិត្តក្នុងរូបនោះ ដូចម្តេចកើត ។ រាងកាយទាំងឡាយរបស់ខ្ញុំដូចគ្នានឹងរូបយន្តដែរ បើវៀរចាករូបធម៌មានចក្ខុជាដើមនោះហើយ រមែងប្រព្រឹត្តទៅមិនបាន រាងកាយបើវៀរចាករូបធម៌ហើយ ប្រព្រឹត្តទៅមិនបានទេ បុគ្គលគប្បីតម្កល់ចិត្តក្នុងរាងកាយនោះដូចម្តេចកើត ។

យថា ហរិតាលេន មក្ខិតំ អទ្ទស ចិត្តិកំ ភិត្តិយា កតំ
តម្ហិ តេ វិបរីតទស្សនំ បញ្ញា មានុសិកា និរត្ថិកា ។
មាយំ វិយ អគ្គតោ កតំ សុបិនន្តេវ សុវណ្ណបាទបំ
ឧបជាវសិ អន្ធ រិត្តកំ ជនមជ្ឈេរិវ រុប្បរូបកំ ។
វដ្តនិរិវ កោដរេហិតា មជ្ឈេពុព្វុឡកា សអស្សុកា
បីឡកោឡិកា ចេត្ថ ជាយតិ វិវិធា ចក្ខុវិធា មណ្ឌិតា[1] ។
ឧចាដិយ[2] ចារុទស្សនា ន ច បជ្ជិត្ថ អលគ្គមានសា[3]
ហន្ទ តេ ចក្ខុំ ហរស្សុ តំ តស្ស នរស្ស អទាសិ តាវទេ ។
តស្ស ច វិរមាសិ តាវទេ រាគោ តត្ថ ខមាបយិ ច នំ
សោត្ថិ សិយា ព្រហ្មចារិនិ ន បុនោ ឯទិសកំ ភវិស្សតិ ។

---

១ ឱ. ម. បិណ្ឌិតា ។ ២ ឱ. ម. ឧប្បាដិយ ។ ៣ ឱ. ម. អសង្គមានសា ។

បុគ្គលឃើញរូបស្រ្តី ដែលគេគួរនឹងជញ្ជាំង លាបលនដោយថ្នាំដ៏ស្រស់យ៉ាងណាមិញ អ្នកមានការឃើញវិបរិត ក្នុងរូបនោះ ក៏យ៉ាងនោះដែរ បញ្ញាជារបស់មនុស្ស ឥតប្រយោជន៍ទេឬ ។ នៃបុគ្គលអន្ធពាល អ្នកស្ទុះចូលមកជិតនូវអត្តភាពដ៏ទទេ ដែលប្រៀបដូចជាថ្ងៃបណ្តើរកូនតាំងនៅក្នុងខាងមុខ ឬដូចជាយល់សប្តិឃើញដើមឈើមាស ពុំនោះដូចជារូបយន្តគ្រាំគ្រាក្នុងកណ្តាលនៃជន ។ ពពុះបាំងស្បែកកណ្តាលភ្នែក ឬព្រៀកទឹកភ្នែក ឬក៏ពកបាយភ្នែកតែងកើតក្នុងមណ្ឌលនៃភ្នែកនោះ ដូចជាពពុះទឹកល័ក្ខដែលបុគ្គលប្រស់លើកម្រាលចៀមស្ងួត ព្រោះថាសណ្ឋានរបស់ភ្នែក មានពណ៌ផ្សេង ៗ ដែលសង្ខារតាក់តែងហើយ ។

នាងសុភាភិក្ខុនី មានចិត្តឥតជាប់ចំពាក់ បានធ្មៀលភ្នែកជាទីស្រឡាញ់ មិនជាប់ចំពាក់ ហើយក៏ឲ្យដល់បុរសនោះក្នុងពេលនោះ ដោយពាក្យថា ហ៎អាត្មាឲ្យភ្នែកដល់អ្នក ចូរអ្នកយកភ្នែកនោះទៅចុះ ។ រាគៈរបស់បុរសនោះ ក៏ប្រាសចេញក្នុងខណៈនោះផង បុរសនោះបានញ៉ាំងភិក្ខុនីនោះឲ្យអត់ទោសក្នុងទីនោះផង ដោយពាក្យថា ម្នាលនាងជាព្រហ្មចារិនី សួស្តីចូរមាន(ដល់នាង) ការប្រព្រឹត្តអនាចារបែបនេះ នឹងមិនមានដល់ខ្ញុំទេ ។

២១៧

ថេរីគាថាយ តឹសនិបាតោ

អាហនិយ ឯឌិសំ ជនំ   អគ្គឹ បជ្ជលិតំវ លិង្ឃិយ
តណ្ហិស្សំ អាសីវិសំ វិយ   អបិ នុ សោត្ថិ សិយា ខមេហិ ដោ។
មុត្តា ច តតោ សា ភិក្ខុនី   អគមិ ពុទ្ធវរស្ស សន្តិកំ
បស្សិយ វរបុញ្ញលក្ខណំ   ចក្ខុ អាសិ យថា បុរាណកន្តិ ។

សុភា ជីវកម្ពវនិកា ។

តឹសនិបាតោ សមត្តោ ។

---

## ២១៧



*បើខ្ញុំបៀតបៀនជន (ដែលគ្មានរាគៈ) យ៉ាងនេះ គឺហាក់ដូចជាខ្ញុំឱបភ្លើងកំពុងឆេះសន្ធោសន្ធៅ ឬចាប់នូវអាសិរ្ពិស បើដូច្នោះ សូមសួស្តីកើតមានដល់នាង សូមនាងអត់ទោសដល់ខ្ញុំ ។*

*ភិក្ខុនីនោះ លុះរួចអំពីបុរសជាអ្នកលេងនោះហើយ ក៏បានទៅកាន់សំណាក់នៃព្រះពុទ្ធដ៏ប្រសើរ ចក្ខុក៏កើតឡើងដូចពីដើម ព្រោះបានឃើញនូវមហាបុរិសលក្ខណៈ ដែលកើតអំពីបុញ្ញសម្ភារ ដ៏ប្រសើរ ។*

សុភាថេរី នៅក្នុងជីវកម្ពវ័ន ។

ចប់ តឹសនិបាត ។

# ថេរីគាថាយ ចត្តាឡីសនិបាតោ

[៣៣៧] នគរម្ហិ កុសុមនាមេ
បាដលិបុត្តម្ហិ បឋវិយា
មណ្ឌេ សក្យកុលេ កុលីនាយោ
ទ្វេ ភិក្ខុនិយោ គុណវតិយោ ។
ឥសិទាសី តត្ថ ឯកា
ទុតិយា ពោធីតិ[១] សីលសម្បន្នា ច
ឈានជ្ឈាយនរតាយោ
ពហុស្សុតាយោ ធុតកិលេសាយោ ។
តា បិណ្ឌាយ ចរិត្វាន
ភត្តត្ថំ ករិយ ធោតបត្តាយោ
រហិតម្ហិ សុខនិសិន្នា
ឥមា គិរា អព្ភុទេសុំ[២] ។
បាសាទិកាសិ អយ្យេ ឥសិទាសិ
វយោបិ តេ អបរិហីនោ
កឹ ទិស្វាន វលិកំ អថាសិ
នេក្ខម្មមនុយុត្តា ។

១ ម. ពោធិថេរី ។ ២ ឱ. ម. អព្ភុទីរេសុំ ។

# ថេរីគាថា ចត្តាឡីសនិបាត

[៣៣៧] ភិក្ខុនីពីររូប ជាកុលធីតាក្នុងសក្យត្រកូល ជាអ្នកមានគុណសម្បត្តិ ក្នុងនគរកុសុមបាដលិបុត្ត ដែលជាមណ្ឌលនៃដែនដី ។ បណ្ដាភិក្ខុនីទាំងពីររូបនោះ ភិក្ខុនី ១ រូបឈ្មោះ ឥសិទាសី ភិក្ខុនីទី ២ ឈ្មោះពោធី ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកត្រេកអរដោយការរំពឹង ក្នុងឈាន ជាពហុស្សូត មានកិលេសកម្ចាត់បង់ហើយ ។ ភិក្ខុនីទាំងពីររូបនោះ ត្រាច់ទៅបិណ្ឌបាត ហើយធ្វើនូវភត្តកិច្ច លុះលាងបាត្រហើយ អង្គុយជាសុខ ក្នុងទីស្ងាត់ ទើបផ្ដើមនិយាយសម្ដីទាំងឡាយនេះថា ។ ម្នាលនាងម្ចាស់ ឈ្មោះឥសិទាសី នាងជាស្រីគួរជ្រះថ្លាទាំងវ័យរបស់នាងក៏មិនទាន់សាបសូន្យ អើចុះ នាងឃើញទោសដូចម្ដេច ទើបមកប្រកបខ្លួនក្នុងបព្វជ្ជា ។

២១៩

ថេរីគាថាយ ចត្តាឡីសនិបាតោ

ឯវមនុយុញ្ជមានា សា

ហិតេ ធម្មទេសនា កុសលា

ឥសិទាសី ឥមំ វចនមាព្រវិ

សុណា ពោធិ យថាម្ហិ បព្វជិតា ។

ឥតោ បរំ វិសជ្ជនកថា

ឧជ្ជេនិយា បុរវរេ មយ្ហំ   បិតា សីលសំវុតោ សេដ្ឋី

តស្សម្ហិ ឯកា ធីតា   បិយា មនាបា ទយិតា ច ។

អថ មេ សាកេតតោ វរកោ   អាគច្ឆិ ឧត្តមកុលីនោ

សេដ្ឋី ពហុតរតនោ តស្ស   មំ សុណ្ហំ អាទាសិ តាតោ ។

សស្សុយា សស្សុរស្ស ច   សាយំ បាតំ បណាមមុបគម្ម

សិរសា ករោមិ បាទេ   វន្ទាមិ យថាម្ហិ អនុសិដ្ឋា ។

យា មយ្ហំ សាមិកស្ស   ភគិនិយោ ភាតុនោ បរិជនោ វា

តំ ឯកវរកំបិ ទិស្វា   ឧព្វិគ្គា អាសនំ ទេមិ ។

អន្នេន បានេន ច ខជ្ជេន ច   យញ្ច តត្ថ សន្និហិតំ

ឆាទេមិ ឧបនយាមិ ច   ទេមិ ច យំ យស្ស បដិរូបំ ។

ឥសិទាសីភិក្ខុនីនោះ ជាអ្នកឈ្លាសវៃក្នុងធម្មទេសនា កាលបើពោធិភិក្ខុនី សាកសួរ ក្នុងហេតុជាប្រយោជន៍ យ៉ាងនេះហើយ ក៏បានពោលនូវពាក្យនេះថាម្នាលនាងពោធិ នាងចូរស្តាប់តាមដំណើរដែលខ្ញុំបួសចុះ ។ លំដាប់អំពីនេះទៅ គឺជាពាក្យវិសជ្ជនា

សេដ្ឋីអ្នកសង្រួមក្នុងសីល ជាបិតារបស់ខ្ញុំ ក្នុងបុរីដ៏ប្រសើរឈ្មោះឧជ្ជេនី (ក្នុងដែនអវន្តិ) ខ្ញុំជាធីតាម្នាក់ ជាទីស្រឡាញ់ពេញចិត្ត ជាអ្នកគួរទទួលសេចក្តីអនុគ្រោះរបស់បិតានោះ ។ លុះចំណេរមកខាងក្រោយ សេដ្ឋីមានត្រកូលដ៏ឧត្តម មានទ្រព្យច្រើន មកអំពីនគរសាកេត ដណ្តឹងខ្ញុំ បិតាក៏បានឲ្យខ្ញុំជាកូនប្រសាររបស់សេដ្ឋីនោះ ។ ខ្ញុំចូលទៅក្រាបក្បាល ថ្វាយបង្គំ នូវជើងម្តាយក្មេកនិងឪពុកក្មេករាល់ល្ងាចព្រឹក តាមដំណើរដែលមាតាបិតាប្រៀនប្រដៅ ។ ខ្ញុំឃើញនូវអ្នកដណ្តឹងសូម្បីម្នាក់ ដែលជាបងប្អូនស្រី បងប្អូនប្រុស ឬជាបរិវាររបស់ស្វាមី ខ្ញុំក៏រលះរលាំងក្រាលអាសនៈ ។ ខ្ញុំអង្គាសផ្គត់ផ្គង់ ឲ្យបាយ ទឹក និងបង្អែម ដែលមានក្នុងលំនៅនោះ តាមសមគួរដល់វត្ថុដែលគេត្រូវការ ។

កាលេន ឧដ្ឋហិត្វា ច បតិឃរំ សមុបគមឹ
ឧម្មារធោតហត្ថបាទា បញ្ជលិកា សាមិកមុបេមិហំ ។
កោច្ឆំ បសាទំ អញ្ជនញ្ច អាទាសកញ្ច គណ្ហិត្វា
បរិកម្មការិកា វិយ សយមេវ បតឹ វិភូសេមិ ។
សយមេវ ឱទនំ សាធយាមិ សយមេវ ភាជនំ ធោវឹ
មាតាវ ឯកបុត្តកំ តថា ភត្តារំ បរិចរាមិ ។
ឯវំ មំ ភត្តិកតំ អនុត្តរំ ការិកំ តំ និហតមានំ
ឧដ្ឋាយិកំ អនលសំ សីលវតឹ ទុស្សតេ ភត្តា ។
សោ មាតរញ្ច បិតរញ្ច ភណតិ អាបុច្ឆាហំ គមិស្សាមិ
ឥសិទាសិយា ន សហ វច្ឆំ ឯកាគារេហំ សហវត្ថុំ ។
មា ឯវំ បុត្ត អវច ឥសិទាសី បណ្ឌិតា បរិព្យត្តា
ឧដ្ឋាយិកា អនលសា កឹ តុយ្ហំ ន រោចតេ បុត្ត ។
ន ច មេ ហឹសតិ កិញ្ចិ ន ចាហំ ឥសិទាសិយា សហ វច្ឆំ
ទេស្សាវ មេ អលំ មេ អាបុច្ឆាហំ គមិស្សាមិ ។
តស្ស វចនំ សុណិត្វា សស្សុ សស្សុរោ ច មំ អបុច្ឆឹសុ

ខ្ញុំក្រោកឡើងតាមកាលគួរហើយ ចូលទៅកាន់ផ្ទះរបស់ប្តី ជូតសម្អាត នូវធរណីទ្វារ (ជាដើម) និងដៃជើង ផ្គងអញ្ជលី ចូលទៅរកប្តី ។ ខ្ញុំយកស្និតសក់ ម្សៅសម្រាប់លាបមុខ ថ្នាំសម្រាប់បន្តក់ភ្នែក និងកញ្ចក់ ស្អិតស្អាងឲ្យប្តីដោយខ្លួនឯង ហាក់ដូចជា(វណ្ណទាសី) អ្នកធ្វើនូវការបម្រើ ។ ខ្ញុំដាំបាយខ្លួនឯង លាងភាជន៍ខ្លួនឯង បម្រើកស្តាដូចជាមាតាថ្នមកូនខ្ចី ។ តែកស្តាតែងខឹងសម្បារនឹងខ្ញុំ ដែលជាស្ត្រីបម្រើបាយ គ្មានស្ត្រីណាលើស ជាស្ត្រីធ្វើការ(គ្រប់យ៉ាង) ជាស្ត្រីមិនមានសេចក្តីប្រកាន់ មានសេចក្តីព្យាយាម មិនខ្ជិលច្រអូស មានមារយាទ យ៉ាងនេះ ។ ស្វាមីនោះនិយាយនឹងមាតាបិតារបស់គេថា ខ្ញុំសូមលា (អ្នកម្តាយលោកឪពុក) ទៅ (ក្នុងទីណាមួយ) (ព្រោះ) ខ្ញុំមិនអាចនៅរួមគ្នាក្នុងផ្ទះមួយ ជាមួយនឹងនាងឥសិទាសីឡើយ ។

(មាតាបិតាពោលថា) នែកូន កុំពោលយ៉ាងនេះឡើយ នាងឥសិទាសី ជាបណ្ឌិតឈ្លាសវៃ ជាស្ត្រីមានសេចក្តីព្យាយាម មិនខ្ជិលច្រអូសទេ ម្នាលកូន ហេតុអ្វី ក៏កូនឯងមិនពេញចិត្ត ។

(កូនពោលថា) នាងឥសិទាសី មិនបៀតបៀនអ្វី ៗ ដល់ខ្ញុំទេ ប៉ុន្តែខ្ញុំមិនអាចនៅជាមួយនឹងនាងឥសិទាសី ព្រោះថានាងឥសិទាសីជាស្រីសម្អប់របស់ខ្ញុំ ខ្ញុំមិនគួរនឹងនៅរួមទេ ខ្ញុំសូមលាទៅហើយ ។

ម្តាយក្មេកនិងឪពុកក្មេក បានស្តាប់ពាក្យកូននោះហើយ សួរខ្ញុំថា

កិស្ស តយា អបរទ្ធំ ភណ កតំ វិស្សដ្ឋា យថាភូតំ ។
នបិហំ អបរជ្ឈំ កិញ្ចិ នបិ ហឹសេវ ន ភណាមិ
ទុព្វចនំ កឹ សក្កា កាតុយេ យំ មំ វិទេស្សតេ ភត្តា ។
តេ មំ បិតុ ឃរំ បដិ- នយឹសុ វិមនា ទុក្ខេន
អវិភូតា បុត្តមនុរក្ខមានា ជិតាម្ហសេ រូបិនឹ លក្ខឹ ។
អថ មំ អទាសិ តាតោ អឌ្ឍស្ស ឃរម្ហិ ទុតិយកុលិកស្ស
តតោ ឧបឌ្ឍសុង្កេន យេន មំ វិន្ទថ សេដ្ឋិ ។
តស្សបិ ឃរម្ហិ មាសំ អវសឹ អថ សោបិ មំ បដិច្ឆតិ
ទាសីវ ឧបដ្ឋហន្តឹ អទូសិកំ សីលសម្បន្នំ ។
ភិក្ខាយ ច វិចរន្តំ ទមកំ ទន្តំ មេ បិតា ភណតិ
សោ ហិសិ មេ ជាមាតា និក្ខិប បោន្តិញ្ច ឃដិកញ្ច ។
សោបិ វិសិត្វា បក្ខំ អថ តាតំ[1] ភណតិ ទេហិ មេ
បោន្តឹ ឃដិកញ្ច កបល្លកញ្ច[2] បុនបិ ភិក្ខំ ចរិស្សាមិ ។
អថ នំ ភណតិ តាតោ អម្មា សព្វោ ច មេ ញាតិគណវគ្គោ

---
១ ម. ភាតំ ។ ២ ឱ. ម. មល្លកញ្ច ។

នាងធ្វើខុសអ្វីទេ នាងចូរប្រាប់កំហុសដែលនាងធ្វើហើយ នាងចូរដោះស្រាយ តាមសេចក្ដីពិតមកចុះ ។

(ខ្ញុំក៏ឆ្លើយថា) ខ្ញុំមិនបានប្រទូស្តអ្វី ៗ ទេ ខ្ញុំមិនបៀតបៀន មិនពោលពាក្យអាក្រក់ (ដល់គាត់ទេ) កស្ដាស្អប់ខ្ញុំ ឲ្យខ្ញុំអាចធ្វើអ្វីកើត ។ ម្ដាយក្មេកនិងឪពុកក្មេកទាំងឡាយនេះ ក៏អាក់អន់ចិត្ត ត្រូវសេចក្ដីព្រួយគ្របសង្កត់ ក៏នាំខ្ញុំត្រឡប់ ទៅកាន់ផ្ទះបិតាវិញ រក្សានូវកូន (ដោយគិតថា) យើងនឹងរកឲ្យបាននូវស្ត្រីមានរូបឆោមដ៏មានសិរី ។ គ្រាក្រោយមក បិតាបានឲ្យខ្ញុំក្នុងផ្ទះនៃត្រកូលទី ២ ជាអ្នកស្ដុកស្ដម្ភ ដោយជំនូនពាក់កណ្ដាលអំពីជំនូនដែលសេដ្ឋីបានជូនមកខ្ញុំមុននោះ ។ ខ្ញុំបាននៅក្នុងផ្ទះនៃប្ដីទី ២ នោះអស់ ១ ខែ គ្រានោះ គាត់ក៏បណ្ដេញខ្ញុំ ដែលជាស្ត្រីខ្នះខ្នែងបម្រើដូចជាទាសី ជាស្ត្រីមិនប្រទូស្ត មានមារយាទល្អ ។ បិតារបស់ខ្ញុំ និយាយនឹងបុរសអ្នកទូន្មាន (ចិត្ត) អ្នកទូន្មាន (កាយនិងវាចា) ដែលកំពុងត្រាច់ទៅដើម្បីកិក្ខាថា អ្នកចូរជាកូនប្រសាររបស់ខ្ញុំ អ្នកចូរបោះបោលនូវកំណាត់សំពត់ និងផ្ដាំង ។ ស្វាមីទី ៣ នោះ បាននៅ (ជាមួយនឹងខ្ញុំ) អស់បក្ខ ១ (កន្លះខែ) ក៏និយាយនឹងបិតាខ្ញុំថា អ្នកចូរឲ្យកំណាត់សំពត់ ផ្ដាំង និងអំបែងមកខ្ញុំវិញ ខ្ញុំនឹងត្រាច់ទៅដើម្បីកិក្ខាទៀត ។ គ្រានោះបិតាមាតា និងពពួកញាតិទាំងអស់របស់ខ្ញុំ និយាយនឹងបុរសនោះថា

កិន្តេ ន ករតិ ឥធ    ភណ ខិប្បំ យន្តេ ករិហិតិ ។
ឯវំ ភណិតោ ភណតិ យទិមេ អត្ថា សក្កោតិ អលំ មយ្ហំ
ឥសិទាសិយា ន វច្ឆំ    ឯកឃរេហំ សហវត្ថុំ ។
វិសជ្ជិតោ កតោ សោ អហំបិ ឯកាកិនី វិចិន្តេមិ
អាបុច្ឆិត្វាន កច្ឆាមិ    មរិតុំ វា បព្វជិតុំ[១] ។
អថ អយ្យា ជិនទត្តា    អាកច្ឆិ កោចរាយ ចរមានា
តាតកុលំ វិនយធរី    ពហុស្សុតា សីលសម្បន្នា ។
តំ ទិស្វាន អម្ហាកំ    ឧដ្ឋាយាសនំ តស្សា បញ្ញាបយឹ
និសិន្នាយ ច ចាទេ    វន្ទិត្វា ភោជនមទាសឹ ។
អន្នចានេន ខជ្ជេន ច    យញ្ច តត្ថ សន្និហិតំ
សន្តប្បយិត្វាន អវចំ    អយ្យេ ឥច្ឆាមិ បព្វជិតុំ ។
អថ មំ ភណតិ តាតោ ឥធេវ បុត្តិកោ[២] ចរាហិ តំ ធម្មំ
អន្នេន ច ចានេន ច    សន្តប្បយ សមណេ ទ្វិជាតីច ។

---
១ ឱ. ម. អាបុច្ឆិត្វន គច្ឆំ មរិតុយេ បព្វជិស្សំ វា ។ ២ ឱ. បុត្តក ។

អ្នកណាមិនធ្វើតាមអ្នកក្នុងទីនេះឬ អ្នកចូរប្រាប់ហេតុដែលគេធ្វើដល់អ្នកឲ្យឆាប់ ។ បុរសនោះ កាលបើគេពោលយ៉ាងនេះហើយក៏ពោលតបថា បើខ្លួនរបស់ខ្ញុំអាចនៅបាន (ក៏នាងឥសិទាសី) មិនគួរដល់ខ្ញុំ (ព្រោះហេតុនោះ) ខ្ញុំមិននៅជាមួយនាងឥសិទាសីក្នុងផ្ទះមួយជាមួយគ្នាទេ ។ បុរសនោះ កាលបើ(បិតារបស់ខ្ញុំ) លះបង់ហើយ ក៏ទៅបាត់ទៅ ចំណែកខាងខ្ញុំជាស្ត្រីនៅតែម្នាក់ឯង គិតថាអាត្មាអញនឹងលាមាតាបិតាទៅស្លាប់ឬទៅបួស ។ គ្រានោះ នាងថេរីជាម្ចាស់ឈ្មោះជិនទត្តា ជាអ្នកទ្រទ្រង់នូវវិន័យ ជាពហុស្សូត បរិបូណ៌ដោយសីល កាលត្រាច់ទៅដើម្បីភិក្ខាហារ ក៏បាននិមន្តមកកាន់ត្រកូលនៃបិតា (ខ្ញុំ) ។ ខ្ញុំឃើញនាងជិនទត្តាថេរីនោះ ក៏ក្រោកឡើង ក្រាលអាសនៈរបស់យើងប្រគេននាងថេរីនោះ លុះព្រះនាងគង់ហើយ ខ្ញុំក៏ថ្វាយបង្គំនូវព្រះបាទា ហើយប្រគេនភោជន ។ ខ្ញុំញ៉ាំងជិនទត្តាថេរី ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងបង្អែម ដែលមានក្នុងលំនៅនោះ ហើយពោលថា បពិត្រព្រះនាងជាម្ចាស់ ខ្ញុំចង់បួស ។ គ្រានោះ បិតាពោលនឹងខ្ញុំថា ម្នាលកូនស្រីតូច នាងចូរប្រព្រឹត្តធម៌នោះក្នុងផ្ទះនេះទៅចុះ ចូរញ៉ាំងសមណៈទាំងឡាយផងព្រាហ្មណ៍ទាំងឡាយផង ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកចុះ ។

ថេរីគាថាយ  ចត្តាឡីសនិបាតោ

អថាហំ ភណាមិ តាតំ   រោទន្តី អញ្ជលឹ បណាមេត្វា
អនុជានាហិ មំ តាត មយា   កតំ(១) កម្មំ តំ និជ្ជរេស្សាមិ ។
អថ មំ ភណតិ តាតោ   ចាបុណ ពោជិញ្ច អគ្គធម្មញ្ច
និព្វានញ្ច លភស្សុ   យំ សច្ឆិការិ ទ្វិបទសេដ្ឋោ ។
មាតាបិតូ អភិវាទយិត្វា   សព្វញ្ច ញាតិគណវគ្គំ
សត្តាហំ បព្វជិតា   តិស្សោ វិជ្ជា អផុស្សយឹ (២) ។
ជានាមិ អត្តនោ សត្ត ជាតិយោ យស្សាយំ ផលំ វិបាកោ
តំ តវ អាចិក្ខិស្សំ   តំ ឯកមនា និសាមេហិ
នគរម្ហិ ឯរកកច្ឆេ   សុវណ្ណការោ អហំ បហុតធនោ
យោព្វនមទេន មត្តោ សោ   បរទារំ អសេវិហំ ។
សោហំ តតោ ចវិត្វា   និរយម្ហិ អបច្ចិសំ ចិរំ
បក្កោ តតោ ច ឧដ្ឋហិត្វា   បក្កដិយា កុច្ឆិមោក្កមឹ ។
សត្តាហំ ជាតកម្មំ   មហាកបិ យូថបោ និល្លច្ឆេសិ
តស្សេតំ កម្មផលំ   យថាបិ គន្ត្វាន បរទារំ ។
សោហំ តតោ ចវិត្វា កាលំ ករិត្វា  សិន្ធវារញ្ញេ
កាណាយ ច ខញ្ជាយ ច   ឯឡកិយា កុច្ឆិមោក្កមឹ ។

១ ឱ. ម. បាបំ ហិ មយា បកតំ ។ ២ ឱ. អផស្សយឹ ។ ម. អបស្សយឹ ។

លំដាប់នោះ ខ្ញុំក៏ប្រណម្យអញ្ជលី យំពោលនឹងបិតាថា បពិត្របិតា សូមលោកអនុញ្ញាតខ្ញុំ ខ្ញុំនឹងញ៉ាំងបាបកម្មដែលខ្ញុំធ្វើហើយនោះ ឲ្យវិនាស ។ គ្រានោះ បិតាពោលនឹងខ្ញុំថា (ព្រះសម្មាសម្ពុទ្ធ) ព្រះអង្គប្រសើរជាងសត្វជើងពីរ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ណា នាងចូរបានលុះនូវពោធិញ្ញាណ និងអគ្គធម៌និងព្រះនិព្វាននោះចុះ ។ ខ្ញុំថ្វាយបង្គំលាបិតាមាតា និងពពួកនៃញាតិទាំងអស់ ហើយបួសបាន ៧ ថ្ងៃ ក៏សម្រេចវិជ្ជា ៣ ។ ខ្ញុំដឹងជាតិរបស់ខ្លួន បាន ៧ ជាតិ ផលវិបាកនេះរបស់កម្មណា ខ្ញុំនឹងប្រាប់នូវកម្មនោះដល់នាង នាងចូរមានចិត្តតែមួយ ចាំផ្ទៀងស្តាប់នូវកម្មនោះ ដូចតទៅនេះ ខ្ញុំជាជាងមាសមានទ្រព្យច្រើន ក្នុងនគរឈ្មោះឯកកច្ឆៈ ខ្ញុំនោះជាមនុស្សស្រវឹងព្រោះការស្រវឹងវ័យ បានប្រព្រឹត្តសេពសំគពនឹងប្រពន្ធបុគ្គលដទៃ ។ ខ្ញុំនោះលុះឃ្លាតចាកអត្តភាពនោះហើយ ក៏ឆេះរោលរាលក្នុងនរកអស់កាលយូរ លុះរួចចាកនរកនោះហើយ មកចាប់បដិសន្ធិក្នុងផ្ទៃនៃមេស្វា ។ ស្វាឈ្មោលធំ ជាម្ចាស់នៃហ្វូង ខាំផ្តាច់នូវជាតកម្ម គឺអង្គជាត (របស់ខ្ញុំ) ដែលទើបនឹងកើតបាន ៧ ថ្ងៃ នុ៎ះជាផលនៃកម្មរបស់ខ្ញុំនោះ ដែលគប់រកនូវប្រពន្ធនៃបុគ្គលដទៃ ។ ខ្ញុំនោះ ធ្វើមរណកាល ច្យុតចាកកំណើតនៃស្វានោះហើយ ក៏ចាប់បដិសន្ធិក្នុងផ្ទៃនៃមេពពែខ្វាក់ផង ខ្វកផង ក្នុងដែននៃស្តេចសិន្ធវៈ ។

ទ្វាទសវស្សានិ អហំ  និល្លច្ឆិតោ ទារកោ បរិហិត្វា
កិមិនា វដ្ដោ អកល្លោ  យថាបិ កត្វាន បរទារំ ។
សោហំ តតោ ចវិត្វា  គោវាណិជកស្ស គាវិយា
ជាតោ វច្ឆោ លាខាតម្ពោ  និល្លច្ឆិតោ ទ្វាទសេ មាសេ ។
តេ បុន នង្គលមហំ  សកដំ ច ធារយាមិ
អន្ធោ វដ្ដោ អកល្លោ  យថាបិ កត្វាន បរទារំ ។
សោហំ តតោ ចវិត្វា  វីថិយា ទាសិយា ឃរេ ជាតោ
នេវ មហិលា ន បុរិសោ  យថាបិ កត្វាន បរទារំ ។
តឹសតិវស្សម្ហិ មតោ  សាកដិកកុលម្ហិ ទារិកា
ជាតា កបណម្ហិ អប្បភោគេ ធនិកបុរិសចាតពហុលម្ហិ ។
តំ មំ តតោ សត្ថវាហោ  ឧស្សន្នាយ វិបុលាយ វឌ្ឍិយា
ឱកឌ្ឍតិ វិលបន្តឹ  អច្ឆិន្ទិត្វា កុលឃរស្ស[១] ។

---
១ ម. កុលឃរស្មា ។

ខ្ញុំត្រូវគេព្រនាក់កូនក្មេងអស់ ១២ ឆ្នាំ ត្រូវគេគ្រៀវ ត្រូវដង្កូវបៀតបៀន ឈឺចាប់ ព្រោះតែអំពើដែលខ្ញុំសេព នូវប្រពន្ធរបស់បុគ្គលដទៃ ។ ខ្ញុំនោះច្យុតចាកកំណើតនៃពពែនោះហើយ ក៏កើតជាកូនគោ អំពីមេគោរបស់ឈ្មួញគោ បាន ១២ ខែ មានរោមក្រហមដូចជាជ្រលក់ល័ខ ហើយត្រូវគេគ្រៀវ ។ ខ្ញុំតែងទាញនូវនង្គ័លនិងរទេះខ្វាក់ ខ្វក ឈឺ ព្រោះតែខ្ញុំសេពនូវប្រពន្ធរបស់បុគ្គលដទៃ ។ ខ្ញុំនោះជាសត្វច្យុតចាកកំណើត នៃគោនោះហើយ ក៏កើតក្នុងផ្ទៃនៃទាសីក្នុងផ្ទះ ក្បែរថ្នល់ មិនប្រាកដជាស្រី មិនប្រាកដជាប្រុស (ខ្ទើយ) ព្រោះតែខ្ញុំសេព នូវប្រពន្ធនៃបុគ្គលដទៃ ។ ខ្ញុំស្លាប់ក្នុងអាយុ ៣០ ឆ្នាំហើយក៏កើតជាទារិកា ក្នុងត្រកូលនៃអ្នករទេះ ដែលជាត្រកូលកំព្រា គ្មានភោគសម្បត្តិ ត្រូវបុរសជាម្ចាស់ទ្រព្យរឹបជាន់ច្រើន ។ កាលការប្រាក់ចម្រើនច្រើនឡើងហើយ នាយឈ្មួញរទេះក៏អូសទាញខ្ញុំ អំពីផ្ទះនៃត្រកូល ដែលកំពុងយំខ្សឹកខ្សួល ។

ថេរីគាថាយ ចត្តាឡីសនិបាតោ

អថ សោឡសមេវស្សេ ទិស្វាន មំ បត្តយោព្វនំ
កញ្ញំ ឱរុទ្ធ តស្ស បុត្តោ គិរិទាសោ នាម នាមេន ។
តស្សបិ អញ្ញា ភរិយា សីលវតី គុណវតី ច
អនុរត្តា ភត្តារំ តស្សាហំ វិទ្វេសនមកាសឹ ។
តស្សេតំ កម្មផលំ យំ មំ អបការិតូន គច្ឆន្តិ
ទាសីវ ឧបដ្ឋហន្តឹ តស្សបិ អន្តោ កតោ មយាតិ ។

ឥសិទាសី ។

